ទស្សនាវដ្ដីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- គុកសោរខ្មែរក្រហម
- ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

[illegible]

លេខ២ ខែកុម្ភៈ ឆ្នាំ២០០០

# ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ២ ខែកុម្ភៈ ឆ្នាំ២០០០


## មាតិកា


- សំបុត្រៈ ការចងចាំ ........ ១

**ផ្នែកឯកសារ**

- ពីឯកអគ្គរដ្ឋទូត ទៅជាអ្នកទោសគុកទួលស្លែង ........ ៤
- អ្នកទោសខ្មែរកម្ពុជាក្រោម ........ ១៥
- ភូមិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ........ ១៧
- កងការពារអ្នកទោសនៅគុកទួលស្លែង ........ ២២
- ការរៀបចំឯកសាររបស់មជ្ឈមណ្ឌលឯកសារ ........ ២៤
- ទូរសារខ្មែរក្រហមពីសមរភូមិមុខ ........ ២៦
- អៀង សារី និងព្រឹត្តិការណ៍បាញ់នាវាម៉ាយ៉ាហ្គេ ........ ២៩

**ផ្នែកប្រវត្តិសាស្ត្រ**

- សិទ្ធិរបស់ខ្មែរក្រហមក្នុងការកម្ទេចប្រជាជនកម្ពុជា ........ ៣០
- ការរកឃើញមន្ទីរស-២១ ........ ៣៨
- គ្រោះថ្នាក់នៃអព្យាក្រឹតភាព ........ ៤១

**ផ្នែកច្បាប់**

- ចំណាត់ប្រភេទឧក្រិដ្ឋកម្មនៃបក្សកុម្មុយនិស្តកម្ពុជា ........ ៤៣
- ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ........ ៤៧
- ភ័ស្តុតាងឯកសារដែលភ្ជាប់មេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនិស្តកម្ពុជា ........ ៥០

**វេទិកាពិភាក្សាជាសាធារណៈ**

- ទស្សនៈជុំវិញតុលាការជំនុំជម្រះក្ដីមេដឹកនាំខ្មែរក្រហម ........ ៥៤

**ទំព័រស្រាវជ្រាវរកគ្រួសារ**

- សុបិន និងការស្វែងរកគ្រួសារ ........ ៥៧
- ខ្ញុំបានជួបឪពុកមាដែលបាត់ខ្លួនក្នុងជំនាន់ ប៉ុល ពត ........ ៦០

**សិល្បៈខ្មែរក្រហម**

- កសិករសហករណ៍ រីករាយប្រមូលផល ........ ក្របក្រោយ









## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងពត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងពត៌មាន
លេខ ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**រាក្ខិនលេខនេះៈ** អេលីហ្សាបែត វ៉ាន់ស្កាក់, វ៉ាអូល ដែន័រ, សាស្ត្រាចារ្យ ដេវីត ឆេនដល័រ, ដាក ម៉ាសត្រអាយនី, ឃែនគុន គ្លែមម័រ, ចន ឆឹឆរអារី, សាស្ត្រាចារ្យ ស៊ីវ ហេឌ័រ **អ្នកនិពន្ធនិងស្រាវជ្រាវៈ** សាន់ កល្យាណ, លី សុផល, ជួង សុភារិទ្ធ **ជំនួយការនិពន្ធនាយកៈ** អែម សុឃីម **និពន្ធនាយករងទី១ៈ** ដាត កុសល **និពន្ធនាយករងទី២ៈ** ស៊ីម សុរិយ៉ា **អ្នកបកប្រែៈ** ឡាយ ពុទ្ធារ៉ា **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ, **គ្រប់គ្រងការចែកផ្សាយៈ** ទ្រី សុភ័ក្ត្រ

## សំបុត្រៈ

# ការចងចាំ

ម្តាយរបស់ខ្ញុំគឺជាអ្នកលក់ត្បូង និងជាមេគ្រួសារដែលមានកូនប្រាំបួននាក់ ។ បងពីរនាក់ក្នុងចំណោមបងប្អូនទាំងប្រាំបួននាក់របស់ខ្ញុំបានបាត់បង់ជីវិតនៅពេលដែលខ្ញុំមិនទាន់ទាំងបានចាប់កំណើតនៅឡើយ ។ ខ្ញុំហៀបនឹងពេញវ័យ ប្អូនខ្ញុំម្នាក់ទៀតបានស្លាប់ចោលខ្ញុំ ។ ខ្ញុំក៏ក្លាយជាកូនពៅបង្អស់ ។ នៅឆ្នាំ១៩៧០ ខ្ញុំមានអាយុប្រាំបួនឆ្នាំ ។ ម្តាយរបស់ខ្ញុំបានប្រើខ្ញុំឲ្យធ្វើជានិរសាររបស់គាត់ គឺនៅក្រោយពេលអនិច្ចកម្មរបស់ឪពុកខ្ញុំ ។ ជានិរសា ខ្ញុំទទួលខុសត្រូវមិនត្រឹមតែទៅសាកសួរប្រមូលពត៌មានតែប៉ុណ្ណោះទេ ប៉ុន្តែគឺថែមទាំងប្រមូលប្រាក់ពីអតិថិជនជូនម្តាយខ្ញុំទៀត ។ ម្តាយខ្ញុំពុំមានរថយន្តសម្រាប់ជិះផ្ទាល់ខ្លួន ។ ហើយគាត់មិនចេះជិះកង់ ។ គាត់មានគំនិតថា កាលបើជិះស៊ីក្លូទៅផ្ទះអតិថិជនរបស់គាត់ វានាំឲ្យគាត់ខាតបង់ពេលវេលានិងលុយកាក់ ។ ដូច្នេះស្ទើរតែរៀងរាល់ពេលទាំងអស់បន្ទាប់ពីខ្ញុំចេញពីសាលារៀន គាត់តែងតែឲ្យខ្ញុំទៅសាកសួរប្រមូលយកពត៌មានឬប្រាក់កាសផ្សេងៗពីអតិថិជន ។ ម្តាយខ្ញុំមិនចេះសរសេរនិងមិនចេះអានទេ ។ ហេតុដូច្នេះគាត់អាចណែនាំប្រាប់ខ្ញុំបានត្រឹមតែពាក្យសម្តីអំពីទីកន្លែងស្នាក់នៅរបស់អតិថិជនរបស់គាត់ ។ ជាធម្មតាខ្ញុំត្រូវសាកសួរមនុស្សម្នាមួយចំនួននៅតាមដងផ្លូវ មុនពេលដែលអាចស្គាល់និងទៅដល់ទីកន្លែងដែលខ្ញុំត្រូវទៅជួប ។ ជាទូទៅ ខ្ញុំឈប់ជាច្រើនកន្លែងដើម្បីសាកសួរមនុស្សនានា ហើយជួនកាលទៀតខ្ញុំថែមទាំងចូលទៅគោរពសាកសួរព្រះសង្ឃដែលជាប្រភពពត៌មានដ៏ទុកចិត្តបំផុត ដើម្បីធ្វើដំណើរទៅដល់តាមអាសយដ្ឋាននានាដូចដែលម្តាយខ្ញុំបានប្រាប់ ។ ធ្វើការបែបនេះសម្រាប់រូបខ្ញុំគឺជាការងារមួយយ៉ាងសប្បាយរីករាយ ពីព្រោះរៀងរាល់ពេលដែលខ្ញុំប្រមូលពត៌មានឬលុយកាក់បានពីអតិថិជន ម្តាយខ្ញុំតែងតែផ្តល់រង្វាន់ដល់ខ្ញុំជាលុយកាក់សម្រាប់ទិញនំចំណីឬទឹកកកឈូសជាដើម ។ មិនត្រឹមតែប៉ុណ្ណោះការងារនេះធ្វើឲ្យខ្ញុំមានឱកាសសន្សំបានលុយគ្រប់គ្រាន់អាចទិញកង៉ាល់ហោះជ័រសម្រាប់លេងទៀតផង ។ ខ្ញុំសម្បូរលុយចាយនិងមានប្រដាប់ប្រដាលេងច្រើនដោយសារធ្វើជានិរសាឲ្យម្តាយរបស់ខ្ញុំ បើប្រៀបធៀបជាមួយនឹងក្មេងឯទៀតដែលនៅផ្ទះជិតខាង ។ ជួនកាលទៀតនោះខ្ញុំយកលុយរង្វាន់មកជប់លៀងមិត្តភក្តិទៀតផង ។ ខ្ញុំរៀនផងនិងធ្វើការជានិរសាររបស់ម្តាយខ្ញុំផង រហូតដល់ពេលដែលពួកខ្មែរក្រហមចូលកាន់អំណាចក្នុងខែមេសា ឆ្នាំ១៩៧៥ ។

ក្នុងឆ្នាំ១៩៧៥ ខ្ញុំមានអាយុបានដប់បួនឆ្នាំ ។ ខ្ញុំរស់នៅក្នុងសង្កាត់ទួលគោក ជាយក្រុងភ្នំពេញ ។ ខ្ញុំចាំបានយ៉ាងច្បាស់ថា ខ្ញុំនៅផ្ទះតែម្នាក់ឯងគត់នៅពេលដែលយោធាខ្មែរក្រហមចូលមកដេញខ្ញុំចេញពីផ្ទះនៅព្រឹកថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៧៥ ។ ម្តាយនិងបងប្អូនខ្ញុំទាំងអស់បានចេញទៅស្នាក់នៅឯផ្ទះឪពុកមាររបស់ខ្ញុំមុនបាត់អស់ទៅហើយដើម្បីសុវត្ថិភាពដល់បងស្រីខ្ញុំម្នាក់ដែលទើបតែមានកូនខ្ចីប្រមាណ១សប្តាហ៍ប៉ុណ្ណោះ ។ ម្តាយខ្ញុំគិតថា គាត់នឹងមកយកខ្ញុំនៅពេលក្រោយ ។ ជ្រុលពេលទៅហើយ ព្រោះពួកយោធាខ្មែរក្រហមបានភ្ជង់កាំភ្លើងដេញខ្ញុំចេញពីផ្ទះឲ្យទៅចូលជាមួយហ្វូងមនុស្សដ៏កុះករនៅតាមផ្លូវ ។ ខ្ញុំដឹងថាកាលណោះខ្ញុំនៅក្មេងពេកមិនដឹងថាមានរឿងអ្វីកើតឡើងទេ ហើយដែលខ្ញុំហាក់ដូចជាមិនខ្វាចអ្វីទាំងអស់ នោះគឺប្រហែលជាមកពីខ្ញុំគ្មានទោសកំហុសអ្វីដែលត្រូវឲ្យខ្លាច ។ ប៉ុន្តែខ្ញុំហាក់ដូចជាដឹងគោលដៅដែលខ្ញុំត្រូវទៅ ។ បន្ទាប់ពីបានដឹងថាពួកខ្មែរក្រហមធ្វើការជម្លៀសនិងចង់ឲ្យប្រជាជនទាំងអស់នៅក្នុងទីក្រុងភ្នំពេញចេញទៅតាមភូមិកំណើតនានាទៅតាមជនបទ ខ្ញុំក៏ចាប់ផ្តើមសួរមនុស្សម្នានៅតាមផ្លូវដើម្បីទៅដល់ស្រុកកំណើតរបស់ម្តាយខ្ញុំដែលខ្ញុំធ្លាប់បានទៅលេងកាលពីខ្ញុំអាយុប្រាំមួយឆ្នាំ (១៩៦៧) ។ ខ្ញុំប្រើប្រាស់វិធីសាស្ត្រដដែលដូចនៅពេលដែលម្តាយរបស់ខ្ញុំប្រើខ្ញុំឲ្យទៅប្រមូលពត៌មានឬលុយកាក់ពីអតិថិជនរបស់គាត់ ។ នៅពេលឈប់សម្រាកតាម

ដងផ្លូវម្តងៗ ខ្ញុំបានសាកសួរព័ត៌មានបន្ថែមទៀតពីមនុស្សម្នានៅតាមដងផ្លូវ រួមទាំងយោធាខ្មែរក្រហមផង អំពីស្រុកកំណើតម្តាយរបស់ខ្ញុំ ។ ខ្ញុំបានរកឃើញភូមិកំណើតម្តាយរបស់ខ្ញុំបន្ទាប់ពីធ្វើដំណើរដោយថ្មើរជើងអស់រយៈពេល១៧ថ្ងៃ ។ ស្រុកកំណើតម្តាយរបស់ខ្ញុំគឺនៅក្នុងភូមិជ្ជួស ឬហៅថាភូមិថ្មី ដែលស្ថិតនៅក្នុងឃុំព្រៃល្វា ស្រុកព្រៃកប្បាស ខេត្តតាកែវ ។ ពីផ្ទះរបស់ខ្ញុំនៅទួលគោកដែលជាកន្លែងកើតនិងរស់នៅរហូតដល់ធំ ហើយធ្វើជានិរសាររបស់ម្តាយខ្ញុំ ទៅដល់ខេត្តតាកែវគឺមានចម្ងាយប្រមាណ៨៥គីឡូម៉ែត្រ ។

ការសាកសួរមនុស្សម្នាដើម្បីរកទិសតំបន់ គឺជាមធ្យោបាយមួយដ៏មានប្រសិទ្ធិភាពណាស់ដើម្បីទៅដល់ទីតាំងណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា ។ គឺជារឿងសាមញ្ញពីព្រោះថាប្រជាជនកម្ពុជាមួយភាគធំជាកសិករ ហើយភាគច្រើនមិនចេះអាននិងសរសេរទេ ។ ការប្រើប្រាស់លេខអាសយដ្ឋានគឺមិនមែនជាភាពចាំបាច់ក្នុងការរកឲ្យឃើញនូវទីតាំងនានានៅក្នុងព្រះរាជាណាចក្រកម្ពុជាឃើញនោះឡើយ ។ យើងអាចវង្វេងផ្លូវវិញផងក៏មិនដឹង ។ ប្រជាជនកម្ពុជាពុំមានការថ្នាំងថ្នាក់សោះឡើយក្នុងការប្រាប់នូវទិសតំបន់នានា ទោះបីជាពេលខ្លះត្រូវចំណាយពេលអស់ច្រើនម៉ោងដើម្បីពន្យល់ថាបន្ទាប់ពីដល់កន្លែងមួយនោះហើយត្រូវទៅដល់ណាទៀត ឬក៏ថាមានផ្ទះប៉ុន្មានស្ថិតនៅបន្ទាប់ពីត្រពាំងមួយ ដើមឈើមួយ ឬវាលគុម្ពោតព្រៃមួយ ដើម្បីទៅដល់គោលដៅរបស់យើង ។

មធ្យោបាយរកទីតាំងណាមួយតាមរយៈការសាកសួរដោយផ្ទាល់មាត់ពុំមានការផ្លាស់ប្តូរបន្តិចឡើយ ហើយនេះគឺជាមធ្យោបាយដ៏មានប្រសិទ្ធិភាពមួយដែលនៅតែប្រើប្រាស់រហូតដល់សព្វថ្ងៃ ។ ក្នុងនាមជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ជាដរាបមកខ្ញុំតែងតែត្រូវធ្វើដំណើរជាមួយ «ក្រុមស្រាវជ្រាវរណ្តៅប្រល័យពូជសាសន៍» ទៅតំបន់ឆ្ងាយៗដាច់ស្រយាលនៅក្នុងបណ្តាខេត្តទាំងឡាយ ដើម្បីប្រមែប្រមូលព័ត៌មានអំពីរណ្តៅសាកសព គុក កន្លែងតម្កល់អដ្ឋិធាតុ និងទីកន្លែងសម្លាប់នានាដែលកិតចាប់ពីសម័យកាលកាន់អំណាចរបស់របបខ្មែរក្រហមមក ។ ការងារនេះគឺពុំមានការខុសគ្នាពី៣០ឆ្នាំមុននៅពេលដែលខ្ញុំធ្វើការជានិរសាឲ្យម្តាយរបស់ខ្ញុំនោះទេ ។ ដូចគ្នាដែរ គឺខ្ញុំបានសាកសួរអ្នកស្រុកដើម្បីឲ្យគាត់ប្រាប់ខ្ញុំអំពីទិសដៅទៅកាន់ទីតាំងប្រល័យពូជសាសន៍ និងភូមិកំណើតរបស់សាក្សីនានាដែលនៅរស់រានមានជីវិតសល់ពីសេចក្តីស្លាប់ដោយរបបខ្មែរក្រហម ដើម្បីខិតខំធ្វើយ៉ាងណាប្រមែប្រមូល និងកត់ត្រាទុកជាប្រវត្តិសាស្ត្រ នូវសេចក្តីចងចាំទាំងអម្បាលម៉ានរបស់សាក្សីទាំងអស់នោះ អំពីសេចក្តីឈឺចាប់ និងបទពិសោធន៍របស់ជនរងគ្រោះក្នុងរបបខ្មែរក្រហម ។ ការចងចាំរឿងរ៉ាវក្នុងរបបប្រល័យពូជសាសន៍ខ្មែរក្រហម គឺពិបាកទទួលយកប៉ុន្តែមានតម្លៃខ្លាំងណាស់ ដែលពុំអាចទុកឲ្យនៅដោយមិនបាននិយាយប្រាប់ការពិតនោះទេ ។ រឿងរ៉ាវនៃអំពើប្រល័យពូជសាសន៍មានសារៈសំខាន់មិនអាចកាត់ថ្លៃបាន ហើយដែលមិនអាចទុកចោលដោយពុំបានកត់ត្រា ឬឲ្យនៅឯកោនៅឯទីតាំងវាលពិឃាតក្រោមព្យុះភ្លៀងនោះឡើយ ។ រឿងរ៉ាវទាំងឡាយត្រូវតែបានកត់ត្រានិងរក្សាទុកដើម្បីជាប្រយោជន៍ដល់កូនចៅខ្មែរជំនាន់ក្រោយៗជាច្រើនតំណ ។ រឿងរ៉ាវទាំងនោះ គឺជាសាច់ឈាមនៃឆ្អឹងដែលពុំទាន់កប់នៅពាសវាលពាសកាល ដែលយើងបានប្រទះឃើញនៅគ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា ។ ឆ្អឹងទាំងនោះមានរាប់សែនរាប់លាន ។ ហើយនៅក្នុងចំណោមនោះគឺមានឆ្អឹងរបស់បងស្រីនិងបងប្អូនដទៃទៀតរបស់ខ្ញុំ ។ ម្តាយរបស់ខ្ញុំមានសំណាងបានរួចជីវិតពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម ។ ប៉ុន្តែពួកខ្មែរក្រហមបានសម្លាប់បងប្អូនរបស់គាត់ចោលគ្មានសល់ម្នាក់ ។ គាត់បានបាត់បង់នូវបងប្អូនញាតិសន្តានស្ទើរតែទាំងអស់ ។ គាត់បានឆ្លងកាត់នូវរាល់ទុក្ខវេទនាគ្រប់បែបយ៉ាងក្រោមរបបខ្មែរក្រហម ។ ឥឡូវនេះម្តាយរបស់ខ្ញុំមានអាយុ៧០ឆ្នាំថ្វាយហើយ តែគាត់នៅរឹងប៉ឹងដដែល ទាំងកម្លាំងចិត្ត និងកម្លាំងកាយ ។ ចំណែកខ្ញុំមានអាយុ៣៩ឆ្នាំហើយក្នុងឆ្នាំ២០០០នេះ ។ ខ្ញុំនៅតែជានិរសាររបស់ម្តាយខ្ញុំ ។ ការងាររបស់ខ្ញុំសម្រាប់ម្តាយដ៏កម្សត់របស់ខ្ញុំនាពេលនេះ គឺមិនមែនប្រមូលព័ត៌មានឬលុយកាក់ពីអតិថិជនឲ្យគាត់ដូចពេលមុនទៀតទេ ប៉ុន្តែគឺប្រមូលការពិត

អំពីរឿងរ៉ាវនៃអំពើប្រល័យពូជសាសន៍ និងយុត្តិធម៌ចំពោះអំពើប្រល័យពូជសាសន៍ដល់ញាតិមិត្តរបស់គាត់ ។ ម្តាយខ្ញុំចំណាយពេលវេលារបស់គាត់ស្ទើរតែទាំងអស់ស្តាប់ធម៌និងបម្រើព្រះសង្ឃនៅឯវត្តអារាម ។ គាត់ពុំមានប្រាក់គ្រប់គ្រាន់ដើម្បីឲ្យជារង្វាន់ដល់ខ្ញុំសម្រាប់ទិញនំចំណីឬភេសជ្ជៈដូចមុនទៀតឡើយ ។ តែផ្ទុយទៅវិញ គាត់បានផ្តល់មកឲ្យខ្ញុំនូវសេចក្តីស្រលាញ់គាំទ្រ និងលើកទឹកចិត្តចំពោះការងាររបស់ខ្ញុំ ក្នុងការស្វែងរកការពិតអំពីប្រវត្តិសាស្ត្រនៃរបបប្រល័យពូជសាសន៍ខ្មែរក្រហម ។ គាត់ជំរុញឲ្យខ្ញុំធ្វើការរួមចំណែកនិងចែករំលែករឿងរ៉ាវប្រវត្តិសាស្ត្រដ៏សំខាន់នេះជាមួយម្តាយគ្រប់រូបៗនៅក្នុងលោក ។



នៅពេលខ្ញុំបានទៅដល់ទីតាំងវាលពិឃាតនីមួយៗ វាបានធ្វើឲ្យខ្ញុំនឹកឃើញដល់ម្តាយរបស់ខ្ញុំ ដែលតែងតែបានទូន្មានខ្ញុំឲ្យស្រឡាញ់ការសិក្សា និងមានភាពរឹងប៉ឹងក្នុងជីវិត ។ គាត់មានជំនឿថា សេចក្តីស្រលាញ់ដែលផុសចេញពីដួងចិត្ត គឺជាមគ្គុទ្ទេសក៍ដែលនឹងនាំសភាវគតិរបស់យើងឲ្យឆ្ពោះទៅរកទិសដៅត្រឹមត្រូវពិតប្រាកដ ។ បេះដូងរបស់យើង គឺជាដួងព្រលឹងរបស់យើង ដែលអ្នកដទៃមិនអាចបំផ្លាញបានឡើយ ។

ពត៌មានស្រាវជ្រាវក្នុងទស្សនាវដ្តីស្វែងរកការពិត គឺជាវិភាគទានមួយយ៉ាងសំខាន់ចំពោះប្រវត្តិសាស្ត្រអំពើប្រល័យពូជសាសន៍នៅកម្ពុជា ហើយវាជាប្រវត្តិសាស្ត្រមួយដ៏សែនរន្ធត់ក្រៃលែង ។ នៅក្នុងនោះមានសេចក្តីបរិយាយអំពីដំណើររឿង បទពិសោធន៍ និងរសជាតិនៃការឈឺចាប់ រងទុក្ខវេទនាគ្រប់បែបយ៉ាងដែលសាក្សីរស់ពីសេចក្តីស្លាប់ជាច្រើននាក់បានបកស្រាយបំភ្លឺយ៉ាងច្បាស់ៗដល់«ក្រុមស្រាវជ្រាវ»របស់ខ្ញុំ ។ ភាគច្រើននៃអ្នកដែលនៅរស់សល់ពីស្លាប់ទាំងអស់គឺជា«ម្តាយ» ។ ទោះបីជាម្តាយទាំងអស់នោះធ្លាប់បានឆ្លងកាត់សម័យកាលប្រវត្តិសាស្ត្រដ៏តក់ស្លុតបែបនេះក៏ដោយ ក៏ប៉ុន្តែម្តាយទាំងអស់នៅតែអាចថែរក្សាកូនចៅរបស់ខ្លួនបាន ហើយរស់នៅដោយមាំមួនខ្លាំងក្លាដដែល ។ ម្តាយជាច្រើនបានរួមចំណែកចែករំលែកជាមួយយើងនូវប្រវត្តិសាស្ត្រមួយដែលគាត់ពុំចង់ឲ្យកើតមានឡើងសាជាថ្មីម្តងទៀតឡើយ ចំពោះកូនប្រុសកូនស្រីរបស់ខ្លួន ។ អត្ថបទជាច្រើននៅក្នុងទស្សនាវដ្តីនេះ គឺជាខ្លឹមសារដែលចេញមកដោយស្មោះសរពីបេះដូង ទឹកភ្នែក និងទុក្ខវេទនារបស់អ្នកម្តាយកម្ពុជាទាំងអស់ ។ គាត់ពុំចង់បានអ្វីពីយើងទាំងអស់គ្នាក្រៅពីឲ្យយើងស្តាប់រឿងរ៉ាវនិងការបួងសួងរបស់គាត់ឲ្យមានយុត្តិធម៌ចំពោះអំពើប្រល័យពូជសាសន៍តែប៉ុណ្ណោះ ។ ក្នុងនាមជានិស្សិតនៅក្នុងបេសកកម្មដ៏សំខាន់ជាប្រវត្តិសាស្ត្រនេះ ខ្ញុំមានកិត្តិយសខ្លាំងណាស់ក្នុងការចូលរួមស្តាប់រឿងរ៉ាវនិងការបួងសួងរបស់ម្តាយទាំងអស់ ជាមួយអ្នកទាំងអស់គ្នាដែលបានអានទស្សនាវដ្តីស្វែងរកការពិត ។ ខ្ញុំជឿជាក់ថា ម្តាយរបស់ខ្ញុំនិងម្តាយទាំងអស់ ពិតជាមានមោទនភាពឥតឧបមាចំពោះការចូលរួមថែរក្សាប្រវត្តិសាស្ត្រដ៏ជូរចត់នេះ ។ **ឆាំង យុ**

# ពីឯកអគ្គរដ្ឋទូតកម្ពុជាប្រជាធិបតេយ្យប្រចាំនៅប្រទេសឡាវ ក្លាយទៅជាអ្នកទោសគុកទួលស្លែង

ម៉ាយ ទូច ហៅ កែម ក្លាយជាអ្នកទោសគុកទួលស្លែង នៅថ្ងៃទី២០ ខែ១១ ឆ្នាំ១៩៧៧ ក្រោយពេលដែលគាត់បំពេញភារកិច្ចជាឯកអគ្គរដ្ឋទូតកម្ពុជាប្រជាធិបតេយ្យប្រចាំនៅប្រទេសឡាវអស់រយៈកាលជិត១ឆ្នាំ (ពីខែ៣ ឆ្នាំ១៩៧៦ ដល់ថ្ងៃទី២៨ ខែ១ ឆ្នាំ១៩៧៧) ។ មុនពេលក្លាយជាឯកអគ្គរដ្ឋទូតកម្ពុជាប្រជាធិបតេយ្យប្រចាំនៅប្រទេសឡាវ ម៉ាយ ទូច បានចូលជាសមាជិកបក្សកុម្មុយនិស្តនៅឆ្នាំ ១៩៦១ ដែលមាន កុយ ធួន ជាមេដឹកនាំខាងតំបន់កំពង់ចាម ។ ឆ្នាំ១៩៦៤ កុយ ធួន បានអប់រំ ទូច ឲ្យចូលស៊ី-អាយ-អេ (CIA) មានភារកិច្ចបង្កប់ស៊ីរ៉ូងផ្ទៃក្នុងបដិវត្តន៍ បំផ្លាញបដិវត្តន៍និងប្រជាជន ឃោសនាបំផុសប្រជាជនឲ្យច្របូកច្របល់និងកសាងកម្លាំងស៊ី-អាយ-អេ ។ ក្រោយរំដោះឆ្នាំ១៩៧៥ គាត់បានធ្វើជាប្រធានការទូតនៅក្រសួងការបរទេស ហើយបានធ្វើជាឯកអគ្គរដ្ឋទូតកម្ពុជាប្រជាធិបតេយ្យប្រចាំប្រទេសឡាវនៅឆ្នាំ១៩៧៦ ។ ម៉ាយ ទូច បានធ្វើសកម្មភាពបំផុសអាណិកជនខ្មែរនៅប្រទេសឡាវឲ្យស្អប់បដិវត្តន៍ ដោយសហការជាមួយទូតវៀតណាមនៅឡាវ ដើម្បីកសាងកម្លាំងទ័ពខ្មែរនៅឡាវឲ្យមកនៅតាមព្រំដែនថៃដើម្បីចូលធ្វើរដ្ឋប្រហារផ្តួលរំលំរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ។

ឯកសារចម្លើយសារភាពរបស់ ម៉ាយ ទូច ដែលគាត់បានសារភាពនៅគុកទួលស្លែង មានចំណាររបស់ ឌុច ដែលជាប្រធានគុកទួលស្លែង។ នៅលើទំព័រខាងមុខសរសេរថា **«បងជាទីគោរព, សកម្មភាពរបស់វាចែកជាពីរៈ ១-ជាមួយផ្នែកប.ព (បក្រពត្តិ) វាទាក់ទងអង្គការហាស់ សេ អ៊ា (UNHCR) បានជួប អ៊ិន តាំ ដោយដកអាណិកជនខ្មែរនៅលាវទៅអប់រំឱយដាច់ខាតប្រឆាំងប.វ (បដិវត្តន៍) នៅថៃ។ ហាស់ សេ អ៊ា ជាផ្នែកមួយនៃអង្គការសហប្រជាជាតិ ។ ហាស់ សេ អ៊ា ហៅឈ្មោះគឺស្នងការដ្ឋានជាន់ខ្ពស់ផ្នែកជនភៀសខ្លួន ។ ២-ជាមួយយួនវាធ្វើការងារជាប់ជាមួយទូតយួនឈ្មោះ ឌិញ យូលៀម និងរដ្ឋមន្ត្រីការបរទេសលាវឈ្មោះ ភូនស៊ី ផាស៊ឹត ក្នុងយុទ្ធសាស្ត្រសហព័ន្ធឥណ្ឌូចិន ។ យួនក៏ត្រូវការយកអាណិកជនខ្មែរនៅលាវប្រើការ ។ ដោយគោរព! ៩-២-៧៨, ឌុច, ២១-២-៧៨»** ។ នៅជ្រុងខាងឆ្វេងប៉ែកខាងក្រោមនៃទំព័រដដែលនេះ មានផ្នែកមួយទៀតនៃចំណាររបស់ ឌុច ថា **«សកម្មភាពវានៅលាវវាសរសេរពីទំព័រ៣៧តទៅ»** ។

ខាងក្រោមនេះគឺជាសកម្មភាពរបស់ ម៉ាយ ទូច តាមរយៈចម្លើយសារភាពរបស់គាត់ៈ

## ១-ប្រវត្តិសកម្មភាពរបស់ ម៉ាយ ទូច ហៅ កែម មុនឆ្នាំ១៩៧៥

ម៉ាយ ទូច ហៅ កែម អាយុ៤២ឆ្នាំ កើតនៅភូមិកោះអណ្តែត ឃុំកោះអណ្តែត ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម មាននាទីជាឯកអគ្គរដ្ឋទូតកម្ពុជាប្រជាធិបតេយ្យប្រចាំប្រទេសឡាវ ។ ឪពុកឈ្មោះ ពាង ម្តាយឈ្មោះ ស៊ុំ។ ឆ្នាំ១៩៤៦ ទូច ចាកចេញពីស្រុកកំណើតមកស្នាក់នៅវត្តបុទុមវតីភ្នំពេញជាមួយបងប្រុសឈ្មោះ ម៉ាយ សែម ជាមេកុដិ ។

ឆ្នាំ១៩៥៣ ទូច ប្រលងជាប់វិញ្ញាបនប័ត្រចេញពីសាលាហ្វ្រង់ស្វាបូដាំង ផ្លាស់ទៅរៀននៅសាលាឈ្នួលកម្ពុជបុត្រ រហូតដល់ឆ្នាំ១៩៥៦ ។ ឆ្នាំ១៩៥៧ រៀនថ្នាក់ទី៣ នៅវិទ្យាល័យសីហនុ កំពង់ចាម ។ ប្រឡងជាប់សញ្ញាប័ត្រឌីប្លូមឆ្នាំ ១៩៥៨ និងចូលធ្វើការជាលេខាធិការនៅក្រសួងការងារភ្នំពេញនៅឆ្នាំ១៩៥៩ ។ ក្នុងឆ្នាំនេះដែរ ទូច បានជាប់នឹងចលនាបដិវត្តន៍ដោយបានទទួលការអប់រំពី វន និង យ៉ែម ។

ឆ្នាំ១៩៦១ ម៉ាយ ទូច បានចូលជាជនបង្គោល ហើយនៅថ្ងៃទី១៦ខែ៤ ឆ្នាំ១៩៦២ បានចូលជាសមាជិកបក្សកុម្មុយនិស្តកម្ពុជាដោយមាន អេប អុន ជាអ្នកខ្ទេវសនាម និង វន ជាអ្នកទទួលស្គាល់ ។

ខែ១០ ឆ្នាំ១៩៦៣ រដ្ឋការផ្លាស់ ម៉ាយ ទូច ឲ្យទៅធ្វើការនៅកំពង់ចាម ។ វន ខ្ទេវសនាមឲ្យទៅរក កុយ ធួន ជាអ្នកទទួល

ខុសត្រូវនៅតំបន់កំពង់ចាម ។

ដើមខែ១១ ឆ្នាំ១៩៦៣ កុយ ធួន ខទេ្វសនាមអំពីភារកិច្ចរបស់ មាយ ទូច គឺរក្សាមន្ទីរនិងធ្វើនិរសាកំពង់ចាម-ភ្នំពេញ ។ ទាក់ទងជាមួយ កុយ ធួន យូរៗទៅ មាយ ទូច សម្គាល់ឃើញថា កុយ ធួន រូបរាងខាងក្រៅជាមនុស្សទន់ភ្លន់ រាបសា ស្លូតបូត ហើយឆ្លាតនិងយកចិត្តទុកដាក់ចំពោះអ្នកដទៃ ។ កុយ ធួន តែងតែផ្តល់លុយកាក់ឬសម្ភារៈឲ្យ ទូច ជាញឹកញាប់ នៅពេលណាដែលគាត់មានការខ្វះខាត ។ អាកប្បកិរិយានិងកាយវិការរបស់ កុយ ធួន ញ៉ាំងឲ្យទំនាក់ទំនងរវាងអ្នកទាំងពីរមានភាពស្និទ្ធស្នាលនិងយោគយល់កាន់តែខ្លាំង ។

ក្នុងខែ៣ ឆ្នាំ១៩៦៤ វេលាថ្ងៃត្រង់មួយ មាយ ទូច បានយកសំបុត្រនិងឯកសារពីភ្នំពេញទៅឲ្យ កុយ ធួន ចំពេលបាយ ។ កុយ ធួន បានអញ្ជើញ មាយ ទូច ឲ្យរួមបាយជាមួយ រួចហើយអង្គុយសំណេះសំណាលគ្នាពីបញ្ហាផ្សេងៗ ។ កុយ ធួន បានឆ្លៀតបញ្ចូលមនោគមន៍វិជ្ជាដល់ ទូច ថា ជាមាគ៌ារបស់អង្គការគឺអ្នកបដិវត្តន៍ត្រូវរស់នៅក្នុងស្មារតីសន្សំសំចៃ កុំខ្ជះខ្ជាយ ត្រូវគិតគូរដល់ការលំបាកខ្វះខាតរបស់ប្រជាជន របស់បដិវត្តន៍ ។ តែជាក់ស្តែងយើងបន្ធូរបន្ថយខ្លះកុំតឹងរ៉ឹងពេក ។ យើងធ្វើបដិវត្តន៍ខ្លះ យើងអធ្យាស្រ័យខ្លះ ទើបយើងមានកម្លាំងធ្វើការ ។ យើងគិតគូរផ្ទាល់ខ្លួនដើម្បីកុំឲ្យវាស្លូតពេក ។ បញ្ហាការពារសុខភាពជាបញ្ហាសំខាន់ដែរ មិត្តត្រូវគិតគូរពីសុខភាពមិត្តផងព្រោះ មិត្តឈឺច្រើន ។ កុយ ធួន ចេះតែលើកបញ្ហាប្រហាក់ប្រហែលនេះមកនិយាយជាញឹកញាប់ ដោយសង្កត់ពីលោកទស្សនៈរស់នៅតាមបែបឯកជនវាស្រួល វាសប្បាយ វាមានសុភមង្គលក្នុងគ្រួសារ ។ មាយ ទូច យល់ថាអ្វីដែល កុយ ធួន និយាយនេះត្រឹមត្រូវខ្លះដែរ ។ មួយរយៈក្រោយមក សភាពការណ៍បដិវត្តន៍ក្នុងសម័យនោះជួបប្រទះនូវបញ្ហាស្មុគស្មាញនិងតឹងតែងខ្លាំង ។ កុយ ធួន បានបន្លើលថា ខ្មាំងឥឡូវបង្កើនការពាតត្បាត ចាប់ចងកាប់សម្លាប់អ្នកបដិវត្តន៍ខ្លាំងសម្បើមណាស់ ។ បដិវត្តន៍មានតែបាតដៃទទេ ប្រកាន់គោលជំហរឯករាជ្យម្ចាស់ការខ្លួនទីពឹងខ្លួន ប្រយុទ្ធតស៊ូទល់នឹងខ្មាំងសត្រូវដែលមានមធ្យោបាយសព្វគ្រប់បង្ក្រាបចលនាបដិវត្តន៍ មិនដឹងជាយ៉ាងណាទេ ។ នៅក្នុងទីក្រុងសភាពការណ៍ក៏តឹងតែងស្មុគស្មាញ នៅជនបទក៏ស្មុគស្មាញ ។ អ្នកបដិវត្តន៍ជាច្រើនត្រូវបានពួកវា(ខ្មាំង) ចាប់ ហើយមួយចំនួនទៀតត្រូវពួកវាសម្លាប់ចោល ។ កុយ ធួន ចេះតែលើកបញ្ហាដដែលៗនេះមកនិយាយ ជាពិសេសបញ្ហាសន្តិសុខផ្ទាល់ខ្លួនធ្វើឲ្យ ទូច កាន់តែមានចិត្តបារម្ភចំពោះសុវត្ថិភាពរបស់ខ្លួនខ្លាំងឡើងៗ ។ កុយ ធួន ក្តាប់ចំណុចខ្សោយបានថា ទូច មានលោកទស្សនៈរស់នៅមិនត្រឹមត្រូវ ធ្វើបដិវត្តន៍ខ្លាចគ្រោះថ្នាក់ ចង់រស់នៅជួបជុំប្រពន្ធកូន គិតគូរតែគ្រួសារឯង ចង់រស់នៅក្នុងជីវភាពសម្បូរសប្បាយ មួយវិញទៀតឆាប់ជឿគេ ។ កុយ ធួន ប្រើប្រាស់ចំណុចខ្សោយទាំងនេះដើម្បីធ្វើការអូសទាញ ទីបំផុត ទូច ក៏ជឿតាមហើយព្រមចូលជាសមាជិកស៊ី-អាយ-អេ ដើម្បីកុំឲ្យមានគ្រោះថ្នាក់ និងដើម្បីកិត្តិយសគ្រួសារទៅអនាគត ។



ថ្ងៃទី២០ ខែ១២ ឆ្នាំ១៩៦៤ កុយ ធួន រៀបចំពិធីបញ្ចូល មាឃ ទូច ទៅក្នុងអង្គការស៊ី-អាយ-អេ ដោយធ្វើនៅផ្ទះ កុយ ធួន នៅសាលារុក្ខារក្សកំពង់ចាម ។ ក្រោយពេលចូលអង្គការស៊ី-អាយ-អេហើយ ទូច មានភារកិច្ចបីគឺៈ

១-កសាងកម្លាំង

២-ឃោសនាអប់រំបំផុសពាក្យចចាមអារាម បង្កឲ្យមានការច្របូកច្របល់ក្នុងជួរមហាជន

៣-បង្កប់ស៊ីរូងផ្ទៃក្នុងបដិវត្តន៍ ដើម្បីបំផ្លាញបដិវត្តន៍ បំផ្លាញប្រជាជន ។

ក្រោយពីចូលជាសមាជិកស៊ី-អាយ-អេហើយ នៅខែ១០ ឆ្នាំ១៩៦៥ មាឃ ទូច បញ្ចូលកម្លាំងពីរនាក់ទៀតដែលគាត់អូសទាញបាន ឲ្យចូលជាសមាជិកស៊ី-អាយ-អេ មានឈ្មោះ ញ៉ៅម សាន និង ភូ ។ មូលហេតុអូសទាញបានដោយសារអ្នកទាំងពីរនេះមានទស្សនះរស់នៅទំនាស់នឹងបដិវត្តន៍ ។ តាមរយៈនេះ ទូច បានអប់រំថា បដិវត្តន៍ជារបបមួយតឹងរ៉ឹងណាស់ ទាំងខាងការរស់នៅ និងខាងគំនិតផ្ទុយប្រឡះពីរបបយើងសព្វថ្ងៃ (សម័យសង្គមរាស្ត្រនិយម) របបយើងសព្វថ្ងៃនេះវាត្រូវនឹងសំណូមពររបស់យើងហើយ ។ ក្រោយមកទៀត មាឃ ទូច ដើរបំផុសពាក្យចចាមអារ៉ាមផ្សេងៗនៅកន្លែងធ្វើការ ក្នុងមជ្ឈដ្ឋានគ្រូបង្រៀនសាលាបច្ចេកទេស នៅតាមទីធ្លាលេងប៊ូល ផ្សាយពីសភាពតោតតោយរបស់កម្លាំងបដិវត្តន៍ ធ្វើឲ្យប្រជាជនបាត់ជំនឿលើបដិវត្តន៍ ។

ឆ្នាំ១៩៦៦ កុយ ធួន បានខទ្ទេសនាមឲ្យ មាឃ ទូច ស្គាល់ ដឿន និង ឈឿន ដើម្បីឲ្យអ្នកទាំងពីរនេះជួយណែនាំ ព្រោះគាត់ត្រូវចេញទៅឆ្ងាយ ។ បន្ទាប់មក មាឃ ទូច អូសទាញបានកម្លាំង៤នាក់ទៀតគឺ គង់ និង យូ ថាន់ ចូលជាសមាជិកស៊ី-អាយ-អេនៅខែ២ ឆ្នាំ១៩៦៦, សួស ស៊ាម និង ជំនឿ ចូលស៊ី-អាយ-អេនៅខែ៥ ឆ្នាំ១៩៦៦ ។ អ្នកទាំង៤រូបសុទ្ធតែជាអតីតគ្រូបង្រៀនសាលាបច្ចេកទេសកំពង់ចាម ។

ខែ៧ ឆ្នាំ១៩៦៦ ដឿន បានហៅប្រជុំមានគ្នា៦នាក់ដាក់ផែនការឲ្យជំរុញគ្រប់សកម្មភាពក្បត់ឲ្យអស់លទ្ធភាពនិងជាប់ទៅតាមសភាពជាក់ស្តែង គឺសំដៅរារាំង ទប់ទល់ និងបំផ្លាញបដិវត្តន៍ ។ ហើយក្នុងខែ៨ ដឿន បានហៅ ទូច, ញ៉ៅម សាន និង ភូ ប្រជុំម្តងទៀត ជំរុញឲ្យគ្រប់ផ្នែកធ្វើសកម្មភាពឲ្យអស់លទ្ធភាព ដើម្បីជំរុញភារកិច្ចឲ្យល្អ ធានាដល់ការពង្រីកកម្លាំងថែមទៀត ។ ក្រោយពីនោះ មាឃ ទូច អូសទាញបានកម្លាំងម្នាក់ទៀតឈ្មោះ សយ អតីតគ្រូបង្រៀននៅសាលាបច្ចេកទេស និងធ្វើពិធីបញ្ចូល សយ ជាសមាជិកស៊ី-អាយ-អេនៅខែ២ ឆ្នាំ១៩៦៧ ដោយមាន ដឿន ជាអ្នកទទួលស្គាល់ ។

ចុងឆ្នាំ១៩៦៧ ដឿន បានហៅប្រជុំនៅផ្ទះ គង់ មានគ្នា៩នាក់គឺ ដឿន, មាឃ ទូច, គង់, យូ ថាន់, សួស ស៊ាម, ជំនឿ, សយ, ញ៉ៅម សាន និង ភូ ខ្លឹមសារប្រជុំគឺជំរុញឲ្យធ្វើសកម្មភាពឲ្យកាន់តែខ្លាំងក្លាថែមទៀតឲ្យទាន់សភាពការណ៍ដែលវិវត្តន៍លឿនទៅមុខ ។

ក្នុងឆ្នាំ១៩៦៨ សភាពការណ៍តឹងតែងខ្លាំង ផ្ទុះកុប្បកម្មដណ្តើមអាវុធ បន្ទាប់មកផ្ទុះសង្គ្រាមផ្ទៃក្នុង ។ ឆ្លៀតឱកាសនេះ ទូច ធ្វើការបំផុសបន្ថែមទៀតពីភាពកម្សោយរបស់បដិវត្តន៍ ដើម្បីអូសទាញកម្លាំងបន្ថែម ។

ចុងឆ្នាំ១៩៦៨ នេះដែរ កុយ ធួន បានមកសំណាក់នៅផ្ទះរបស់ មាឃ ទូច ប្រហែល១ខែដើម្បីធ្វើការជាមួយមនុស្សមួយចំនួនដែលគាត់ហៅមក ក្នុងនោះមានឈ្មោះ ពក ដែលត្រូវរបួសមកសម្រាកព្យាបាលនៅទីនេះ និងឈ្មោះ ឈាន ទូតប្រចាំក្រុងហាណូយផងដែរ ។ ក្នុងរយៈកាលនេះ ទូច មាននាទីយាមកាមផ្ទះសម្បែងឲ្យល្អ ។ ក្រោយពីសំណាក់ធ្វើការមួយរយៈ កុយ ធួន ត្រឡប់ទៅវិញ ។ ខែ៣ ឆ្នាំ១៩៦៩ ដឿន បានធ្វើការប្រជុំជាមួយមនុស្ស៩នាក់មាន ដឿន, មាឃ ទូច, គង់, យូ ថាន់, សួស ស៊ាម, ជំនឿ, សយ, ញ៉ៅម សាន និង ភូ ។ ក្នុងអង្គប្រជុំ ដឿន បានលើកឡើងថា សភាពការណ៍វិវត្តលឿនទៅមុខ ដើម្បីឲ្យស្របនឹងសភាពការណ៍នេះ ចាំបាច់ណាស់មិត្តយើងត្រូវឈ្មុសឈ្មុលខិតខំសម្រុកសកម្មភាពការងារឲ្យមានសន្ទុះខ្លាំងក្លា មានតែយ៉ាងនេះទេទើបយើងអាចឆក់យកសភាពការណ៍ឲ្យអនុគ្រោះយើងបាន ។ កន្លងមកការងារយើងមិនមានសន្ទុះអីទេ យើងធ្វើដែរតែក្នុងលក្ខណៈធម្មតា ។ ខែ៣ ឆ្នាំ១៩៧០ ដឿន បានហៅអ្នកទាំង៩រូបដដែលមកប្រជុំម្តងទៀត ហើយណែនាំថា ឥឡូវសភាពការណ៍រដ្ឋប្រហារបានសម្រេចផលហើយ ប៉ុន្តែខាង





បដិវត្តន៍មិនឱបដៃនៅស្ងៀមចំពោះសភាពការណ៍នេះទេ ។ ដូច្នេះ មិត្តយើងម្នាក់ៗត្រូវខិតខំក្តាប់សភាពការណ៍នេះ ហើយខំបង្កើនសកម្មភាពគ្រប់ផ្នែកឲ្យខ្លាំងដើម្បីសម្រេចភារកិច្ចឲ្យបានល្អ ទប់ទល់សភាពការណ៍នេះ ។

ក្រោយរដ្ឋប្រហារចលនាមហាជនធ្វើបាតុកម្មប្រឆាំងរដ្ឋប្រហារឡើងដល់កម្រិតខ្ពស់ គ្មានកម្លាំងអីរារាំងចលនានេះបានទេ ។ មាយ ទូច បានធ្វើសកម្មភាពទប់ទល់ចលនានេះដោយឃោសនាថា មកធ្វើបាតុកម្មហ្នឹងមិនដឹងជាប្រាថ្នាអីទេ នៅតែផ្ទះខំធ្វើការទៅវាមិនស្រួលជាង ។

ពាក់កណ្តាលខែ៦ ឆ្នាំ១៩៧០ ឈ្មោះ ណន បានប្រាប់ ទូច ឲ្យចេញទៅតំបន់រំដោះ ។ មាយ ទូច បានចេញទៅស្រុកស្ទឹងត្រង់ដែលមានឈ្មោះ ពក រង់ចាំនៅទីនោះ ។ ពក បាននាំ ទូច និងមនុស្សម្នាក់ទៀតទៅដល់មន្ទីរក-២១(មន្ទីរភូមិភាគឧត្តរ) ។ ខែ១០ ឆ្នាំ១៩៧០ មាយ ទូច បានបញ្ចូលមនុស្សបីនាក់ទៀតដែលគាត់អូសទាញបានជាសមាជិកស៊ី-អាយ-អេ ។ អ្នកដែលចូលថ្មីត្រូវបានដាក់ផែនការឲ្យធ្វើសកម្មភាពបំផ្លាញបដិវត្តន៍ ធ្វើសកម្មភាពគាបគៀតប្រជាជនដែលរកស៊ីលក់ដូរបន្តិចបន្តួច រឹបអូសទំនិញកំប៉ិកកំប៉ុករបស់ប្រជាជន រហូតដល់ពេលខ្លះចាប់ឃុំឃាំងប្រជាជនពីបញ្ហាតូចតាចមិនសមហេតុផល ។ មួយចំណែកទៀត ធ្វើសកម្មភាពប្រឆាំងនឹងវិភាគទានបដិវត្តន៍ បំផុសឲ្យប្រជាជនមើលឃើញថា វិភាគទានបដិវត្តន៍វាដូចជាការយកពន្ធនៅក្នុងសង្គមចាស់ដែរ ។

ខែ១ ឆ្នាំ១៩៧១ អង្គការភូមិភាគតម្រូវឲ្យ មាយ ទូច ទៅរៀននៅសាលាបក្សលើកទីមួយនៅក-២៥ នៅក្នុងសង្កាត់បង្កីតាំងរេន តំបន់១៣០ រយៈពេលជាង១ខែដោយមានបងទីមួយ និងបងទីពីរជាគណៈអប់រំ ។

ខែ៦ ឆ្នាំ១៩៧១ មាយ ទូច ក្លាយជាសមាជិកគណៈអប់រំភូមិភាគដែលមានឈ្មោះ សោម (ទីវ អុល) ជាប្រធាន ។

ខែ១១ ឆ្នាំ១៩៧១ អង្គការភូមិភាគបានរំសាយគណៈអប់រំភូមិភាគ ។ ឈ្មោះ សោម ត្រូវដកទៅកន្លែងផ្សេង ។

ខែ ២ ឆ្នាំ ១៩៧២ អង្គការភូមិភាគបានចាត់តាំង មាឃ ទូច ជាសមាជិកស្រុកចំការលើ ។ មានតួនាទីនេះ ទូច ចាប់ផ្តើមជំរុញខាងពាណិជ្ជកម្មឲ្យទិញដូរខុសទិសដៅដែលអង្គការកំណត់ ហើយធ្វើឲ្យខាងពាណិជ្ជកម្មក្លាយទៅជាពាណិជ្ជកម្មដើម្បីចំណេញ ។ បំផុសកម្មាភិបាលឲ្យវក់នឹងការស៊ីផឹកគគ្រឹកគគ្រេង បន្ថយស្មារតីប្រយុទ្ធ ស្មារតីអង្គការធូររលុង ។ ខែ៧ អង្គការភូមិភាគតម្រូវឲ្យ មាឃ ទូច ទៅចូលរៀនក្នុងសាលាសន្និបាតភូមិភាគ ដែលធ្វើនៅក្នុងព្រៃមួយក្នុងបរិវេណសង្កាត់ទួលសម្បូរ ស្រុកស្ទឹងត្រង់ មានរយៈពេលជាង១ខែកន្លះ ដោយមានបងទីមួយជាគណៈអប់រំ ។ ចប់សន្និបាតអង្គការដកឲ្យមកធ្វើការនៅខាងក្រសួងសេដ្ឋកិច្ចវិញ ។ គណៈកម្មធិការសេដ្ឋកិច្ចមានឈ្មោះ ហុន ជាប្រធាន និង សាធ អនុប្រធាន ។ ឆ្លៀតពេលនោះ ឃួន បានណែនាំឲ្យស្គាល់ គុណ និង ហាក់ ហើយប្រាប់ថា ខ្ញុំស្នើឲ្យមិត្តយើងទាំងអស់ស្គាល់គ្នាក្នុងខ្សែស៊ី-អាយ-អេ ដើម្បីសម្រួលដល់សកម្មភាពផ្សេងៗក្នុងគណៈសេដ្ឋកិច្ចថ្មីនេះ ។

ខែ៧ ឆ្នាំ ១៩៧៣ មាឃ ទូច ត្រូវ ឃួន ដកចេញពីផ្នែកពាណិជ្ជកម្ម ហើយក្នុងមួយរយៈខ្លីគាត់ត្រូវគ្មានការងារធ្វើ បន្ទាប់មកទើបបានការតែងតាំងជាសមាជិកក្រសួងសេដ្ឋកិច្ចភូមិភាគឧត្តរ ទទួលនាទីជាប្រធានមន្ទីរសេដ្ឋកិច្ច ។ នៅទីនេះ មាឃ ទូច បានបំផុសបុគ្គលិកមន្ទីរពេទ្យឲ្យធ្វើការងារខ្ជិលច្រអូស មិនរវីរវល់ថែទាំអ្នកជំងឺ ។ ឲ្យខាងស្លថ្នាំនិងចាក់ថ្នាំធ្វើការខុសអនាម័យនាំឲ្យអ្នកជំងឺកើតដំបៅអាប់សែគ្រប់ៗគ្នា ធ្វើឲ្យកើតមានភាពស្មុគស្មាញអាប់អួរពេញក្នុងមន្ទីរពេទ្យទាំងមូល ។ សភាពនេះធ្វើឲ្យយុទ្ធជនយុទ្ធនារីមានសភាពស្អុះស្អាប់មិនស្និទ្ធស្នាលនឹងគ្នា ធ្វើឲ្យប៉ះពាល់ដល់សតិអារម្មណ៍អ្នកជំងឺ ម្យ៉ាងទោមនស្ស ម្យ៉ាងទៀតអស់ជំនឿលើពេទ្យទាំងស្រុង ។ ទន្ទឹមនឹងនេះបានបំផ្លាញសម្ភាររបស់អង្គការមានក្រណាត់ជាឌិប១០គី អង្រឹង៥គី និងថ្នាំពេទ្យមួយឡាំង ទុកឲ្យបែកខ្ទេចខ្ទី ត្រូវភ្លៀងលិចរហែករលួយនៅក្នុងឃ្លាំង ។

ចុងខែ៨ ឆ្នាំ១៩៧៤ អង្គការភូមិភាគបានចាត់តាំងគណៈកម្មការមួយ ដើម្បីទទួលខុសត្រូវក្នុងការសាងសង់វិមានបញ្ចុះសពកម្មាភិបាលយុទ្ធជននៅសមរភូមិមុខ ។ គណៈកម្មការនេះមានសមាជិក៨រូបក្នុងនោះ មាឃ ទូច ទទួលនាទីខាងផ្នែកតុបតែងលម្អ ។ គោលបំណងស្របច្បាប់ពីការសាងសង់វិមាននេះគឺ ដើម្បីរំឭកដល់វិញ្ញាណក្ខន្ធកម្មាភិបាលយុទ្ធជនដែលបានពលីនៅសមរភូមិមុខ និងលើកទឹកចិត្តដល់ឪពុកម្តាយសព ។ ជឿន បានហៅ មាឃ ទូច ទៅណែនាំថា ការបំផុសឲ្យសង់វិមាននេះជាផែនការរបស់ស៊ី-អាយ-អេដោយមានគោលបំណង ១-រារាំងនិងទប់ទល់ចលនាបង្កបង្កើនផលនៅសមរភូមិក្រោយ ២-បំផ្លាញទ្រព្យសម្បត្តិរបស់អង្គការនិងទ្រព្យសម្បត្តិរបស់មហាជន ៣-បង្កទំនាស់រវាងបដិវត្តន៍និងប្រជាជន និងបំផុសកំហឹងក្នុងជួរប្រជាជន ។ ជឿន និយាយទៀតថា ការងារការដ្ឋាននេះមានទំហំធំណាស់ដែរទាំងការប្រើកម្លាំងមនុស្ស កម្លាំងសម្ភារ និងពេលវេលា ។ ដូច្នេះ ស្នើមិត្តជំរុញការងារសំណង់នេះឲ្យមានសកម្មភាពខ្លាំងក្លា និងមមាញឹក ព្រោះបើសកម្មភាពការដ្ឋានខ្លាំងគឺដោយសារមនុស្សមកធ្វើការមានចំនួនច្រើន ។ ដូច្នេះ ការដ្ឋានសំណង់នេះជាកន្លែងដែលស្មុគស្មាញ និងមានទំនាស់ទាំងនៅមូលដ្ឋានការដ្ឋានផ្ទាល់ ។ ហេតុនេះយើងត្រូវធ្វើសកម្មភាពឲ្យបានល្អ ។ មាឃ ទូច គោរពតាមការណែនាំនេះ ធ្វើសកម្មភាពបំផ្លាញនៅខាងផ្នែកតុបតែងលម្អ និងខាងសំណង់ ។ ខាងការតុបតែងលម្អ មាឃ ទូច បានបំផ្លាញដើមម្នាស់ជាច្រើនរយដើម និងដើមដូងដែលយកមកសម្រាប់ដាំក្នុងទីធ្លាវិមានរាប់សិបដើមដោយដឹកជញ្ជូនពីមូលដ្ឋានមកដល់ទុកចោលឲ្យខូចប្រើការលែងកើត ។ ឯខាងសំណង់ជាក់ស្តែង ជួនកាលផ្ទះកំពុងសង់ត្រូវ មាឃ ទូច ឲ្យរុះរើផ្នែកខ្លះហើយឲ្យកែជាថ្មីឡើងវិញ ជួនកាលរុះរើផ្នែកខាងនេះប៉ះប៉ូវផ្នែកខាងនោះ ជួសជុល កែលម្អ ដោះដូរឡើងវិញ មិនចេះចប់មិនចេះហើយ ដោយលើកហេតុផលថាធ្វើនេះមិនទាន់សម មិនទាន់ល្អ មិនទាន់ម៉ត់ចត់ ។ល ។ ទន្ទឹមនឹងនេះបានរួមសកម្មភាពបំផ្លាញព្រៃឈើម៉ៃសាក់និងគគីដែលអង្គការសម្រេចឲ្យកាប់ដើមធំៗយកមកប្រើប្រាស់ក្នុងការដ្ឋាន ។ ដោយយកលេសថាគ្រឿងសំណង់ខ្លះត្រូវនឹងដើមម៉ៃសាក់តូចៗ ទូច ក៏បានជំរុញឲ្យកាប់ដើមម៉ៃសាក់តូចៗច្រើនរយដើមទៀត ។

ខែ១១ ឆ្នាំ១៩៧៤ ឈ្មោះ ស្រេង ហៅទៅណែនាំនៅមន្ទីររបស់ សាធ នៅស្ទឹងត្រង់ ដែលមានអ្នករួមប្រជុំគឺជា

សមាជិកស៊ី-អាយ-អេក្នុងគណៈកម្មាការសំណង់ចំនួន៤នាក់ ។ ផែនការប្រជុំគឺ ស៊ី-អាយ-អេ មានផែនការទម្លាក់គ្រាប់បែកលើការដ្ឋានវិមានបញ្ចុះសពក្នុងគោលបំណងៈ

១-សម្លុតស្មារតីប្រជាជន និងបំផុសកំហឹងប្រជាជនឲ្យទោមនស្សនឹងបដិវត្តន៍

២-បំផ្លាញអាយុជីវិតប្រជាជនស្លូតត្រង់នៅក្នុងការដ្ឋាន

៣-បំផ្លាញសំណង់និងសម្ភារផ្សេងៗនៅការដ្ឋាន

ការទម្លាក់គ្រាប់បែកគឺហៅតាមទូរលេខដែលខាង បងយួន (ធ្វើការនៅសមរភូមិមុខភ្នំពេញ) ជាអ្នករ៉ាប់រងឲ្យមកទម្លាក់នៅការដ្ឋានតែម្តង ។ ឯពេលវេលាអាចក្នុងអំឡុងខែ១២ ឆ្នាំ១៩៧៤ ។ ដល់ចុងខែ១២ ឆ្នាំ១៩៧៤ យន្តហោះធុនស្ទាបកាត់ចំនួន២គ្រឿង បានមកទម្លាក់គ្រាប់បែកលើការដ្ឋានក្នុងពេលព្រឹកចំនួន៥-៦គ្រាប់ ពេលល្ងាចមកទម្លាក់ថែម២-៣គ្រាប់ទៀត បណ្តាលឲ្យផ្ទះដែលសង់រួចត្រូវខូចខាតអស់២-៣ខ្នង តែមិនបណ្តាលឲ្យប៉ះពាល់ដល់អាយុជីវិតមនុស្សទេ ។ ក្រោយពីការទម្លាក់គ្រាប់បែកនោះមកការដ្ឋានសំណង់ថយសកម្មភាព មនុស្សកាន់តែតិចទៅៗ ។ ប្រហែល១ខែក្រោយ ការដ្ឋានសំណង់វិមានបញ្ចុះសពត្រូវបញ្ឈប់លែងដំណើរការតទៅទៀត ។ ផ្ទះសម្បែងដែលសង់ហើយ និងសម្ភារគ្រប់បែបយ៉ាងត្រូវរុះរើដឹកជញ្ជូនទៅមូលដ្ឋានវិញ ។

## ២-ប្រវត្តិសកម្មភាពរបស់ មាយ ទូច ក្រោយឆ្នាំ១៩៧៥

ខែ២ ឆ្នាំ១៩៧៥ មាយ ទូច ត្រឡប់មកធ្វើការនៅមន្ទីរសេដ្ឋកិច្ចភូមិភាគឧត្តរវិញ ។ នៅអង្គភាពនេះមាននាទីជំរុញការដេរសម្លៀកបំពាក់ដើម្បីផ្តល់ឲ្យយុទ្ធជន-យុទ្ធនារីក្នុងក្រសួងសេដ្ឋកិច្ចទាំងអ្នកថ្មីទាំងអ្នកចាស់ដែលកំពុងខ្វះខោអាវគ្រប់ៗគ្នា ។ ប៉ុន្តែពួកគេមិនឃើញមានខំតាមសភាពការណ៍សោះ ម្នាក់ៗធ្វើបែបធម្មតា ខ្វះសម្រាក ខ្វះជជែកគ្នា ខ្វះឈរ ខ្វះធ្វើការ ព្រងើយកន្តើយនឹងការងារមិនសម្រេចតាមផែនការដែលបានដាក់ចុះ ។ ព្រមជាមួយនេះ មាយ ទូច នៅបានបំផ្លាញសម្ភារក្នុងអង្គភាពគឺបំផ្លាញខោអាវ៣០កំប្លេដោយទុកចោលឲ្យភ្លៀងលិចរលួយខូច និងបំផ្លាញម៉ាស៊ីនដេរអស់៥គ្រឿងដោយដោះខ្ចៅក្នុងម៉ាស៊ីនគ្រវាត់ចោល ។

ក្រោយថ្ងៃរំដោះបានទាំងស្រុង មាយ ទូច ត្រូវដកមកធ្វើការនៅភ្នំពេញវិញ ។ ចុងខែ៥ ឆ្នាំ១៩៧៥ យួន បានចាត់តាំង មាយ ទូច ជាអនុប្រធានផ្សាររដ្ឋភ្នំពេញ ដែលពេលនោះមានឈ្មោះ ឈឿន ជាប្រធាន ។ ពាក់កណ្តាលខែ៦ ឈ្មោះ ឈឿន ត្រូវដកទៅទទួលការងារផ្សេងវិញ ពេលនោះគណៈពាណិជ្ជកម្មបានចាត់តាំង មាយ ទូច ជាប្រធានផ្សាររដ្ឋ ។ នៅផ្សាររដ្ឋនេះ ទូច បានបំផុសឲ្យមានទំនាស់ជាមួយអង្គភាពយោធាដែលប្រចាំការនៅទីនោះ ធ្វើឲ្យមានបរិយាកាសអាប់អួរសៅហ្មងរវាងគ្នានឹងគ្នា ពង្រីកទំនាស់ឲ្យកាន់តែធំនិងស្មុគស្មាញដោះស្រាយមិនចេះចប់ ។ លើសពីនេះនៅបំផុសបញ្ហាសីលធម៌រវាងនារីនិងបុរសឲ្យចោទឡើងជាបន្តបន្ទាប់ បង្កើតជាបញ្ហាច្របូកច្របល់ក្នុងអង្គភាព ។ បំផុសឲ្យម្នាក់ៗស្រឡាញ់ចូលចិត្តសម្ភារប្រណិតៗ ចូលចិត្តហ៊ឺហា រស់នៅភ្លើតភ្លើន ធ្វើអ្វីសេរីតាមចិត្ត ធ្វើឲ្យមានសភាពរយីករយាកគ្មានសណ្តាប់ធ្នាប់នៅក្នុងអង្គភាពទាំងមូល ។ នៅអង្គភាពផ្សាររដ្ឋនេះ មាយ ទូច កសាងបានកម្លាំងបីនាក់ថែមទៀតមានឈ្មោះ ឆេង, អឿន និងឈ្មោះ វ៉េន ។

ខែ៩ ឆ្នាំ១៩៧៥ ដដែល ឈឿន បានហៅ មាយ ទូច និងមនុស្ស៧រូបទៀតទៅប្រជុំនៅមន្ទីរពាណិជ្ជកម្មនាមាត់ទន្លេ ។ ក្នុងអង្គប្រជុំ ឈឿន បានលើកឡើងថា ផែនការរួមគឺធ្វើការបំផ្លិចបំផ្លាញមូលដ្ឋានសេដ្ឋកិច្ចសំខាន់ៗ ។ នៅក្នុងក្រុងមានរោងចក្រធំៗនិងសំខាន់ រោងចក្រអគ្គិសនី និងឃ្លាំងមួយចំនួន ។ ព្រមជាមួយនេះនៅមានភារកិច្ចមួយទៀតគឺ អង្គភាពនីមួយៗត្រូវរៀបចំទុកដាក់ស្បៀងដើម្បីម្ចាស់ការជាមុន ។ ស្បៀងត្រូវត្រៀមតាំងពីឥឡូវនេះទៅឲ្យបានហ្មត់ចត់និងត្រឹមត្រូវ ។ ភារកិច្ចត្រៀមស្បៀងនេះសម្រាប់ខែ៤-៥ ឆ្នាំ១៩៧៦ ។ បើសម្រេចភារកិច្ចនេះបានគឺជាការរួមចំណែកសម្រាប់ផែនការរួមគឺ កម្ទេចក្បាលម៉ាស៊ីនដឹកនាំរបស់បក្សកុម្មុយនិស្តកម្ពុជាដើម្បីដណ្តើមយកអំណាចនាឆ្នាំខាងមុខ ។ មាយ ទូច និងគ្នីគ្នាបានអនុវត្តតាមការណែនាំរបស់ ឈឿន ដោយចាប់ផ្តើមប្រមូលស្បៀងលាក់ទុកមានអង្ករ អំបិល ត្រីងៀត ប្រហុក ទឹកដោះគោ ស្ករស ថ្នាំពេទ្យ និងសម្ភារបន្ទាប់បន្សំផ្សេងទៀត ។ ការលាក់សម្ភារត្រូវធ្វើដោយប៉ិនប្រសប់និងឈ្លាសវៃ ពិនិត្យពិច័យឲ្យច្បាស់ចៀសវាងធ្វើការងារខ្ជីខ្ជាមិនប្រយ័ត្នប្រយែងនាំឲ្យបែកការណ៍ ។

នៅខែ១០ ឆ្នាំ ១៩៧៥ គណៈពាណិជ្ជកម្មចាត់តាំង មាឃ ទូច ឲ្យទៅរៀននៅសាលាបក្សលើកទីមួយ ។ វគ្គអប់រំនេះ ធ្វើនៅពហុកីឡដ្ឋានភ្នំពេញ មានរយៈពេលជាង១ខែហើយបង់ទីពីរជាគណៈអប់រំ ។ ខែ១១ ចេញពីសាលាបក្សវិញអង្គការដក មាឃ ទូច ឲ្យមកធ្វើការនៅក្រសួងការបរទេស ។ បានមួយរយៈ អង្គការក៏ប្រគល់ភារកិច្ចឲ្យធ្វើជាប្រធានពិធីការទូតនៅក្រសួងការបរទេស ។ ចុងខែ១២ ដឿន បានហៅកម្លាំងចំនួន១០នាក់ ក្នុងនោះមាន មាឃ ទូច ដងដែរ ទៅប្រជុំនៅមន្ទីរពាណិជ្ជកម្មនាមាត់ទន្លេដើម្បីបញ្ជាក់បន្ថែមអំពីផែនការក្បត់ដែលត្រូវអនុវត្តន៍ក្នុងពេលបុណ្យជាតិខែ៤ ឆ្នាំ១៩៧៦ ។ ដឿន បានលើកឡើងថា អង្គភាពនីមួយៗត្រូវទទួលខុសត្រូវក្នុងការរួមចំណែកអនុវត្តផែនការរួម គឺកម្ទេចក្បាលម៉ាស៊ីនដឹកនាំរបស់បក្សកុម្មុយនិស្តកម្ពុជា ដើម្បីដណ្តើមយកអំណាចនៅក្នុងពេលបុណ្យជាតិខែមេសា ឆ្នាំ១៩៧៦ ខាងមុខនេះ ។ ផែនការនេះបានរៀបចំល្អិតល្អន់ រង់ចាំតែពេលអនុវត្តទេ ។ ឯអ្នកអនុវត្តន៍គឺ យុទ្ធជនខាងកងពលឈ្មោះ អឿន ដែលទទួលភារៈយាមក្នុងពិធីបុណ្យនេះ ។ ដូច្នេះអ្នកយាមដែលត្រូវកាន់អាវុធអាកាស្រាប់ យើងក៏សម្រេចយកអាវុធនេះប្រើក្នុងការបាញ់តម្រង់ទៅអង្គការនៅលើវេទិកាតែម្តង ។

ដើមឆ្នាំ១៩៧៦ អង្គការសម្រេចឲ្យ មាឃ ទូច ទៅធ្វើជាឯកអគ្គរដ្ឋទូតកម្ពុជាប្រជាធិបតេយ្យប្រចាំប្រទេសឡាវ ។ ខែ២ ឆ្នាំ១៩៧៦ មុនពេលចេញទៅប្រទេសឡាវ មាឃ ទូច បានទៅជួប ឈឿន នៅមន្ទីរពាណិជ្ជកម្មនាមាត់ទន្លេ។ ឈឿន បានណែនាំថា មិត្តត្រូវបន្តសកម្មភាពរបស់យើងនៅប្រទេសឡាវជាបន្តទៀត ។ នៅស្រុកឡាវមានអាណិកជនខ្មែរដែរ ពួកនេះរស់នៅក្នុងសង្គមចាស់រហូត ដូច្នេះខាងជំហរទស្សនៈនយោបាយក៏ចាស់ អនុគ្រោះដល់សកម្មភាពការងាររបស់យើង ។ មិត្តមានភារកិច្ចកៀងគរពួកអាណិកជនខ្មែរទាំងនោះ ហើយកសាងឲ្យទៅជាកម្លាំងប្រឆាំងបដិវត្តន៍ ប្រឆាំងកុម្មុយនិស្ត ។ កម្លាំងនេះមិត្តត្រូវរៀបចំបញ្ជូនមកក្នុងប្រទេសជាបន្តបន្ទាប់តាមផ្លូវស្របច្បាប់ ។ រីឯបញ្ហាទទួលកម្លាំងនោះខាងខ្ញុំទទួលភារៈដោះស្រាយ ។ យើងនឹងប្រើកម្លាំងនេះធ្វើវិទ្ធង្សនាបំផ្លិចបំផ្លាញនៅតាមមូលដ្ឋាន សហករណ៍ព្រមទាំងជាកម្លាំងបង្កប់នៅក្នុងអង្គភាពនានា ធ្វើសកម្មភាពកសាងកម្លាំងជាសម្ងាត់សម្រាប់ជាយុទ្ធសាស្ត្រយូរអង្វែង វាយដណ្តើមអំណាចពីបក្សកុម្មុយនិស្តកម្ពុជានៅពេលដែលសភាពការណ៍អនុគ្រោះ ។ មួយចំណែកទៀត សូមមិត្តពិនិត្យលទ្ធភាពបញ្ជូនកម្លាំងអាណិកជនខ្មែរនៅឡាវទៅជំរុំខ្មែរភៀសសឹកនៅថៃ ដើម្បីបម្រើផែនការទៅមុខ គឺកសាងកម្លាំងនេះទៅជាកម្លាំងដាច់ខាតប្រឆាំងបក្សកុម្មុយនិស្តកម្ពុជា ប្រឆាំងបដិវត្តន៍កម្ពុជា ។ នៅត្រង់នេះ(ទំព័រ៤០) មានចំណារដែលជាប្រភេទអក្សរដូចគ្នាទៅនឹងអក្សរចំណាររបស់ ឌុច នៅទំព័រខាងមុខដែរថា **«ភារកិច្ចប្រឆាំងប.វ** (បដិវត្តន៍) **ប្រឆាំងប.ក.ក.** (បក្សកុម្មុយនិស្តកម្ពុជា) **ដែលអាឈឿន ប្រគល់ឱយគឺក្តាប់**



***អាណិកជនខ្មែរនៅលាវហើយកសាងពួកនេះឲ្យដាច់ខាតប្រឆាំង ប.ក.ក.»*** ។

នៅថ្ងៃទី២២ ខែ២ ឆ្នាំ១៩៧៦ មាឃ ទូច បានចេញដំណើរទៅបំពេញភារកិច្ចជាឯកអគ្គរដ្ឋទូតកម្ពុជាប្រជាធិបតេយ្យប្រចាំនៅប្រទេសឡាវ ។ ការបំពេញភារកិច្ចនៅប្រទេសឡាវចាប់ពីខែ៣ ឆ្នាំ១៩៧៦ ។

## ៣-អំពីសកម្មភាពក្បត់របស់ មាឃ ទូច នៅប្រទេសឡាវ

នៅប្រទេសឡាវ មាឃ ទូច បានចាប់ផ្តើមទំនាក់ទំនងជាមួយឈ្មោះ ព្រឿង យូរៗទៅក៏អូសទាញ ព្រឿង ឲ្យចូលរួមក្នុងកម្លាំងក្បត់ជាមួយខ្លួនដោយលើកឡើងថា នៅកម្ពុជា ក្រោយរំដោះមានជួបការលំបាកស្មុគស្មាញជាច្រើន រហូតមកដល់ឥឡូវបញ្ហាស្បៀងនិងបញ្ហាជម្រកសម្រាប់ប្រជាជនដោះស្រាយមិនបានដែលធ្វើឲ្យជីវភាពប្រជាជនកាន់តែលំបាកវេទនាខ្លាំងឡើង ។ ទូចចេះតែលើកឡើងបែបនេះជារឿយៗ មិនតែប៉ុណ្ណោះនៅបានស្នើព្រឿង ឲ្យនាំអាណិកជនខ្មែរមកលេងដើម្បីបានស្គាល់និងរាប់អានគ្នាតទៅ ម្យ៉ាងទៀត ទូច ស្នើយកផ្ទះរបស់ ព្រឿង ធ្វើជាកន្លែងជួបនឹងអ្នកទាំងនោះផង ។ មិនយូរប៉ុន្មានតាមរយៈ ព្រឿង, មាឃ ទូច ក៏បានស្គាល់ឈ្មោះ យ៉េន និង កុយ ។

នៅក្នុងខែ៦ ឆ្នាំ១៩៧៦ មាឃ ទូច បានហៅព្រឿង ឲ្យមកធ្វើការនៅស្ថានទូតជាមួយក្នុងតួនាទីជាអ្នកបកប្រែនិងធ្វើការងាររការិយាល័យខ្លះ តែគោលបំណងសំខាន់នោះគឺចង់ប្រើប្រាស់ ព្រឿង ឲ្យធ្វើជានិរសាទាក់ទងនឹងបរទេសដែលពាក់ព័ន្ធក្នុងការងារក្បត់ ។ ព្រមជាមួយនេះក៏បានហៅ យ៉េន មកធ្វើការងារក្នុងស្ថានទូតដែរ គឺពេលថ្ងៃឲ្យបោសប្រាសជុំវិញទីធ្លា និងពេលយប់យាមកាមការពារសន្តិសុខក្នុងស្ថានទូត តែតាមការពិតគឺដើម្បីការពារសន្តិសុខការងារក្បត់របស់គាត់តែប៉ុណ្ណោះ ។

ដើម្បីជំរុញភារកិច្ចកសាងកម្លាំង មាឃ ទូច បានអប់រំព្រឿង, យ៉េន និង កុយ ឲ្យទៅជាកម្លាំងស្នូល ហើយតាមរយៈអ្នកទាំងបីនេះនឹងធ្វើសកម្មភាពកសាងកម្លាំងអាណិកជនខ្មែរឲ្យទៅជាកម្លាំងក្បត់នឹងបក្សកុម្មុយនិស្តកម្ពុជា ក្បត់នឹងប្រជាជនកម្ពុជា ។ ចំពោះការងារនេះ មាឃ ទូច បានយកផ្ទះ ព្រឿង ធ្វើជាកន្លែងសម្រាប់ធ្វើសកម្មភាពផ្សេងៗក្នុងការកៀងគរប្រមូលនិងកសាងកម្លាំងអាណិកជនខ្មែរទៅថ្ងៃមុខទៀត ។ មានគូសបន្ទាត់ពីក្រោមឃ្លានេះ និងមានជាចំណារអក្សរតែមួយដូចគ្នានឹងចំណារខាងមុខថា **«វាក្តាប់អាព្រឿងដើម្បីក្តាប់អាណិកជនខ្មែរទាំងអស់នៅលាវ»** (ទំព័រ៤៣) ។

នៅខែ៦ ឆ្នាំ១៩៧៦ មាឃ ទូច បានទៅជួបទូតវៀតណាមឈ្មោះ ឌិញ ញ៉ូលៀម នៅស្ថានទូតវៀតណាម ដើម្បីសួរសុខទុក្ខនិងសំណេះសំណាលឆ្លើយតបនឹងគេដែលបានមកគួរសមនឹងគាត់កាលពីទើបនឹងមកដល់ ។ ក្នុងឱកាសនោះ ឌិញ ញ៉ូលៀម និយាយថា ប្រទេសទាំងពីរធ្លាប់បានសាមគ្គីគ្នាជាមួយនឹងប្រទេសឡាវ ធ្វើការតស៊ូប្រឆាំងនឹងអាណានិគមបារាំងនិងចក្រពត្តិអាមេរិកាំងរហូតបានឯករាជ្យរៀងៗខ្លួន ។ ដូច្នេះប្រទេសយើងទាំងបីមានប្រវត្តិតស៊ូរួមគ្នា ត្រូវតែសាមគ្គីគ្នាឲ្យបានជិតស្និទ្ធរឹងប៉ឹងដើម្បីរួមគ្នាកសាងប្រទេសក្នុងពេលបច្ចុប្បន្ននិងទៅអនាគត ។ ឌិញ ញ៉ូលៀម បានបន្តទៀតថា បក្សនិងរដ្ឋាភិបាលវៀតណាមចាត់ទុកបញ្ហាសាមគ្គីប្រទេសទាំងបីជាបញ្ហាសំខាន់ជាយុទ្ធសាស្ត្រ ។ ការប្រាស្រ័យទាក់ទងរវាងស្ថានទូតយើងទាំងពីរមុខជាល្អប្រសើរមិនខាន ហើយនឹងជួយជំរុញធ្វើឲ្យបញ្ហាសាមគ្គីរវាងស្ថានទូតយើងទាំងពីរមានលក្ខណៈរឹងប៉ឹងនិងជិតស្និទ្ធ ។ មានចំណារនៅក្បែរនេះជាអក្សរតែមួយដូចខាងលើដាក់ថា **«ទូតយួនស្ទាបអាទូច»**(ទំព័រ៤៣) ។ ក្រោយពីនោះ ទូតវៀតណាមបានសុំជួប មាឃ ទូច ៣-៤ដងទៀត ។ ក្នុងការជួបគ្នា៣-៤ដងនេះ ឌិញ ញ៉ូលៀម បានយល់និងស្គាល់ជំហររបស់ មាឃ ទូច ហើយការប្រាស្រ័យទាក់ទងរវាងអ្នកទាំងពីរកាន់តែមានលក្ខណៈស្និទ្ធស្នាលជាងមុន ។ នៅឃ្លានេះមានគូសបន្ទាត់ពីក្រោម ហើយចារដោយអក្សរដដែលថា **«យួនក្តាប់ទស្សនៈអាទូចបាន»** (ទំព័រ៤៤) ។

ក្រៅពីជួបជាមួយទូតវៀតណាមហើយ មាឃ ទូច បានទៅសុំជួបលោក ភូនសុី ដាសុីត រដ្ឋមន្ត្រីការបរទេសឡាវដើម្បីសម្តែងការគួរសម ។ ក្រោយពីបានសួរសុខទុក្ខគ្នាទៅវិញទៅមកលោក ភូន និយាយថា ខ្ញុំមានការបារម្ភដោយឃើញថាការទាក់ទងកម្ពុជា-វៀតណាមមានទំនាស់តឹងតែង ។ ចំពោះខ្ញុំចង់ឃើញការទាក់ទងរវាងកម្ពុជា-វៀតណាមមានបរិយាកាសល្អឡើងវិញ ។ បន្ទាប់ពីនោះលោក ភូន ក៏លើកខ្លឹមសារប្រហាក់ប្រហែល

ឌិញ ញ៉ូលៀម លើកឡើងដែរ ។ ត្រង់នេះ(ទំព័រ៤៨) មានចំណារដូចនឹងអក្សររបស់ ឌុច ថា **«ភូនស៊ី ផាស៊ីត ស្នាបស្នង់អាទូច»** ។

ចុងខែ៦ ឆ្នាំ១៩៧៦ លោក ភូន បានផ្ញើលិខិតអញ្ជើញ មាឃ ទូច ទៅពិសាបាយក្នុងនោះ ឌិញ ញ៉ូលៀម ក៏ត្រូវបានអញ្ជើញចូលរួមដែរ ។ បន្ទាប់ពីបាយរួចពួកគេចាប់ផ្តើមពិភាក្សាលើបញ្ហាមួយចំនួនដែលទាក់ទងរវាងប្រទេសទាំងបី ។ លោក ភូន និយាយថា «យើងត្រូវឯកភាពគ្នាដើម្បីសម្រេចគំនិតសហព័ន្ធឥណ្ឌូចិន ។ ខាងឡាវបានឯកភាពទាំងស្រុងអំពីយុទ្ធសាស្ត្របង្កើតសហព័ន្ធឥណ្ឌូចិននេះ ។ ហេតុនេះយើងត្រូវធ្វើសកម្មភាពដើម្បីអូសទាញកម្ពុជាឲ្យចូលក្នុងសហព័ន្ធនេះ ។ មិត្តមកធ្វើការនៅវៀងចន្ទមានលទ្ធភាពច្រើនក្នុងការកៀងគរកម្លាំងអាណិកជនខ្មែរ ព្រោះត្រូវកសាងកម្លាំងទាំងនេះឲ្យទៅជាកម្លាំងដែលប្រឆាំងកុម្មុយនិស្តកម្ពុជា ប្រឆាំងបដិវត្តន៍កម្ពុជា ដើម្បីបញ្ចូលធ្វើសកម្មភាពវិទ្ធង្សនាបំផ្លាញនៅក្នុងប្រទេស ម្យ៉ាងទៀតត្រៀមកម្លាំងនេះសម្រាប់ទៅថ្ងៃមុខ ។ ទន្ទឹមនឹងនេះត្រូវធ្វើសកម្មភាពបំផុសការឃោសនាវាយឥទ្ធិពលបដិវត្តន៍កម្ពុជាធ្វើឲ្យសកលលោកឃើញថា របបកម្ពុជាប្រជាធិបតេយ្យមិនយុត្តិធម៌ មិនស្អាតស្អំ ផ្តាច់ការ បំបាត់សិទ្ធិសេរីភាពប្រជាជន ប្រជាជនរស់នៅក្នុងសភាពតោកយ៉ាកលំបាកវេទនាឥតស្រាកស្រាន្ត» ។ អង្គប្រជុំឯកភាពគ្នាលើភារកិច្ចមួយចំនួន គឺ មាឃ ទូច ត្រូវអូសទាញអាណិកជនខ្មែរនៅឡាវឲ្យចូលរួមជាមួយគាត់, ឌិញ ញ៉ូលៀម ជួយក្នុងការប្រមូលកម្លាំងដោយរៀបចំក្រុមកីឡាជារូបភាព និងមាននាទីទាក់ទងទៅក្នុងប្រទេសកម្ពុជាតាមរយៈទូតវៀតណាមនៅភ្នំពេញ ។ ពួកគេបិទការពិភាក្សាដោយសង្ឃឹមថា កិច្ចសហការគ្នារិតតែល្អប្រសើរថែមទៀត ដើម្បីជំរុញផែនការឲ្យបានលឿនជាអតិបរមា ។ កបាំខណ្ឌនេះមានចំណារជាអក្សរតែមួយនឹងអក្សររបស់ ឌុច ថា **«ភូនស៊ី ផាស៊ីត ទូតយួន អាទូច ចាប់ផ្តើមធ្វើការជាមួយគ្នាតាមគោលការណ៍សហព័ន្ធឥណ្ឌូចិន** » (ទំព័រ៤៨) ។

ក្រោយនោះបន្តិច ឌិញ ញ៉ូលៀម បានស្នើជួប មាឃ ទូច តែពីរនាក់ ។ ការជួបលើកនេះ ឌិញ ញ៉ូលៀម និយាយថា «បក្សនិងរដ្ឋាភិបាលវៀតណាមកំណត់បញ្ហាសហព័ន្ធឥណ្ឌូចិននេះជាយុទ្ធសាស្ត្រសំខាន់ ។ បច្ចុប្បន្នសម្រេចមិនបាននឹងសម្រេចទៅអនាគត ១០-២០-៣០ឆ្នាំតកូនតចៅទៅថ្ងៃមុខ យុទ្ធសាស្ត្រសហព័ន្ធឥណ្ឌូចិននឹងបានទៅជាបញ្ហាសំខាន់ជិតជាប់ក្នុងគំនិតប្រជាជនវៀតណាមទាំងមូល ។ បក្សនិងរដ្ឋាភិបាលវៀតណាមមិនបោះបង់ចោលយុទ្ធសាស្ត្រយកប្រទេសកម្ពុជាឲ្យនៅក្នុងសហព័ន្ធនេះទេ គឺគ្រប់រយៈគ្រប់ជំនាន់នឹងធ្វើសកម្មភាពដើម្បីសម្រេចយុទ្ធសាស្ត្រនេះ» ។ ឌិញ ញ៉ូលៀម និយាយទៀតថា ក្រោយពីសម្រេចយុទ្ធសាស្ត្រសហព័ន្ធឥណ្ឌូចិនហើយ នឹងអនុវត្តយុទ្ធសាស្ត្រមួយទៀត គឺធ្វើឲ្យប្រជាជនទាំងបីប្រទេសទៅជាជាតិវៀតណាមទាំងអស់ ។ ដើម្បីសម្រេចយុទ្ធសាស្ត្រខាងលើនេះ បក្សនិងរដ្ឋាភិបាលវៀតណាមនឹងធ្វើសកម្មភាពគ្រប់បែបយ៉ាងទាំងអស់ ហើយមានលទ្ធភាពនិងមធ្យោបាយដើម្បីសម្រេចយុទ្ធសាស្ត្រនេះ ។ ពេលនេះមិនបានថ្ងៃក្រោយយូរបុណ្ណាប់នឹងសម្រេចបាន ។ ប្រទេសវៀតណាមមានមិត្តខាងសង្គមនិយមដូចជាសូវៀតជាដើម ជួយគាំទ្រនិងឧបត្ថម្ភពេញទី ដូច្នេះមានកម្លាំងធ្វើអីក៏បាន» ។

នៅខែ៧ ឆ្នាំ១៩៧៦ មាឃ ទូច បានទៅជួបប្រធានអង្គការហាស់-សេ-អ៊ែរ សួរនាំពីបញ្ហាជម្លៀសប្រជាជនទៅប្រទេសថៃ និងច្បាប់ទម្លាប់ផ្សេងៗពីការទាក់ទងជំរុំខ្មែរភៀសសឹក និងអង្គការហាស់-សេ-អ៊ែរនៅថៃ ។ ត្រង់នេះមានចំណារថា **«វាជាមួយផ្នែកច,ព**(បក្រពត្តិ) **តាមអង្គការ ហាស់ សេ អ៊ា»** និងមានកំណត់សម្គាល់នៅត្រង់អង្គការហាស់-សេ-អ៊ែរ ហើយសរសេរយ៉ាងវែងថា **«ហាស់ សេ អ៊ា តាមវាបញ្ជាក់គឺឈ្មោះថា ស្នងការដ្ឋានជាន់ខ្ពស់ខាងជនភៀសខ្លួន ជាផ្នែកមួយនៃអង្គការសហប្រជាជាតិ»** ។ អក្សរនៃចំណារទាំងពីរផ្នែកនេះសុទ្ធសឹងដូចទៅនឹងអក្សរចំណាររបស់ ឌុច នៅទំព័រខាងមុខដែរ ។ ប្រធានហាស់-សេ-អ៊ែរឈ្មោះ រ៉ូឡង់ដ៍ ជាជនជាតិបារាំង បានអះអាងចំពោះ មាឃ ទូច ថា បញ្ហាជម្លៀសអាណិកជនខ្មែរទៅប្រទេសថៃ អង្គការហាស់-សេ-អ៊ែរនឹងរ៉ាប់រងទាំងអស់ ព្រមទាំងសម្រួលសំបុត្រស្នាមឲ្យអាណិកជនខ្មែរផង ។

ក្នុងខែ៧ ឆ្នាំ១៩៧៦ អង្គការបានហៅ មាឃ ទូច ឲ្យមករៀនសូត្រនិងធ្វើការជាមួយអង្គការនៅភ្នំពេញមួយរយៈ ។ មាឃ ទូច បានមកដល់ភ្នំពេញនៅដើម ខែ៨ ឆ្នាំ១៩៧៦ ។ មកដល់ភ្នំពេញ មាឃ ទូច បានទៅជួប ឈឿន ។ ឈឿន

បានប្រាប់ថា ផែនការក្បត់កាលពីបុណ្យជាតិខែ៤ ឆ្នាំ១៩៧៦ នោះត្រូវបរាជ័យទៅហើយ ដោយសារអង្គការបានប្តូរវិធានការខាងសន្តិសុខនៅព្រឹកថ្ងៃបុណ្យ គឺហាមមិនឲ្យមានអាវុធគ្រាប់រំសេវអីទាំងអស់នៅក្នុងពិធីបុណ្យ ដូច្នេះយុទ្ធជនដែលទទួលភារៈខាងបាញ់កាំភ្លើងត្រូវគេដកអាវុធនិងគ្រាប់អស់ ហើយឲ្យនៅមួយកន្លែង ។ ក្នុងឱកាសនោះ មាយ ទូច ក៏បានរាយការណ៍ពីការងារនៅប្រទេសឡាវរួមមាន បញ្ហាដែលបានពិភាក្សាជាមួយទូតវៀតណាមនិងឡាវ បញ្ហាអាណិកជនខ្មែរនៅឡាវនិងថៃ និងបញ្ហាទាក់ទងជាមួយអង្គការហាស់-សេ-អ៊ែរ ។ បីថ្ងៃក្រោយមក ឈឿន បានជួប មាយ ទូច ម្តងទៀតនិងបានឆ្លើយតបអ្វីដែល មាយ ទូច បានធ្វើនោះថាគាត់ឯកភាពហើយ គាត់នឹងទទួលខុសត្រូវក្នុងការទាក់ទងជំរុំខ្មែរភៀសខ្លួនទៅទល់ដែនកម្ពុជា-ថៃក្នុងស្រុកអារញ្ញ ដើម្បីឲ្យខាងជំរុំខ្មែរភៀសសឹកទៅទាក់ទងទទួលអាណិកជនខ្មែរពីអង្គការហាស់-សេ-អ៊ែរដែលខាងឡាវបញ្ជូនមក ។ ជំរុំនេះមាន អ៊ុន តាំ ជាអ្នកទទួលខុសត្រូវ ។ ឈឿន នៅបានណែនាំបន្ថែមថា ចំពោះផែនការជម្លៀសនេះគឺដើម្បីវាយឥទ្ធិពលនយោបាយរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យលើឆាកអន្តរជាតិ សំដៅធ្វើឲ្យសកលលោកយល់ថា កម្ពុជាប្រជាធិបតេយ្យអយុត្តិធម៌ មិនត្រឹមត្រូវ អនុវត្តរបបផ្តាច់ការទៅលើប្រជាជន បានជាអាណិកជនខ្មែរនៅបរទេសមិនព្រមវិលត្រឡប់ចូលក្នុងប្រទេសរបស់ខ្លួនវិញ ។ ទន្ទឹមនឹងនេះ សំដៅធ្វើឲ្យរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យត្រូវឯកោពីប្រជាជនសកលលោក ។ កម្លាំងដែលបានបំពាក់ខាងនយោបាយរឹងប៉ឹងហើយ គឺជាកម្លាំងប្រយុទ្ធសម្រាប់ធ្វើវិទ្ធង្សនាបំផ្លិចបំផ្លាញលបលួចចូលបង្កការអុកឡុកក្នុងភូមិស្រុកក្បែរជាយដែន និងកម្លាំងមួយផ្នែកទៀតត្រៀមជាប្រចាំសម្រាប់ទៅអនាគតក្នុងការវាយបកមកកម្ពុជាប្រជាធិបតេយ្យ រួមផ្សំនឹងកម្លាំងក្បត់ក្នុងប្រទេស ។ ខែ៩ ឆ្នាំ១៩៧៦ មាយ ទូច ត្រឡប់ទៅវៀងចន្ទវិញធ្វើសកម្មភាពបំផុសឲ្យអាណិកជនខ្មែរនៅឡាវរត់ទៅជំរុំជនភៀសសឹកខ្មែរ-ថៃជាបន្តបន្ទាប់ ។

ខែ១០ ឆ្នាំ១៩៧៦ អ៊ុន តាំ បានមកវៀងចន្ទតាមរយៈអង្គការហាស់-សេ-អ៊ែរ ដោយមាន វ៉ូឡង់ង៉ ជាអ្នកទទួលខុសត្រូវក្នុងដំណើរនេះ ។ អ៊ុន តាំ បានជួបជាមួយ មាយ ទូច រយៈពេលប្រហែលជិតមួយម៉ោងដើម្បីសំណេះសំណាលគ្នានិងនិយាយពីការងារជនភៀសខ្លួននៅជំរុំទល់ដែនខ្មែរ-ថៃ (នៅត្រង់កថាខណ្ឌនេះមានចំណារជាអក្សរដូចខាងមុខថា **«វាបានជួបអា អ៊ុន តាំ តាមរយៈ ហាស់ សេ អ៊ែ»**) ។ ក្នុងឱកាសជួបគ្នានោះ អ៊ុន តាំ លើកឡើងថា សព្វថ្ងៃនេះនៅក្នុងជំរុំខ្មែរភៀសសឹកបានខិតខំយកចិត្តទុកដាក់ធ្វើការអប់រំកសាងកម្លាំងអាណិកជននេះដើម្បីកសាងឲ្យទៅជាកម្លាំងដែលមានជំហរនយោបាយប្រឆាំងកុម្មុយនិស្ត ។ កម្លាំងនេះជាកម្លាំងត្រៀមប្រចាំការគ្រប់កាលៈទេសៈ ដើម្បីធ្វើសកម្មភាពគ្រប់បែបយ៉ាង ធ្វើវិទ្ធង្សនាបំផ្លិចបំផ្លាញបដិវត្តន៍កម្ពុជា ព្រមទាំងជាកម្លាំងប្រយុទ្ធទៅអនាគតក្នុងការវាយបកមកកម្ពុជាប្រជាធិបតេយ្យរួមផ្សំនឹងកម្លាំងនៅខាងក្នុងប្រទេសដើម្បីដណ្តើមយកអំណាចមកវិញ ។ អំពីបញ្ហាជម្លៀសអាណិកជនខ្មែរទៅប្រទេសថៃមានសភាពងាយស្រួលដោយបានអង្គការហាស់-សេ-អ៊ែរ ទទួលខុសត្រូវផ្តល់មធ្យោបាយទាំងអស់ តាំងពីបញ្ហាធ្វើសំបុត្រស្នាម រហូតដល់បញ្ហាប្រគល់ឲ្យទៅខាងជំរុំខ្មែរភៀសសឹក...» ។ បន្ទាប់ពី អ៊ុន តាំ ត្រឡប់ទៅវិញ មាយ ទូច បានប្រគល់ការងារជម្លៀសអាណិកជនខ្មែរទៅប្រទេសថៃឲ្យមក ព្រឿង ជាអ្នកធ្វើសកម្មភាព ។

ខែ១១ ឆ្នាំ១៩៧៦ និងខែ១ ឆ្នាំ១៩៧៧ មាយ ទូច ធ្វើការអូសទាញអាណិកជនខ្មែរបានមួយចំនួនទៀតដូចជា យ៉េន, កុយ, ជាងលឹម, ជាងអ៊ុន, ឪពុករបស់ កុយ និងអ្នកបើករថយន្តចំណាស់ម្នាក់ដែលបើករថយន្តឲ្យស្ថានទូតតាំងពីយូរមកហើយ ។ ខ្ញុំមសារអប់រំគឺយកសភាពការណ៍នៅកម្ពុជាមកនិយាយឲ្យឃើញពីការលំបាកវេទនារបស់ប្រជាជន ពីការគាបសង្កត់សិទ្ធិសេរីភាពរបស់ប្រជាជន ពីការអនុវត្តន៍របបផ្តាច់ការកាប់សម្លាប់ប្រជាជនដើម្បីឲ្យពួកគេអស់ជំនឿលើរបបថ្មីនៅកម្ពុជាប្រជាធិបតេយ្យ ។

ដើមខែ១ ឆ្នាំ១៩៧៧ ភូនស៊ី ផាស៊ុត, ឌិញ ញ៉ូលៀម និង មាយ ទូច បានជួបប្រជុំគ្នាលើកអំពីផែនការដែលត្រូវអនុវត្តចំពោះកម្ពុជា ។ ឌិញ ញ៉ូលៀម បានលើកឡើងថា អាណិកជនខ្មែរដែលកសាងបានជាកម្លាំងហើយមួយចំនួនត្រូវបញ្ជូនឲ្យទៅក្នុងប្រទេសកម្ពុជា ។ កម្លាំងនេះមួយផ្នែក ធ្វើសកម្មភាពចំពោះមុខគឺធ្វើវិទ្ធង្សនាបំបែកបំបាក់ផ្ទៃក្នុងមហាជន ធ្វើការបំផ្លិចបំផ្លាញ

សម្ភារតូចធំ ព្រមទាំងធ្វើសកម្មភាពអុកឡុកនៅតាមសហករណ៍ រោងចក្រ និងអង្គភាពផ្សេងៗ ។ មួយផ្នែកទៀតជាកម្លាំងបង្កប់ស៊ីរូងផ្ទៃក្នុងមហាជន ធ្វើសកម្មភាពសម្ងាត់កសាងកម្លាំងនៅក្នុងជួរមហាជន ដើម្បីទៅអនាគតធ្វើយ៉ាងណាប្រកាន់តួនាទីដឹកនាំតាមសហករណ៍ រោងចក្រ និងអង្គភាពនានា ។ យើងធ្វើសកម្មភាពតាមវិធីបំភ្លៃបង្វែរមាគ៌ាដើម្បីកាឡៃពណ៌រដ្ឋអំណាចបដិវត្តន៍ ឬតាមវិធីក្តោងដណ្តើមអំណាចតែម្តង ។ ឯកម្លាំងអាណិកជនខ្មែរមួយផ្នែកដែលនៅខាងក្រៅប្រទេស គឺសម្រាប់ធ្វើសកម្មភាពផ្សេងៗ មានបង្កការអុកឡុកនៅតាមជាយដែនជាដើម ។ ដោយឡែកនៅតាមទល់ដែនឡាវ-កម្ពុជាត្រូវបង្កឲ្យមានភាពតានតឹង ធ្វើ សកម្មភាពអុកឡុកឲ្យរំខានស្មុគស្មាញ ដែលនឹងធ្វើឲ្យទំនាស់កាន់តែរីកធំនិងកាន់តែស្មុគស្មាញពីបញ្ហាព្រំដែនកម្ពុជា-ឡាវ ។ មានចំណារនៅត្រង់នេះជាអក្សរដូចខាងមុខដែរថា «**ផែនការយួនបញ្ជូនអាណិកជនខ្មែរភ្នាក់ងារវ៉ាមកកម្ពុជា**»(ទំព័រ៥២) ។



ចុងខែ១ ឆ្នាំ១៩៧៧ អង្គការបានហៅ មាឃ ទូច ត្រឡប់មកប្រទេសកម្ពុជាវិញ ដើម្បីសួរមតិបញ្ហាមួយចំនួន ។ មុនពេលត្រឡប់មកវិញ មាឃ ទូច បានប្រគល់ការងារឲ្យ ព្រឿង, កុយ និង យ៉េន ទទួលខុសត្រូវជំនួស ។ ថ្ងៃទី២៨ ខែ១ ឆ្នាំ១៩៧៧ មាឃ ទូច បានចេញដំណើរពីវៀងចន្ទ ហើយមកដល់ភ្នំពេញ ថ្ងៃទី៤ ខែ២ ឆ្នាំ១៩៧៧ ។ តាំងពីមកដល់ក្នុងប្រទេស មាឃ ទូច សំណាក់នៅក្នុងមន្ទីរប-១ រហូតដល់ថ្ងៃទី២២ ខែ៧ ឆ្នាំ១៩៧៧ ។ នៅថ្ងៃទី ២៣ ខែ៧ ឆ្នាំ១៩៧៧ អង្គការដកមាឃ ទូច ឲ្យទៅនៅក្នុងផ្ទះមួយតែម្នាក់ឯងនៅក្នុងអង្គភាពមិត្តមាស ហើយថ្ងៃទី២ ខែ៨ ឆ្នាំ១៩៧៧ អង្គការបញ្ជូនក្រុមគ្រួសាររបស់ មាឃ ទូច ឲ្យមករស់នៅជាមួយគាត់ ។

បន្ទាប់មកថ្ងៃទី២០ ខែ១១ ឆ្នាំ១៩៧៧ មាឃ ទូច ត្រូវអង្គការចាប់បញ្ជូនមកខាងក្រសួងសន្តិសុខ ។

ការពិនិត្យជារួមទៅលើឯកសារចម្លើយសារភាព យើងដឹងថា ការសួរចម្លើយ មាឃ ទូច នៅក្នុងគុកទួលស្លែងប្រព្រឹត្តទៅអស់រយៈពេល១៨ថ្ងៃទើបចប់សព្វគ្រប់ ដោយមានអ្នកសួរឈ្មោះ លី នៅក្នុងពួក «ក» ។ ឯកសារចម្លើយសារភាពជាអត្ថបទសរសេរដៃមានកម្រាស់៥៨សន្លឹក មានហត្ថលេខារបស់ មាឃ ទូច និងចុះកាលបរិច្ឆេទនៅគ្រប់សន្លឹកទាំងអស់ តាំងពីថ្ងៃសួរដំបូងរហូតដល់ថ្ងៃចុងបញ្ចប់ និងមានស្នាមមេដៃរបស់សាមីខ្លួននៅទំព័រចុងក្រោយផងដែរ ។ ឯកសារត្រូវបានផ្ញើជូនសមមិត្តវ៉ាន់ ។ ការដឹងបានដោយសារនៅទំព័រខាងមុខនៃឯកសារក្រៅពីចំណាររបស់ ឌុច នៅមានចំណារជាអក្សរធំៗមួយទៀតនៅផ្នែកខាងលើដាក់ថា «**ស.មវ៉ាន់**» ។

នៅទំព័រទី៥៥-៥៦-៥៧ ជាផ្នែកចុងបញ្ចប់នៃចម្លើយសារភាពមានបញ្ជីឈ្មោះមួយក្រោមចំណងជើងថា «បញ្ជីឈ្មោះអ្នកដែលរួមសកម្មភាពជាមួយខ្ញុំ» ដែលមានឈ្មោះមនុស្ស ៦០នាក់ត្រូវបាន មាឃ ទូច រាយការណ៍ថាមានពាក់ព័ន្ធជាមួយខ្លួន ។ ក្នុងចំណោមឈ្មោះទាំង៦០នាក់នោះ ១១នាក់មានបញ្ជាក់នៅក្នុងរង្វង់ក្រចកថា «**ចាប់ខ្លួនហើយ**» និងឈ្មោះ៥នាក់ទៀតមានបញ្ជាក់ថា «**ស្លាប់**» ។ នៅចុងបញ្ចប់នៃបញ្ជីនេះមានហត្ថលេខានិងស្នាមមេដៃរបស់ មាឃ ទូច ហៅ កែម ។

អត្ថបទខាងលើនេះ ជាសេចក្តីសង្ខេបចេញពីឯកសារ J០០៨១២បបគខ ជាចម្លើយសារភាពរបស់អ្នកទោសគុកទួលស្លែងឈ្មោះ មាឃ ទូច ហៅ កែម មានតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។

**កល្យាណ**

# អ្នកទោសខ្មែរកម្ពុជាក្រោម

របបសាធារណរដ្ឋខ្មែរដឹកនាំដោយលោកសេនាប្រមុខ លន់ នល់ បានដួលរលំនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ប្រទេសកម្ពុជាបានផ្លាស់ប្តូរការគ្រប់គ្រងទៅជារបបកម្ពុជាប្រជាធិបតេយ្យ ឬរបបខ្មែរក្រហម ។ ក្នុងអំឡុងពេលដែលរបបនេះកំពុងកាន់អំណាច ពួកខ្មែរក្រហមបានប្រើគ្រប់មធ្យោបាយតាមដាន ចាប់ឃុំឃាំង និងកាប់សម្លាប់ជនទាំងឡាយណាដែលប្រឆាំងនឹងមាគ៌ាដឹកនាំរបស់ខ្លួន ឬជនទាំងឡាយណាដែលរបបនេះសង្ស័យថាជា «ខ្មាំង ឬអ្នកទោសអន្តការ» ។ ក្នុងចំណោមមនុស្សរាប់លាននាក់ដែលខ្មែរក្រហមបានសម្លាប់ចោល គឺមានខ្មែរកម្ពុជាក្រោម ។

ខ្មែរនិងកម្ពុជាក្រោមគឺជាជាតិសាសន៍តែមួយ ហើយមានដើមកំណើតចេញមកពីប្រភពតែមួយដូចគ្នា គឺចេញមកពីនគរគោកធ្លកនៅសតវត្សទី១ ។[១] ខ្មែរកម្ពុជាក្រោមជាច្រើនត្រូវខ្មែរក្រហមចោទថាជាខ្មាំង ហើយចាប់ដាក់ឃុំឃាំងនៅគុកទួលស្លែង ដែលបែកចេញបីប្រភេទ ។ ប្រភេទទី១ គឺជាទាហានដែលយកការណ៍ឲ្យវៀតណាម ប្រភេទទី២ គឺពួកតស៊ូបម្រើលន់ នល់ និងប្រភេទទី៣ គឺពួកប្រជាជនធម្មតាសុទ្ធសាធរស់នៅកម្ពុជាក្រោម ។

<u>ប្រភេទទី១</u> ខ្មែរក្រហមហៅថាជាភ្នាក់ងារចារកម្មយួន ក្រុមនេះគឺជាកម្ពុជាក្រោមដែលបានចូលបម្រើក្នុងចលនាបក្សពលករយុវជនហូជីមិញ (បង្កើតនៅឆ្នាំ១៩៣០) ដើម្បីបណ្តេញចក្រពត្តិអាមេរិកចេញពីវៀតណាមខាងត្បូង ។ ហើយបន្ទាប់ពីបណ្តេញពួកអាមេរិកហើយ ក្រុមនេះនៅតែបន្តធ្វើការងារឲ្យវៀតណាមទាំងផ្នែកស៊ីវិលនិងយោធា ។ តាមចម្លើយសារភាពនៅគុកទួលស្លែង (ឯកសារ Y-២៧) ធ្វើនៅថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៧៨ យឿង កែវ អាយុ២៧ឆ្នាំ ជាខ្មែរក្រោម និងប្រពន្ធឈ្មោះ គីម លន ត្រូវបានយោធាខ្មែរក្រហមចាប់បាននៅថ្ងៃទី៤ ខែមករា ឆ្នាំ១៩៧៨ នៅពេលដែលកំពុងធ្វើដំណើរតាមទូកមកកាន់កោះរុងជាមួយនិងស្ត្រីវៀតណាម៣នាក់ ទៀតគឺ ទ្រីអ៊ុក ទ្រីណាង់ និង ប្រាំទ្រីមួយ ស្ត្រីវៀតណាមទាំងនេះ តាមផែនការគឺមកដើម្បីអូសទាញសតិអារម្មណ៍យុវជនកម្ពុជា ។ យឿង កែវ កើតនៅភូមិថ្កុក ឃុំយឿងវ៉ា ស្រុកពាម ខេត្តក្រមួនស កម្ពុជាក្រោម ។ យឿង កែវ បានសារភាពថា កាលពីឆ្នាំ១៩៦៨ បានទៅបួសជាសង្ឃនៅវត្តថ្កុក ដែលស្ថិតនៅក្នុងភូមិថ្កុក រហូតដល់ឆ្នាំ១៩៧៥ទើបសឹក ។ នៅឆ្នាំ១៩៧៤ ក្នុងអំឡុងពេលកំពុងបួស មានកម្មាភិបាលវៀតណាមខាងជើង៣នាក់មានឈ្មោះ អុង មីុយច (ប្រធានឃុំយឿងវ៉ា សម្ងាត់) យឿងទ្រី (ប្រធានភូមិថ្កុក សម្ងាត់) និង គង់ (ឈ្លបភូមិថ្កុក សម្ងាត់) បានមកអប់រំ យឿង កែវ, យឿង ចយ, និង យឿង ប៉ូវ ជាសង្ឃឲ្យចូលរួមចលនារបស់វៀតណាម ហើយបានប្រគល់ភារកិច្ចឲ្យបំផុសប្រជាជននិងព្រះសង្ឃឲ្យប្រឆាំងនឹងពួកទាហាន ង្វៀនវ៉ាន់ធីវ ។ យឿង កែវ បម្រើចលនានេះរហូតដល់វៀតណាមខាងត្បូងបានរំដោះក្នុងឆ្នាំ១៩៧៥ ។ ហើយក្រោយមក អុង មីុយច បានចាត់តាំង យឿង កែវ ឲ្យធ្វើការនៅក្នុងពាណិជ្ជកម្មនៅឃុំយឿងវ៉ា ។ ហើយនៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៧៨ អុង មីុយច បានហៅ យឿង កែវ មកប្រជុំ ហើយដាក់ផែនការណ៍ឲ្យចុះស៊ើបការណ៍នៅកម្ពុជា ។ យឿង កែវ សារភាពថា វៀតណាមបានដាក់ផែនការឲ្យមកស៊ើបយកការណ៍ ១-ពីមូលដ្ឋានទ័ពរបស់កងទ័ពបដិវត្តន៍ ទីតាំងកាំភ្លើងធំ រថក្រោះ នាវាចម្បាំងចាប់ពីកំពង់សោមដល់ក្រុងកែបខេត្តកំពត ។ បន្ទាប់ពីចាប់ខ្លួនត្រូវខ្មែរក្រហមបញ្ជូនមកកាន់ក្រុងកំពង់សោមចំនួន៣យប់ ។ ហើយនៅថ្ងៃទី៨ ខែមករា ឆ្នាំ១៩៧៨ អន្តការក៏បញ្ជូនមកមន្ទីរ

ស-២១(គុកទួលស្លែង) នៅភ្នំពេញ។ នៅគុកទួលស្លែង ត្រូវឈ្មោះ អឿន, ខន, និង ចិន (អ្នកសួរចម្លើយនៅមន្ទីស-២១) ។ សួរចម្លើយនៅថ្ងៃ១៦ ខែមករា ឆ្នាំ១៩៧៨ ។

ករណីមួយទៀតនៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៧៨ សឹង ស៊ាប (ក្នុងផ្លាកជាប់នឹងរូបថត) ហើយទំនងជាសរសេរ សឹន ស៊ាប (ក្នុងអក្សរវាយអង្គុលីលេខពីក្រោមរូបថត) ដែលជាខ្មែរកម្ពុជាក្រោម ត្រូវពួកខ្មែរក្រហមចាប់ខ្លួនបាននៅពេលដែលកំពុងដើរចូលភូមិអូររាំង ស្រុកសែនមនោរម្យ ខេត្តរតនគិរី ដើម្បីស៊ើបការណ៍ពីកម្ពុជា។ នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៨ សឹង ស៊ាប សរសេរចម្លើយសារភាពនៅទីនោះ រួចហើយទើបអង្គការបញ្ជូនមកគុកទួលស្លែងនៅភ្នំពេញ។ នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៧៨ ត្រូវឈ្មោះ ចាន់ (អ្នកសួរចម្លើយនៅមន្ទីរស-២១) ឲ្យសរសេរប្រវត្តិរូប និងសួរចម្លើយម្តងទៀតនៅក្នុងគុកទួលស្លែង។ នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៧៨ ត្រូវសន្តិសុខគុកទួលស្លែងយកទៅសម្លាប់ (បញ្ជីខ្មៅគុកទួលស្លែងឆ្នាំ១៩៧៨) ។ តាមចម្លើយសារភាពរបស់ សឹង ស៊ាប ធ្វើនៅ




ថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៩ នៅខេត្តមណ្ឌលគិរី គាត់បានសារភាពថា នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៧៩ អនុសេនីយ៍ផ្កាយ៤ (តាមឯកសារដើម) ដាន ផា បានចាត់តាំង សឹង ស៊ាប ជាពលបាលផ្កាយបី (តាមឯកសារដើមនាទីប្រធានកងអនុសេនាតូចលេខ៣ អនុសេនាធំលេខ១ វរសេនាតូចលេខ១ វរសេនាធំ៨១២ កងពលលេខ៥ ភូមិភាគ៧) និងទាហានវៀតណាម៥នាក់ទៀតឲ្យចុះមកស៊ើបការណ៍ពីកម្ពុជា។ នៅព្រឹកថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧៨ សឹង ស៊ាប និងបក្ខពួកក៏បានធ្វើដំណើរមកដល់អូររាំង ស្រុកសែនមនោរម្យ ខេត្តមណ្ឌលគិរី ហើយត្រូវពួកខ្មែរក្រហមចាប់ខ្លួនបាននៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ ១៩៧៨ ។ តាមចម្លើយសារភាពដែលមានចំណងជើងថា «អំពីប្រវត្តិរូបនិងសកម្មភាពឈ្លានពានកម្ពុជា» (ឯកសារតម្កល់នៅមជ្ឈមណ្ឌលឯកសារ) សឹង ស៊ាប អាយុ២៨ឆ្នាំ ខ្មែរកម្ពុជាក្រោម កើតនៅពពុះទឹក ឃុំភូមី ស្រុកបាសាក់ ខេត្តឃ្លាំង កម្ពុជាក្រោម។ កាលពីក្មេងធ្លាប់រៀននៅសាលាបឋមសិក្សានិងមធ្យមសិក្សាខេត្តឃ្លាំង ហើយបន្ទាប់មកបានបួស៥ឆ្នាំ។ នៅខែសីហា ឆ្នាំ១៩៧៥ រដ្ឋអំណាចវៀតណាមបានចាត់តាំងឲ្យធ្វើជាស្មៀនឃុំនៅឃុំភូមី ស្រុកបាសាក់ ខេត្តឃ្លាំង។ នៅខែសីហា ឆ្នាំ១៩៧៧ បានចូលចលនាយុវជនកុម្មុយនិស្តហូជីមិញ ដល់ខែតុលា ឆ្នាំ១៩៧៧ វិថាញ់ ជាគណៈស្រុក បានចាត់តាំងឲ្យទៅរៀននៅសាលាយោធាចំនួន៤ខែ គឺរៀនពីនយោបាយ បច្ចេកទេសយោធា និងរបៀបស៊ើបអង្កេត។

ករណីមួយទៀតគឺ ចៅ គីម។ ចៅ គីម ជាខ្មែរកម្ពុជាក្រោមដែលត្រូវពួកខ្មែរក្រហមចាប់ឃុំឃាំងនៅគុកទួលស្លែង។ មុនពេលត្រូវចាប់ខ្លួន ចៅ គីម ក៏ធ្លាប់ចូលបម្រើការងារក្នុងចលនាបក្សយុវជនពលករហូជីមិញ និងធ្លាប់ទទួលបានប័ណ្ណសរសើរពី គុងថាញ់ អនុលេខាស្រុកទ្រីទន នៅថ្ងៃទី១៧ ខែ១០ ឆ្នាំ១៩៧៦ អំពីភាពសកម្មក្នុងការបំផុសចលនាបក្សយុវជនពលករហូជីមិញ (ឯកសារគុកទួលស្លែង) ។

ប្រភេទទី២ គឺពួកខ្មែរម្ពុជាក្រោមដែលបម្រើចលនាមហាសាមគ្គីសេរីកាឥណ្ឌូចិន ដែលដឹកនាំដោយប្រមុខ (តទៅទំព័រទី២០)

## ប្រជាជនកម្ពុជា

គឺជាជនកម្ពុជាគ្រប់ជនជាតិរួមមានទាំងជនជាតិខ្មែរទាំងជនជាតិភាគតិចទាំងអស់នៅតាមមូលដ្ឋាននានានិងតំបន់នានាទូទាំងប្រទេសដែលមានកំណើតកើតជា និងរស់នៅបង្កបង្កើនផលនៅលើទឹកដីកម្ពុជាប្រជាធិបតេយ្យយើងតាំងពីយូរលង់មកហើយ ។ ប្រជាជនកម្ពុជាយើងមានជាតិកំណើតនិងរស់នៅលើទឹកដីកម្ពុជាតាំងពីកកើតប្រទេសកម្ពុជាយើងមក ។

ក្នុងឆ្នាំ១៩៧៧ កម្ពុជាប្រជាធិបតេយ្យយើងមានប្រជាជនទាំងអស់ចំនួន ៧.៧០០.០០០ នាក់ ។ ប្រជាជនកម្ពុជាគ្រប់រូបសុទ្ធតែជាកម្មករ-កសិករសមូហភាពទាំងអស់ ។ ប្រជាជនយើង៨០ភាគរយជាកសិករសហករណ៍ ។ ២០ភាគរយទៀតជាកម្មករសហជីពនិងជាយុទ្ធជន-យុទ្ធនារីនៃកងទ័ពបដិវត្តន៍កម្ពុជាដែលជាកូនចៅប្រជាជន កម្មករកសិករ ហើយដែលមានភារកិច្ចការពារជាតិនិងរួមចំណែកកសាងជាតិយ៉ាងជិតស្និទ្ធជាមួយពុកម៉ែកម្មករ-កសិករ ។ ប្រជាជនកម្មករ-កសិករសមូហភាពយើងរស់នៅសុខដុមរម្យនាក្នុងមហាសាមគ្គីជាតិទាំងមូល ហើយរួមគ្នាប្រកបការងារពលកម្មបង្កបង្កើនផល កសាង និងការពារសង្គមជាតិកម្ពុជាសមូហភាពស្មើភាព ប្រជាធិបតេយ្យពិតប្រាកដ ដោយគ្មានប្រកាន់ពូជសាសន៍ គ្មានអ្នកមាន គ្មានអ្នកក្រ គ្មានវណ្ណៈជិះជាន់គេ គ្មានវណ្ណៈត្រូវគេជិះជាន់ ។



អត្ថបទភូមិសាស្ត្រកម្ពុជាប្រជាធិបតេយ្យផ្នែកនយោបាយ បោះពុម្ពដោយក្រសួងសិក្សាធិការកម្ពុជាប្រជាធិបតេយ្យ លើកទី១ ឆ្នាំ១៩៧៧ សម្រាប់ថ្នាក់ទី២ (ដែនទីបោះពុម្ពផ្សាយឆ្នាំ១៩៧៦)

ដូច្នេះប្រជាជនកម្ពុជាយើងគ្មានចោទបញ្ហាអត់ការងារធ្វើ គ្មានចោទបញ្ហាចាកចោលភូមិកំណើត គ្មានចោទបញ្ហាមានប្រជាជនច្រើនពេកនៅកន្លែងណាមួយដូចសង្គមសក្តិភូមិនាយទុនពីមុនឡើយ ។

ក្រោយមហាជ័យជំនះ ១៧ មេសា ១៩៧៥ ប្រជាជនកម្ពុជាប្រជាធិបតេយ្យយើងកើនចំនួនក្នុងមួយឆ្នាំៗលើសកាលពីក្នុងសង្គមចាស់ ។ នេះក៏មកពីជីវភាពគ្រប់ផ្នែករបស់ប្រជាជនយើងត្រូវបានកែប្រែនិងលើកស្ទួយជាលំដាប់ ។

## រដ្ឋធានី និងអង្គការរដ្ឋ

ដើម្បីបម្រើកិច្ចការរដ្ឋ ទាំងក្នុងទាំងក្រៅ ប្រទេសឲ្យបានសមស្រប អង្គការបដិវត្តយើងបានយកទីក្រុងភ្នំពេញធ្វើជារដ្ឋធានីនៃកម្ពុជាប្រជាធិបតេយ្យយើង ។ ដូច្នេះទីក្រុងភ្នំពេញជាកន្លែងប្រជុំអង្គការរដ្ឋទាំងអស់របស់ប្រទេសយើង ។ អង្គការរដ្ឋរបស់ប្រទេសយើងគឺៈ

**១ - សភាតំណាងប្រជាជនកម្ពុជា**

សភាតំណាងប្រជាជនកម្ពុជាមានសមាជិកទាំងអស់២៥០នាក់ ដែលជ្រើសតាំងឡើងដោយប្រជាជនកម្ពុជា និងកងទ័ពបដិវត្តន៍កម្ពុជា តាមការបោះឆ្នោតដោយផ្ទាល់និងដោយសម្ងាត់ក្នុងរយៈកាល៥ឆ្នាំម្តង ។ សមាជិក១៥០នាក់ជាតំណាងកសិករ ។ ៥០នាក់ជាតំណាងកម្មករ និង៥០នាក់ទៀតជាតំណាងកងទ័ពបដិវត្តកម្ពុជា ។ សមាជិកទាំងអស់សុទ្ធតែជាអ្នកធ្លាប់រួមសុខទុក្ខ រួមតស៊ូ រួមរស់នៅ និងរួមប្រយុទ្ធធ្វើការងារជាមួយប្រជាជនកម្មករ កសិករ និងយុទ្ធជនយុទ្ធនារីនៃកងទ័ពបដិវត្តន៍កម្ពុជានៅក្នុងសម័យតស៊ូបដិវត្តកន្លងមក ក៏ដូចនៅក្នុងសម័យការពារនិងកសាង

កម្ពុជាប្រជាធិបតេយ្យយើងបច្ចុប្បន្ននេះដែរ ។ សភាតំណាងប្រជាជនកម្ពុជាមានភារៈធ្វើច្បាប់ សម្រេចច្បាប់ ពិនិត្យតាមដានការអនុវត្តច្បាប់ និងកំណត់មាគ៌ានយោបាយរបស់កម្ពុជាប្រជាធិបតេយ្យយើង ។ សភាតំណាងប្រជាជនកម្ពុជាមានគណៈកម្មាធិការអចិន្ត្រៃយ៍មួយ និងគណៈកម្មការផ្សេងទៀតមួយចំនួនដូចជា គណៈកម្មការសេដ្ឋកិច្ច គណៈកម្មការការពារប្រទេស គណៈកម្មការបរទេស គណៈកម្មការវប្បធម៌ សង្គមកិច្ច និងសុខាភិបាលជាដើម ។

## ២-គណៈកម្មាធិការតុលាការ

គណៈកម្មាធិការតុលាការ ជ្រើសតាំងឡើងដោយសភាតំណាងប្រជាជនកម្ពុជា ។ គឺជាអង្គការតុលាការរបស់ប្រជាជនតំណាងយុត្តិធម៌របស់ប្រជាជន ការពារយុត្តិធម៌របស់ប្រជាជន ការពារសិទ្ធិសេរីភាពប្រជាធិបតេយ្យរបស់ប្រជាជន ហើយផ្តន្ទាទោសដល់គ្រប់សកម្មភាពដែលប្រឆាំងនឹងរដ្ឋរបស់ប្រជាជន ឬដែលល្មើសនឹងច្បាប់រដ្ឋ របស់ប្រជាជនកម្មករ កសិករ និងកងទ័ពបដិវត្តន៍កម្ពុជាយើង ។

## ៣-គណៈប្រធានរដ្ឋ

គណៈប្រធានរដ្ឋជាអង្គការតំណាងឲ្យរដ្ឋកម្ពុជាប្រជាធិបតេយ្យយើងនៅក្នុងប្រទេសនិងក្រៅប្រទេស ក្នុងក្របខ័ណ្ឌរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងតាមច្បាប់ និងតាមមាគ៌ានយោបាយរបស់សភាតំណាងប្រជាជនកម្ពុជា ។ គណៈប្រធានរដ្ឋមានប្រធានមួយរូប អនុប្រធានទី១មួយរូប និងអនុប្រធានទី២មួយរូប ដែលជ្រើសតាំងឡើងដោយសភាតំណាងប្រជាជនកម្ពុជា ។

## ៤-រដ្ឋាភិបាល

រដ្ឋាភិបាលជាអង្គការអនុវត្តច្បាប់និងមាគ៌ានយោបាយរបស់សភាតំណាងប្រជាជនកម្ពុជា ហើយទទួលខុសត្រូវក្នុងបញ្ហានេះនៅចំពោះមុខសភាតំណាងប្រជាជនកម្ពុជា ។ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យយើង ជ្រើសតាំងឡើងដោយសភាតំណាងប្រជាជនកម្ពុជា ។ រដ្ឋាភិបាលមានរដ្ឋមន្ត្រីទី១មួយរូបជាតំណាងនិងទទួលខុសត្រូវ ហើយមានឧបនាយករដ្ឋមន្ត្រី-រដ្ឋមន្ត្រី និងប្រធានគណៈកម្មាធិការច្រើនរូបទៀតទៅតាមចំនួនក្រសួង និងចំនួនគណៈកម្មាធិការ ។ ដូចជាក្រសួងការបរទេស ក្រសួងសេដ្ឋកិច្ច ក្រសួងការពារប្រទេស ក្រសួងឃោសនាការនិងព័ត៌មាន ក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច ក្រសួងសាធារណការ ក្រសួងវប្បធម៌-អប់រំ និងសិក្សាធិការ គណៈកម្មាធិការកសិកម្ម គណៈកម្មាធិការឧស្សាហកម្ម គណៈកម្មាធិការពាណិជ្ជកម្ម គណៈកម្មាធិការគមនាគមន៍ គណៈកម្មាធិការថាមពល គណៈកម្មាធិការចម្ការកៅស៊ូជាដើម ។

# អំពីសហករណ៍ និងសហជីព

សព្វថ្ងៃនេះ កម្ពុជាប្រជាធិបតេយ្យយើងបានបែងចែកជារដ្ឋធានី ខេត្ត ភូមិភាគ តំបន់ ស្រុក ឃុំ និងសហករណ៍ ។

រដ្ឋធានីភ្នំពេញ ជាទីក្រុងប្រជុំអង្គការនយោបាយទាំងអស់របស់កម្ពុជាប្រជាធិបតេយ្យយើង ។ ឯខេត្តមួយចំនួនក៏មានទីក្រុងដែរ ។ ប៉ុន្តែទីក្រុងនេះមិនមែនដូចទីក្រុងក្នុងសម័យសង្គមចាស់ទេ គឺគ្រាន់តែជាកន្លែងរស់នៅនិងធ្វើការងាររបស់កម្មករសហជីពយើងប៉ុណ្ណោះ ។ ក្រៅពីនេះ នៅទូទាំងប្រទេសកម្ពុជាយើង សុទ្ធសឹងជាកន្លែងរស់នៅនិងធ្វើការងាររបស់កសិករសហករណ៍យើងទាំងអស់ ។ ដូច្នេះ សហករណ៍និងសហជីព ជាមូលដ្ឋានសំខាន់បំផុតនៃសង្គមកម្ពុជាប្រជាធិបតេយ្យយើង ។ ដោយប្រទេសកម្ពុជាយើងជាប្រទេសកសិកម្មមានប្រជាកសិករ៨០ភាគរយនៃចំនួនប្រជាជនយើងទាំងអស់ ដូច្នេះ សហករណ៍ជាមូលដ្ឋានបផ្អែកសំខាន់ជាងគេរបស់កម្ពុជាប្រជាធិបតេយ្យយើង ។

## I-អំពីសហករណ៍:

សហករណ៍កសិករយើងចាប់កើតឡើងពីថ្ងៃ២០ ខែឧសភា ឆ្នាំ១៩៧៣ ក្នុងភ្លើងសង្គ្រាមបដិវត្តន៍ដ៏សន្ធោសន្ធៅ ហើយរីកចំរើនធំធាត់ជាបន្តបន្ទាប់ដោយជំហានលោតផ្លោះ ។ នៅពេលចាត់តាំងដំបូង សហករណ៍យើងជាសហករណ៍ក្រុមមានសមាជិកពី ១០-១៥ ទៅ៣០គ្រួសារប៉ុណ្ណោះ ។ ក្រោយមហាជ័យជំនះ១៧ មេសា ១៩៧៥ សហករណ៍យើងបានវិវត្តមកជាសហករណ៍ភូមិទាំងអស់ហើយ ។ ហើយមកដល់

ដើមឆ្នាំ១៩៧៧ សហករណ៍យើងកាន់តែរីកចំរើនខ្លាំងក្លាទៀត រហូតដល់វិវត្តមកជាសហករណ៍(រួមភូមិតិចជាង១.០០០គ្រួសារ និងសហករណ៍ឃុំទាំងអស់១.០០០គ្រួសារ) ។

១.ជារូបភាពចាត់តាំង សហករណ៍គឺជាអង្គការចាត់តាំងមួយរបស់ប្រជាជនកសិករយើង ។ សហករណ៍កសិកររស់នៅហូបចុក រៀនសូត្រ កំសាន្ត ធ្វើការងារ និងទទួលផលស្មើៗគ្នាជាសមូហភាព ។ ឯខ្លឹមសាររបស់សហករណ៍វិញគឺមានធាតុពិតបដិវត្តដែលប្រឆាំង និងកំទេចដាច់ខាតនូវរបបជិះជាន់ និងរបបកម្មសិទ្ធិឯកជនរបស់វណ្ណៈសក្តិភូមិ នាយទុន ហើយកសាងការពារ និងពង្រីង-ពង្រីករបបស្មើភាពសមូហភាពរបស់វណ្ណៈកម្មករ-កសិករ ក្រោមការដឹកនាំរបស់អង្គការបដិវត្តកម្ពុជា ។

ឧទាហរណ៍ ៈ

-សហករណ៍ប្រមូលផ្តុំដីធ្លី គោ-ក្របី នង្គ័ល រនាស់ ពូជធារដែលជាមធ្យោបាយផលិតកម្មសំខាន់ៗ ដាក់ជាសម្បត្តិរួមរបស់សហករណ៍ ហើយរួមគ្នាបង្កបង្កើនផលជាសមូហភាព ។ ដូច្នេះគ្មានកសិករណាម្នាក់ខ្វះដី ខ្វះគោ-ក្របី ពូជធារ...ហើយរត់ទៅជួលឬទៅប្រវាស់គេដើម្បីបានស្រែ បានគោ-ក្របី មកបង្កបង្កើនផលចិញ្ចឹមជីវិតដូចមុនទៀតឡើយ ។ ហើយក៏គ្មានអ្នកណាម្នាក់មានដីមានគោ-ក្របី នង្គ័ល-រនាស់ សំរាប់ជួល ឬប្រវាស់ឱយគេដើម្បីកេងប្រវ័ញ្ចយកផលលពីញើសឈាមរបស់កសិករក្រីក្រដែរ ។

-សហករណ៍បែងចែកផលស្មើៗគ្នាជាសមូហភាព ហើយសាមគ្គីជួយគ្នាទៅវិញទៅមកគ្មានប្រកាន់ថាសហករណ៍ណា ឬសហករណ៍ណាឡើយ ។ ទន្ទឹមនេះ សហករណ៍យើងបានវាយកំទេចទស្សនៈ-សតិអារម្មណ៍ និងគោលជំហររបស់វណ្ណៈជិះជាន់គ្រប់ប្រភេទ ហើយកសាងទស្សនៈ សតិអារម្មណ៍ និងគោលជំហរសមូហភាពនៃវណ្ណៈកម្មករ-កសិករបដិវត្តន៍ ឱយដល់សមាជិកជាប់ជានិច្ច ។

២-សហករណ៍ជាកម្លាំងធំធេងខ្លាំងក្លាណាស់ ក្នុងការកសាងប្រទេស ។ ជាក់ស្តែងគ្រាន់តែក្នុងរយៈពេលដ៏ខ្លី សហករណ៍បានប្រែក្លាយមាតុភូមិកម្ពុជាយើងឲ្យមានអាងទឹក ព្រែកជីក ទំនប់ប្រឡាយ ប្រព័ន្ធភ្លឺស្រែថ្មីខាត់ខ្វែងជាក្រឡាឈើត្រង់យ៉ាងច្រើនស្អេកស្កះដែលធ្វើឲ្យជនបទកម្ពុជាយើងក្លាយទៅជាសួនស្រូវនិងសួនដំណាំយ៉ាងស្រស់បំព្រងខ្លួបប្រាំង ខ្លួបវស្សា ។

៣-សហករណ៍ជាគ្រឹះ និងជាកំពែងថែបយ៉ាងរឹងមាំបំផុតសំរាប់ការពាររដ្ឋអំណាចបដិវត្តនិងការពារកម្ពុជាប្រជាធិបតេយ្យយើង ។ ព្រោះសហករណ៍បានវាយកំទេចខ្មាំងសត្រូវគ្រប់ប្រភេទ និងវាយកម្ទេចទាំងរបប ទាំងទស្សនៈ-សតិអារម្មណ៍ និងគោលជំហររបស់វណ្ណៈជិះជាន់ផ្សេងៗទាំងអស់ ។

## II- អំពីសហជីពៈ

ជារូបភាពចាត់តាំង សហជីព គឺជាអង្គការចាត់តាំងមួយរបស់វណ្ណៈកម្មករ ។ កម្មករ គឺប្រជាជនដែលធ្វើការងារនៅក្នុងរោងចក្រ រោងជាងជីកជញ្ជូន-កំពង់ផែ រទេះភ្លើង នេសាទត្រីចិញ្ចឹមសត្វ នៅការដ្ឋានកសិកម្ម សំរាប់យកផលិតផលទៅបម្រើឧស្សាហកម្ម និងបម្រើជីវភាពប្រជាជនដូចជាការដ្ឋាន ស្រែអំបិលចំការកៅស៊ូ...ជាដើម ។

ចំពោះលក្ខណៈចាត់តាំង និងខ្លឹមសាររបស់សហជីពកម្មករក៏ដូចលក្ខណៈចាត់តាំងនិងខ្លឹមសាររបស់សហករណ៍កសិករដែរ ។ ប៉ុន្តែសហជីពកម្មករ មានតួនាទីសំខាន់ គឺកសាង និងជំរុញឧស្សាហកម្មជាតិយើង ។ ទន្ទឹមនឹងនេះ សហជីពកម្មករក៏មានភារកិច្ចបង្កបង្កើនផលឧបត្ថម្ភខ្លួន ដើម្បីសំរាលបន្ទុករដ្ឋយើងដែរ ។

ក្នុងដំណាក់កាលបដិវត្តន៍ថ្មីនៃការកសាង និងការពារប្រទេសបច្ចុប្បន្ននេះ សហជីពកម្មករយើងគ្រប់ផ្នែកទាំងអស់កំពុងវាយសំរុកបង្កើនផលិតផល និងវាយសំរុកកែប្រែរោងចក្រចាស់ៗដែលរណបបរទេសខាងវត្ថុធាតុដើម ឲ្យប្រើប្រាស់វត្ថុធាតុដើមក្នុងប្រទេសវិញ ព្រមទាំងកសាងរោងចក្រថ្មីសំរាប់បំរើកសិកម្ម និងជីវភាពប្រជាជនយើងយ៉ាងខ្លាំងក្លាបំផុត ។ សរុបមក សហករណ៍ និងសហជីពជាសម្ពន្ធភាពកម្មករកសិករក្រោមការដឹកនាំរបស់អង្គការបដិវត្តន៍កម្ពុជា ។ ផ្អែកលើកម្លាំងសម្ពន្ធ័ភាពកម្មករ-កសិករនេះ បដិវត្តន៍កម្ពុជាយើងបានពង្រីង-ពង្រីករបបសមូហភាពកាន់តែរឹងមាំ និងវាយកម្ទេចទាំងរបប ទាំងទស្សនៈ-សតិអារម្មណ៍ និងគោលជំហររបស់វណ្ណៈនាយទុន-សក្តិភូមិ និងវណ្ណៈជិះជាន់គ្រប់ប្រភេទទាំងអស់ ហើយវាយសំរុកកសាង និងការពារកម្ពុជាប្រជាធិបតេយ្យយើងឲ្យរីកចំរើនដោយជំហានលោតផ្លោះតាមមាគ៌ាឯករាជ-ម្ចាស់ការរបស់អង្គការបដិវត្តយើង ។

**(តមកពីទំព័រទី១៦)** ចលនា ចៅ ដរា ។ លោក ចៅដរា គឺជាលោកសេនាប្រមុខ លន់ នល់ ដែលប្រកាន់យករបបសាធារណរដ្ឋ ពីថ្ងៃទី៦ ខែ១០ ឆ្នាំ១៩៧០ ដល់ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងជាប្រធានរណសិរ្សតស៊ូកម្ពុជាក្រោម ដែលបង្កើតឡើងនៅថ្ងៃទី១៨ ខែ៣ ឆ្នាំ១៩៦០ នៅស្រុកស្វាយទង ខេត្តមាត់ជ្រូក ហើយស្លាប់នៅថ្ងៃ១៧ ខែ១១ ឆ្នាំ១៩៨៥ នៅសហរដ្ឋអាមេរិក (ដកស្រង់ចេញពីសៀវភៅ«ទុក្ខកម្ពុជាក្រោម» បោះពុម្ពឆ្នាំ១៩៩៧ ដោយ ថាច់ សិរ) ។ ក្រុមនេះក៏ជាសត្រូវរបស់ខ្មែរក្រហមដែរ ហើយមួយចំនួនត្រូវបានខ្មែរក្រហមចាប់ឃុំឃាំងនិងសម្លាប់ចោល ។ យោងតាមលិខិតបន្ទាប់ការរបស់លោក ចៅ ដរា ប្រមុខចលនាមហាសាមគ្គីសេរីកាឥណ្ឌូចិន មុនពេលចាកចេញឆ្ពោះទៅកាន់សហរដ្ឋអាមេរិកបានតែងតាំងលោក ចៅ មី ជាអគ្គមេបញ្ជាការចលនាមហាសាមគ្គីនៅថ្ងៃទី៣០ ខែ១១ ឆ្នាំ១៩៧៦ បានតែងតាំងលោក ចៅ ប្រុស ជាអនុមេបញ្ជាការចលនាមហាសាមគ្គី និងលោកវរសេនីយ៍ត្រី យ៉ញ យ៉ោម ជាមេបញ្ជាការកងវរសេនាតូច ហើយនៅថ្ងៃទី៨ ខែ១២ ឆ្នាំ១៩៧៦ តែងតាំងលោក ចៅ សុខសំណាង ជាមេបញ្ជាការកងវរសេនាតូច (ឯកសារទួលស្លែង) ។ «ការតែងតាំងនេះមានប្រសិទ្ធិភាពចាប់តាំងពីថ្ងៃចេញលិខិតនេះតទៅរហូតដល់ថ្ងៃខ្ញុំវិលមកពីបរទេសវិញ» ។ នៅលើលិខិតបន្ទាប់ការនេះ មានចំណាររបស់ពួកសន្តិសុខខ្មែរក្រហមថា ***សំគាល់ សួរវាថាតើគ្រានេះមានសេចក្តីថាយ៉ាងម៉េច? ពាក្យខាងក្រោមពាក្យ «ប្រធានាធិបតី» គឺ«លន់ នល់»ឬ?***

យោងតាមប្រវត្តិរូបនៅគុកទួលស្លែង (ឯកសារទួលស្លែង Box21) ចៅ សុន អាយុ៣៦ ខ្មែរក្រោម កើតនៅភូមិកំពង់ស្ពាន ឃុំកូវកែ ស្រុកកូវកែ ខេត្តបាសៀង កម្ពុជាក្រោម អតីតទាហានសក្តិ២ នៅកំពង់សោម រត់ចូលព្រៃនៅខែ៦ ឆ្នាំ១៩៧៥ ត្រូវទាហានខ្មែរក្រហមចាប់បាន និងឃុំខ្លួននៅគុកទួលស្លែង ហើយឲ្យសរសេរប្រវត្តិរូប ។ តាមសេចក្តីរាយការណ៍របស់ខ្មែរក្រហមកាលពីថ្ងៃទី១១ ខែ១២ ឆ្នាំ១៩៧៦ ជូនមកគណៈតំបន់តាកែវថា កាលពីថ្ងៃទី១០ ខែ១២ ឆ្នាំ១៩៧៦ នៅឃុំរាមអណ្តើក ខ្មែរក្រហមបានចាប់ទាហានខ្មែរដែលរត់មកពីស្រុកយួន ប្រដាប់ដោយអាវុធ៣៧ដើម ទាំងអស់៦៧នាក់ គឺខ្មែរនៅស្រុកខ្មែរខ្លះ និងខ្មែរនៅកម្ពុជាក្រោមខ្លះ ។ អ្នកទាំងនេះរត់ពីប្រទេសវៀតណាមនៅយប់ថ្ងៃទី៨ ខែ១២ ឆ្នាំ១៩៧៦ ដើរមកខាងត្បូងភ្នំដិន មកសម្រាកនៅភ្នំសោម១យប់ ។ ពួកនេះត្រូវខ្មែរក្រហមចោទថាជាខ្សែរបស់មហាចលនាសាមគ្គីឥណ្ឌូចិន ដែលកំពុងប្រយុទ្ធជាមួយយៀកកុងកុម្មុយនិស្ត ហើយសុំជំនួយពីចក្រពត្តិអាមេរិក ។ នៅព្រឹកថ្ងៃទី១១ ខែ១២ ឆ្នាំ១៩៧៦ ខ្មែរក្រហមបានបញ្ជូនទៅមន្ទីរសន្តិសុខស្រុក ដោយដឹកតាមរថយន្តចំនួន៩ជើង ។ ជើងទី១ ដឹកដោយរថយន្តតូចមានគ្នាបីនាក់ គឺមេបញ្ជាការថ្នាក់វរសេនីយ៍ ជើងទី៨មានម្នាក់លួចរត់ហើយត្រូវបាញ់ស្លាប់ ជើងទី៩ មាន៧នាក់លួចរត់តែត្រូវបាញ់ស្លាប់ទាំងអស់ ។

<u>ប្រភេទទី៣</u> គឺជាប្រជាជនខ្មែរកម្ពុជាក្រោមដែលភៀសខ្លួនចូលស្រុកខ្មែរហើយត្រូវខ្មែរក្រហមចាប់ឃុំឃាំង ឬត្រូវខ្មែរក្រហមចាប់នៅពេលខ្មែរក្រហមវាយចូលវៀតណាមកាលពីឆ្នាំ១៩៧៧ និង១៩៧៨ ។ ឧទាហរណ៍ដូចជាលោក ថាច់ យ៉ាវ អាយុ៦៥ និងកូនប្រុសពីរនាក់ ថាច់ ចំរើន (ឯកសារទួលស្លែង Box2) អាយុ២៣ឆ្នាំ និង ថាច់ សារឿន (ឯកសារទួលស្លែង Box2) អាយុ២១ឆ្នាំ ជាកម្ពុជាក្រោម រស់នៅភូមិប្រស្នា ឃុំប្រស្នា ស្រុកគីយិញ ខេត្តមាត់ជ្រូក កម្ពុជាក្រោម មុខរបរធ្វើចំការ អ្នកទាំងបីត្រូវពួកខ្មែរក្រហមចាប់បាននៅកម្ពុជាក្រោម រួចបញ្ជូនមកដាក់គុកទួលស្លែង នៅថ្ងៃទី៣ ខែ៩ ឆ្នាំ១៩៧៨ នៅផ្ទះ៣២ បន្ទប់ធំ៨ បន្ទប់តូច១៦ ហើយសួរប្រវត្តិរូប (ឯកសារទួលស្លែង Box2) ។ លោក គង់ ស៊ិន (ឯកសារទួលស្លែង Box2) ឈ្មោះប្រើ ប៊ុនធឿន អាយុ៣៥ឆ្នាំ ខ្មែរក្រោម មុខរបរជាអ្នកកាត់សក់នៅវាលបឹស កម្ពុជាក្រោម រស់នៅភូមិឫស្សីស្រុក ឃុំកំពង់ត្រាច ស្រុកកំពង់ត្រាច ខេត្តកំពត ត្រូវខ្មែរក្រហមចាប់នៅកម្ពុជាក្រោម រួចឃុំខ្លួននៅក្នុងគុកទួលស្លែងនៅថ្ងៃទី៩ ខែ១ ឆ្នាំ១៩៧៨ ហើយសួរប្រវត្តិរូប ។

តាមការសម្ភាសន៍ជាមួយលោក សំ អាយុ៣៧ឆ្នាំ ជាអតីតកុមារក្នុងកងការពារអ្នកទោសនៅស-២១ (គុកទួលស្លែង)

សព្វថ្ងៃរស់នៅខេត្តកំពង់ឆ្នាំង គាត់បាននិយាយថា នៅឆ្នាំ១៩៧៧ មានអ្នកទោសប្រុស-ស្រីកម្ពុជាក្រោមនិងវៀតណាមជាប់គុក ក្នុងនោះមានអ្នកទោសស្ត្រីកម្ពុជាក្រោមម្នាក់បានសុំសារុងគាត់ គាត់ក៏ឲ្យសារុងទៅអ្នកទោសនោះទៅ ពេលគាត់ឲ្យសារុងទៅអ្នកទោសមានអ្នកដទៃឃើញ គាត់ត្រូវបានអង្គការចោទថាបែចូវអ្នកទោស ហើយត្រូវបានពួកខ្មែរក្រហមដាក់ទណ្ឌកម្មបង្អត់បាយចំនួន៧ថ្ងៃ ក្រោយមកអង្គការឲ្យគាត់ទៅរែកអាចម៍ពីម៉ោង៦ទៅ៧ព្រឹក រួចបោសអគារ បោចស្មៅ និងដាំត្រកួន។

ក្រោយឆ្នាំ១៩៧៩ ក្នុងចំណោមអ្នកទោសនៅទួលស្លែងប្រមាណជិត២០០០០នាក់ មានតែអ្នកទោសប្រមាណ៧នាក់ប៉ុណ្ណោះ ដែលរួចរស់ជីវិត។

**ឆៀង សុភៈវិជ្ជា**

(១) នគរគោកធ្លក ឬនគរភ្នំ ក្រោយមកត្រូវប្តូរទៅជាអាណាចក្រចេនឡាវិញ គឺចេនឡាដីគោកនិងចេនឡាលិចទឹក ហើយដោយសារតែការឈ្លានពានទឹកដីពីសំណាក់ប្រទេសជិតខាងដូចជា សៀម និង អណ្ណាម (វៀតណាម) ធ្វើឲ្យអាណាចក្រខ្មែរបាត់បង់ទឹកដីមួយផ្នែកធំ គឺទឹកដីមួយផ្នែកត្រូវសៀមយក ហើយទឹកដីចេនឡាលិចទឹកទាំងមូលត្រូវធ្លាក់ទៅក្នុងការគ្រប់គ្រងរបស់វៀតណាមរហូតមកដល់សព្វថ្ងៃ។ ទឹកដីចេនឡាលិចទឹកចាប់ផ្តើមបាត់បង់បន្តិចម្តងៗចាប់ពីសតវត្សរ៍ទី១៧ (រាជជ័យជេដ្ឋាទី២ ពីឆ្នាំ១៦១៨ ដល់ ១៦២៨) រហូតមកដល់ឆ្នាំ១៨៤០ ទើបទឹកដីកម្ពុជាក្រោមទាំងមូលធ្លាក់ក្នុងដៃវៀតណាមដែលមានទាំងអស់១៩ខេត្ត ហើយក្រោយមកទឹកដីចេនឡាលិចទឹកត្រូវបានហៅថាកូសាំងស៊ីន ឬកម្ពុជាក្រោម (ដកស្រង់ចេញពីសៀវភៅ«ទុក្ខកម្ពុជាក្រោម» បោះពុម្ពនៅសហរដ្ឋអាមេរិក ឆ្នាំ១៩៩៧ ដោយ ថាច់ សិរ)។




ស្នើអ,កពិនិត្យ, ២១,១១,៧៦, ១៩៧១ នៅសាលមហោស្រព។
១, ស្គាល់ផល្លានៅចុងឆ្នាំ១៩៧០ ២, មូលហេតុស្គាល់ ប៉ុក-ថន នាំឲ្យស្គាល់។ ៣, ជិតស្និតនឹងផល្លាតាំងពីចុងឆ្នាំ១៩៧១។

បងជាទីគោរព! ដោយឃើញរូបនេះកាលនៅក្មេងពេក។ ចោទបញ្ហាថា តើពីរនាក់នេះស្គាល់គ្នាពីអង្កាល បើមួយនៅសៀមរាប មួយនៅ កំពង់ចាម មួយគ្រូ មួយអ្នកបច្ចេកទេស។ ឲ្យគេបញ្ជាក់ នួន ឃឿន វាឆ្លើយដូចចំណារខាងលើ។ ដោយគោរព! ឌុច, ១៨.១១.៧៦

## សេចក្តីអំពាវនាវ

អត្ថបទក្នុងទស្សនាវដ្តីនេះ ជាពិសេសក្នុងផ្នែកឯកសារ ដូចជា «ជនជាតិចាមនៅគុកទួលស្លែង»ក្នុងលេខទី១ និង «កងការពារអ្នកទោសនៅគុកទួលស្លែង» នឹងត្រូវប្រមូលផ្តុំសរសេរជាសៀវភៅប្រវត្តិសាស្ត្រស្តីអំពីរបបខ្មែរក្រហម។ បច្ចុប្បន្នមជ្ឈមណ្ឌលឯកសារមានគម្រោងស្រាវជ្រាវលើប្រធានបទចំនួន១៩ ទាក់ទងនឹងប្រវត្តិនិងការរំលោភសិទ្ធិមនុស្សមកលើជនជាតិភាគតិច កុមារ ជនជាតិតំបន់ភ្នំ ស្ត្រី ព្រះសង្ឃ បូជនីយដ្ឋានតម្កល់អដ្ឋិធាតុជាដើម។

មជ្ឈមណ្ឌលឯកសារសូមអំពាវនាវ និងស្វាគមន៍រាល់ស្មារតីស្មគ្រ័ចិត្តសហការផ្លាស់ប្តូរពត៌មាននិងឯកសារ។ ពត៌មានពាក់ពន្ធ័នឹងគ្រប់វិស័យនៃរបបខ្មែរក្រហម សុទ្ធតែមានសារៈសំខាន់ចំពោះប្រវត្តិសាស្ត្ររបបនេះ។ ពត៌មានមានច្រើនប្រភេទ ក្នុងនោះរាប់បញ្ចូលទាំងកាសែតអាន, សៀវភៅ, សំបុត្រសរសេរដៃ, ទូរលេខ, សៀវភៅកំណត់ហេតុ, របាយការណ៍, ប្រវត្តិរូប, កាសែ្សតសំលេង, ហ្វីលកុនឬវីដេអូ, រូបថត, ប្រសាសន៍ឆ្លើយបំភ្លឺ។ល។

ទំនាក់ទំនងៈ លោក សឹម សុរិយ៉ា
- ទូរសព្ទ័ៈ ២១១ ៨៧៥
- ប្រអប់សំបុត្រលេខៈ ១១១០ ភ្នំពេញ
- E-mail : dccam@bigpond.com.kh

# កងការពារអ្នកទោសនៅគុកទួលស្លែង

ក្នុងដំណើរការងារលើទឹកដីខេត្តកំពង់ឆ្នាំង កាលពីដំណាច់ខែធ្នូឆ្នាំ១៩៩៩កន្លងទៅនេះ គឺចំពេលដែលស្រូវវស្សារបស់បងប្អូនកសិករទុំពេញស្រែមើលទៅពណ៌ក្រហមច្រាលដូចកំរាលមាសគួរជាទីពេញចិត្តនិងមោទនៈក្រៃលែង ។ ខ្ញុំបានជួបប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយបងប្អូនអតីតកុមារនៃខេត្តកំពង់ឆ្នាំង(តំបន់៣១) ជាច្រើនរូបដែលត្រូវខ្មែរក្រហមបញ្ជូនមកធ្វើការនៅមន្ទីរស-២១ (គុកទួលស្លែង) ដោយបែងចែកជាក្រុមដូចជា ក្រុមចាប់ ក្រុមសួរចម្លើយ ក្រុមកងការពារ និងក្រុមភស្តុភារជាដើម ។ ក្នុងពេលនេះខ្ញុំសូមលើកជូនមិត្តអ្នកអាននូវខ្លឹមសារដែលយើងជួបផ្ទាល់ជាមួយលោក ពៅ អាយុ៣៨ឆ្នាំ សព្វថ្ងៃជាកសិករ ។ ពៅ ជាអតីតឈ្លបការពារអ្នកទោសដ៏ក្មេងខ្ចីម្នាក់ក្នុងចំណោមឈ្លបក្មេងៗដទៃទៀតដែលរស់នៅនិងធ្វើការផ្ទាល់នៅគុកទួលស្លែង ។ ពៅ បានលាតត្រដាងពីជីវិតរបស់គាត់ផ្ទាល់ ក្នុងភារៈជាកងការពារអ្នកទោសម្នាក់បានជួបប្រទះ ក៏ដូចជាជនរងគ្រោះក្នុងសម័យខ្មែរក្រហមដែលជាប់ឃុំឃាំងនៅគុកទួលស្លែង ។

មុនពេលចូលបម្រើបដិវត្តន៍ខ្មែរក្រហម ពៅ ជាក្មេងចូលចិត្តលេងបាញ់ឃ្លី គប់វង់ និងបិទពួនតាមរបៀបក្មេងជនបទ ។ នៅឆ្នាំ១៩៧៣ ពេលមានអាយុ១៣ឆ្នាំ ពៅ បានត្រូវចូលបម្រើជាឈ្លបឃុំ ស្រុក និងតំបន់ក្រោមការខទ្ទេនាមរបស់ ធឿន ។ ទីបំផុត ពៅ ត្រូវបានប្រមូលឡើងរថយន្តមកភាគ(ភ្នំពេញ) នៅគុកទួលស្លែងជាមួយកុមារដ៏ទៃទៀតក្នុងភូមិស្រុកនៃខេត្តកំពង់ឆ្នាំង តាមរយៈរថយន្តហ្សេអិមសេ GMC អាមេរិកជាច្រើនគ្រឿង ។



មុននឹងចូលបម្រើការងារជាកងការពារអ្នកទោសនៅគុកទួលស្លែង ពៅ ត្រូវបានពួកខ្មែរក្រហមបញ្ជូនទៅតាខ្មៅដើម្បីហាត់ហ្វឹកហ្វឺនក្បួនយុទ្ធសាស្ត្រទ័ពដូចជាបច្ចេកទេសកាំភ្លើង បោកគ្រាប់បែក ចាក់ចំពុះទុង និងក្បាច់ការ៉ាតេពីអ្នកបង្ហឹកជាជនជាតិចិនជាច្រើនរូប ដែលក្នុងចំណោមនោះ ពៅ នៅចាំបានឈ្មោះគ្រូធំជាងគេគឺឈ្មោះ ហ៊ូ វ៉ាន់ហ៊ីង ។ ពៅ ជាសិស្សឆ្នើមម្នាក់ក្នុងចំណោមសិស្សជាច្រើនរយនាក់ ដែលលទ្ធផលចុងក្រោយត្រូវបានក្លាយខ្លួនជាកងការពារអ្នកទោសនៅក្នុងគុកទួលស្លែងក្រោមការគ្រប់គ្រងផ្ទាល់របស់សមមិត្ត ហ៊ី និងសមមិត្ត ឌុច ។

ពៅ បានពិពណ៌នាតាមការចងចាំរបស់គាត់អំពីទិដ្ឋភាពទូទៅនៃគុកទួលស្លែងថា ជាកន្លែងមួយដ៏តឹងរ៉ឹងនិងពោរពេញទៅដោយគ្រោះថ្នាក់ ព្រោះជុំវិញគុកមានរបងព័ទ្ធដោយសង្ក័សីនិងរបងលួសដែលមានខ្សែភ្លើងឆក់ ។ នៅគុកទួលស្លែង អគារទាំងអស់មាន ខាងជើង១ កណ្តាល២ និងសងខាង២ ហើយអគារនីមួយៗមាន៣ជាន់ ដែលញាត់ពេញទៅដោយអ្នកទោស ។ អគារខាងលើបំផុតសម្រាប់អ្នកទោសស្រាលដាក់ខ្នោះវែង អគារក្រោមសម្រាប់អ្នកទោសធ្ងន់ដែលមានតែមួយនាក់ប៉ុណ្ណោះសម្រាប់មួយបន្ទប់ ។ នៅក្នុងបន្ទប់នោះគ្មានអ្វីក្រៅពីធុងលាមកមួយ ដែលអ្នកទោសអាចបង្វិលខ្លួនមកត្រឹមធុងលាមកប៉ុណ្ណោះ ព្រោះជើងរបស់គេត្រូវដាក់ខ្នោះសោរជាប់យ៉ាងតឹង ។ អ្នកទោសនៅគុកទួលស្លែងមានច្រើនប្រភេទ ពិសេសប្រភេទចារកម្មក្បត់នឹងបដិវត្តន៍និងលទ្ធិរបស់ពួកខ្មែរក្រហម ដែលត្រូវចាប់មកពីគ្រប់ស្រុកនិងតំបន់ទូទាំងប្រទេស រួមទាំងអ្នកធ្វើការនៅគុកទួលស្លែងនេះផងដែរ ។

រយៈពេលបីឆ្នាំក្នុងការងារជាកងការពារអ្នកទោស នៅគុកទួលស្លែង ពៅ អះអាងថា

នៅឆ្នាំ១៩៧៧ ពួកបូព៌ារាប់ពាន់នាក់ត្រូវបានដឹកមកនិងសម្លាប់ចោលនៅគុកទួលស្លែងទាំងឡាយៗ ដោយសារ សោ ភឹម ដែលជាមេដឹកនាំនៅភូមិភាគបូព៌ាក្បត់ប្រឆាំងនឹងគោលនយោបាយដឹកនាំរបស់បក្សបដិវត្តន៍កម្ពុជាប្រជាធិបតេយ្យ ។ អ្នកទោសត្រូវបញ្ជូលគុកដើម្បីរង់ចាំការសួរចម្លើយពីសំណាក់ក្រុមសួរចម្លើយនិងពីមេគុក ឌុច និងទីបំផុតត្រូវទទួលនូវវាសនាបែបណាមួយតាមការកំណត់របស់មេពេជ្ឈឃាត ឌុច នេះ ។ ពៅ រៀបរាប់ពីវិធីដែលពួកខ្មែរក្រហមនៅមន្ទីរស-២១ធ្វើទារុណកម្មលើអ្នកទោសរួមមានដូចជា ចាក់ភ្នែក អារសាច់ដោយកាំបិត ចាក់ធ្លាយដើមទ្រូងពីមុខទៅក្រោយរួចចុកសាប៊ូចូលឲ្យក្រហល់ក្រហាយ អារសាច់ប្រឡាក់អំបិល និងប្រើខ្សែភ្លើងឆក់ជាដើម ។ ទារុណកម្មទាំងនេះគឺធ្វើលើអ្នកទោសរហូតបានចម្លើយ បន្ទាប់មកគឺអ្នកទោសត្រូវរង់ចាំសេចក្តីស្លាប់ ដោយការអូសចេញទៅដើម្បីវាយ ឬអារ-កចោលនៅបរិវេណគុកទួលស្លែង ឬបញ្ជូនទៅខាងក្រៅដូចជា បឹងជើងឯក និងព្រៃសជាដើម ។ ពៅ អះអាងថា គ្មានអ្នកទោសណាម្នាក់បានរួចខ្លួន ឬមានជីវិតរស់ទេ ប្រសិនបើត្រូវពួកខ្មែរក្រហមចាប់បញ្ជូនចូលគុកទួលស្លែងនោះ ។

នៅគុកទួលស្លែង ពៅ មានភារកិច្ចយាមការពារអ្នកទោស ថែទាំបាញ់ទឹកបោសសម្អាតបន្ទប់ និងធ្វើយ៉ាងណាកុំឲ្យអ្នកទោសដែលនៅក្នុងគុកមានគ្រោះថ្នាក់ ។ ពៅ ប្រដូចក្រុមអ្នកយាមទៅនឹងឆ្នាំយាមឃ្លាំង ព្រោះពេលគេយកទំនិញចេញផុតពួកឆ្នាំឃ្លាំងពុំអាចដឹងថាទំនិញទាំងនោះត្រូវគេយកទៅទីណាឡើយ ។ ពៅ បញ្ជាក់ថាក្រុមយាមអ្នកទោសមានភារកិច្ចប្រគល់អ្នកទោសណាមួយឲ្យទៅក្រុមសួរចម្លើយ (ឧទាហរណ៍អ្នកទោសលេខ១០) តាមក្រដាសដែលអ្នកសួរប្រគល់ឲ្យ ។ បន្ទាប់មក ក្រុមយាមគ្មានសិទ្ធិដឹងពុថាអ្នកទោសនោះទៅណា ឬធ្វើអ្វីឡើយ ។

ជីវិតនៅក្នុងគុកទួលស្លែង គឺសែនពិបាកនិងពោរពេញដោយទុក្ខព្រួយ ព្រោះជុំវិញខ្លួនសុទ្ធសឹងតែជាទិដ្ឋភាពដ៏រន្ធត់តក់ស្លុត ទារុណកម្ម និងអំពើកាប់សម្លាប់ ។ អ្នកទោសនៅគុកទួលស្លែង មិនមែនសុទ្ធតែត្រូវដឹកមកពីតំបន់ឆ្ងាយៗប៉ុណ្ណោះទេ ប៉ុន្តែអ្នកទោសទាំងនោះរួមមានទាំងក្រុមការពារ ក្រុមសួរ និងក្រុមដទៃទៀត ដែលជាអ្នកធ្វើការនៅក្នុងគុកទួលស្លែងនេះផ្ទាល់តែម្តង ។ ឈ្លប នៅក្នុងគុកទួលស្លែងក៏ត្រូវភិតភ័យនិងជីវិតផ្ទាល់ខ្លួនឯងម្នាក់ៗយ៉ាងខ្លាំង ព្រោះការរស់នៅទីនោះមានវិន័យតឹងរ៉ឹង ។ ម្យ៉ាងទៀត អ្នកធ្វើខុសទាំងអស់មានឱកាសតិចណាស់សម្រាប់កែខ្លួនលើកំហុសដែលបានប្រព្រឹត្ត ជាពិសេសបើអ្នកណាម្នាក់ធ្វើខុស ឬត្រូវសង្ស័យថាជាប់ពាក់ព័ន្ធនឹងនយោបាយរឿងអ្វីមួយ ឬនរណាម្នាក់ គឺពិតជាមានគ្រោះថ្នាក់ដល់អាយុជីវិតមិនខាន ។

ដូចករណីមិត្តភក្តិរបស់ ពៅ ពីរនាក់ទៀតឈ្មោះ ហុង និង មឿន ដែលចេញពីភូមិស្រុកជាមួយគ្នាហើយធ្វើការនៅកងការពារជាមួយ ពៅ ដែរនោះ ត្រូវបានអង្គការចាប់ដាក់គុកទួលស្លែងនិងសម្លាប់ចោលនៅឆ្នាំ១៩៧៨ ។ ហុង ជាប្រធានវរៈនៃក្រុមកងការពារអ្នកទោស តែត្រូវខ្មែរក្រហមសម្លាប់ចោលដោយសង្ស័យថាជាខ្មាំងបង្កប់ ព្រោះអ្នកទោសពីរនាក់ក្នុងបន្ទប់គុកដែល ហុង យាម សម្លាប់ខ្លួនដោយចងកនឹងក្រមា និងម្នាក់ទៀតប្រើស្លាបព្រាក្តាចាក់សរសៃដៃខ្លួនឯងស្លាប់ ។

ចំណែក មឿន ពេលបើករថយន្តទៅដឹកបន្លែនៅតាខ្មៅកាត់តាមបឹងទំពុន ដួររអិលព្រោះទឹកជំនន់បូមមិនទាន់ ធ្វើឲ្យរថយន្តធ្លាប្រឹតាក្រឡាប់ ទីបំផុតវាសនារបស់ មឿន ក៏ដូច ហុង ដែរ គឺត្រូវស្លាប់យ៉ាងអាណោចអធមជាទីបំផុត ។ មុនពេលពួកខ្មែរក្រហមចាប់យកទៅសម្លាប់ មឿន បានផ្តាំ ពៅ ថាៈ «បើឯងបានទៅផ្ទះជួយប្រាប់ម៉ែអញផង ថាអញអត់រស់ទេ» ។

ពៅ ហៅជីវិតខ្លួនឯងថាដូចបានរស់ឡើងវិញដូច្នោះ ព្រោះរូបគាត់ក៏ត្រូវពួកខ្មែរក្រហមនាំខ្លួនចូលសួរចម្លើយ និងជាប់គុកអស់រយៈពេលមួយខែកន្លះដែរពីករណី ហុង និង មឿន នេះដោយអង្គការចោទថាជាខ្សែរជាមួយគ្នាព្រោះរស់នៅភូមិស្រុកតែមួយ ។ ពៅ និយាយថាគាត់បដិសេធពាក្យចោទប្រកាន់ទាំងក្តីអស់សង្ឃឹម តែដោយសំណាងល្អ ពៅ ត្រូវបាន ដុល ដែលជាប្រធានក្រុមសួរចម្លើយ ដោះលែង ហើយបញ្ជូនឲ្យចូលធ្វើការនៅកងពល៥០២ រហូតដល់ឆ្នាំ១៩៧៩ ។

ពៅបន្តថា ក្នុងពេលធ្វើការងារនៅគុកទួលស្លែងនោះ គាត់បានជួបជាមួយ ឌុច ស្ទើររាល់ថ្ងៃ ព្រោះ ឌុច ដើរសួរចម្លើយអ្នកទោសនិងបញ្ជាឲ្យគេសម្លាប់អ្នកទោសក្នុងបន្ទប់ណាដែលត្រូវសម្លាប់និងយកអ្នកទោសផ្សេងមកដាក់ជំនួស បានសេចក្តីថា ត្រូវសម្លាប់អ្នកណាចោលនាំអ្នកណាចូលគឺមានតែ ឌុច ម្នាក់ប៉ុណ្ណោះ ។ ពៅ ហៅហេតុការណ៍នេះថា ***«អាចាស់បោះចោលទៅ អាថ្មីរើសដាក់ជំនួស»*** ។

**អៀ ម៉េងទ្រី**

# របៀបរៀបចំឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

ឯកសាររាប់ម៉ឺនសន្លឹកស្តីអំពីរឿងរ៉ាវខ្មែរក្រហម ត្រូវបានរៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជាតាមប្រព័ន្ធបណ្ណាសារដ្ឋានអន្តរជាតិ ។ ឯកសារទាំងនេះត្រូវបានចងក្រងនិងស្រាវជ្រាវឡើងដោយបុគ្គលិកនៃមជ្ឈមណ្ឌលឯកសារកម្ពុជាដែលជាជនជាតិខ្មែរទាំងស្រុង ដោយមានការសហការពីទួលស្លែង, ក្រសួងមហាផ្ទៃ, បណ្ណាសារដ្ឋានជាតិ, និងតាមបណ្តាខេត្តទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងអ្នកជំនាញនៅអូស្ត្រាលីនិងអាមេរិក ។ ការរៀបចំឯកសារមានលក្ខណៈស្មុគស្មាញផ្នែកបច្ចេកទេស បែបបទការថែរក្សា និងឆ្លងកាត់ជាច្រើនដំណាក់កាលនៃការរៀបចំដែលបានកំណត់ជាឯកសណ្ឋានមួយ ។

### របៀបរៀបចំឯកសារចូលៈ

ក្រោយពីទទួលបានឯកសារ បុគ្គលិកផ្នែកឯកសារបានចាប់ផ្តើមថតចម្លងភ្លាម ។ ការថតចម្លងនេះយើងរក្សានូវរូបភាពដើមទាំងអស់ ដោយពុំឲ្យបាត់រូបរាងដើមនៃឯកសារដើមឡើយ ។ ការធ្វើបែបនេះ គឺយើងចង់រក្សាតម្លៃនៃឯកសារដើម និងដើម្បីជៀសវាងការធ្វើឲ្យរហែកខូចខាតឯកសារដើមដែលមានចំណាស់២០ទៅ៣០ឆ្នាំមកហើយ ។ បន្ទាប់ពីថតចម្លងឯកសាររួច យើងបានជ្រើសរើសឯកសារដាក់តាមប្រភេទនីមួយៗដាច់ដោយឡែកពីគ្នា ។ ឧទាហរណ៍ៈ ឯកសារជាប្រវត្តិរូប ឯកសារនិយាយពីបញ្ហាសង្គមនយោបាយ ចម្លើយសារភាព និងបញ្ហាផ្សេងៗ ។ យើងដាក់ដោយឡែកពីគ្នា និងរៀបតាមលំដាប់នៃកាលបរិច្ឆេទរបស់ឯកសារ និងប្រភពដែលបានទទួលឯកសារទាំងនោះ ។

### ១-របៀបចុះលេខឯកសារៈ

ក្រោយពីដាក់តាមប្រភេទឯកសាររួចយើងក៏ចាប់ផ្តើមរៀបចំតាមលំដាប់បន្តទៀត គឺយកឯកសារនីមួយៗទៅចុះលេខដោយបានកំណត់យក៦តួ ។ ឧទាហរណ៍ D០០០០១ (មជ្ឈមណ្ឌលឯកសារយើងបានកំណត់យកអក្សរ D ដាក់ពីមុខមានន័យថាៈ DC-Cam ឬមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ឯ D០០០០១ មានន័យថា ឯកសារទី១តម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា) ។ យើងធ្វើការចុះលេខនេះរហូតដល់ចប់តាមប្រភេទឯកសារនីមួយៗដែលបានរើសរួចជាស្រេច ។ ការចុះលេខគឺយើងយកប៊ិកពណ៌ក្រហមចុះនៅចុងសន្លឹកខាងលើនៃទំព័រដំបូងនៃឯកសារដែលបានថតចម្លងរួច ។

### ២-របៀបចុះបញ្ជីៈ

ក្រោយពីចុះលេខរួច យើងផ្តើមធ្វើបញ្ជីឯកសារតាមប្រភេទឯកសារនីមួយៗដោយគូសតារាងជា៧ខ្ទង់ **ទី១** លេខរៀងឯកសារ (សម្រាប់សម្គាល់លេខឯកសារនៅក្នុងមជ្ឈមណ្ឌលយើង) **ទី២** លេខឯកសារ (ជាលេខរបស់ម្ចាស់ដើមនៃឯកសារ) ។ **ទី៣** ចុះកាលបរិច្ឆេទរបស់ឯកសារកើតក្នុងឆ្នាំណា ។ **ទី៤** ចុះប្រភពឯកសារ (គឺចុះឈ្មោះទីកន្លែងតម្កល់ឯកសារ ឬឈ្មោះបុគ្គលដែលផ្តល់ឯកសារ) ។ **ទី៥** ចុះចំណងជើងឯកសារ (បើសិនក្នុងឯកសារនោះពុំមានចំណងជើងទេ យើងអាចបង្កើតចំណងជើងដោយខ្លួនឯងដោយដាក់នៅក្នុងតង្កៀប[...] ។ ការដាក់ក្នុងតង្កៀបនេះមានន័យថាឯកសារនេះពុំមានចំណងជើងទេ គឺយើងបង្កើតចំណងជើងដោយខ្លួនឯង) ។ **ទី៦** ចុះកាលបរិច្ឆេទនៃការទទួលឯកសារ (បានសេចក្តីថា យើងយកឯកសារពីទីកន្លែងដើមនៅថ្ងៃណា យើងចុះកាលបរិច្ឆេទថ្ងៃនោះនៅក្នុងបញ្ជី) ។ **ទី៧** ចុះប្រភេទនៃឯកសារ (តើឯកសារនោះជាប្រភេទសៀវភៅ ប្រភេទជាឯកសាររាយ ជារូបថត ហ្វីល កាសែតសំឡេង ឬកាសែតវីដេអូ ។ល ។) ។ ក្រោយពីចុះបញ្ជីរួចយើងក៏រៀបឯកសារដាក់ទូរតាមលំដាប់លេខរៀង និងតាមប្រភេទនៃឯកសារនីមួយៗ ដើម្បីងាយស្រួលក្នុងការរកឯកសារ ។

### ៣-ធ្វើកាតាឡុកឯកសារៈ

យើងយកឯកសារដែលចុះលេខរួច ទៅសរសេរលម្អិត

លើតារាងក្រដាសផ្ទុកពត៌មានសរុបដែលភាសាអង់គ្លេសហៅថា Worksheet ដែលរៀបចំហើយជាស្រេចដោយប្រព័ន្ធទិន្នន័យដែលយើងប្រើក្នុងកម្មវិធីកុំព្យូទ័រវីនអាយស៊ី ដែលបានថតចម្លងចេញពីកុំព្យូទ័រសម្រាប់កំណត់សម្គាល់ពត៌មាន ។

គ្រាន់តែយើងបំពេញពត៌មានបន្ថែមអ្វីដែលមានក្នុងឯកសារ ទៅក្នុងតារាងអធិប្បាយអំពីឯកសារ ។ ដែលតម្រូវទៅតាមប្រភេទប្រព័ន្ធ ។ ឧទាហរណ៍ ទិន្នន័យគន្ថនិទេស ជាឯកសារចំរុះពុំមែនជាប្រវត្តិរូបរបស់មនុស្ស) និងប្រព័ន្ធទិន្នន័យប្រវត្តិរូប ។

ប្រពន្ធ័ទិន្នន័យប្រវត្តិរូបបញ្ចូលពត៌មាន ដែលជាប្រវត្តិរូបអ្នកទាំងឡាយណាដែលធ្លាប់ជាសមាជិកខ្មែរក្រហមចាប់ពីថ្នាក់គណៈកម្មាធិការស្រុកឡើងទៅ ។ ប្រធានកងចល័តធំៗ ឬស្ថាប័នសំខាន់ៗផ្សេងៗទៀតដូចជាៈ អ្នកជាប់ពន្ធនាគារ, អ្នកដឹកនាំអង្គភាពទ័ពចាប់ពីថ្នាក់អនុសេនាធំឡើងទៅ, អ្នកសម្លាប់ រំលោភ ឬធ្វើទារុណកម្មក្នុងឧប្បត្តិហេតុជាក់លាក់ ដែលក្នុងករណីនេះយើងសម្គាល់ឈ្មោះបុគ្គលនិងកន្លែង ឬកាលបរិច្ឆេទនៃឧប្បត្តិហេតុនេះយ៉ាងលម្អិត ។ តារាងអធិប្បាយទិន្នន័យប្រវត្តិរូប យើងបានកំណត់យក៤៥ចំណុចពត៌មានដែលអធិប្បាយជាសង្ខេបរួមមាន ឈ្មោះ ប្រភព ឈ្មោះហៅក្រៅ ភេទ ស្ថានភាពសង្គមក្នុងសម័យ ប៉ុល ពត, ថ្ងៃ ខែ ឆ្នាំកំណើត និងអាយុ, ទីកន្លែងកំណើត, កន្លែងស្លាប់, ឈ្មោះឪពុក, ឈ្មោះម្តាយ, កម្រិតវប្បធម៌, ឋានៈ ឬតួនាទីក្រោយឆ្នាំ១៩៧៩, ឈ្មោះអ្នកទទួលខុសត្រូវ, ឈ្មោះអ្នករួមការងាររជាមួយ, ឈ្មោះជនដែលដល់ ។ល ។

ទិន្នន័យគន្ថនិទេសសម្រាប់បញ្ចូលពត៌មានជាសៀវភៅ ឬជាប្រភេទឯកសារដែលមានការពាក់ព័ន្ធសកម្មភាពនយោបាយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឯកសារទូរលេខរបស់កម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពរបស់អ្នកទោស កំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍ខ្មែរក្រហម ឯកសាររណសិរ្ស ឯកសារផ្សេងៗយកមកពីប្រភពដទៃទៀត ។ នៅក្នុងទិន្នន័យគន្ថនិទេស យើងបានកំណត់យក៥ ០ចំណុចពត៌មានសំខាន់ៗនៃឯកសារនីមួយៗ ដើម្បីបញ្ចូលទៅក្នុងក្រដាសផ្ទុកពត៌មានសរុបដូចជាៈ លេខកូដឯកសារ, ទីកន្លែងនិងឆ្នាំបោះពុម្ព, ចំណងជើងឯកសារ, កែសម្រួលដោយអ្នកណា, សេចក្តីសង្ខេបជាពីរភាសា (ខ្មែរនិងអង់គ្លេស) ចំនួនសន្លឹក, វគ្គនៃការចេញឯកសារ លេខសម្គាល់ឯកសារដើម, កំណត់សម្គាល់ភាសាដើមនៃឯកសារ, កំណត់សម្គាល់ការចុះទីតាំងកន្លែងបោះពុម្ពផ្សាយ ទីតាំងឯកសារដើម និងកាលបរិច្ឆេទរបស់ឯកសារដើម, កំណត់សម្គាល់ប្រភេទពត៌មានឯកសារ, ប្រភេទនៃការរៀបចំឯកសារ, ប្រភេទអក្សររបស់ឯកសារ «សរសេរដោយដៃឬដោយអង្គុលីលេខ» ប្រភពឯកសារ, មាតិកា, សង្ខេបអត្ថន័យឯកសារ, បកប្រែ, ប្រភពនៃក្រុមឯកសារ «ឯកសារសំណុំរឿងសន្តិសុខ» ។ល ។

## ៤-របៀបបញ្ចូលពត៌មានក្នុងកុំព្យូទ័រ

ក្រោយពីធ្វើកាតាឡុកឯកសាររួច យើងក៏យកឯកសារទាំងនេះបញ្ចូលទៅក្នុងកម្មវិធីវីនអាយស៊ីស ។ ទិន្នន័យដែលបញ្ចូលទៅក្នុងទីតាំងផ្ទុកពត៌មានសរុប មានផ្ទុកពត៌មានជាភាសាខ្មែរនិងអង់គ្លេស ។

ទាំងអស់ដូចបានរៀបរាប់ខាងលើគឺយើងអនុវត្តន៍តាមប្រពន្ធ័ UNESCO (អង្គការវប្បធម៌ វិទ្យាសាស្ត្រ និងអប់រំរបស់អង្គការសហប្រជាជាជាតិ) គឺមានលក្ខណៈងាយស្រួលក្នុងការរកឯកសារណាមួយដោយចំណាយពេលតិចបំផុតត្រឹមតែ២ឬ៣នាទីប៉ុណ្ណោះយើងអាចរកឃើញភ្លាម ។ ឧទាហរណ៍ៈ បើយើងចង់រកមនុស្សឈ្មោះ **ក** ប៉ុន្តែយើងពុំដឹងឈ្មោះ **ក** នៅក្នុងឯកសារលេខណាទេ យើងត្រូវវាយឈ្មោះ **ក** ចូលទៅក្នុងទីតាំងស្វែងរកឯកសារក្នុងកម្មវិធីស៊ីឌីអេសអាយស៊ីស រួចហើយយើងចុចវានឹងប្រាប់ភ្លាមអំពីឯកសារទាំងអស់ដែលមាននិយាយអំពីឈ្មោះ «**ក**» ហើយយើងចុច «ចំណុចបង្ហាញ យើងនឹងអាចមើលឯកសារផ្ទុកពត៌មានសរុបអំពីឯកសារមួយនោះទាំងស្រុង» យើងអាចបើកមើលបន្តដើម្បីរកឯកសារដើមចេញមកពីប្រភពណា ។ ករណីនេះ យើងអាចរកឈ្មោះ **ក** ឃើញបានលុះត្រាតែយើងបានបញ្ចូលឯកសារឈ្មោះ **ក** ទៅក្នុងកម្មវិធីវីនអាយស៊ីសរួចមកហើយដែរ ។

**វ៉ែអម សុខឃីម**





គីមត្រាង កើតនៅត្រាវិញ ឆ្នាំ១៩៣០




សមមិត្ត វ៉ាន់



បង វ៉ាន់ ឬបង៨១

# ឯកសារខ្មែរក្រហមពីសមរភូមិមុខ



**ផ្ញើ និងចម្លងជូន អ៊ឹំ ម៉ាន់**

●●●●● នៅក្នុងរបបខ្មែរក្រហម របៀបមួយក្នុងការអនុវត្តន៍គោលនយោបាយឲ្យមានប្រសិទ្ធិភាពគឺ ការបញ្ជូនពត៌មានទៅថ្នាក់ដឹកនាំតាមរយៈទូរសារ ។ ទូរសារជាច្រើនត្រូវបានរកឃើញនៅឆ្នាំ១៩៩៧ ។ ទូរសាររាប់រយត្រូវបានបញ្ជូនទៅថ្នាក់ដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យជាប្រចាំថ្ងៃ មកពីថ្នាក់មូលដ្ឋាននិងសមរភូមិមុខ រួមមានសេចក្ដីរាយការណ៍អំពីការងារផលិតស្រូវ សតិអារម្មណ៍ប្រជាជន ការចាប់មនុស្សឬជនសង្ស័យ ការងាររកងទ័ព ការងារការទូត បញ្ហាព្រំដែន ការវាយលុកជាមួយវៀតណាម ការប៉ះទង្គិចជាមួយថៃ ការបោសសម្អាតខ្មាំងផ្ទៃក្នុង និងកិច្ចការដទៃទៀតជាលម្អិត ។ ភាគច្រើននៃទូរសារទាំងនេះផ្ញើជូនទៅមន្ទីរ៨៧០ ដែលជាមន្ទីររបស់ ប៉ុល ពត និងកម្មាភិបាលជាន់ខ្ពស់នៃគណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនិស្តកម្ពុជា និងគណៈកម្មាធិការអចិន្ត្រៃយ៍ និងមេបញ្ជាការកងទ័ពមួយចំនួន ព្រមទាំងបានចម្លងជូនថ្នាក់ដឹកនាំដទៃទៀតជ្រាបជាពត៌មាន និងដើម្បីអនុវត្ត●●●●●

ខ្ញុំសូមដកស្រង់ពត៌មានទូរសារ១ចំនួនជូននៅក្នុងទំព័របន្ទាប់ ។

**ឆាំង យុ**








ឬបងធំទី៣ សូ ហាវ កើតនៅប៉េកាំងថ្ងៃទី១ ខែ១ ឆ្នាំ១៩៣០ ខ្មែរក្រហមផ្ដាច់ខ្លួន អៀង សារី

◆◆◆ទូរលេខ៨១ ជំរាបបងជាទីគោរព យើងខ្ញុំសូមរាយការណ៍បញ្ហាមួយចំនួនៈ១- សភាពការណ៍ ០១០ឃ នៅមុខព្រួញទី២ ចំណុចភ្នំ១២០អង្គភាពប្រតិបត្តិការចាប់ប្រជាជនបាន៦នាក់ ប្រជាជននៅភូមិទំពួនរ៉ឹងរត់ឆ្នាំ៦៨ ចាប់បាននៅថ្ងៃ២៣-១ កន្លែងអូរសាគរជាប់អូរតាមូ ។ អូតាមូនេះនៅជិតអូរខាំផា នៅក្នុងព្រំដែនយើង ។ តាមប្រជាជនឲ្យដឹងនៅភូមិផាវនៅជិតៗនោះដែរ ។ បងប្អូនកំពុងតែរកថែម តែមិនទាន់ឃើញ ។ ២-សភាពការណ៍ប្រជាជនជំលៀសពីលាវ បានរៀបចំផ្ញើតាមប្អូនភូមិនៅឃុំលេខ៣ហើយ ។ បងថា វន ចុះទៅដង៦វិញហើយ ។ ប្រជាជនចំនួនទាំង១១១គ្រួសារមានមនុស្ស៦៣៦នាក់ ។ ពេលឆែកយកបានគ្រាប់បែកដៃ៣គ្រាប់ គ្រាប់ការ៉ាប៊ីន១០គ្រាប់ សៀវភៅរៀនភាសាលាវ៥ក្បាល វិទ្យុចាប់សម្លេង៧គ្រឿង ។ អាវុធនិងវិទ្យុ ខាងគណៈចាត់តាំងដកទុកសិន បានចែកខោអាវ ចាន ឆ្នាំង នឹងឧបករណ៍ផលិតកម្ម តែនៅខ្វះច្រើន ។ សូមជូនពរបងសុខសប្បាយនឹងជ័យជំនះ ដោយការវកិច្ចបដិវត្តបំផុត, ប៊ុត ថ្ងៃ២៩-១, ចម្លងជូន បងប៉ុល បងនួន បងវ៉ាន់ បងរី បងខៀវ បងឌឿន ទុកឯកសារ◆◆◆ទូរលេខៈ ៣១,២៦៥ ខ្ទង់ គោរពជូន ម.៨៧០ ជាទីស្នេហានឹងរលឹក ថ្ងៃ៧-៣ នៅត្រង់អាងសីឡា ទាស់ពីមុនពួកតម្រួតថៃវាឆ្លងខាងមកដីមានជាន់មីនផ្ទុះ២គ្រាប់បណ្តាលឲ្យវាស្លាប់៤នាក់ រួចផុតមកវាឲ្យយន្តហោះ ហោះតាមប្រទល់ដែនបាញ់កាំភ្លើង ពីលើយន្តហោះមកដីយើងអស់កន្លះម៉ោង ។ ហើយបាញ់កាំភ្លើងធំជាង ២០គ្រាប់ ចូលដីយើង ។ ព្រឹកថ្ងៃ៦-៣ យន្តហោះធុនសេ១៣០ ១គ្រឿង ចូលពីអូរជ្រៅខាងជើងថ្នល់ប្រហែល១គីឡូពីថ្នល់ ។ ហោះជិតដល់ភូមិនិមិត្តរួចបត់ទៅវិញ បងប្អូនបាញ់ដែរតែបាញ់មិនត្រូវ ។ ក្រោយពីយន្តហោះរួច ខាងទាក់ទូរស័ព្ទពីថៃមកយើងភ្លាម តែបងប្អូនអត់ស្តាប់ អត់ឆ្លើយព្រោះយើងអត់ឲ្យនិយាយជាមួយវា ។ ហើយខាងត្បូងភ្នំម៉ាឡៃ ខ្មាំងថៃចូលមកជាន់មីនផ្ទុះ១គ្រាប់ ស្លាប់៣នាក់ យើងយកបានអាវុធ៦ដើម អាកា១ អា៧៩...។ ស្នើសមមិត្ត ខៀវ បើមានកម្មាភិបាលអាចជួយណែនាំពីបាញ់យន្តហោះបានស្នើ១នាក់ ២នាក់ ។ ព្រោះបងប្អូនបាញ់វាមិនត្រូវសោះ ។ វាចូលមកជ្រៅដែរ ។ ដោយសាមគ្គីភាពខ្ពស់បំផុត, ថ្ងៃ៩-៣ ញឹម, ទទួលថ្ងៃ១០-៣ ម៉ោង ៦ៈ៣០, ចម្លងជូនៈ អ៊ុំ អ៊ុំនួន បងវ៉ាន់ បងវន បងខៀវ មន្ទីរឯកសារ◆◆◆ ទូរលេខៈ ៥០,៩៤៨ខ្ទង់ គោរពជូនបងជាទីស្នេហា និងរលឹក រឿងអាភឿនប្រធានគណៈពាណិជ្ជតំបន់ យប់ថ្ងៃ១៤-៧ ពេលគណៈតំបន់មកភ្នំពេញ ពេលអង្គភាពពាណិជ្ជនៅការដ្ឋានទំនប់ឯខ្វាំង វានៅផ្ទះរវាង វាគម្រាមរំលោភសេពកាមគ្រួសារយុទ្ធជន ក្នុងអង្គភាពពាណិជ្ជអស់៥នាក់ ដែលសុទ្ធតែមានផ្ទៃពោះ ពេលនោះយុទ្ធជនម្នាក់បានទាន់អាភឿនកំពុងចាប់គ្រួសារខ្លួនក៏រត់ទៅរាយការណ៍ជូនមិត្តយើងក្នុងគណៈកម្មាធិការពាណិជ្ជ ។ យើងសួរនារីទាំងអស់ដែលត្រូវវារំលោភ នារីថា វាថាឲ្យតែស្រែកបាញ់ចោល តែប្រាប់គេបាញ់ចោល ។ ការវកិច្ចបដិវត្តសែនកក់ក្តៅបំផុត, ថ្ងៃ១៨-៧-៧៦ ហង្ស, ចម្លងជូនៈ បងនួន បងខៀវ បងវ៉ាន់ មន្ទីរឯកសារ◆◆◆ទូរលេខលេខ៧៨ ជំរាបបង ម.៨៧០ នឹងបងរី ជាទីគោរព. យើងខ្ញុំសូមរាយការណ៍អំពីលទ្ធផលនៃការជួបវៀតណាម ថ្ងៃ ២៤-១ ១-ប្រតិភូវាមាន៦នាក់ ឈ្មោះ លីយ៉ាំង អនុប្រធានគណៈយោធភូមិភាគជាប្រធានប្រតិភូ ។ ២-ពេលជួបគ្នាគេឲ្យយើងខ្ទេសនាមមុន ។ ខ្ញុំខ្ទេសនាមតាមគម្រោង អង្គការណែនាំដោយសង្កត់ធ្ងន់សភាពការណ៍នៅ០១០ខ ។ ក្រោយខ្ទេសនាមចប់វាលើកបញ្ហាចោទប្រកាន់សង្កត់យើងខ្លាំងថា យើងរំលោភបូរណភាពដែនដីវាអស់ជាច្រើនគីឡូម៉ែត្រនៅ០១០ក-០១០ខ-នឹង ០១០គ ។ វាថាវាធ្វើសម្បទានអស់ប៉ុណ្ណោះហើយ សុខចិត្តដកពី០១០ក ទាំងអស់ ហើយប្រមូលកម្លាំងមកបោះទីតាំងចុងក្រោយបំផុតគឺនៅ០១០ខនេះ ។ វាថានៅ ០១០ខ យើងចូលជ្រៅកៀកអូរសេដ្ឋី២-៣គីឡូប៉ុណ្ណោះ ហើយយុទ្ធជនវាទ្រាំទ្រលែងបានហើយ ។ យើងខ្ញុំបានលើកបញ្ហាយកដែនទឹមកធ្វើជាមូលដ្ឋាន ដើម្បីពិភាក្សាគ្នាវាបដិសេធដាច់ខាត ។ វាថាដែនទីរបស់ចក្រពត្តិ ចក្រពត្តិគូរទុកសម្រាប់តែឲ្យយើងទំនាស់គ្នាទេ ហើយវាលើកបញ្ហាឲ្យយើងចេញប្រញាប់ពី០១០ខនេះ ។ ស្នើអង្គការជួយមតិតម្រែតម្រង់ថែម ។ សំគាល់ៈ -០១០ក គឺមុខព្រួញភូមិសោប, -០១០ខ គឺមុខព្រួញអូរវ៉ាយ -០១០គ គឺមុខព្រួញផ្លូវ១៩ ។ សូមជូនពរបងសុខសប្បាយ នឹងជ័យជំនះ ដោយគោរព ប៊ុត ថ្ងៃ២៦-១-៧៦, ចម្លងជូនៈ បងប៉ុល បងនួន បងវ៉ាន់ បងរី បងខៀវ បងឌឿន ទុកឯកសារ១ ច្បាប់, ទទួលថ្ងៃ២៦-១-៧៦ ម៉ោង ១៣ៈ០០◆◆◆ ទូរលេខ ៧៩ ជំរាបបងជាទីគោរព យើងខ្ញុំសូមរាយការណ៍អំពីសេចក្តីសម្រេចរបស់អង្គប្រជុំគណៈប្រតិភូយោធភូមិភាគទី៥ វៀតណាម នឹងយោធភូមិភាគឥសានកម្ពុជា ថ្ងៃ២៤-១-៧៦ ។ ទីតាំងក្រោយពេលដែលទាំងសងខាងសម្រុះសម្រួលកំណត់ខាងលើ គឺជាទីតាំងបណ្តោះអាសន្នមានតម្លៃរហូតដល់ពេលមជ្ឈិមបក្សទាំង២មានការសម្រេចពេញសិទ្ធ ។ ក-បញ្ហាប្រជាជនៈ ចំពោះបញ្ហាប្រជាជនគណៈប្រតិភូទាំង២បានឯកភាពគ្នាថាៈ១- ប្រជាជនកម្ពុជាដែលបានរត់ឆ្លងដែនទៅទឹកដីវៀតណាមខាងផ្នែកវៀតណាមឯកភាពនឹងយល់ស្របថា នឹងរាយការណ៍ជូនគណៈបញ្ជាការយោធភូមិភាគទី៥ទាំងមូលនឹងប្រគល់លក្ខណៈសម្បត្តិងាយស្រួលជូនកម្មាភិបាលកម្ពុជា ដើម្បីអប់រំនឹងនាំយកប្រជាជននោះត្រឡប់ទៅកម្ពុជាវិញ ។ បើប្រជាជននោះមិនយល់ព្រមទុកនៅទីនោះសិន ។ ២-ចំពោះប្រជាជនវៀតណាមនៅភូមិសោប ដែលកងការពារព្រំដែនកម្ពុជាជំលៀសចេញពីទីនោះដើម្បីដោះស្រាយបញ្ហាស្មុគស្មាញនៅព្រំដែន ប្រតិភូខាងកម្ពុជាបានឯកភាពថា នឹងទៅរាយការណ៍ជូនគណៈយោធភូមិភាគទាំងមូលជូនផ្នែកវៀតណាមវិញ ។ ចំពោះការប្រគល់ជូនវិញនេះ ខាងកម្ពុជានឹងយកចិត្តទុកដាក់

សមហេតុផលចំពោះទ្រព្យសម្បត្តិប្រជាជនទាំងនោះ ។ សូមជូនពរបងសុខសប្បាយនឹងជ័យជំនះ ។ ដោយគោរព ប៊ុត ថ្ងៃ៧-១-៧៦ គោរពជូនបងៈ ប៉ុល, នួន, វ៉ាន់, ម៉ុល រី, ខៀវ, ឡឿន, យួ ◆◆◆ទូរលេខៈ ៥៨, ១៤១ៈ ខ្ទង់ គោរពជូន ម.៨៧០ ជាទីគោរពស្នេហា ទូរលេខនេះជូនទៅខាងក្រសួងទូតចិនប្រចាំភ្នំពេញ ។ ខ្លឹមសារខាងក្រោមនេះ÷ សូមជូនទូតប្រទេសចិនផ្នែកសេដ្ឋកិច្ច ជាទីគោរពស្នេហា សូមជូនដំណឹងដល់សមមិត្ត ចឹងយីឈាង ដែលនៅធ្វើការប្រជុំនៅឯភ្នំពេញ សូមផ្ញើមកប្រញាប់ សូមបន្ថែមរនាស់រាស់ទទឹងស្រែ១គ្រឿង ។ ដោយសាមគ្គីភាពខ្ពស់បំផុត ថ្ងៃ៧-៥ ក្រុមកសិកម្ម ទទួលថ្ងៃ៨-៥-៧៧ ម៉ោង ០៩ៈ០០ បញ្ជាក់ៈ ទូរលេខនេះមកពីខាងបងញឹម ។ ចម្លងជូនៈ អ៊ុំ អ៊ុំនួន បងវ៉ាន់ បងវន បងខៀវ មន្ទីរឯកសារ◆◆◆ ទូរលេខ៨៤, ១៦០ខ្ទង់ ជូនបងជាទីស្នេហា តាមការពិភាក្សាជាមួយចិនដែលនាំកប៉ាល់នេសាទ៨គ្រឿងមកនេះ ។ សូមបងមានសុខភាពបរិបូរ ៨-៥ ឡូញ ទទួលថ្ងៃ៨-៥-៧៧ ម៉ោង ១៨ៈ០, ចម្លងជូនៈ អ៊ុំ អ៊ុំនួន បងវ៉ាន់ បងខៀវ មន្ទីរឯកសារ◆◆◆ ទូរលេខៈ ៣៦, ២១០ ខ្ទង់ ជូនបងជាទីគោរពស្នេហា យើងខ្ញុំសូមជំរាបបងដូចតទៅៈ ថ្មីៗនេះនៅវៀងចន្ទ និស្សិតជាន់ខ្ពស់គ្រប់សាលានៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ បាននាំគ្នាឡើងស្នើសួរដល់លោកភូមីវង្សវិចិត្ត ឧបនាយករដ្ឋមន្ត្រីក្រសួងសិក្សានឹងវប្បធម៌មានសំនួរ ។ ថ្មីៗនេះខ្មាំងបានបោកគ្រាប់បែកមួយគ្រាប់នៅជិតផ្សារព្រឹកធ្វើឲ្យរបួសធ្ងន់ពីរនាក់ ។ ដោយការតភាពបដិវត្តយ៉ាងកក់ក្តៅបំផុត ថ្ងៃ៨-៥-៧៧ ឌាន ទទួលថ្ងៃ ៩-៥-៧៧ ម៉ោង១០ៈ០០ ចម្លងជូនៈ អ៊ុំ អ៊ុំនួន បងវ៉ាន់ បងវន បងខៀវ មន្ទីរឯកសារ◆◆◆ ទូរលេខៈ ៣២៤, ១២៣០ៈ ខ្ទង់ គោរពជូន គណៈ៨៧០ ជាទីស្នេហា យើងខ្ញុំរាយការណ៍សភាពការណ៍មួយចំនួនដូចខាងក្រោមនេះ÷ សព្វថ្ងៃនេះ ខ្មាំងថៃវាជំរុញឲ្យពួកអាអ៊ិនតាំធ្វើសកម្មភាពអុកឡុកយើងនៅតាមព្រំដែន ដោយវាចាត់តាំងជាក្រុមតូចៗឲ្យលួចចូលមកក្នុងដីយើងដើម្បីមកធ្វើសកម្មភាពលួចវាយឈ្លបយើងផង នឹងធ្វើសកម្មភាពរាយការណ៍ពីយើងផង ។ **១-ខ្មាំងខាងព្រំដែនលាវ**ៈ មានសភាពស្ងប់ស្ងាត់ គ្មានអីគួរឲ្យចាប់អារម្មណ៍ទេ ។ **២-សភាពការណ៍ខ្មាំងខាងក្នុង**ៈ យើងកំពុងបន្តបោសសំអាតពួកអានៅសេសសល់ជាបន្តបន្ទាប់ទៀត ។ ដែលវាប្រឆាំងបដិវត្តយើងទាំងចំហរក្តី ទាំងដោយសម្ងាត់ក្តី ។ ជូនពរសុខសប្បាយ ជ័យជំនះ ថ្ងៃ១០-៤-៧៨ សែ, ទទួលថ្ងៃ១១-៤-៧៨ ម៉ោង ១៣ៈ០០នាទី ចម្លងជូនៈ អ៊ុំ អ៊ុំនួន អ៊ុំវ៉ាន់ អ៊ុំវន មន្ទីរឯកសារ◆◆◆ ទូរលេខៈ ០៨, ៣៧១ៈ ខ្ទង់ ជូនបងជាទីគោរព ១-អំពីសភាពការពារ និយាយរួមនៅតាមព្រំដែនក៏ដូចផ្ទៃក្នុងមូលដ្ឋានមិនមានសភាពអីធ្ងន់ធ្ងរទេ ។ នៅព្រំដែនយើងរុញច្រានខ្មាំងដដែល ពួកចារកម្មវាចូលពាកន្លែង ពីរលើកក៏យើងកម្ទេចមួយចំនួន រួចមួយចំនួន ពួកក្បត់ផ្ទៃក្នុងបានបោសសម្អាត និងយកចំលើយជាបន្តបន្ទាប់ ។ សូមបងបានសុខសប្បាយ និងជ័យជំនះ, វី ថ្ងៃ២១-៤-៧៨ ទទួលថ្ងៃ២១-៤-៧៨ ម៉ោង ១៥ៈ១៥ នាទី ចម្លងជូនៈ អ៊ុំ អ៊ុំនួន អ៊ុំវ៉ាន់ អ៊ុំវន មន្ទីរ ឯកសារ◆◆◆

**អៀង សារី និងព្រឹត្តការណ៍នៃការបាញ់នាវាម៉ាយ៉ាហ្គេ Mayaguez របស់សហរដ្ឋអាមេរិកៈ** អៀង សារី ឧបនាយករដ្ឋមន្ត្រីនៃរបបកម្ពុជាប្រជាធិបតេយ្យបានធ្វើសេចក្តីថ្លែងការណ៍នៅទីក្រុងញូវយ៉ក នាថ្ងៃទី៦ ខែកញ្ញា ឆ្នាំ១៩៧៥ ថាៈ «យើងខ្ញុំសូមរៀបរាប់ប្រាប់អស់លោកអ្នក អំពីរឿងរ៉ាវកប៉ាល់ម៉ាយ៉ាហ្គេ ។ តាមការជាក់ស្តែងបញ្ហានេះគឺមិនគួរឈានដល់ការបង្ហូរឈាមគ្នាដ៏ធំនោះទេ ។ ខ្ញុំគឺជាអ្នកចាត់ការរឿងនេះដោយដៃខ្ញុំផ្ទាល់ ។ ក្នុងស្មារតីប្រុងប្រយ័ត្នបដិវត្ត កងកម្លាំងប្រដាប់អាវុធរបស់យើងខ្ញុំបានឃើញកប៉ាល់ម៉ាយ៉ាហ្គេបើកចូលយ៉ាងកៀកមកជិតដែនកោះរបស់យើង ដូច្នេះយុទ្ធជនរបស់យើងត្រូវតែចាប់កប៉ាល់នោះ ។ តាមពត៌មានខាងយើងខ្ញុំ កប៉ាល់ម៉ាយ៉ាហ្គេបានចូលមកជិតក្នុងចម្ងាយប្រាំមួយគីឡូម៉ែត្រពីកោះ ។ នៅពេលដែលកងកម្លាំងប្រដាប់អាវុធយើងចាប់បានកប៉ាល់នោះ យើងខ្ញុំដែលកំពុងនៅក្នុងទីក្រុងភ្នំពេញពុំបានជ្រាបពីបញ្ហានេះទេ រហូតទាល់តែយើងបានឮតាមរយៈវិទ្យុផ្សាយសម្លេងអាមេរិកវិញ ពីព្រោះបច្ចេកវិទ្យាអាមេរិកអាចធ្វើឲ្យពួកគេបញ្ជូនពត៌មានបានលឿនជាងកងកម្លាំងប្រដាប់អាវុធរបស់យើង ។ ក្រោយពីបានដឹងអំពីបញ្ហាកប៉ាល់ម៉ាយ៉ាហ្គេ យើងខ្ញុំក៏បានធ្វើការទាក់ទងជាមួយកងកម្លាំងប្រដាប់អាវុធដែលស្ថិតនៅលើកោះ ហើយយើងខ្ញុំបានហៅមេបញ្ជាការនៃកងកម្លាំងទាំងនោះឲ្យមកភ្នំពេញរាយការណ៍ប្រាប់យើងអំពីបញ្ហានេះ ។ នៅម៉ោងប្រមាណ២រសៀល ក្រុមកងកម្លាំងប្រដាប់អាវុធបានមកដល់ភ្នំពេញ ។ នៅម៉ោង៥ល្ងាច យើងខ្ញុំបានបញ្ជូនពួកគេត្រឡប់ទៅវិញជាមួយនឹងបញ្ជាឲ្យដោះលែងកប៉ាល់ម៉ាយ៉ាហ្គេរជាបន្ទាន់ ពីព្រោះយើងខ្ញុំពុំចង់មានបញ្ហាស្មុគស្មាញជាមួយរដ្ឋាភិបាលអាមេរិក ។ តែនៅក្នុងខណៈដែលយើងខ្ញុំកំពុងបញ្ជាឲ្យដោះលែងកប៉ាល់ ពួកអាមេរិកាំងបានទម្លាក់គ្រាប់ជាច្រើនមកលើកោះតាង ។ ទាហានអាមេរិកាំងបានទម្លាក់គ្រាប់លើកោះតាងយ៉ាងច្រើនសន្ធឹកសន្ធាប់រហូតទាល់តែពួកគេគិតថា ប្រាកដជាគ្មាននរណាម្នាក់នៅលើកោះអាចមានជីវិតបានឡើយ ។ ប៉ុន្តែផ្ទុយទៅវិញ កងកម្លាំងប្រដាប់អាវុធរបស់យើងកំពុងលាក់ខ្លួននៅលើកោះរង់ចាំពួកទាហានអាមេរិកាំងដើរចូលមក ។ នៅពេលទាហានអាមេរិកាំងចូលមក យើងខ្ញុំក៏វាយប្រហារទៅលើពួកគេទៅ ។ យើងខ្ញុំមានការសោកស្តាយណាស់ចំពោះបញ្ហានេះ គឺមិនចាំបាច់ធ្វើឲ្យមានស្លាប់បាត់បង់ជីវិតយ៉ាងច្រើនបែបនេះសោះឡើយ ។ យើងខ្ញុំបានចេញបញ្ជាឲ្យខាងក្រុងព្រះសីហនុ ដោះលែងក្រុមទាហាននិងនាវិកអាមេរិកាំងទាំងអស់ ប៉ុន្តែពួកអាមេរិកាំងបែរជាចូលមកទម្លាក់គ្រាប់ដាក់យើងដាក់ទីក្រុងសីហនុ និងវាលរាម បណ្តាលឲ្យស្លាប់បាត់បង់អាយុជីវិតប្រជាកសិករស្លូតត្រង់អស់ជាច្រើន ។ ប្រែសម្រួលដោយៈ ឡាយ ពុទ្ធារ៉ា

ប្រភពពត៌មានៈ ទស្សនាវដ្តីទិនានុប្បវត្តិនៃមជ្ឈមណ្ឌលពត៌មានឥណ្ឌូចិន ចេញផ្សាយខែកុម្ភៈ-មីនា ឆ្នាំ១៩៧៦

# សិទ្ធិរបស់ខ្មែរក្រហមក្នុងការកម្ទេចប្រជាជនកម្ពុជា



## ១-ការទប់ស្កាត់ជាអន្តរជាតិចំពោះលទ្ធិផ្តាច់ការនិយម

ឆ្លើយតបទៅនឹងលោក កុតស្គី, ឡេនីន បានសរសេរក្នុងឆ្នាំ១៩១៦ថា: «លក្ខណៈចម្លែកនៃលទ្ធិចក្រពត្តិនិយមគឺនិន្នាការរបស់លទ្ធិនេះក្នុងការទន្ទ្រានយកមិនត្រឹមតែប្រទេសជាតិដែលពឹងផ្អែកលើវិស័យកសិកម្មជាធំប៉ុណ្ណោះទេ ប៉ុន្តែគឺទន្ទ្រានយកប្រទេសជាតិគ្រប់ប្រភេទទាំងអស់[១]» ។

ឈរលើសេចក្តីអះអាងនេះ មេដឹកនាំកុម្មុយនិស្តរូបនេះនឹងបង្កើតនូវការតស៊ូប្រឆាំងនឹងលទ្ធិចក្រពត្តិនិយមដើម្បីសបញ្ជាក់ឲ្យឃើញច្បាស់ជាថ្មីថា សិទ្ធិស្វ័យសម្រេចពីជោគវាសនាប្រទេសជាតិរបស់ប្រជាពលរដ្ឋគឺពិតជាត្រឹមត្រូវ ។ ម្ភៃប្រាំបួនឆ្នាំក្រោយមក សិទ្ធិនោះនឹងបង្កើតបានជាមូលដ្ឋានដ៏សំខាន់មួយក្នុងចំណោមសិទ្ធិជាមូលដ្ឋានគ្រឹះទាំងឡាយនៃធម្មនុញ្ញអង្គការសហប្រជាជាតិ ។

ទស្សនះរបស់ ឡេនីន ចំពោះកត្តា«ស្វ័យសម្រេច» នេះបានជះឥទ្ធិពលយ៉ាងខ្លាំងនាំឲ្យមានការបកស្រាយបញ្ចូលកត្តានេះទៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ ។ យោងទៅតាមកថាខណ្ឌទី២ នៃមាត្រា១ របស់ធម្មនុញ្ញអង្គការសហប្រជាជាតិស្តែងឲ្យឃើញថាអង្គការសហប្រជាជាតិ គឺតាមគោលដៅរបស់ខ្លួនត្រូវ«បង្កើតចំណងមិត្តភាពរវាងបណ្តាប្រទេសជាតិនានាលើសកលលោកដោយឈរលើមូលដ្ឋានគោរពគោលការណ៍ស្តីអំពីសិទ្ធិស្មើភាពគ្នា និងសិទ្ធិស្វ័យសម្រេចរបស់ប្រជាពលរដ្ឋទាំងអស់ និងចាត់នូវវិធានការសមរម្យផ្សេងៗទៀតដើម្បីពង្រឹងសន្តិភាពសកលលោក[២]» ។ កថាខណ្ឌទី៧ នៃមាត្រា២ សង្កត់ធ្ងន់បញ្ជាក់អំពីគោលការណ៍ស្តីអំពីការមិនចូលធ្វើអន្តរាគមន៍: «គ្មានអ្វីដែលមានចែងនៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិនេះអាចផ្តល់នូវសិទ្ធិអំណាចដល់អង្គការសហប្រជាជាតិឲ្យចូលធ្វើអន្តរាគមន៍នៅក្នុងបញ្ហានានា ដែលជាសំខាន់ស្ថិតនៅក្នុងដែនសមត្ថកិច្ចក្នុងស្រុករបស់រដ្ឋណាមួយ ឬក៏អាចតម្រូវឲ្យរដ្ឋជាសមាជិករបស់ខ្លួនទាំងឡាយដាក់បញ្ហាបែបនោះដើម្បីដោះស្រាយនៅក្រោមធម្មនុញ្ញសព្វថ្ងៃនេះបានឡើយ...[៣]» ។

ឆ្លងកាត់វិបត្តិទាំងឡាយដែលបានកើតមានកន្លងមក ហើយជាក់ស្តែងដោយសារថា គោលគំនិតរបស់ឡេនីននេះត្រូវបាន

គាំទ្រយ៉ាងមុតមាំពីបណ្តារដ្ឋដែលស្វែងរកឯករាជ្យចេញពីការធ្វើអាណានិគមនិយមនោះ វាស្តែងឲ្យឃើញថា សិទ្ធិស្វ័យសម្រេចរបស់ប្រជាពលរដ្ឋ គឺសំដៅភាគច្រើនលើការប្រកាសឲ្យដឹងឮជាទូទៅ និងជាដំណើរការនូវសិទ្ធិដែលរដ្ឋអធិបតេយ្យត្រូវមាន ជាជាងលើការទទួលស្គាល់នូវសិទ្ធិស្វ័យសម្រេចរបស់ប្រជាពលរដ្ឋនៃរដ្ឋនោះ ដូចជាចំពោះបញ្ហារៀបចំប្រទេសជាតិ និងការជ្រើសរើសរដ្ឋាភិបាលរបស់ខ្លួនជាដើម ។

ជាការពិតណាស់ នៅក្នុងរយៈកាល៣០ឆ្នាំកន្លងមក មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តនូវសេចក្តីសម្រេចមួយចំនួន ដែលសំដៅពង្រឹងគោលការណ៍ស្តីអំពីសិទ្ធិស្វ័យសម្រេចរបស់ប្រជាពលរដ្ឋនេះ ។ ក៏ប៉ុន្តែនាថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៦០ នៅខណៈដែលមហាសន្និបាតអង្គការសហប្រជាជាតិបានប្រកាសជាសាធារណៈថា «ប្រជាពលរដ្ឋគ្រប់សញ្ជាតិទាំងអស់ត្រូវមានសិទ្ធិស្វ័យសម្រេច ហើយអនុលោមទៅតាមសិទ្ធិនេះត្រូវមានសិទ្ធិកំណត់ស្ថានភាពផ្លូវច្បាប់របស់ខ្លួន និងស្វែងរកដោយសេរីនូវការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមនិងវប្បធម៌របស់ខ្លួន[៤]» ។ នៅថ្ងៃទី ២១ ខែធ្នូ ឆ្នាំ១៩៦៥ មហាសន្និបាតដដែលនោះបានអនុម័តនូវសេចក្តីប្រកាសមួយទៀតស្តីអំពីភាពមិនអាចទទួលយកបាននូវការធ្វើអន្តរាគមន៍នៅក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋនានា និងក្នុងការការពារឯករាជ្យភាព និងអធិបតេយ្យភាពរបស់បណ្តារដ្ឋ» ដែលចងគោលការណ៍នៃសិទ្ធិស្វ័យសម្រេចជាប់ជាមួយគោលការណ៍នៃការមិនធ្វើអន្តរាគមន៍ក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋដទៃ[៥] ។ ហេតុដូច្នេះគឺបណ្តារដ្ឋទាំងអស់នោះឯងដែលជាអ្នកទទួលសិទ្ធិក្នុងការជ្រើសរើសប្រព័ន្ធនយោបាយបែបណាមួយនៅក្នុងរដ្ឋរបស់ខ្លួន ។ ហេតុដូច្នេះការបង្កើតការហាមឃាត់មិនឲ្យធ្វើអន្តរាគមន៍ក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋដទៃនោះគឺគ្រាន់តែបម្រើឲ្យផលប្រយោជន៍ឲ្យបណ្តារដ្ឋទាំងនោះប៉ុណ្ណោះ ។ គ្មានអ្វីបានផ្លាស់ប្តូរជាដុំកំភួនទេ ។ គោលការណ៍នៃការមិនធ្វើអន្តរាគមន៍នេះនៅតែជាមូលដ្ឋានគ្រឹះសម្រាប់ទំនាក់ទំនងរវាងរដ្ឋនិងរដ្ឋដដែល ។ លោកសាស្ត្រាចារ្យផ្នែកច្បាប់អន្តរជាតិ ព្យែរ ម៉ែរតង់ (Pierre Mertens) នៅសកលវិទ្យាល័យហ្វ្រីនៃប្រ៊ុសសែល Free University of Brussels (ប្រទេសបែលហ្ស៊ិក) ធ្វើការគូសបញ្ជាក់ចំណុចនោះដោយផ្អែកលើទ្រឹស្តីប្រាកដនិយមថា «សិទ្ធិស្វ័យសម្រេចរបស់ប្រជាពលរដ្ឋនានា គឺកន្លងមកគ្មានអ្វីក្រៅពីអភ័យឯកសិទ្ធិរបស់ព្រះអង្គម្ចាស់នានាក្នុងការកំណត់សម្រេចលើបញ្ហាទាំងឡាយដើម្បីប្រជារាស្ត្រនោះឡើយ[៦] ។ ធម្មនុញ្ញអង្គការសហប្រជាជាតិគឺសំដៅធ្វើការការពារជាលក្ខណៈអន្តរជាតិកុំឲ្យមានថ្នាក់ដឹកនាំរដ្ឋផ្តាច់ការ ។ យោងតាមអ្នកដើរតាមគន្លង ឡេនីន លោក អន់តូនីញ៉ូ កាសេស Antonio Cassese បានធ្វើការកត់សម្គាល់ថា «នៅក្នុងរដ្ឋអធិបតេយ្យភាពមួយសិទ្ធិស្វ័យសម្រេចមានន័យថា គឺជាសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការជ្រើសរើសរបបសង្គមនិយមមួយ ហើយដែលផលវិបាករបស់វាគឺស្ថិតនៅត្រង់ថា សិទ្ធិស្វ័យសម្រេចនោះត្រូវបានទទួលស្គាល់ពេញលេញតែនៅក្នុងប្រទេសសង្គមនិយមតែប៉ុណ្ណោះ[៧]» ។ ការទទួលស្គាល់សិទ្ធិទាំងអស់នោះទៀតសោត គឺបានបំពាក់ដល់ប្រជាពលរដ្ឋទាំងអស់នូវអ្វីដែលលទ្ធិនេះហៅថា «អភ័យឯកសិទ្ធិ» ក្នុងការទទួលបានរបបសង្គមមួយបែបនោះដោយមិនឲ្យធ្វើការផ្លាស់ប្តូរ ។ សក្ខីកម្មបានសបញ្ជាក់នៅក្រុងប៊ែរឡាំង(ប្រទេសអាល្លឺម៉ង់) ក្នុងឆ្នាំ១៩៥៣, ទីក្រុងប៊ុយដាប៉េស(ប្រទេសហុងគ្រី) ក្នុងឆ្នាំ១៩៥៦, ទីក្រុងប្រាក (ប្រទេសឆេកូស្លូវ៉ាគី) ក្នុងឆ្នាំ១៩៦៨, ទីក្រុងវ៉ាសូវី (ប្រទេសប៉ូឡូញ) ក្នុងឆ្នាំ១៩៨១ ។

នៅក្នុងសង្គមប្រជាធិបតេយ្យរបស់លោកខាងលិច យើងអាចសង្កេតឃើញមានការយល់ដឹងប្រហាក់ប្រហែលគ្នាអំពីគោលគំនិតស្តីអំពីសិទ្ធិស្វ័យសម្រេចនេះ គឺថាការផ្លាស់ប្តូរនានាលើសណ្តាប់ធ្នាប់ផ្ទៃក្នុងរបស់ប្រទេសមួយដែលជាប្រតិកម្មទៅនឹងប្រព័ន្ធដឹកនាំមួយគ្មានភាពយុត្តិធម៌ ជាទូទៅត្រូវបានគេសង្កេតឃើញថាប្រទេសនោះជួបប្រទះនឹងភាពមិនទុកចិត្តគ្នា ហើយជាក់ស្តែងគឺភាពប្រទូស្តរាយនឹងគ្នា(ដូចជាប្រទេសគុយបា និងប្រទេសនីការ៉ាហ្គ័រ) ។ ផ្ទុយទៅវិញ ជាច្រើនទសវត្សរ៍កន្លងមក ការផ្តួលរំលំដោយកម្លាំងយោធារបស់រដ្ឋាភិបាលនិយមលទ្ធិប្រជាធិបតេយ្យគឺត្រូវបានទទួលនូវការអបអរសាទរដោយស្មោះស្ម័គ្រ ឬមួយក៏ត្រូវបានចាត់ទុកថាជាទង្វើមួយដែលតម្រូវមិនឲ្យមានការធ្វើអន្តរាគមន៍ក្នុងកិច្ចការផ្ទៃក្នុងរបស់ប្រទេសនោះ (ប្រទេសអេស្ប៉ាញ ក្នុងឆ្នាំ១៩៣៦, ប្រទេសក្រិក ក្នុងឆ្នាំ១៩៦៧, ប្រទេសឈីលី ក្នុងឆ្នាំ១៩៧២, ប្រទេសថៃ ក្នុងឆ្នាំ១៩៩១...) ។

មកទល់សព្វថ្ងៃនេះ គឺកម្រណាស់ដែលថាប្រជាពលរដ្ឋនៃប្រទេសនានាអាចមានលទ្ធភាពធ្វើការសម្រេចលើជោគវាសនារបស់ខ្លួនដោយសេរីនោះ ។ មកពីលទ្ធិកុម្មុយនិស្តម៉ាក្សក្តី ឬលទ្ធិមូលធនរីលស្រ៊ីតក្តី មនុស្សលោកកាន់តែច្រើនត្រូវធ្លាក់ក្នុងទាសភាព ។ ភាពប្រែប្រួលក្រឡាប់ចាក់ដែលបានលេចឡើងដោយមានការស្វាគមន៍ និងដោយមិនបានរំពឹងទុកនៅក្នុងតំបន់អឺរ៉ុបកណ្តាលនិងសហព័ន្ធសាធារណរដ្ឋសង្គមនិយមសូវៀតដែលជាដំណើរការមួយមិនបានបញ្ចប់ដោយពេញលេញនោះ មិនអាចធ្វើឲ្យយើងបំភ្លេចបានទេថា មនុស្សជាតិយើងប្រមាណមួយភាគបួននៅតែត្រូវទទួលរងនូវការដឹកនាំផ្តាច់ការលើវណ្ណៈអធន ហើយជាមួយគ្នានោះដែរ មនុស្សជាតិចំនួនជាងពីរភាគបួនទៀតត្រូវជាប់ខ្លួនរើមិនរួចនៅក្នុងសេចក្តីឈឺចាប់ខ្លោចផ្សានិងអំពើហិង្សាយ៉ាងកម្រោល ដែលពួកលោកខាងលិចហើយជាពិសេសសហរដ្ឋអាមេរិកខ្លួនឯងបានធ្លាប់ជួបប្រទះ ។

ដើម្បីវាយបកប្រឆាំងនឹងពួកចក្រពត្តិនិយម មហាអំណាចពិភពលោកសម័យថ្មីបានប្រកាសថា ការធ្វើអន្តរាគមន៍ ការលូកដៃចូលក្នុងអធិបតេយ្យភាព និងការជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងប្រទេសដទៃ គឺជាបទឧក្រិដ្ឋក្រោមច្បាប់អន្តរជាតិ ។ ការចែងជាច្បាប់នេះគឺចាំបាច់ណាស់ក្នុងការទប់ស្កាត់កុំឲ្យកើតមានឡើងបាននូវសណ្តាប់ធ្នាប់ប្រជាធិបតេយ្យអន្តរជាតិ ជាអ្វីដែលមិនត្រឹមតែមិនបានដោះស្រាយបញ្ហាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពុំបានជួយដល់ប្រទេសដែលឈរលើអព្យាក្រឹតមិនយកលទ្ធិឆ្វេងនិយមឬស្តាំនិយម ហើយដែលបានជ្រើសយកការដឹកនាំនយោបាយមួយខ្លួនឯង ។

មូលដ្ឋានគ្រឹះដ៏ចម្បងមួយនៃលទ្ធិប្រជាធិបតេយ្យពោលគឺ ឧត្តមភាពនៃច្បាប់(ច្បាប់ជាធំ) ត្រូវបានបំភ្លៃក្នុងគោលបំណងដើម្បីប្រើប្រាស់ជាហេតុផលសម្រាប់រុញច្រានមនុស្សជាតិរាប់លាននាក់ឲ្យឃ្លាតចេញឆ្ងាយពីការទទួលបាននូវគុណប្រយោជន៍ដែលគោលការណ៍«ឧត្តមភាពនៃច្បាប់»នេះបានផ្តល់ឲ្យ ។ ទង្វើនេះធ្វើឲ្យមានលេចជាសំណួរថា តើវាមិនស្ថិតនៅក្នុងសមត្ថកិច្ចច្បាប់អន្តរជាតិទេឬយ៉ាងណា បានជារបបរបស់រដ្ឋនានានៅចន្លោះមហាសមុទ្រមេឌីទែរ៉ាណេនិងមហាសមុទ្រឥណ្ឌារៀងរាល់ថ្ងៃតែងតែបានរំលោភបំពានលើសិទ្ធិមនុស្សជាមូលដ្ឋានគ្រឹះបំផុត បែរជាត្រូវទទួលបាននូវការស្តាបនាឬការគាំទ្រទៅវិញ?

## ២-ភាពគ្មានជំនួយអន្តរជាតិចំពោះប្រជាពលរដ្ឋមួយដែលកំពុងស្ថិតនៅក្នុងគ្រោះថ្នាក់

បន្ទាប់ពីមហាវិនាសកម្មរបស់ជនជាតិជ្វីហ្វមក ទោះជាមានវត្តមានអង្គការសហប្រជាជាតិ ហើយអង្គការសហប្រជាជាតិបានអនុម័តដោយមានសំឡេងគាំទ្រយ៉ាងច្រើនលើសលប់ទៀតផងនូវឧបករណ៍ច្បាប់ដ៏គួរឲ្យកត់សម្គាល់នានាដែលទប់ស្កាត់មនុស្សជាតិកុំឲ្យរំលោភបំពានលើជនរួមជាតិរបស់ខ្លួន ហើយលើសពីនេះទៅទៀត ទោះបីជាមនុស្សគ្រប់ៗរូបសុទ្ធតែបានយល់ដឹងអំពីអំពើសម្លាប់រង្គាលទាំងឡាយដែលកំពុងតែកើតមាននោះក៏ដោយក៏រដ្ឋាភិបាលនៃប្រទេសភាគច្រើនបានបដិសេធមិនប្រើប្រាស់ឧបករណ៍ច្បាប់ទាំងនោះ ដែលតាមរយៈច្បាប់ទាំងនេះរដ្ឋាភិបាលទាំងនោះអាចដាក់








ការគាបសង្កត់ទៅលើប្រទេសណាមួយបាន ហើយមិនត្រឹមតែប៉ុណ្ណោះ រដ្ឋាភិបាលនៃប្រទេសទាំងនោះថែមទាំងធ្វើការបដិសេធរហូតដល់មិនព្រមចូលធ្វើអន្តរាគមន៍ក្នុងការបញ្ឈប់អំពើសម្លាប់រង្គាល និងខកខានពុំបានបញ្ឈប់អំពើប្រល័យពូជសាសន៍ថ្មីមួយទៀត គឺការសម្លាប់បំផុតពូជប្រជាពលរដ្ឋកម្ពុជារាប់លាននាក់ ដែលធ្វើឡើងដោយពួកខ្មែរក្រហម ។

នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៤៦ មហាសន្និបាតអង្គការសហប្រជាជាតិបានប្រកាសថា «ការបង្ក្រាបឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ គឺជាភារកិច្ចរបស់អន្តរជាតិទាំងមូល[៨]» ។ នៅថ្ងៃដដែលនោះ មហាសន្និបាតអង្គការសហប្រជាជាតិបានធ្វើការបញ្ជាក់យ៉ាងច្បាស់ទៅលើគោលការណ៍ច្បាប់អន្តរជាតិ ដែលទទួលស្គាល់ដោយលក្ខន្តិកៈរបស់តុលាការនូរិមបឺក និងដោយសវនាការរបស់តុលាការនោះ[៩] ។ ២ឆ្នាំក្រោយមកគឺនៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៤៨ មហាសន្និបាតដដែលនេះបានអនុម័តពង្រាងច្បាប់លើអនុសញ្ញាស្តីអំពីការទប់ស្កាត់និងការផ្តន្ទាទោសបទឧក្រិដ្ឋប្រល័យពូជសាសន៍[១០] ។

គេអាចគិតថាសេចក្តីប្រកាសយ៉ាងឱឡារិកជាផ្លូវការដ៏ច្រើនសន្ទឹកសន្ទាប់បែបនេះ ដោយមានសភានិងរដ្ឋាភិបាលយ៉ាងច្រើនបាននាំគ្នាចូលរួមផ្តល់សច្ចាប័នលើសេចក្តីប្រកាសទាំងអស់នោះផង គឺអាចការពារមនុស្សជាតិឲ្យរួចផុតពីអំពើសម្លាប់រង្គាលម្តងហើយម្តងទៀត ដែលអំពើសម្លាប់រង្គាលបែបនោះកន្លងមកក្នុងឆ្នាំ១៩៤៥ បានបន្តឲ្យមានសម្រែកទាមទារយ៉ាងដាច់អហង្កាប៉ុន្តែដោយស្មោះស្ម័គ្រថា «សូមកុំឲ្យមានជាថ្មីទៀត!» ។

ប៉ុន្តែ ការគិតនិងក្តីសង្ឃឹមបែបនេះបានត្រូវរលាយសូន្យ ។ ដើម្បីតែពាក្យថា សិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលសិទ្ធិស្វ័យសម្រេចជូសមុខឲ្យប្រជាជាតិរបស់ខ្លួន សហគមន៍អន្តរជាតិបានបណ្តោយឲ្យមហាវិនាសកម្មថ្មីមួយកើតឡើងជាថ្មីម្តងទៀត ។ ក្នុងឆ្នាំ១៩៧៥ នៅពេលដែលបក្សពួកនិងបរិវាររបស់ ប៉ុល ពត ដណ្តើមយកអំណាចគ្រប់គ្រងប្រទេសបាន ពិភពលោកទាំងមូលពិតជាបានដឹងយ៉ាងពិតប្រាកដ ។ នៅពេលដែលប្រទេសកម្ពុជាបានដួលរលំទាំងស្រុង ហើយដែលប្រែក្លាយទៅជាជំរុំប្រមូលផ្តុំដ៏ធំមួយនោះ ប្រជាជនកម្ពុជាបានខិតខំព្យាយាមគ្រប់បែបយ៉ាងធ្វើយ៉ាងណាភៀសខ្លួនចេញពីប្រទេសឲ្យរួច ក្នុងអំឡុងពេលប៉ុន្មានសប្តាហ៍ក្រោយមកប៉ុណ្ណោះសាក្សីមានចំនួនកាន់តែច្រើនឡើងៗ ។

ជាក់ស្តែងនៅថ្ងៃទី២៤ និង២៥ ខែតុលា ឆ្នាំ១៩៧៥ រយៈពេល៦ខែបន្ទាប់ពីពួកខ្មែរក្រហមវាយដណ្តើមយកទីក្រុងភ្នំពេញបាន លោក ហ្វ្រង់ស្វ័រ ប៉ុងសូ François Ponchaud បានបញ្ចប់អត្ថបទមួយរបស់លោក ហើយបានចុះផ្សាយនៅលើទំព័រកាសែតឡាគ្រ័រ La Croie ។ អត្ថបទនោះបានពិពណ៌នាយ៉ាងក្បោះក្បាយ ឆ្លុះបញ្ចាំងពីទិដ្ឋភាពនានានៃគ្រោះមហន្តរាយនិងសោកនាដកម្មរបស់កម្ពុជា គឺការជម្លៀសប្រជាជនដោយបង្ខំឲ្យចាកចេញពីទីក្រុងនិងទីប្រជុំជនទៅកាន់ទីជនបទនានា ការសម្លាប់ទាហាននិងអ្នករដ្ឋការនៃរបបមុនយ៉ាងរង្គាល ការកាប់សម្លាប់មនុស្សក្នុងលក្ខណៈជាប្រព័ន្ធ ការបង្កើតជាសហករណ៍រួមទូទាំងប្រទេស ការបង្ខំឲ្យធ្វើពលកម្ម ការបង្អត់អាហារ ។ល។ លោក ហ្វ្រង់ស្វ័រ បានធ្វើការបញ្ជាក់បន្ថែមនិងផ្តល់នូវភស្តុតាងយ៉ាងពេញលេញជាថ្មីថែមទៀត ក្នុងរយៈពេល៣ឆ្នាំក្រោយមកទៀត[១១] ។ លោក ណាយ៉ាន់ ចាន់ដា និងលោក វីល្លៀម សក្រោះ ជាអ្នកជំនាញពីរនាក់ក្នុងចំណោមអ្នកជំនាញដ៏ល្បីល្បាញបំផុតលើបញ្ហាកម្ពុជា ក៏បានផ្តល់នូវការបញ្ជាក់អះអាងដូចគ្នានេះដែរក្នុងប៉ុន្មានខែក្រោយមកនោះ[១២] ។ នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ស្នាដៃនិពន្ធលើកទីមួយបានឆ្លងកាត់ការបោះពុម្ពផ្សាយប្រាប់ពិភពលោកឲ្យបានដឹងថា «នៅកម្ពុជា របបកម្ពុជាប្រជាធិបតេយ្យមិនយកមនុស្សទៅ«កសាង»ធ្វើ«ជីវទស្សន៍» ទៀតទេ គឺតាមពិតរបបនេះប្រហារជីវិតមនុស្សដោយក្រុមបាញ់ប្រហារ»[១៣] ។ មួយខែក្រោយមកទៀត លោក ប៊ែរណា អាមែល បានចងក្រងសេចក្តីរៀបរាប់របស់សាក្សីរាប់សិបនាក់ ដែលចង្អុលបង្ហាញអំពីការប្រែក្លាយសង្គមកម្ពុជាឲ្យទៅជាកន្លែងដ៏ធំមួយសម្រាប់ផ្តាច់ជីវិតមនុស្ស[១៤] ។ នាដើមខែមករា ឆ្នាំ១៩៧៧ សៀវភៅស្នាដៃនិពន្ធរបស់លោក ហ្វ្រង់ស្វ័រ ប៉ុងសូ បានលេចរូបរាងឡើងក្រោមចំណងជើងថា «កម្ពុជាឆ្នាំសូន្យ»[១៥] ហើយត្រូវបានបកប្រែទៅជាច្រើនភាសាផងនោះ បានផ្សព្វផ្សាយពាសពេញពិភពលោក ។ ឆ្នាំដដែលនោះ នៅក្នុងប្រទេសអាមេរិកវិញ លោក ប៉ែរិន និង ដូល បានចេញផ្សាយនូវស្នាដៃមួយឈ្មោះថា







«ឃាតកម្មលើទឹកដីដ៏ស្ងប់ស្ងាត់មួយ Murder of a Gentle Land»[១៦] ។ នៅក្នុងអំឡុងពេលពីរឆ្នាំបន្ទាប់មកទៀត មានអត្ថបទរាប់សិបថែមទៀតដែលលាតត្រដាងអំពីវិសាលភាពនៃសោកនាដកម្ម ដែលធ្វើឲ្យប្រជាជាតិកម្ពុជាខ្ទេចខ្ទីរស្មើរលោយសាបសូន្យ ។ ជាចុងក្រោយ ក្នុងខែមេសា ឆ្នាំ១៩៧៨ នាទីក្រុងអូស្លូ (ប្រទេសន័រវែស) ក្រុមអ្នកត្រួតពិនិត្យអន្តរជាតិដែលចំណុះដោយអ្នកជំនាញនិងសាក្សីជាច្រើន បានប្រមូលចងក្រងបាននូវទិន្នន័យដ៏ច្រើនលើសលប់ ។ ក្នុងខែមិថុនា ឆ្នាំ១៩៧៨ លោក ជីន ឡាកុត ជាអ្នកសង្កេតការណ៍ម្នាក់ក្នុងចំណោមអ្នកសង្កេតការណ៍ដ៏ហ្មត់ចត់បំផុតលើបញ្ហាជីវិតរបស់ប្រជាជាតិកម្ពុជា បានចេញស្នាដៃជាសៀវភៅដ៏តូចមួយប្រកបដោយអត្ថន័យយ៉ាងសោកសង្រេង ក្រោមចំណងជើងថា «ប្រជាជនកម្ពុជាត្រូវតែរស់!»[១៧] ក្នុងន័យអំពាវនាវឲ្យមនុស្សជាតិក្នុងលោកបានដឹងឮ ។

ប៉ុន្តែជាអកុសល គ្មាននរណាបានដឹងឮអំពីសេចក្តីអំពាវនាវដ៏ក្រៀមក្រំនោះឡើយ ។ សាធារណជនទូទាំងសកលលោកពិតជាបានទទួលពត៌មានទាំងនេះ ប៉ុន្តែគេកម្រនឹងបញ្ចេញជាចលនាឬសកម្មភាពក្នុងការជួយឈឺឆ្អាលអំពីសោកនាដកម្មនេះឡើយ ។ អង្គការធំៗជាច្រើនដែលប្រយុទ្ធប្រឆាំងដើម្បីសិទ្ធិមនុស្សនៅតែសំងំយ៉ាងស្ងាត់ស្ងៀម និងស្តែងឲ្យឃើញយ៉ាងច្បាស់ថា ពួកគេមានការភ័យខ្លាចក្នុងការចោទសួរចំពោះរបបកុម្មុយនិស្តមួយដែលកកើតចេញពីសង្គ្រាម«រំដោះជាតិ» ។ តែទោះជាយ៉ាងណាក៏ដោយការប្រកាសមិនទទួលស្គាល់អំពីអត្ថិភាពនៃជំរុំឃុំឃាំងប្រមូលផ្តុំគឺហួសសម័យលែងមាននរណាជឿជាក់ទៀតហើយ[១៨] ។ រដ្ឋាភិបាលនានាក៏បានយល់ដឹងអំពីបញ្ហានេះដែរ ។ គ្មានអ្វីដែលគួរឲ្យសង្ស័យទៀតទេចំពោះសោកនាដកម្មនៅកម្ពុជា ព្រោះពត៌មានត្រូវបានផ្សព្វផ្សាយជ្រួតជ្រាបទៅដល់មនុស្សគ្រប់ស្រទាប់ គ្រប់ច្រកល្ហក ។ ពិតណាស់ រដ្ឋាភិបាលទាំងនោះមិនត្រឹមតែបានយល់ដឹងប៉ុណ្ណោះទេ ប៉ុន្តែអ្នកខ្លះទៀតថែមទាំងបានសម្តែងចេញបញ្ឈរក់ពីជំហររបស់ខ្លួនទៀតផងលើបញ្ហានេះ ។ បើពិចារណាអំពីភាពអវិជ្ជមានដោយផ្នែកខ្លះៗលើបញ្ហាប្រល័យពូជសាសន៍ ដែលជាឥរិយាបថដែលរដ្ឋាភិបាលទាំងនោះមានជាប់ជាប្រចាំតាំងពីឆ្នាំ១៩៧៩មកនោះវាជាការមួយគួរឲ្យចាប់អារម្មណ៍ណាស់ក្នុងការបរិយាយសាជាថ្មីឡើងវិញអំពីសេចក្តីប្រកាសនានារបស់មេដឹកនាំលោកខាងលិចមួយចំនួន និងគំនិតផ្តួចផ្តើមនានាដែលប្រកាន់យកដោយរដ្ឋាភិបាលមួយចំនួន ពាក់ព័ន្ធនឹងបញ្ហារំលោភសិទ្ធិមនុស្សនៅកម្ពុជាចន្លោះឆ្នាំ១៩៧៥-៧៩ ។

កាលណោះសាធារណជនគ្រប់មជ្ឈដ្ឋានត្រូវតែរង់ចាំរហូតដល់ឆ្នាំ១៩៧៨ ទើបក្រុមអាជ្ញាធរនយោបាយធ្វើការប្រកាសឲ្យបានដឹងបានឮអំពីជំហររបស់ខ្លួន ។ នៅក្នុងអំឡុងពេលនៃសម័យប្រជុំលើកទី៣៤ដែលប្រារព្ធឡើងចាប់ពីថ្ងៃទី៦ ខែកុម្ភៈ ដល់ថ្ងៃទី១០ ខែមិនា ឆ្នាំ១៩៧៨ នោះ គណៈកម្មការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិដែលបានជួបប្រជុំគ្នានៅទីក្រុងហ្សឺណែវ បានធ្វើការពិភាក្សាយ៉ាងយូរអំពីការរំលោភសិទ្ធិមនុស្ស

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

លោក ឡុត បូស្តុន គាត់នាមឲ្យចក្រភពអង់គ្លេស ធ្វើការប្រកាសថា «...ការរំលោភសិទ្ធិមនុស្សនោះ...ពិតជាបន្តឲ្យមានការរំលោភសិទ្ធិមនុស្សដ៏ល្បីសុះសាយនិងតក់ស្លុតបំផុតដែលពុំដែលមានចាប់តាំងពីសង្គ្រាមលោកលើកទី២មក... ។ ការធ្វើមិនដឹងមិនឮចំពោះការពិតទាំងអស់នេះ នឹងធ្វើឲ្យខូចកិត្តិយសជាបន្តបន្ទាប់ដល់គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ហើយមិនត្រឹមតែប៉ុណ្ណោះប្រហែលជាដល់អង្គការសហប្រជាជាតិទាំងមូលទៀតផង នេះបើនិយាយនៅក្រោមក្រសែភ្នែក និងទស្សនៈរបស់សាធារណជនអន្តរជាតិ ។ ហើយជាមួយនឹងហេតុផលនេះឯងដែលរដ្ឋាភិបាលចក្រភពអង់គ្លេសបានសម្រេចលើកយកពត៌មានអំពីសោកនាដកម្មដែលកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យមកធ្វើការពិភាក្សានៅចំពោះមុខគណៈកម្មការសិទ្ធិមនុស្សពេលនេះ ។ បញ្ហាទាំងនោះគឺអំពើព្រៃផ្សៃយង់ឃ្នងដែលមានលក្ខណៈជាប្រព័ន្ធ អាជ្ញាធរនៃរបបកម្ពុជាប្រជាធិបតេយ្យបានប្រព្រឹត្តិមកលើប្រជាជនកម្ពុជាតាមទំនើងចិត្ត ។ សមាជិកជាន់ខ្ពស់នៃរបបខ្មែរក្រហមបានសម្រេចឲ្យមន្ត្រីនិងបុគ្គលិកយោធារបស់ខ្លួនប្រតិបត្តិតាមគោលនយោបាយតាមទំនើងចិត្តមួយក្នុងការតាមដាន និងកម្ទេច ដែលជាទូទៅធ្វើឡើងក្នុងរបៀបមួយយ៉ាងសាហាវឃោរឃៅ និងអមនុស្សធម៌លើប្រជាជនកម្ពុជាយ៉ាងច្រើនឥតគណនា ក្នុងនោះរួមមានមន្ត្រីនៃរបបមុន ទាហាន ប៉ូលីស មន្ត្រីរដ្ឋការ គ្រូបង្រៀន សិស្ស និស្សិត ស្រីពេស្យា និងព្រះសង្ឃ ។ល ។ ជាការពិតណាស់ មេដឹកនាំសាសនាមកពីក្រុមសាសនាតូចតាចនានាក៏ស្ថិតនៅក្នុងចំណោមជនរងគ្រោះទាំងអស់នោះដែរ ហើយក៏មានករណីជាច្រើនទៀតដែលក្នុងនោះភ័ស្តុតាងបង្ហាញថា គ្រួសារជនរងគ្រោះទាំងអស់នោះត្រូវស្លាប់ជាមួយនឹងជនរងគ្រោះដែរ ។ យោងតាមអង្គហេតុដែលបានរាយការណ៍ ប្រជាជនដែលមានជីវិតរួចពីសម័យនោះ សុទ្ធតែធ្លាប់ត្រូវបានពួកខ្មែរក្រហមដាក់កម្រិតឲ្យរស់នៅក្នុងស្ថានភាពរស់នៅជាខ្ញុំបម្រើ ឬជាទាសភាព[១៩]» ។

ក្រោយពីបានធ្វើការរិះគន់យ៉ាងខ្លាំងក្លាលើចក្រភពអង់គ្លេសដែលល្បីល្បាញទូទាំងពិភពលោកថា «មានប្រពៃណីជាប្រទេសចក្រពត្តិនិយមពូកែខាងធ្វើអាណានិគមនិយម ពូកែខាងប្រើប្រាស់ឥទ្ធិពលសេដ្ឋកិច្ចនិងនយោបាយរបស់ខ្លួនដើម្បីត្រួតត្រាប្រទេសដទៃ និងពូកែខាងក្បត់គ្នាឯងផងដែរនោះ» លោក ទឹម ហុក ដែលជាមន្ត្រីតំណាងរបបកម្ពុជាប្រជាធិបតេយ្យធ្វើការថ្កោលទោសចក្រភពអង់គ្លេសថាប្រើ «កលល្បិចដ៏អាម៉ាស់នេះ ដែលជាការជ្រៀតជ្រែកដែលមិនអាចអត់ឱនឲ្យបានក្នុងកិច្ចការផ្ទៃក្នុងរបស់ប្រទេសកម្ពុជា ដែលជារដ្ឋមួយមានឯករាជ្យភាព អធិបតេយ្យភាព អព្យាក្រិត្យ និងមិនចូលបក្សសម្ព័ន្ធ»[២០] ។

ការជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋ ដែលមានអធិបតេយ្យភាព ដែលជារូបមន្តដ៏មហាស្ចារ្យទាញរដ្ឋាភិបាលនានាឲ្យចេញឆ្ងាយពីការទទួលខុសត្រូវទាំងអស់ ត្រូវបានទទួលជោគជ័យ ។ ក្នុងនាមជាអ្នកទប់ស្កាត់ចំពោះអំពើចក្រពត្តិនិយមនិងអាណានិគមនិយមផ្នែកសេដ្ឋកិច្ចនិងនយោបាយ គ្រប់រូបភាព ពួកខ្មែរក្រហមអាចសម្លាប់មនុស្សយ៉ាងរង្គាលដោយគ្មានការដាក់ទោសពៃរ៍មកលើខ្លួន ។ អ្នកដែលសម្លាប់ចោលនូវបញ្ញាវ័ន្តទាំងអស់បែរជាត្រូវបានការពារដោយធម្មនុញ្ញអង្គការសហប្រជាជាតិ ។

នាថ្ងៃទី៨ ខែមិនា ឆ្នាំ១៩៧៨ គណៈកម្មការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ នៅក្រោមគំនិតផ្តួចផ្តើមរបស់ចក្រភពអង់គ្លេស ដោយមានការគាំទ្រពីសំណាក់ប្រទេសអូទ្រីសនិងស៊ុយអែដផងនោះ បានធ្វើសេចក្តីសម្រេចស្នើសុំដល់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិឲ្យពិភាក្សាពិចារណាអំពីបញ្ហាអជ្ញាធរនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយថែមទាំងបានសំណូមពរឲ្យអនុគណៈកម្មការនេះបន្តភារកិច្ចរបស់ខ្លួនក្នុងការពិនិត្យពិចារណាលើបញ្ហានេះតទៅទៀតនាសម័យប្រជុំខែសីហាឆ្នាំដដែលនោះ ។ បេសកជនពិសេសរបស់អង្គការសហប្រជាជាតិម្នាក់ត្រូវបានជ្រើសតាំងឡើង ហើយទទួលបន្ទុកធ្វើការសិក្សាស្រាវជ្រាវយ៉ាងល្អិតល្អន់លើបញ្ហារំលោភសិទ្ធិមនុស្សក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

នាថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៦ លោកប្រធានាធិបតីសហរដ្ឋអាមេរិក ជីមី ខាធ័រ បានចេញសេចក្តីអំពាវនាវដល់គ្រប់ប្រទេសទាំងអស់ឲ្យចេញមុខប្រឆាំងជាសាធារណៈចំពោះសកម្មភាពរំលោភសិទ្ធិមនុស្សដែលមានលក្ខណៈជាប្រព័ន្ធនៅក្នុងប្រទេសកម្ពុជា ។ ប្រធានាធិបតីអាមេរិកដែលមានអំណាចជា

ប្រមុខប្រតិបត្តិ បានបញ្ជាក់លើសេចក្តីថ្លែងការណ៍ថា «សហរដ្ឋអាមេរិកមិនអាចខកខានក្នុងការថ្កោលទោសរដ្ឋាភិបាលកម្ពុជា ដែលជាអ្នករំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរបំផុតនៅក្នុងពិភពលោក នាពេលបច្ចុប្បន្ននេះជាដាច់ខាត» ។

៤ខែបន្ទាប់មក សមាជិកព្រឹទ្ធសភាអាមេរិក ចច មាក់ហ្គោវឹន ដែលជាអតីតបេក្ខជនឈរឈ្មោះតំណែងប្រធានាធិបតីរបស់អាមេរិក បានធ្វើសេចក្តីថ្លែងការណ៍ទៅកាន់គណៈកម្មការព្រឹទ្ធសភាអាមេរិក ។ ដោយធ្វើការសន្និដ្ឋានថា របបកម្ពុជាប្រជាធិបតេយ្យគឺជាអ្នកទទួលខុសត្រូវចំពោះការបាត់បង់អាយុជីវិតមនុស្ស២លានកន្លះ លោកបានស្នើសុំឲ្យមានការរៀបចំបង្កើត «អន្តរាគមន៍ផ្នែកយោធាជាលក្ខណៈអន្តរជាតិ» ដើម្បី «ផ្តួលរំលំរដ្ឋាភិបាលកម្ពុជា» ដែលជាប់ទោសពីបទប្រល័យពូជសាសន៍[២១] ។

សេចក្តីអំពាវនាវទាំងនេះ ពុំបាននាំមកនូវលទ្ធផលជាដុំកំភួនណាមួយឡើយ ។ នៅក្នុងខែសីហា ឆ្នាំ១៩៧៨ អនុគណៈកម្មការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ធ្វើការកត់ត្រាអំពីសេចក្តីរាយការណ៍បរិយាយប្រាប់របស់សាក្សីដែលកាន់តែមានចំនួនច្រើនឡើងៗ ស្តីអំពីអំពើប្រល័យពូជសាសន៍ដែលកំពុងតែកើតមានឥតឈប់ឈរ ។ របាយការណ៍កសិណសាក្សីទាំងអស់នោះមានសុពលភាពកាន់តែខ្លាំងឡើងរហូតទាល់តែទទួលបាននូវការគាំទ្រពីសំណាក់រដ្ឋាភិបាលប្រទេសនានាជាច្រើន ។

ជាក់ស្តែង នៅពេលចាប់ផ្តើមការងាររបស់ខ្លួន អនុគណៈកម្មការនេះបានទទួលនូវរបាយការណ៍ប្រមាណជិត៩៩៥ទំព័រ ដែលក្នុងនោះមានសេចក្តីរាយការណ៍កសិណសាក្សី សេចក្តីប្រកាស និងសញ្ញាគាំទ្រយ៉ាងច្រើនពីរដ្ឋាភិបាលនានា ដូចជាអាមេរិក អូស្ត្រាលី អង់គ្លេស កាណាដា និងន័រវ៉ែស ក៏ដូចជាអង្គការលើកលែងទោសអន្តរជាតិ និងគណៈកម្មការចៅក្រមអន្តរជាតិ ។ សេចក្តីទុក្ខសោកបានលាតត្រដាងឲ្យឃើញនៅក្នុងគ្រប់រូបភាពគ្រប់វិសាលភាពការរំលោភសិទ្ធិមនុស្សនៅកម្ពុជា គឺមានលក្ខណៈជាទ្រង់ទ្រាយធំ និងជាប្រព័ន្ធ ។ ជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលស្លាប់អាចមានចំនួនលើសពីចំនួន២លាននាក់ ដូចដែលបាន៉ស្មានដោយរដ្ឋាភិបាលនៃប្រទេសមួយចំនួន ។ របាយការណ៍[២២] ដែលបានដាក់ជូនក្រោយពីបំពេញភារកិច្ចរួចដោយលោក ប៊ូឌីបា ដែលជាប្រធាននៃអនុគណៈកម្មការនេះ ទាញសេចក្តីសន្និដ្ឋានជាបញ្ចប់ថាជាអំពើប្រល័យពូជសាសន៍[២៣] ។

## ៣-អំពើប្រល័យពូជសាសន៍ដែលប្រព្រឹត្តដោយរួចទោសទាំងស្រុង

ទោះបីជាយ៉ាងណាក៏ដោយ សួរថាតើរដ្ឋាភិបាលនៃបណ្តាប្រទេសផ្សេងដែលព្រួយបារម្ភអំពីជោគវាសនាដ៏ខ្លោចផ្សារបស់ប្រជាជាតិកម្ពុជា បានធ្វើសំណូមពរអ្វីខ្លះនាពេលនោះៈ ស្នើសុំដល់ក្រុមប្រឹក្សាសន្តិសុខឲ្យជួយបញ្ឈប់ការសម្លាប់រង្គាលឥតឈប់ឈរ? ស្នើសុំដល់មហាសន្និបាតអន្តរជាតិដែលត្រូវកោះប្រជុំនាពេលក្រោយនោះបន្តិច? ឬស្នើសុំឲ្យបញ្ជូនគណៈកម្មការស៊ើបអង្កេតមួយមក? ឬមួយក៏ស្នើសុំឲ្យចាត់វិធានការជាដុំកំភួនជាបន្ទាន់ក្នុងរបៀបមួយដែលអាចផ្លាស់ប្តូរវិធីសាស្ត្ររបស់រដ្ឋាភិបាលភ្នំពេញ?

ដោយត្រូវគោរពអធិបតេយ្យភាពជាតិ និងប្រកាន់យក







កាតព្វកិច្ចមិនជ្រៀតជ្រែកប្រទេសដទៃ នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៧៨ ប្រទេសទាំងនោះបានសំណូមពរឲ្យ«ប្រធានឬសមាជិកនៃអនុគណៈកម្មការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ដែលប្រធាននៃគណៈកម្មការនេះសម្រេចតែងតាំង»ធ្វើការវិភាគឯកសារដែលបានទទួលទាំងអស់នោះក្នុងនាមជាអនុគណៈកម្មការ ព្រមទាំងវិភាគលើសេចក្តីអត្ថាធិប្បាយនិងសេចក្តីសង្កេតការណ៍ទាំងឡាយរបស់អនុគណៈកម្មការ ក៏ដូចជាឯកសារដែលពាក់ព័ន្ធផ្សេងៗទៀត...[២៥]» ។

ហេតុដូច្នេះ នេះគឺជាការជួបប្រជុំមួយនៃអ្នកជំនាញដែលមានភារកិច្ចជាអន្តរជាតិក្នុងការបង្ការប្រជាជាតិក្នុងសកលលោកឲ្យរួចផុតពីការរំលោភបំពានសិទ្ធិមនុស្សគ្រប់បែបយ៉ាង ។ ក្រុមអ្នកជំនាញទាំងអស់នោះត្រូវបានបំភ្លឺឲ្យយល់ដឹងច្បាស់អំពីការរំលោភទ្រង់ទ្រាយធំបែបនេះ ដែលបំពេញលក្ខណៈជាអំពើប្រល័យពូជសាសន៍ ។ ថ្វីបើពុំមានសញ្ញាណចង្អុលបង្ហាញឲ្យឃើញថា ការប្រព្រឹត្តបែបនេះបានបញ្ចប់ក៏ដោយ ក៏កត្តាដែលធ្វើឲ្យអ្នកជំនាញទាំងអស់ពេញចិត្តស្កប់ចិត្តសព្វគ្រប់នោះគឺគ្មានអ្វីក្រៅពីការធ្វើវិភាគមួយនោះឡើយ ។

តើជីវិតមនុស្សម្នាក់មានតម្លៃប៉ុនណានៅក្រោមក្រសែភ្នែកនៃនីតិវិធីរបស់អង្គការសហប្រជាជាតិ? តើជីវិតមនុស្សម្នាក់មានតម្លៃប៉ុនណាបើប្រៀបធៀបទៅនឹងការគោរពចំពោះរដ្ឋនានាថ្វីបើរដ្ឋទាំងអស់នោះប្រមាថមាក់ងាយចំពោះគោលការណ៍ជាមូលដ្ឋានគ្រឹះបំផុតនៃលទ្ធិប្រជាធិបតេយ្យនិងការគោរពសិទ្ធិមនុស្សក៏ដោយ?

របាយការណ៍កសិណសាក្សីទាំងអស់ និងគោលជំហរនានាដែលរដ្ឋទាំងឡាយប្រកាន់យកចំពោះការរំលោភសិទ្ធិមនុស្សនៅកម្ពុជា ត្រូវបានបដិសេធតាមរយៈសារទូរលេខមួយច្បាប់ផ្ញើមកពីក្រុងភ្នំពេញនៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៨ ដោយរដ្ឋមន្ត្រីការបរទេសក្រោម ប៉ុល ពត គឺ អៀង សារី ដែលប្រកាសថាៈ «យើងខ្ញុំបដិសេធចំពោះសេចក្តីសម្រេចរបស់អនុគណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ដែលធ្វើការជ្រៀតជ្រែកដោយឥតអៀនខ្មាស់ក្នុងកិច្ចការផ្ទៃក្នុងរបស់របបកម្ពុជាប្រជាធិបតេយ្យ...[២៦]» ។

ដោយសារមានការជ្រៀតជ្រែកមែន ដូច្នេះអ្វីក្រៅពីនេះពុំមានសារៈសំខាន់ធំដុំទេ ។ ទស្សនៈគឺមានឥទ្ធិពលខ្លាំងជាងអង្គហេតុ ។ គ្រាន់តែចោទថា «ជ្រៀតជ្រែកនៅក្នុងកិច្ចការផ្ទៃក្នុង» អាចលុបបំបាត់បទឧក្រិដ្ឋរាប់លានករណីអាចទុកជាមោឃៈនូវសេចក្តីអះអាងរបស់សាក្សីនានា ហើយវាក៏អាចបដិសេធការផ្តល់នូវមតិយោបល់លើដីកាណាមួយទៀតផង ។ រាល់ការចោទប្រកាន់ទោសទាំងអស់គឺចាត់ទុកជាមោឃៈ និងគ្មានសុពលភាពតាមផ្លូវច្បាប់ ។ ការជជែកចរចាគ្នាត្រូវបានបញ្ចប់ ។ សព្វថ្ងៃនេះពិភពលោកដឹងថាអំណះអំណាងជាកសិណសាក្សីដែលប្រមូលបានរវាងឆ្នាំ១៩៧៥ និង១៩៧៩ ស្តីអំពីអំពើព្រៃផ្សៃរបស់ពួកបរិវារ ប៉ុល ពត គឺមានស្ថានភាពពិតដូចបានរៀបរាប់ខាងលើដូច្នោះមែន ។ មិនត្រឹមតែប៉ុណ្ណោះ បន្ថែមពីលើចំនួនមនុស្សដែលបានឃើញព្រឹត្តិការណ៍ជាក់ស្តែងដោយផ្ទាល់ភ្នែកផង របាយការណ៍កសិណសាក្សីទាំងអស់នោះមានចំនួនគ្រប់គ្រាន់ណាស់ទៅហើយក្នុងឆ្នាំ១៩៧៨ អាចធ្វើឲ្យគេសន្និដ្ឋានយ៉ាងសមហេតុផលថា ទង្វើរបស់ពួកខ្មែរក្រហមគឺមានលក្ខណៈដូចគ្នាទៅនឹងសម័យកាលរបស់ពួកណាស៊ី ។ តែទោះជាដូច្នេះក្តី កសិណសាក្សីទាំងនេះនៅតែពុំគ្រប់គ្រាន់នៅឡើយក្នុងការជំរុញឲ្យប្រទេសដែលកាន់លទ្ធិប្រជាធិបតេយ្យចេញជាសកម្មភាពឆ្លើយតបចំពោះបញ្ហានេះ ។ នៅកម្ពុជាឯណោះវិញប្រជាជនខ្មែរមួយចំនួនបានរត់ភៀសខ្លួនចេញពីប្រទេស ហើយបាននិយាយប្រាប់ឲ្យគេឯងបានដឹងអំពីរឿងរ៉ាវដ៏គួរឲ្យភ័យខ្លាចនិងវេទនារបស់ខ្លួន ប្រជាជនជាច្រើនទៀតបាននិងកំពុងរង់ចាំឲ្យមានជាសកម្មភាពឬវិធានការពីសំណាក់មជ្ឈដ្ឋានអន្តរជាតិ[២៧] ។ តែអន្តរជាតិពុំបានមកជួយទេ ។ ពេលនោះការស្រោចស្រង់ប្រជាពលរដ្ឋកម្ពុជាឲ្យរួចផុតពីអំពើឃោរឃៅរបស់ពួកខ្មែរក្រហមដោយអ្នករំដោះជាតិដែលមិនយូរប៉ុន្មានក្រោយមកក្លាយទៅជាអ្នកគ្រប់គ្រងទឹកដី គឺជាការចាំបាច់ណាស់ ។ តើក្រុមប្រទេសប្រជាធិបតេយ្យរបស់លោកខាងលិចបានបន្សល់ទុកនូវជម្រើសបែបណាដល់ប្រជាពលរដ្ឋកម្ពុជា ដែលមានបំណងរំដោះប្រទេសជាតិរបស់ខ្លួនចេញពីរាល់អំពើនិងទ្រឹស្តីបែបណាហ្ស៊ីនិយមរបស់ខ្មែរក្រហមនាពេលនោះ?

## ៤- ការរៀបចំសេរីភាពជាអន្តរជាតិ

ករណីប្រទេសកម្ពុជាគឺជាឧទាហរណ៍ **(តទៅទំព័រទី៤០)**

***(តពីលេខមុន)*** ឥទ្ធិពលនៃមហន្តរាយក្រោមរបបខ្មែរក្រហមមកលើប្រជាជនកម្ពុជាដែលបានឃ្លាតឆ្ងាយពីប្រទេស ហើយដែលត្រឡប់មកវិញ មានទំហំធំធេងហួសពីការស្មានទៅទៀត ។ ជាឧទាហរណ៍លោក ជ័យ សោភ័ណ ដែលជាជនកុម្មុយនិស្តកម្ពុជាអាយុ៤៧ឆ្នាំ ធ្លាប់បានប្រយុទ្ធក្នុងសង្គ្រាមតស៊ូប្រឆាំងនឹងអាណានិគមនិយមបារាំងក្នុងអំឡុងទសវត្សរ៍ឆ្នាំ៥០ ។ សោភ័ណ បានរស់នៅក្នុងប្រទេសវៀតណាមតាំងពីឆ្នាំ១៩៥៥ ហើយបានទទួលការបណ្តុះបណ្តាលជាអ្នកកាសែតមួយរូប ។ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ សោភ័ណ រីករាយឥតឧបមាដែលបានវិលត្រឡប់មកស្រុកកំណើតរបស់គាត់វិញជាមួយកងទ័ពវៀតណាម ។ ក៏ប៉ុន្តែ គាត់មានការតក់ស្លុតស្ទើរគាំងបេះដូងដោយសារអ្វីដែលគាត់បានប្រទះឃើញ ដែលប៉ុន្មានឆ្នាំក្រោយមក សោភ័ណ បានរំឭកឡើងវិញថា គាត់«ឈរស្រក់ទឹកភ្នែកពេញមួយរសៀល» ។



**សម្លេងពីមន្ទីរ ស-២១**
**វគ្គទី១: ការរកឃើញមន្ទីរ ស-២១**
**ដោយសាស្ត្រាចារ្យ ដេវីដ ឆេនដល័រ**

ប៉ុន្មានថ្ងៃបន្ទាប់មក កងទ័ពវៀតណាមបានបោះពួយឆ្លងកាត់ក្រុងភ្នំពេញ ។ ថ្ងៃទី៨ ខែមករា នៅផ្នែកខាងត្បូងនៃទួលស្វាយព្រៃ អ្នកថតរូបផ្នែកកាសែតជាជនជាតិវៀតណាម២រូបបានរួមដំណើរការលុកលុយនេះ ត្រូវបានដឹកសំដៅទៅបរិវេណពិសេសមួយ ដែលនៅធុំក្លិនអសោចពីសាកសពដែលកំពុងហើមរលេះរលួយ ។ ទីកន្លែងដីស្ងាត់ជ្រងំនិងពោរពេញដោយក្លិនស្អុយ ត្រូវបានហ៊ុមព័ទ្ធដោយរបងស័ង្កសីបន្ថុបពីលើដោយលួសបន្លាព័ទ្ធជារាងស្ទើរយ៉ាងចាក់ស្រេះ ។ នៅនឹងរបងទ្វារចូលមានព្យួរបដាពណ៌ក្រហមមួយដែលសរសេរដោយអក្សរពណ៌លឿងជាពាក្យស្លោកភាសាខ្មែរថា «ពង្រឹងស្មារតីបដិវត្តន៍ ត្រូវការពារខ្លួនរបស់យើងប្រឆាំងនឹងយុទ្ធសាស្ត្រនិងល្បិចកលរបស់សត្រូវ ដើម្បីការពារប្រទេស ប្រជាជន និងបក្ស» ។ កន្លែងនេះពុំមានអត្តសញ្ញាណកម្មអ្វីផ្សេងក្រៅពីនេះទេ ។

នៅពេលជ្រៀតចូលទៅក្នុងបរិវេណនេះ អ្នកថតរូបជនជាតិវៀតណាមទាំងពីររូបនេះបានចាប់ភ្លឹកដឹងថា ទីធ្លានេះជាបរិវេណដែលស្តែងឲ្យឃើញថាជាទីធ្លារបស់អតីតសាលាវិទ្យាល័យដ៏ធំទូលាយ និងចាស់ទ្រុឌទ្រោម មានទំហំប្រវែង៤០០ម៉ែត្រពីខាងកើតទៅខាងលិច និង៦០០ម៉ែត្រពីខាងជើងទៅខាងត្បូង ។ បរិវេណគុកទួលស្លែងរួមមានអគារថ្មចំនួន៤ដែលដុសលាងយ៉ាងស្អាត អគារនីមួយៗមានកម្ពស់៣ជាន់ ដោយមានផ្លូវដើរពីម្ខាងទៅម្ខាងទៀត ។ អគារទី៥ដែលជាអគារសង់ពីឈើមានតែ១ជាន់បែរមុខទៅទិសខាងលិច ពុះចែកបរិវេណនេះទៅជាទីធ្លាវាលស្មៅដូចគ្នាបេះបិទ២ ។ នៅផ្នែកខាងក្រោយនៃទីធ្លា មានអគារមួយខ្ពស់ជាងគេ បែរមុខទៅទិសខាងកើតឆ្ពោះទៅផ្លូវចូលធំ ។ អគារស្រដៀងគ្នានេះ មានទីតាំងនៅខាងចុងបំផុតបញ្ជាក់ពីព្រំដែនខាងជើងនិងខាងត្បូងនៃបរិវេណនេះ ។[៨] គោលបំណងនៃបរិវេណនេះពុំមានភាពច្បាស់លាស់ទេ ចំពោះអ្នកថតរូបកាសែតជនជាតិវៀតណាមទាំង២រូបនេះនាពេលនោះ ទោះបីជាអគារតែ១ជាន់ដែលមានក្រដាសនិងសម្ភារការិយាល័យនៅរាត់រាយ ពិតជាត្រូវបានដឹងថាបានប្រើប្រាស់សម្រាប់ការងាររដ្ឋបាលនៅទីនោះក៏ដោយ ។

នៅតាមបន្ទប់ជាន់ខាងក្រោមនៃអគារដែលនៅចុងខាងត្បូងបំផុត អ្នកថតរូបជនជាតិវៀតណាមបានប្រទះឃើញសាកសពមនុស្សប្រុសមួយចំនួនដែលទើបនឹងត្រូវបានសម្លាប់ថ្មីៗ ។ សាកសពមួយចំនួនជាប់ច្រវាក់ទៅនឹងគ្រែដែក ។ សាកសពទាំង

នោះស្លាប់ដោយអាវុ-ក ។ ឈាមនៅដក់លើកម្រាលឥដ្ឋសើមៗនៅឡើយនាពេលនោះ ។

សរុបទាំងអស់សាកសពចំនួន១៤ដែលត្រូវបានរកឃើញនៅក្នុងបរិវេណនោះ ដែលបញ្ជាក់ថាទើបតែនឹងត្រូវបានសម្លាប់តែពីរ-បីថ្ងៃមុននេះប៉ុណ្ណោះ ។[៩]

នៅបន្ទប់រៀនធំៗនៅជាន់ខាងលើនៃអគារខាងលិចកងទ័ពវៀតណាមដែលដើរល្បាតបានប្រទះឃើញខ្នោះជើង ខ្នោះដៃ រំពាត់ និងខ្សែប្រវាក់ ទាំងគរៗ ។ បន្ទប់ដទៃៗទៀតនៅជាន់ខាងលើ ត្រូវបានបែងចែកដោយជញ្ជាំងខណ្ឌធ្វើអំពីឥដ្ឋប្រហោងរនេងរនូង ទៅជាបន្ទប់តូចៗ ដែលអ្នកទោសត្រូវបានដាក់ខ្នោះជើងភ្ជាប់ទៅនឹងបន្ទប់នេះ ដូចដែលប្រវត្តិវិទូវិល្លៀម សក្រោះ បានសរសេរថា «ខ្នោះដែកដ៏ធំដែលស្ទើរតែធំស្មើនឹងយុថ្កាកប៉ាល់» ។ កេសគ្រាប់មួយចំនួនមានផ្ទុកទៅដោយលាមកមនុស្ស ។[១០] នៅជាន់ទីពាមានបន្ទប់ដែលធំជាងមុនបន្តិច ហើយដែលត្រូវបានសាងសង់ហ្មត់ចត់ជាង ដោយបន្ទប់នីមួយៗមានជញ្ជាំងនិងទ្វារធ្វើអំពីឈើ ។

អ្នកថតរូបវៀតណាមដែលចូលមកក្នុងបរិវេណនេះ បានថតរូបគ្រប់បន្ទប់ទាំងអស់នៅក្នុងគុកនេះ ដោយបន្ថែមរូបថតសាកសពទាំងនោះផង ។ បន្ទាប់មក អ្នកថតរូបវៀតណាមទាំង២ «បានរាយការណ៍ទៅអាជ្ញាធរវៀតណាម» អំពីអ្វីដែលពួកគេទាំង២បានឃើញ ។ នៅល្ងាចថ្ងៃដដែលនោះ សាកសពទាំងអស់ត្រូវបានដុត «ដើម្បីធ្វើអនាម័យ» នៅទីនោះ ។ រូបថតមួយចំនួនដែលបានថតនៅពេលនោះ ឥឡូវនេះត្រូវបានព្យួរនៅក្នុងបន្ទប់ដែលសាកសពត្រូវបានប្រទះឃើញពីដំបូង ។

ប្រមាណពីរ-បីថ្ងៃបន្ទាប់មក អាជ្ញាធរវៀតណាមនិងជំនួយការជាជនជាតិកម្ពុជា បានរកឃើញនៅតាមបណ្តាផ្ទះដែលនៅក្បែរនោះ នូវឯកសាររាប់ពាន់សន្លឹកជាភាសាខ្មែររូបថតដែលថតភ្លាមចេញភ្លាមរាប់ពាន់សន្លឹក ហ្វីលមិនទាន់ផ្តិតរាប់ពាន់ សៀវភៅកំណត់ហេតុរបស់កម្មាភិបាលខ្មែរក្រហមរាប់រយ និងឯកសារបោះពុម្ពផ្សាយរួចរបស់របបកម្ពុជាប្រជាធិបតេយ្យ ទាំងគំនរៗ ។ នៅរោងជាងមួយក្បែរទ្វារចូល ពួកគេបានប្រទះឃើញរូបសំណាកពីក្បាលដល់ត្រឹមស្មាធ្វើពីស៊ីម៉ង់ត៍ដែលមានទំហំធំជាងរូបពិតរបស់នាយករដ្ឋមន្ត្រីរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុល ពត ដែលជារូបសំណាកមួយកំណាត់ខ្លួនរបស់ប៉ុល ពត ដែលទំនងជាឆ្លាក់ចម្លងចេញពីរូបថតមកវិញ ។

ទ័ពវៀតណាមបានប្រទះដោយភាពចៃដន្យនូវអគាររបស់ខ្មែរក្រហមដ៏សាហាវឃោរឃៅ និងមានសារៈសំខាន់នេះ ។ ឯកសារដែលប្រទះឃើញនៅទីកន្លែងនេះបានបង្ហាញយ៉ាងឆាប់ដែរថា បរិវេណសាលានេះត្រូវបានចាត់តាំងបង្កើតក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ដោយប្រើឈ្មោះហៅកាត់ថាជាស-២១ ។ អក្សរ «ស» ទំនងជាជំនួសឲ្យសាលា រីឯលេខ «២១» គឺជាលេខកូដសម្រាប់សន្តិបាល ជាពាក្យខ្មែរដែលបានមកពីការបញ្ចូលគ្នារវាងពាក្យ២គឺ សន្តិសុខ និង នគរបាល (ប៉ូលិស) ។ «ស-២១» ឬ «សន្តិបាល» គឺជាឈ្មោះសម្រាប់នគរបាលសន្តិសុខរបស់របបកម្ពុជាប្រជាធិបតេយ្យ ឬផ្នែកពិសេស ។

ប្រមាណពីរ-បីសប្តាហ៍ក្រោយមក ប្រវត្តិនៃមជ្ឈមណ្ឌលឧក្រិដ្ឋកម្មនេះត្រូវបានផ្គុំបញ្ចូលគ្នា ។ នៅដើមទសវត្សរ៍ឆ្នាំ៦០ នៅពេលដែលប្រទេសកម្ពុជាត្រូវបានដឹកនាំដោយព្រះបាទនរោត្តម សីហនុ ទីនេះគឺជាវិទ្យាល័យមួយ ។ សាលានេះត្រូវបានដាក់ឈ្មោះថា ពញាយ៉ាត ជារឿងនិទានដំណាលបន្តមកថាជាស្តេចខ្មែរមួយអង្គដែលជាប់ពាក់ព័ន្ធជាមួយនឹងការបង្កើតក្រុងភ្នំពេញ ។[១២] បន្ទាប់ពីទ្រង់ សីហនុ ត្រូវបានផ្តួលរំលំពីអំណាចនៅឆ្នាំ១៩៧០ ដែលជាព្រឹត្តិការណ៍មួយជាផ្កាភ្លើងបញ្ឆេះសង្គ្រាមស៊ីវិលនៅក្នុងប្រទេសកម្ពុជា សាលានេះគឺជាសាលាដែលត្រូវបានយកឈ្មោះតាមស្រុកមួយដែលនៅក្បែរនោះ គឺទួលស្វាយព្រៃ ។ សាលាបឋមសិក្សាដែលនៅជាប់គ្នានេះហៅថាទួលស្វែង ។ ឈ្មោះនេះត្រូវបានប្រើប្រាស់ដើម្បីដាក់ឈ្មោះឲ្យទីធ្លាទាំងមូលនៅឆ្នាំ១៩៨០ បន្ទាប់ពីទីនេះក្លាយទៅជាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ប្រហែលជាពីព្រោះដើមស្វែងមានផ្លែពុល ។[១៣]

**(នៅមានត)**

[៨]-[១៣] ឯកសារយោងពុំត្រូវបានបកប្រែទេ ។

(តមកពីទំព័រទី៣៧) គំរូមួយ ។ ច្បាប់អន្តរជាតិដែលបានបង្កើតឡើងតាំងពីឆ្នាំ១៩៤៥ និងប្រតិបត្តិដោយអង្គការសហប្រជាជាតិទាំងមូល គឺប្រើប្រាស់ដើម្បីការពាររដ្ឋនានា និងរបបទាំងឡាយដែលគ្រប់គ្រងអំណាចក្នុងប្រទេស ។ ច្បាប់អន្តរជាតិពុំបានការពារបុគ្គល ក្រុមមនុស្ស ឬប្រជាពលរដ្ឋប្រទេសណាមួយទេ ។ មកទល់សព្វថ្ងៃនេះ ប្រហែលជាមានអនុសញ្ញាអន្តរជាតិចំនួន៧០ ដែលទាក់ទងនឹងសិទ្ធិមនុស្ស ត្រូវបានអនុម័តឡើង ។ នៅពេលដែលពួកខ្មែរក្រហមកាន់កាប់ប្រទេសកម្ពុជា ឧបករណ៍ច្បាប់អន្តរជាតិបែបនេះចំនួនប្រមាណ៥០ បានចូលជាធរមានស្រេចទៅហើយ ។ ប៉ុន្តែខ្លឹមសារដ៏ប្រពៃនៃច្បាប់អន្តរជាតិទាំងនោះបានស្តែងឲ្យឃើញថា ពុំមានប្រយោជន៍អ្វីជាសំខាន់បន្តិចសោះដល់ជីវិតប្រជាជនកម្ពុជាចំនួន២ ឬ៣លាននាក់ ដែលជាជនរងគ្រោះនៃរបបមួយដែលទទួលស្គាល់ដោយច្បាប់អន្តរជាតិថាម្ចាស់ផ្តាច់មុខស្របច្បាប់ លើប្រទេសនិងមនុស្សដែលរស់នៅក្នុងប្រទេសនេះ ។ សេចក្តីថ្លៃធ្នូទទួលស្គាល់របបដ៏សាហាវនោះចោទជាសំណួរដែលស្ថិតនៅជាការពិតមួយដ៏ឃោរឃៅ ទោះនៅក្នុងប្រទេសកម្ពុជាក៏ដូចជានៅក្នុងប្រទេសផ្សេងៗទៀតដែរថាតើត្រូវមានការការពារជាអន្តរជាតិបែបណាចំពោះប្រជាពលរដ្ឋ? ប្រព័ន្ធដែលបង្កើតឡើងដោយអង្គការសហប្រជាជាតិធ្វើព្រងើយកន្តើយចំពោះបញ្ហាជាក់ស្តែងបីគឺៈ ១-គោលការណ៍ប្រជាធិបតេយ្យត្រូវបានអនុវត្តតែក្នុងប្រទេសមួយចំនួនតូចប៉ុណ្ណោះ ។ ២-ការគោរពមនុស្សម្នាក់ថាជាបុគ្គលមួយរូប ឬជាសមាជិកក្រុមសង្គមមួយគឺភាគច្រើនមិនត្រូវបានអើពើ និង ៣-សូម្បីតែប្រទេសប្រជាធិបតេយ្យនៅក្រោមច្បាប់សណ្តាប់ធ្នាប់អន្តរជាតិក៏អាចធ្វើជាយានសម្រាប់អំពើនិងអនុវត្តទ្រឹស្តីយង់ឃ្នងផងដែរ ។ ចំពោះអ្នកដែលមមើមមាយយល់ខុសអំពីការរីកលូតលាស់នាពេលថ្មីៗនៃលទ្ធិប្រជាធិបតេយ្យ ការអានរបាយការណ៍ចុងក្រោយបង្អស់របស់អង្គការលើកលែងទោសអន្តរជាតិនឹងធ្វើឲ្យពួកគេអាចវិលត្រឡប់ទៅរកការពិតវិញបាន ។

ការការពាររដ្ឋនានាគឺវិលត្រឡប់ថយក្រោយទៅការពារក្របខ័ណ្ឌស្ថាប័នមួយ ដែលនៅក្នុងក្របខ័ណ្ឌនោះអ្វីៗគ្រប់យ៉ាងគឺសុទ្ធតែអាចអនុញ្ញាតឲ្យធ្វើបាន ។ វាគឺជាការពង្រឹងប្រទេសមួយជ្រុងតូចនៅក្នុងសកលលោក ដោយពុំបានយកមកពិចារណានូវសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការជ្រើសរើសដោយសេរីនូវរបបនយោបាយដែលខ្លួនពេញចិត្ត ។

តើត្រូវធ្វើការបង្រួបបង្រួមអធិបតេយ្យភាពជាតិនិងការសម្រេចចិត្តដោយសេរីរបស់ប្រជាពលរដ្ឋទាំងឡាយដោយរបៀបណា ដោយសារថាអ្នកគ្រប់គ្រងរដ្ឋអធិបតេយ្យភាពទាំងនោះពុំបានឬលែងបានផុសចេញមកពីឆន្ទៈដោយសេរីរបស់ប្រជាជនទេនោះ?

តើត្រូវធ្វើយ៉ាងណាដើម្បីធានាឲ្យបាននូវសមភាពរបស់រដ្ឋនានា និងដើម្បីការពាររដ្ឋទាំងអស់នោះឲ្យរួចផុតពីការធ្វើអន្តរាគមន៍គ្រប់រូបភាពទាំងអស់ដោយប្រទេសដទៃ ដោយទន្ទឹមនឹងពេលនោះត្រូវរក្សាការការពារនេះ កុំឲ្យផ្តល់សិទ្ធិស្របច្បាប់ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ?

វាជាការបន្ទាន់មួយហើយដែលជនរងគ្រោះកម្ពុជារាប់លាននាក់ក្នុងគ្រោះមហន្តរាយនៃរបបខ្មែរក្រហម បាននាំគ្នាស្រែកដង្ហោយចង់បានជាមួយប្រជាជាតិជាច្រើនទៀត ក្នុងការផ្តលរំលំលំដាប់ថ្នាក់នៃការឲ្យតម្លៃទាំងនេះ ។ មុនពេលមានច្បាប់របស់រដ្ឋនីមួយៗត្រូវមានច្បាប់មនុស្សជាតិ ។ ច្បាប់មនុស្សជាតិត្រូវនាំមុខច្បាប់របស់រដ្ឋ ។ វាជាការបន្ទាន់ណាស់ក្នុងការដាក់វិស័យសិទ្ធិមនុស្សឲ្យចេញផុតពីដែនសមត្ថកិច្ចរបស់រដ្ឋ ។

ជោគវាសនារបស់មនុស្សជាតិគឺមិនមែនជាកិច្ចការផ្ទៃក្នុងរបស់ប្រទេសណាមួយទេ ហើយវាក៏មិនមែនជាបញ្ហាដែនសមត្ថកិច្ចជាតិណាមួយដែរ ។ ជាខ្លឹមសារ វាជាបញ្ហាអន្តរជាតិដែលមិនអាចត្រូវមានការបកស្រាយច្រើនបែបច្រើនយ៉ាងខុសគ្នាបានទេ ។ តើសេចក្តីប្រកាសស្តីអំពីបញ្ហាសិទ្ធិមនុស្សនោះមិនមែនជា«សកល»ទេឬ? សិទ្ធិសេរីភាពជាមូលដ្ឋានគ្រឹះគឺមិនអាចធ្វើការបែងចែកបានឡើយ ។

អាស្រ័យហេតុនេះ ការរៀបចំឲ្យមានចំណងសាមគ្គីភាពជាអន្តរជាតិនៅក្នុងចំណោមមនុស្សទាំងស្រីទាំងប្រុសដែលមានសិទ្ធិសេរីភាព គឺជាប្រការមួយដែលត្រូវធ្វើជាបន្ទាន់ ។

**វ៉ាអ៊ូល វ៉ៃន័រ**

(១-២៧) មានឯកសារយោង ប៉ុន្តែពុំត្រូវបានដាក់ទេ ។

# គ្រោះថ្នាក់នៃអព្យាក្រឹតភាព

## ការបែកបាក់ទំនាក់ទំនងរវាងកម្ពុជានិងសហរដ្ឋអាមេរិកឆ្នាំ១៩៦៥

**(តពីលេខមុន)** *ទំនាក់ទំនងរវាងសហរដ្ឋអាមេរិកនិងកម្ពុជាពុំធ្លាប់ដែលល្អូកល្អិននឹងគ្នាឡើយ ។ ជានិច្ចកាល ទំនាក់ទំនងនេះតម្រូវឲ្យមានការពុះពារលើមធ្យោបាយការទូតដ៏ខ្លាំងក្លានិងស្រួចស្រាល់ដើម្បីរក្សាទំនាក់ទំនងនេះឲ្យស្ថិតក្នុងជំហរជាមិត្តភាព ។ ចាប់តាំងពីប្រទេសកម្ពុជាទទួលបានឯករាជ្យពីបារាំងក្នុងឆ្នាំ១៩៥៣-៥៤មក ទ្រង់ សីហនុ បានព្យាយាមដើរតាមផ្លូវអព្យាក្រឹតអន្តរជាតិដាច់ខាត ។ នៅពេលសង្គ្រាមត្រជាក់ឈានដល់ចំណុចកំពូល សហរដ្ឋអាមេរិកសម្លឹងមើលប្រទេសដែលពុំមានសុឆន្ទៈចងសម្ព័ន្ធជាមួយប្រទេសលោកខាងលិចដោយក្រសែភ្នែកមិនទុកចិត្ត ។ ក៏ប៉ុន្តែ ប្រវត្តិវិទូ ប្រែនស៍* H.W. Brands *បានបកស្រាយថា នយោបាយរបស់អាមេរិកចំពោះប្រទេសអព្យាក្រឹតអាចពុំមានមនោគមន៍វិជ្ជាដែលជាការគួរឲ្យកត់សម្គាល់ប្លែក ទោះបីជាការវាយប្រហាររិះគន់ដ៏ក្តៅគគុកដែលផុសចេញពីមន្ត្រីជាន់ខ្ពស់នៅវ៉ាស៊ីនតោនយ៉ាងណាក៏ដោយ ។ ទោះបីជាកម្ពុជាពុំនៅក្នុងចំណោមប្រទេសដែលត្រូវបានរាប់បញ្ចូលទៅក្នុងការសិក្សារបស់ប្រវត្តិវិទូ ប្រែនស៍ក៏ដោយ ផ្លូវដើររបស់អាមេរិកចំពោះកម្ពុជានៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ៥០ និង៦០ គឺក្នុងទិដ្ឋភាពមួយចំនួនអាចប្រែប្រួលបត់បែនបានខុសពីធម្មតា ។ សរុបទៅ អព្យាក្រឹតភាពរបស់កម្ពុជាគឺជាអ្វីដែលកម្ពុជាប្រាថ្នាចង់បាន ក្នុងកាលៈទេសៈដែលប្រទេសនេះចងសម្ព័ន្ធមិត្តជាមួយវៀតណាមខាងជើង និងចិន«ក្រហម» ។ មន្ត្រីជនជាតិអាមេរិកាំងមួយចំនួន បានចាត់ទុកការថែរក្សាឯករាជ្យភាពរបស់កម្ពុជា បន្ថែមពីនេះគឺឯករាជ្យភាពអព្យាក្រឹតរបស់កម្ពុជា ថាមានសារៈសំខាន់ជាអាយុជីវិតទាំងស្រុងចំពោះការសង្គ្រោះអាស៊ីភាគអគ្នេយ៍ទាំងមូល ។ មន្ត្រីម្នាក់បានអត្ថាធិប្បាយថា ប្រទេសកម្ពុជាគឺជា «ដុំកង់នៅក្នុងបញ្ហាអាស៊ី-អគ្នេយ៍» ហើយលើសពីនេះ ពេញមួយទសវត្សរ៍ឆ្នាំ៥០ សហរដ្ឋអាមេរិកបានផ្តល់ជំនួយសេដ្ឋកិច្ចដល់កម្ពុជា ។ ឧទាហរណ៍ដ៏គ្រប់គ្រាន់នោះគឺមហាវិថីមិត្តភាពខ្មែរ-អាមេរិក ដែលភ្ជាប់ក្រុងភ្នំពេញជាមួយនឹងកំពង់ផែក្រុងកំពង់សោម ដែលទើបតែនឹងសង់ថ្មីសន្លាង ។ ផ្លូវនេះបានសាងសង់ចប់ជាស្ថាពរនៅឆ្នាំ១៩៥៩ ផ្លូវនេះអំណោយផលឲ្យកម្ពុជាអាចនាំចូលទំនិញដោយពុំចាំបាច់ពឹងផ្អែកលើផ្លូវទឹកទន្លេមេគង្គដែលឆ្លងកាត់*



ប្រទេសវៀតណាម ។ សូម្បីតែសព្វថ្ងៃនេះ ប្រជាជនកម្ពុជានៅតែចងចាំមហាវិថីនេះជាឧទាហរណ៍មួយនៃជំនួយអាមេរិកដែលមានលក្ខណៈជួយស្ថាបនា ។

មិនតែប៉ុណ្ណោះ សហរដ្ឋអាមេរិកបានបញ្ចេញសាច់ដុំកំញើញដាក់ស្ពានរំលងក្បាលបារាំង ហើយបានចាប់ផ្តើមផ្តល់នូវសព្វាវុធហើយនិងឧបករណ៍សម្ភារយោធាដទៃទៀតដល់កម្ពុជា ។ នៅត្រឹមដើមទសវត្សរ៍ឆ្នាំ៦០ សហរដ្ឋអាមេរិកបានជួយចេញថវិកា៣០ភាគរយនៃគម្រោងថវិកាយោធារបស់ប្រទេសកម្ពុជាទាំងមូល ហើយផ្តល់នូវសព្វាវុធនិងសម្ភារដ៏ច្រើនសន្ធឹកសន្ធាប់ដល់កម្ពុជា ។ អ្វីដែលគួរឲ្យកត់សម្គាល់ជាងនេះទៀតនោះ គឺសហរដ្ឋអាមេរិកបានដាក់ក្រុមទីប្រឹក្សាជំនួយយោធាមួយដែលជាភាសាអង់គ្លេសហៅថា “Military Assistance Advisory Group” ប្រចាំនៅកម្ពុជា ដែលពេលនោះតាំងខ្លួនជាប្រទេសអព្យាក្រឹតតែមួយគត់នៅក្នុងពិភពលោក ដែលអាចធ្វើដូច្នេះបាន ។

ក៏ប៉ុន្តែ ទោះបីជាសហរដ្ឋអាមេរិកបានផ្តល់ជំនួយយោធានិងសេដ្ឋកិច្ចដល់កម្ពុជាក៏ដោយ ការមិនចូលចិត្តរបស់អាមេរិកចំពោះនយោបាយការបរទេសរបស់ទ្រង់ សីហនុ កាន់តែកើនឡើងជាលំដាប់ ហើយមិនតែប៉ុណ្ណោះ អាមេរិកប្រើប្រាស់វិធីទប់ទល់នឹងនយោបាយបរទេសរបស់ទ្រង់ សីហនុ ទៀតផង ។ ការខ្វល់ខ្វាយដ៏ចម្បងរបស់ទ្រង់ សីហនុ (ក៏ដូចជ្រាលជ្រៅចំពោះប្រទេស ជិតខាងដែលមានប្រជាជនច្រើន ហើយមានអំណាចខ្លាំងជាងកម្ពុជា គឺប្រទេសថៃនិងវៀតណាម ។ ទោះបីជាភាពស្អប់ខ្ពើមចំពោះប្រទេសទាំងពីរនេះមានជាយូរមកហើយ ហើយមានឥទ្ធិពលទាក់ទងផ្ទាល់តិចតួចយ៉ាងណាជាមួយនឹងសង្គ្រាមត្រជាក់ក៏ដោយ ក៏ការពិតដែលថាប្រទេសថៃនិងវៀតណាមខាងត្បូងគឺជាសម្ព័ន្ធមិត្តសង្គ្រាមត្រជាក់របស់សហរដ្ឋអាមេរិក ធ្វើឲ្យទំនាក់ទំនងល្អរវាងសហរដ្ឋអាមេិកនិងកម្ពុជាមានការលំបាកក្នុងការថែរក្សា ។ ទ្រង់ សីហនុ ពេលនោះមានការសង្ស័យចំពោះចេតនារបស់អាមេរិក ដោយជឿថាសហរដ្ឋអាមេរិកបានគាំទ្រនិងរហូតដល់ជំរុញឲ្យថៃនិងវៀតណាមទន្ទ្រានចូលក្នុងមាតុភូមិរបស់ទ្រង់ ហើយមិនតែប៉ុណ្ណោះមានការប្រណែនត្រង់ថា ជំនួយរបស់អាមេរិកទៅប្រទេសជិតខាងមានចំនួនច្រើនជាងជំនួយដែលផ្តល់ឲ្យកម្ពុជា ។ អ្វីដែលជាគ្រោះមហន្តរាយជាពិសេសចំពោះទំនាក់ទំនងសហរដ្ឋអាមេរិកនិងកម្ពុជាគឺ ទ្រង់ សីហនុ មានជំនឿដល់កម្រិតស្ទើរតែច្បាស់ក្រឡែតថា សហរដ្ឋអាមេរិក (ហើយជាពិសេសភ្នាក់ងារស៊ី-អាយ-អេអាមេរិក) កំពុងតែគាំទ្រក្រុមកម្ពុជាដែលប្រឆាំងនឹងទ្រង់ សីហនុ គឺចលនាខ្មែរសេរីដែលដឹកនាំដោយ សឺង ង៉ុកថាញ់ អ្នកស្នេហាជាតិកម្ពុជានិងអតីតមន្ត្រីមួយរូបដែលធ្វើសកម្មភាពចេញពីមូលដ្ឋាននានានៅវៀតណាមនិងថៃ ។

ព្រះរាជតម្រិះរបស់ទ្រង់ សីហនុ នាពេលនោះពុំមែនជាការស្រមើស្រមៃទាំងស្រុងនោះទេ ។ ជាពិសេសបន្ទាប់ពីទ្រង់ សីហនុ ទទួលស្គាល់សាធារណរដ្ឋប្រជាមានិតចិន ហើយសុំជំនួយពីបណ្តាប្រទេសដែលនៅក្នុងប្លុកសូវៀត សហរដ្ឋអាមេរិកផ្តល់ជំនួយជាសម្ងាត់ដល់វៀតណាមខាងត្បូង និងកិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសថៃ ដើម្បីបំផ្លិចបំផ្លាញរដ្ឋាភិបាលរបស់ទ្រង់ ។ ក្នុងឆ្នាំ១៩៥៨ សហរដ្ឋអាមេរិកមានការជាប់ពាក់ព័ន្ធដោយផ្ទាល់ក្នុងគម្រោងធ្វើរដ្ឋប្រហារដែលពុំបានសម្រេចផ្តួលរំលំទ្រង់ សីហនុ ។ មន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក បានសរសេរប្រមាណ២-៣ខែបន្ទាប់ពីព្រឹត្តិការណ៍នេះថា «សារៈសំខាន់នៃការវិវត្តន៍ក្នុងការធ្វើឲ្យទំនុកចិត្តរបស់កម្ពុជាចំពោះមូលហេតុរបស់សហរដ្ឋអាមេរិក មិនអាចយកមកធ្វើការចាប់អារម្មណ៍ខ្លាំងជ្រុលពេកទេ» ។ ទំនាក់ទំនងក្នុងឆ្នាំ១៩៥៩នោះគានតឹងជាទីបំផុត រហូតទាល់តែមន្ត្រីអាមេរិកនៅក្រុងភ្នំពេញប្រើពាក្យរៀបរាប់ថាជា «ឆ្នាំពោរពេញដោយបញ្ហា» ។

បន្ទាប់ពីពេលនោះមក ពីព្រោះតែទ្រង់ សីហនុ មានប្រជាប្រិយភាពដ៏មហិមានៅក្នុងប្រទេសកម្ពុជា យោធាក៏មានភក្តីភាពជាមួយទ្រង់ ហើយទ្រង់កំពុងតែបង្ក្រាបចលនាកុម្មុយនិស្តនិងពួកឆ្វេងនិយមដទៃទៀតនៅក្នុងស្រុកផងនោះ ក្រសួងការបរទេសអាមេរិកបានប្តេជ្ញាចិត្តថា សកម្មភាពប្រឆាំង សីហនុ គឺពុំទទួលផលជាវិជ្ជមាន ប៉ុន្តែផ្ទុយទៅវិញជះឥទ្ធិពលអាក្រក់ត្រឡប់មកលើខ្លួនវិញ ។

**(នៅមានត)** **វ៉ៃយនគុន វ៉ក្លែមម័រ**

# ចំណាត់ប្រភេទឧក្រិដ្ឋកម្មនៃបក្សកុម្មុយនិស្តកម្ពុជាៈ គោលការណ៍ "គ្មានច្បាប់ គ្មានឧក្រិដ្ឋកម្ម" និងនិយមន័យច្បាប់នៃអំពើប្រល័យពូជសាសន៍

ចន្លោះឆ្នាំ១៩៧៥ និង ១៩៧៩ បក្សកុម្មុយនិស្តកម្ពុជាបានអនុវត្តអ្វីដែលជាទូទៅត្រូវបានហៅថារបប«ប្រល័យពូជសាសន៍»។ ជាលទ្ធផល អ្នកសង្កេតតាមដានជាច្រើនអាចពុំមានការពេញចិត្តប្រសិនបើតុលាការឬអង្គជំនុំជម្រះក្តីព្រហ្មទណ្ឌមួយបានរកឃើញថា អតីតមន្ត្រីបក្សកុម្មុយនិស្តមានទោសកំហុសចំពោះបទឧក្រិដ្ឋអ្វីមួយដែលស្រាលជាង«បទឧក្រិដ្ឋប្រល័យពូជសាសន៍»។ ទោះបីជាយ៉ាងណាក៏ដោយ និយមន័យឧក្រិដ្ឋកម្មប្រល័យពូជសាសន៍តាមផ្លូវច្បាប់ ដូចដែលនិយមន័យនេះអាចយកទៅអនុវត្តចំពោះព្រឹត្តិការណ៍ដែលបានកើតឡើងនៅក្នុងអំឡុងរបបដឹកនាំរបស់កម្ពុជាប្រជាធិបតេយ្យ គឺមានទំហំតូចចង្អៀតជាងអត្ថន័យទូទៅនៃពាក្យនេះ។ អត្ថបទនេះយកមកពិចារណានូវច្បាប់ស្តីអំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងគោលការណ៍«គ្មានច្បាប់ គ្មានឧក្រិដ្ឋកម្ម» ដែលចេញពីភាសាឡាតាំង Nullem crimen sine lege ដោយប៉ុនប៉ងវែកញែកឲ្យជ្រះស្រឡះអំពីបញ្ហាច្បាប់មួយចំនួនដែលទាក់ទងនឹងការជំនុំជម្រះក្តីដែលនឹងកើតឡើងនាពេលអនាគតខាងមុខនេះ។

## ១-គោលការណ៍គ្មានច្បាប់ គ្មានឧក្រិដ្ឋកម្ម

ការពិភាក្សាផ្នែកច្បាប់អំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ណាក៏ដោយដែលទាក់ទងទៅនឹងមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ តម្រូវឲ្យមានការយល់ដឹងអំពីគោលការណ៍នេះ ដែលត្រូវបានស្គាល់ក្នុងច្បាប់អន្តរជាតិថាជាគោលការណ៍គ្មានច្បាប់គ្មានឧក្រិដ្ឋកម្ម ប្រសិនបើគេបកប្រែតាមន័យត្រង់ចេញពីភាសាឡាតាំង ពាក្យនេះមានន័យថា «គ្មានឧក្រិដ្ឋកម្មដោយពុំមានច្បាប់»។ គោលការណ៍«គ្មានច្បាប់ គ្មានឧក្រិដ្ឋកម្ម» នេះមានន័យថា បុគ្គលម្នាក់អាចត្រូវបានកាត់ក្តីឲ្យជាប់ពិរុទ្ធអំពីឧក្រិដ្ឋកម្មមួយដែលបានកើតឡើងនៅចំពេលដែលអំពើនោះត្រូវបានប្រព្រឹត្ត ហេតុដូច្នេះគោលការណ៍នេះហាមប្រាមការយកមកអនុវត្តន៍នូវច្បាប់ព្រហ្មទណ្ឌដែលហៅថា«ច្បាប់ប្រតិសកម្ម ឬច្បាប់ដែលកើតឡើងក្រោយពេលដែលអំពើត្រូវបានប្រព្រឹត្ត»។

ប្រព័ន្ធច្បាប់សំខាន់ៗទាំងអស់លើពិភពលោកប្រកាន់ខ្ជាប់ទៅនឹងគោលការណ៍ «គ្មានច្បាប់ គ្មានឧក្រិដ្ឋកម្ម»នេះ ដែលត្រូវបានទទួលស្គាល់ជាសកលដោយអ្នកប្រាជ្ញច្បាប់ថាជាការការពារជាចាំបាច់មួយនូវសិទ្ធិរបស់បុគ្គល។

គោលការណ៍ «គ្មានច្បាប់ គ្មានឧក្រិដ្ឋកម្ម» នេះគឺមានសារៈសំខាន់ណាស់សម្រាប់ការនាំយកមេដឹកនាំខ្មែរក្រហមមកកាត់ទោស ពីព្រោះវាមានន័យថា អតីតមន្ត្រីនៃបក្សកុម្មុយនិស្តកម្ពុជាអាចត្រូវបានរកឃើញថាមានទោសចំពោះបទល្មើសព្រហ្មទណ្ឌនានាដែលបានកើតឡើងនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យប៉ុណ្ណោះ គឺនៅពេលដែលអំពើឃោរឃៅព្រៃផ្សៃរបស់ពួកគេត្រូវបានប្រព្រឹត្ត។ ហេតុដូច្នេះ បរិបទច្បាប់និងនិយមន័យនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មដទៃទៀតដែលត្រូវបានចោទប្រកាន់ដោយពុំមានសំអាងលើមេដឹកនាំខ្មែរក្រហម ត្រូវតែកំណត់យកចេញពីច្បាប់ដែលមានជាធរមាននៅចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

## ២-និយមន័យនៃអំពើប្រល័យពូជសាសន៍

អំពើប្រល័យពូជសាសន៍បានលេចចេញជាបទឧក្រិដ្ឋអន្តរជាតិមួយបន្ទាប់ពីសង្គ្រាមលោកលើកទី២ ដែលត្រូវបានណែនាំឲ្យស្គាល់ជាលើកដំបូងនៅក្នុងធម្មនុញ្ញសម្រាប់ការជំនុំជម្រះក្តីនៅទីក្រុងនូរិមបឺក ហើយត្រូវបានបញ្ជាក់យ៉ាងច្បាស់ក្រឡែតនៅក្នុងអនុសញ្ញាស្តីអំពីអំពើប្រល័យពូជសាសន៍ដែលចូលជាធរមានក្នុងឆ្នាំ១៩៥១។ អនុសញ្ញានេះត្រូវបានផ្តល់សច្ចាប័នយ៉ាងពេញលេញដោយប្រទេសជាងមួយរយ ហើយតម្រូវឲ្យប្រទេសជាហត្ថលេខីទៅនឹងអនុសញ្ញានេះមានកាតព្វកិច្ចហាមឃាត់ ដាក់ទណ្ឌកម្ម និងទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ប្រទេសកម្ពុជាបានក្លាយទៅជាប្រទេសហត្ថលេខីនៃអនុសញ្ញានេះដោយពុំបង្អារ«១»រក្សាទុកចាប់តាំងពីពេលផ្តល់សច្ចាប័នមកម្ល៉េះ

ហេតុដូច្នេះកម្ពុជាត្រូវបានចង់តាមផ្លូវច្បាប់ដោយ«ខ»ទាំងឡាយពីឆ្នាំ ១៩៧៥តមក ។

ទោះបីជាច្បាប់អន្តរជាតិពិតប្រាកដជាបានចងប្រទេសកម្ពុជាតាមផ្លូវច្បាប់ឲ្យដាក់ទោសជនដែលប្រព្រឹត្តអំពើប្រល័យពូជសាសន៍ក្នុងឆ្នាំ១៩៧៥ក៏ដោយ ក៏ភាពបត់បែននៃច្បាប់ចំពោះបទឧក្រិដ្ឋនេះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នៅតែជាប្រធានបទនៃការជជែកដ៏ខ្លាំងក្លាមួយ ។ មាត្រា ២ នៃអនុសញ្ញាស្តីអំពីអំពើប្រល័យពូជសាសន៍បានចែងអំពីនិយមន័យ«ជាទំនៀមទម្លាប់» នៃបទល្មើសប្រល័យពូជសាសន៍តែមិនទូលំទូលាយថា÷

ក្នុងអនុសញ្ញាស្តីអំពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មានន័យថា អំពើណាមួយក្នុងចំណោមអំពើខាងក្រោមនេះដែលត្រូវបានប្រព្រឹត្តដោយមានចេតនាបំផ្លិចបំផ្លាញទាំងស្រុង ឬដោយផ្នែក នូវក្រុមជនជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាបែបនេះ÷

ក-ការសម្លាប់សមាជិកទាំងឡាយនៅក្នុងក្រុមជនជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា ។

ខ-បង្កការឈឺចាប់ និងខូចខាតជាដំណាំខាងផ្នែករាងកាយ ឬផ្នែកសតិបញ្ញា ដល់សមាជិកទាំងឡាយនៅក្នុងក្រុម ។

គ-បង្កឡើងដោយចេតនានូវមហន្តរាយ ឬការហិនហោចដល់ស្ថានភាពរស់នៅរបស់សង្គមមនុស្សដោយបំផ្លិចបំផ្លាញក្រុមទាំងមូល ឬផ្នែកខ្លះៗនៃសង្គម ។

ឃ-ដាក់បង្ខំនូវវិធានការនានាដែលបង្កមិនឲ្យមានកំណើតទារកនៅក្នុងសង្គម ។

ង-ការបង្ខិតបង្ខំផ្លាស់ប្តូរយកកូនក្មេងចេញពីសង្គមមួយទៅដាក់នៅសង្គមមួយទៀត ។

២-អំពើដូចគ្នាខាងលើនេះត្រូវតែសំដៅទៅលើក្រុម «ជនជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា» មួយ ។



៣-អំពើដូចគ្នាខាងលើនេះត្រូវតែ«បានប្រព្រឹត្តដោយចេតនាដើម្បីកម្ទេចឲ្យវិនាសចំពោះក្រុមទាំងមូល ឬភាគខ្លះនៃក្រុមនោះ» ។

ដើម្បីបង្ហាញការរំលោភបំពានអនុសញ្ញាអំពើប្រល័យពូជសាសន៍មួយ កត្តាទាំងបីត្រូវតែកើតឡើង ។

និយមន័យនៃអំពើប្រល័យពូជសាសន៍នៅក្នុងមាត្រា២ ពិពណ៌នាអំពីធាតុផ្សំសំខាន់ៗទាំង២នៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលជាធាតុផ្សំជាមូលដ្ឋាននៃគ្រប់បទឧក្រិដ្ឋទាំងអស់នោះគឺ អំពើ

(អំពើព្រហ្មទណ្ឌដែលត្រូវបានប្រព្រឹត្ត) ហើយនិងចេតនា (ចេតនាប្រព្រឹត្តអំពើឧក្រិដ្ឋនោះ)។ ដើម្បីដាក់ឲ្យបុគ្គលម្នាក់ទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើប្រល័យពូជសាសន៍ ធាតុផ្សំទាំងពីរនេះត្រូវតែបំពេញ ចុងចោទត្រូវតែបានប្រព្រឹត្តអំពើមួយក្នុងចំណោមអំពើដែលបានរៀបរាប់ពី «ក» ដល់ «ង»ខាងលើ ហើយជនចុងចោទនោះត្រូវតែបានប្រព្រឹត្តអំពើនោះដោយមាន«ចេតនាបំផ្លិចបំផ្លាញទាំងស្រុងឬដោយផ្នែកនូវក្រុមប្រជាជាតិ ជនជាតិភាគតិចពូជសាសន៍ ឬសាសនា»។ ធាតុផ្សំចុងក្រោយនេះគឺ«ចេតនាដែលជាប្រធានបទដ៏ចម្បងក្នុងការលើកយកមកវែកញែកស្តីអំពីថាតើ «អំពើប្រល័យពូជសាសន៍»មានរូបរាងយ៉ាងដូចម្តេចតាមនិយមន័យនេះ នៅក្នុងការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមនាពេលខាងមុខនេះ។

### ក-បញ្ហានៃក្រុមដែលត្រូវបានការពារ

និយមន័យនៃអំពើប្រល័យពូជសាសន៍នៅក្នុងមាត្រា២នៃអនុសញ្ញានេះ បានបង្កើតឲ្យមានការជជែកវែកញែកដ៏តានតឹងមួយនៅក្នុងបរិបទនៃរបបកម្ពុជាប្រជាធិបតេយ្យ ពីព្រោះនិយមន័យនេះអាចត្រូវបានទាញហេតុផលថា ពុំបានការពារជនជាតិខ្មែរដែលមានចំនួនដ៏ច្រើនលើសលប់ក្នុងប្រទេសកម្ពុជាដែលត្រូវបានសម្លាប់ដោយបក្សកុម្មុយនិស្តកម្ពុជា។ ដោយតម្រូវឲ្យមានចេតនាដើម្បីបំផ្លិចបំផ្លាញទាំងស្រុង ឬមួយផ្នែកនៃ «ក្រុមជនជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា» បែបនោះ អនុសញ្ញានេះទំនងជាបានការពារជនជាតិចាម អាណិកជនវៀតណាម និងជនជាតិភាគតិចដទៃទៀតដែលរស់នៅក្នុងប្រទេសកម្ពុជា ប៉ុន្តែគេអាចទាញហេតុផលដោយទុកឲ្យប្រជាជនខ្មែរភាគច្រើនពុំមានការការពារតាមផ្លូវច្បាប់ទៅវិញ។

គេអាចទាញហេតុផលថា គោលនយោបាយរបស់របបបក្សកុម្មុយនិស្តកម្ពុជាបានចង្អុលបង្ហាញអំពីចេតនាបំផ្លាញជនជាតិខ្មែរ ពលរដ្ឋកម្ពុជា និងព្រះពុទ្ធសាសនិក «ដោយផ្នែក»។ ក៏ប៉ុន្តែការទាញហេតុផលនេះអាស្រ័យទៅលើការបកស្រាយមាត្រា២នៃអនុសញ្ញាស្តីអំពីអំពើប្រល័យពូជសាសន៍ដែលអាចឬក៏មិនអាចធ្វើឲ្យតុលាការ ឬអង្គជំនុំជម្រះក្តីលើបក្សកុម្មុយនិស្តកម្ពុជាជឿបាន។ ដើម្បីបកស្រាយអនុសញ្ញានេះតុលាការឬអង្គជំនុំជម្រះក្តីនឹងពិចារណាមិនត្រឹមតែអត្ថន័យធម្មតានៃកថាខណ្ឌដែលពាក់ព័ន្ធប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពិចារណាលើឯកសារនៃការផាររៀបចំដំបូងនៃអនុសញ្ញានេះលម្អិតថែមទៀត។ ទោះបីជាការវិភាគរបស់អ្នកប្រាជ្ញមួយចំនួនបង្ហាញថាគ្មានអ្វីនៅក្នុងអត្ថបទឬកិច្ចការរៀបចំដំបូងនៃអនុសញ្ញាអំពីអំពើប្រល័យពូជសាសន៍គាំទ្រការកែតម្រូវការបកស្រាយណាមួយដោយដកចេញនូវក្រុមប្រជាជនភាគច្រើនចេញពីការការពាររបស់ច្បាប់នេះក៏ដោយ ក៏ការទាញហេតុផលដ៏មានសុពលភាពមួយអាចត្រូវបានធ្វើឡើងដោយចង្អុលបង្ហាញថាអនុសញ្ញានេះត្រូវបានព្រៀងឡើងនៅក្នុងគំនិតអ្នកពង្រៀងគឺសំដៅការពារក្រុមជនជាតិភាគតិច។

អ្នកគាំទ្រសិទ្ធិមនុស្សមួយចំនួនបានទាញហេតុផលថានិយមន័យនៃអំពើប្រល័យពូជសាសន៍នៅក្នុងអនុសញ្ញាស្តីអំពីអំពើប្រល័យពូជសាសន៍ពុំបានតំណាងឲ្យច្បាប់ដែលអាចអនុវត្តន៍បាននៅក្នុងឆ្នាំ១៩៧៥ទេ ពីព្រោះនិយមន័យទូលំទូលាយជាងនេះបានក្លាយជាផ្នែកមួយនៃ«ច្បាប់អន្តរជាតិតាមទំនៀមទម្លាប់»។ ទោះបីជាទំនៀមទម្លាប់ត្រូវបានទទួលយកជាប្រភពមួយក្នុងចំណោម«ប្រភព»ដ៏មានអំណាចនៃច្បាប់អន្តរជាតិក៏ដោយ ច្បាប់ជាទំនៀមទម្លាប់ពិបាកនឹងយកមកធ្វើជាសំអាងណាស់ ពីព្រោះច្បាប់ជាទំនៀមទម្លាប់ពុំមានអត្ថិភាពក្នុងទ្រង់ទ្រាយជាលាយលក្ខណ៍អក្សរនិងជាក់លាក់ណាស់។ ហេតុដូច្នេះហើយ ច្បាប់ជាទំនៀមទម្លាប់ពុំអាចដោះស្រាយបញ្ហានេះឲ្យបានច្បាស់បានឡើយ ហើយជាពិសេសក្នុងការជំនុំជម្រះក្តីខ្មែរក្រហមនាពេលខាងមុខ។ ក៏ប៉ុន្តែតុលាការឬអង្គជំនុំជម្រះដែលទទួលខុសត្រូវនឹងត្រូវធ្វើការសម្រេចចិត្តផ្លូវច្បាប់ដ៏សំខាន់មួយ ដោយផ្អែកលើការទាញហេតុផលជំទាស់របស់អ្នកច្បាប់ពាក់ព័ន្ធទៅនឹងទំហំនៃក្រុមដែលទទួលការការពារក្រោមនិយមន័យនៃអំពើប្រល័យពូជសាសន៍ដែលអាចអនុវត្តន៍បាន។

### ខ-បញ្ហានៃតម្រូវការ «ចេតនា»

ទោះបីជាតុលាការឬអង្គជំនុំជម្រះក្តីរកឃើញថាជនរងគ្រោះខ្មែរភាគច្រើនក្រោមរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានការពារដោយអនុសញ្ញាស្តីអំពីអំពើប្រល័យពូជសាសន៍ ឬក៏ពុំត្រូវបានការពារយ៉ាងណានោះក៏ដោយ ក៏បញ្ហាផ្លូវច្បាប់ដែលប្រកបដោយចម្រូងចម្រាស់ទី២ លើនិយមន័យនៃអំពើប្រល័យពូជសាសន៍គឺ




ស្តង់ដារនៃតម្រូវការ«ចេតនា» ។ ដោយចង្អុលបង្ហាញថា អតីតមេដឹកនាំបក្សកុម្មុយនិស្តកម្ពុជាមានចេតនា«បំផ្លិចបំផ្លាញ»ក្រុមដែលត្រូវបានការពារ «ទាំងស្រុងឬដោយផ្នែក» គឺទំនងជាចំណុចដ៏លំបាកបំផុតក្នុងការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមអំពីបទប្រល័យពូជសាសន៍ ។ ភាសាដែលអនុសញ្ញានេះបានបញ្ជាក់ច្បាស់ថាអំពើឧក្រិដ្ឋដោយគ្មានរើសមុខទោះបីជាអំពើទាំងនោះតាមពិតជះឥទ្ធិពលលើក្រុមដែលត្រូវបានការពារក៏ដោយ ក៏អំពើទាំងនោះពុំគ្រប់គ្រាន់នៅឡើយ ។ ចុងចោទត្រូវតែពិតប្រាកដថាមានចេតនាបំផ្លិចបំផ្លាញទាំងស្រុងឬដោយផ្នែកនូវក្រុមដែលត្រូវបានការពារនោះ ។ ភ័ស្តុតាងកម្រិតណាដែលបំពេញតម្រូវការ «ចេតនាបំផ្លិចបំផ្លាញ» និងចំណែកប៉ុន្មាននៃក្រុមនេះ នេះទើបបំពេញធាតុផ្សំ«ដោយផ្នែក» ក្រោមអនុសញ្ញានេះនៅតែពុំច្បាស់លាស់នៅឡើយ ។ ជាថ្មីម្តងទៀត តុលាការឬអង្គជំនុំជម្រះក្តីដែលទទួលខុសត្រូវ និងស្តាប់ការទាញហេតុផលរបស់អ្នកច្បាប់ដែលការពារក្តី ហើយនិងព្រះរាជអាជ្ញាបន្ទាប់មកនឹងឈានដល់សេចក្តីសន្និដ្ឋានផ្នែកច្បាប់ដ៏សំខាន់មួយ ។

### ៣-សេចក្តីសន្និដ្ឋាន វិបាកនានាចំពោះការកាត់ទោស

ដោយមិនគិតអំពីសេចក្តីសន្និដ្ឋានផ្លូវច្បាប់ជាក់លាក់ណាមួយត្រូវបានទាញចេញដោយតុលាការឬអង្គជំនុំជម្រះក្តីណាមួយ អំពើប្រល័យពូជសាសន៍គឺជាបទឧក្រិដ្ឋដ៏លំបាកមួយ ដើម្បីបង្ហាញភ័ស្តុតាងសម្រាប់ការកាត់ក្តីមួយ ។ ទោះបីជាភ័ស្តុតាងជាច្រើនដែលមានស្រាប់បង្ហាញថា បក្សកុម្មុយនិស្តកម្ពុជាពាក់ព័ន្ធក្នុងការធ្វើទុក្ខបុកម្នេញនិងការសម្លាប់មនុស្សដ៏រីករាលដាលធំធេងយ៉ាងណាក៏ដោយ ក៏ការបង្ហាញភ័ស្តុតាងថាបក្សកុម្មុយនិស្តកម្ពុជាមានចេតនាបំផ្លិចបំផ្លាញទាំងស្រុងឬដោយផ្នែកនៃក្រុមដែលត្រូវបានការពារជាក់លាក់ក្រោមអនុសញ្ញាស្តីអំពីអំពើប្រល័យពូជសាសន៍ គឺជាបញ្ហាដ៏លំបាកខ្លាំងណាស់ ។

មធ្យោបាយដ៏ច្បាស់លាស់បំផុតដើម្បីបង្ហាញថាមន្ត្រីបក្សកុម្មុយនិស្តកម្ពុជាមានចេតនាដែលជាតម្រូវការចាំបាច់នោះគឺត្រូវផ្តល់ភ័ស្តុតាងឯកសារដូចជា បទបញ្ជាដែលមានចុះហត្ថលេខាឬអនុក្រឹតនានាដែលចង្អុលបង្ហាញនូវចេតនារបស់មន្ត្រីនៃបក្សកុម្មុយនិស្តកម្ពុជានោះ ។ កសិណសាក្សីបញ្ជាក់ពីសេចក្តីអត្ថាធិប្បាយឬការទាក់ទងផ្ទាល់មាត់នានា គឺជាមធ្យោបាយមួយចំនួនក្នុងចំណោមមធ្យោបាយដែលមានប្រសិទ្ធិភាពនានាដើម្បីចង្អុលបង្ហាញចេតនានេះ ។ ភ័ស្តុតាងប្រយោលនៃអំពើឃោរឃៅព្រៃផ្សៃនានាដែលត្រូវបានប្រព្រឹត្តដោយបក្សកុម្មុយនិស្តកម្ពុជាប្រឆាំងនឹងក្រុមដែលត្រូវបានការពារក៏មានតម្លៃតាមផ្លូវច្បាប់ដែរ រួមមានរណ្តៅសាកសពរួម និងកសិណសាក្សីនៃអំពើប្រល័យពូជសាសន៍ ។

(នៅមានត)

ចន ឌីឆរអារី

# ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ



ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានហាមប្រាមដោយច្បាប់ទំនៀមទម្លាប់អន្តរជាតិ ។ ដោយសារពុំមានសន្ធិសញ្ញាពហុភាគីដែលមានសមត្ថកិច្ចស្តីអំពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ វាជាការចាំបាច់ដែលត្រូវរិះរកឧបករណ៍ច្បាប់ សេចក្តីប្រកាស និងស្ថាប័ននានា ដើម្បីដកស្រង់និងបង្កើតធាតុផ្សំទាំងឡាយនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលត្រូវបានហាមប្រាមនេះ ។ ប្រភពច្បាប់ខុសប្លែកដោយឡែកៗទាំងនេះបានបង្កើតនិយមន័យចំរុះមួយដែលជាមូលហេតុធ្វើឲ្យមានការលំបាកក្នុងការកំណត់ទំហំនាពេលបច្ចុប្បន្ននិងពីមុននៃបទល្មើសនេះ ។ កាលពីដើមឡើយការបង្កើតឡើងនូវនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទំនងជាផ្សារភ្ជាប់បទល្មើសនេះទៅនឹងលក្ខខ័ណ្ឌសង្គ្រាមមួយ ។ ពុំទាន់ដឹងច្បាស់នៅឡើយថាតើសព្វថ្ងៃនេះនៅតែទាមទារបំពេញតម្រូវការ«សម្ព័ន្ធភាពសង្គ្រាម»លើច្បាប់នេះនៅឡើយឬយ៉ាងណានោះទេ ។ គួរកត់សម្គាល់ថា ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវតែប្រព្រឹត្តឡើងនៅក្នុងទ្រង់ទ្រាយធំឬក៏ជាផ្នែកមួយនៃគោលនយោបាយជាប្រព័ន្ធ ។ ជាទីបញ្ចប់ និយមន័យមួយចំនួននៃបទល្មើសនេះតម្រូវថា អំពើទាំងឡាយណាដែលអាចចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិបាន លុះត្រាតែអំពើនោះត្រូវបានប្រព្រឹត្តឡើងដោយមានមូលហេតុពាក់ព័ន្ធនឹងលក្ខណៈពិសេសនៃជនរងគ្រោះ ។

## ១-សម្ព័ន្ធភាពសង្គ្រាម

ធម្មនុញ្ញទីក្រុងឡុងដែលចែងពីការកាត់ទោសឧក្រិដ្ឋជនសង្គ្រាមណាស៊ី (ខែសីហា ឆ្នាំ១៩៤៥) នៅទីក្រុងនូរិមប៊ឺកនៃប្រទេសអាល្លឺម៉ង់បានប្រកាសជាលើកដំបូងនូវទស្សនៈអំពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ ពាក្យ«ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ»នេះពិពណ៌នានូវបទល្មើសទាំងឡាយដែលមិនរាប់បញ្ចូលជាឧក្រិដ្ឋកម្មសង្គ្រាម ព្រោះបទល្មើសទាំងនេះត្រូវបានគេប្រព្រឹត្តប្រឆាំងទៅនឹងប្រជាពលរដ្ឋនៃរដ្ឋខ្លួនឬប្រឆាំងនឹងប្រជាពលរដ្ឋនៃរដ្ឋសម្ព័ន្ធមិត្ត ។ មាត្រា៦ នៃធម្មនុញ្ញបានឲ្យនិយមន័យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិថា ជា«អំពើឃាតកម្ម ការសម្លាប់បំផុតពូជ ទាសភាព ការនិរទេស និងអំពើអមនុស្សធម៌ដទៃទៀតដែលបានប្រព្រឹត្ត

ប្រឆាំងនឹងជនស៊ីវិលទាំងឡាយ នៅមុនឬនៅក្នុងពេលសង្គ្រាម ឬមួយក៏ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា នៅក្នុងការប្រព្រឹត្ត ឬទាក់ទងនឹងឧក្រិដ្ឋកម្មនានានៅក្នុងដែនសមត្ថកិច្ចនៃតុលាការនូរិមប៊ឺកនេះ ទោះបីជាមានការរំលោភ ឬគ្មានការរំលោភលើច្បាប់ក្នុងស្រុកនៃប្រទេសដែលបទល្មើសត្រូវបានប្រព្រឹត្តក៏ដោយ» ។ តាមរបៀបនេះ ធម្មនុញ្ញសម្រាប់តុលាការនូរិមប៊ឺកបានកំណត់និយមន័យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិពាក់ព័ន្ធទៅនឹងសង្គ្រាម ហើយនិងឧក្រិដ្ឋកម្មដទៃទៀតដែលតុលាការនូរិមប៊ឺកមានដែនសមត្ថកិច្ចទៅលើ គឺឧក្រិដ្ឋកម្មសង្គ្រាម ឬក៏ឧក្រិដ្ឋកម្មនានាប្រឆាំងនឹងសន្តិភាព តាំងពីដំបូងម្ល៉េះ ។

បណ្តាប្រទេសសម្ព័ន្ធមិត្តបានកាត់ទោសឧក្រិដ្ឋជនសង្គ្រាមបន្ថែមទៀតនៅក្នុងតំបន់ក្រោមការកាន់កាប់ដែលស្ថិតនៅក្រោមច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០ (ដែលអនុម័តដោយក្រុមប្រឹក្សាត្រួតពិនិត្យរបស់សម្ព័ន្ធមិត្តលើប្រទេសអាល្លឺម៉ង់ ខែធ្នូ ឆ្នាំ ១៩៧៥) ដែលបញ្ចូលច្បាប់អន្តរជាតិ ។ ច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០ បានអនុម័តនូវនិយមន័យបទល្មើសប្រឆាំងនឹងមនុស្សជាតិស្រដៀងគ្នានេះដែរ ប៉ុន្តែលុបចោលនូវសម្ព័ន្ធភាពសង្គ្រាម ការទាក់ទងជាមួយឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មដែលប៉ះពាល់ដល់សន្តិភាព ។ ច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០ បានកំណត់បទល្មើសប្រឆាំងនឹងមនុស្សជាតិថាជា«អំពើសាហាវឃោរឃៅនិងបទល្មើស ដែលរាប់បញ្ចូលដោយមិនកម្រិតនូវឃាតកម្ម ការសម្លាប់បំផុតពូជ ការដាក់ជាទាសករ ការនិរទេស ការដាក់គុក ការធ្វើទារុណកម្ម រំលោភលើផ្លូវភេទ ឬក៏អំពើអមនុស្សធម៌ផ្សេងទៀត ដែលប្រព្រឹត្តមកលើជនស៊ីវិល ឬការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ពូជសាសន៍ នយោបាយ ទោះបីជារំលោភ ឬមិនរំលោភលើច្បាប់ក្នុងស្រុកនៃប្រទេស ដែលនៅទីនោះអំពើទាំងនេះត្រូវបានប្រព្រឹត្តក៏ដោយ» ។ យោងទៅតាមតុលាការក្នុងស្រុកមួយដែលបានកោះឲ្យបង្កើតឡើងក្រោមច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០ សម្ព័ន្ធភាពសង្គ្រាមត្រូវបានជម្រុះចោលពីធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលចែងនៅក្នុងច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ១០ ដើម្បីផ្តល់អំណាចដល់តុលាការក្នុងស្រុកនោះមានដែនសមត្ថកិច្ចលើការជំនុំជម្រះជនជាប់ចោទជនជាតិអាល្លឺម៉ង់ដែលប្រព្រឹត្តអំពើអមនុស្សធម៌ទៅលើប្រជាជាតិអាល្លឺម៉ង់ខ្លួនឯងមុនពេលផ្ទុះសង្គ្រាមលោកលើកទី២ ។



នៅឆ្នាំ១៩៤៦ អង្គការសហប្រជាជាតិសម្រេចយល់ព្រមទទួលយកនូវគោលការណ៍នៃច្បាប់អន្តរជាតិមួយចំនួនដែលបានចែងក្នុងធម្មនុញ្ញនៃតុលាការយោធាអន្តរជាតិ ហើយសុំឲ្យគណៈកម្មការច្បាប់អន្តរជាតិ[១] ឲ្យរៀបចំនូវក្រមច្បាប់ពង្រាងមួយស្តីអំពីបទល្មើសប្រឆាំងសន្តិភាពនិងសន្តិសុខមនុស្សជាតិ គឺ«ក្រមច្បាប់ពង្រាង» ដែលនឹងបង្រួបបង្រួមគ្រប់ធាតុផ្សំនៃគោលការណ៍ច្បាប់ទាំងឡាយរបស់តុលាការនូរិមប៊ឺកជាមួយនឹងបទល្មើសដទៃទៀត ដែលជូនយោបល់ដោយរដ្ឋាភិបាលនៃបណ្តារដ្ឋនានា ។ កាលពីមុនគេយល់ឃើញថា មានតែបទល្មើសទាំងឡាយដែលនឹងរំលោភលើច្បាប់អន្តរជាតិ និង«ប៉ះពាល់ដល់ទំនាក់ទំនងអន្តរជាតិ» ក្នុងរបៀបមួយដែលអាចបង្កគ្រោះថ្នាក់ចំពោះការទ្រទ្រង់សន្តិភាពប៉ុណ្ណោះ នឹងត្រូវបញ្ចូលទៅក្នុងក្រមច្បាប់សង្ខេបនេះ ។ ក្នុងពង្រាងជាលើកដំបូងនៃគោលការណ៍ទាំងនោះ គណៈកម្មការច្បាប់អន្តរជាតិបានពិភាក្សាអំពីតម្រូវការ«សម្ព័ន្ធភាពសង្គ្រាម» ក្នុងឆ្នាំ១៩៥៤ គណៈកម្មការនេះបានបោះឆ្នោតធ្វើការលុបបំបាត់ចោលតម្រូវការនេះ ហើយអនុម័តយកនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិថាជា «អំពើអមនុស្សធម៌ៈ ឃាតកម្ម ការសម្លាប់បំផុតពូជ អំពើទាសភាព ការនិរទេស ឬការធ្វើទុក្ខបុកម្នេញប្រឆាំងនឹងប្រជាជនស៊ីវិលដោយមូលហេតុវប្បធម៌ សាសនា ពូជសាសន៍ និងនយោបាយសង្គម ដោយអាជ្ញាធរនៃរដ្ឋមួយ ឬក៏ដោយសារបុគ្គលនោះប្រព្រឹត្តក្រោមការញុះញង់ ឬដោយមានការអនុគ្រោះដោយអាជ្ញាធរទាំងនេះ ។ អនុសញ្ញាឆ្នាំ១៩៦៨ ស្តីអំពីការមិនអនុវត្តដែនអាជ្ញាយុកាលច្បាប់របស់អង្គការសហប្រជាជាតិចំពោះឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក៏គិតគូរជាបន្ថែមទៀតដល់ការពង្រីកនិយមន័យដ៏ទូលាយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយបន្ថែមត្រង់ចំណុច «ទោះបីជាប្រព្រឹត្តក្នុងពេលសង្គ្រាម ឬក៏ក្នុងពេលមានសន្តិភាពដូចដែលបានកំណត់ក្នុងធម្មនុញ្ញនៃតុលាការយោធាអន្តរជាតិ» ។

ថ្មីៗនេះ លក្ខន្តិកៈច្បាប់នៃតុលាការអន្តរជាតិសម្រាប់ប្រទេសយូហ្គោស្លាវីលេចឡើងនូវវត្តមានធាតុផ្សំ«សម្ព័ន្ធភាពសង្គ្រាម» ដែលលើកដំបូងមានចែងក្នុងធម្មនុញ្ញតុលាការយោធាអន្តរជាតិ មាត្រា៥ ប្រគល់អំណាចឲ្យតុលាការសម្រាប់ប្រទេសយូហ្គោស្លាវីមានដែនសមត្ថកិច្ចជំនុំជម្រះអំពើដូចតទៅ «នៅពេលប្រព្រឹត្តក្នុងពេលប៉ះទង្គិចដោយអាវុធ ទោះបីជាមានចរិតក្នុងស្រុកឬអន្តរជាតិក៏ដោយ ហើយនិង «ការដឹកនាំប្រឆាំងទល់នឹងជនស៊ីវិលមួយចំនួនដូចជាៈ ឃាតកម្ម ការសម្លាប់បំផុតពូជ ការដាក់ជាទាសករ ការនិរទេស ការដាក់គុក ការធ្វើទារុណកម្ម ការរំលោភផ្លូវភេទ ការធ្វើទុក្ខបុកម្នេញចំពោះមូលហេតុសាសនា ពូជសាសន៍ និងនយោបាយ ហើយនិងអំពើអមនុស្សធម៌ដទៃទៀត» ។ លោក ម័ររិនទាញហេតុផលថា ការរក្សា «សម្ព័ន្ធភាពសង្គ្រាម» អាចត្រូវបានបកស្រាយពន្យល់ពីការព្រួយបារម្ភរបស់«អ្នកពង្រាង»ទាំងនោះថាសមាជិកមួយចំនួននៃក្រុមប្រឹក្សាសន្តិសុខ អាចនឹងប្រឆាំងចំពោះការដាក់ឲ្យទៅជាបទល្មើសឧក្រិដ្ឋនូវការរំលោភលើសិទ្ធិមនុស្សក្នុងពេលកំពុងមានសន្តិភាព ។ ទោះជាយ៉ាងណាក៏ដោយ ក៏ការអធិប្បាយបកស្រាយទាំងនោះដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលសង្កត់ធ្ងន់ថាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានហាមឃាត់ «ដោយមិនគិតថាតើបទល្មើសនោះត្រូវបានប្រព្រឹត្តឡើងនៅក្នុងពេលសន្តិភាព ឬក្នុងជម្លោះប្រដាប់អាវុធ ទោះជាក្នុងលក្ខណៈជាតិឬអន្តរជាតិក៏ដោយ» បានបង្ហាញពី «ការកំណត់ដែនសមត្ថកិច្ចក្នុងការអនុវត្តន៍ ជាជាងការគ្រាន់តែឲ្យនិយមន័យ ។ ការប្រកាសគាំទ្រដល់លក្ខន្តិកៈជំនុំជម្រះក្តីសម្រាប់ប្រទេសរ្វាន់ដា ដែលមិនបញ្ចូលធាតុផ្សំ«សម្ព័ន្ធភាពសង្គ្រាម» ថ្លែងថា «តុលាការរ្វាន់ដាត្រូវមានដែនសមត្ថកិច្ចកាត់ទោសបុគ្គលទាំងឡាយឲ្យទទួលខុសត្រូវចំពោះបទល្មើសទាំងនេះ ពេលអំពើនេះត្រូវបានប្រព្រឹត្តជាផ្នែកមួយនៃការប្រព្រឹត្តជាប្រព័ន្ធ ឬការវាយប្រហារប្រឆាំងនឹងប្រជាជនស៊ីវិលដោយឈរលើមូលហេតុសាសនាពូជសាសន៍ នយោបាយ ឬជាតិពន្ធ ដូចជាឃាតកម្ម...» ។

## ២-ទ្រង់ទ្រាយធំ ឬលក្ខណៈជាប្រព័ន្ធនៃបទល្មើស

អំពើនីមួយៗអាចឈានដល់កម្រិតឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតែប្រសិនណាបើការប្រព្រឹត្តទាំងនោះមានទ្រង់ទ្រាយធំ «មានន័យថាចំនួនជនរងគ្រោះត្រូវតែច្រើន» ឬមានលក្ខណៈជាប្រព័ន្ធ «មានន័យថាត្រូវមានភ័ស្តុតាងបញ្ជាក់អំពីគោលនយោបាយ ឬកម្រិតនៃការគ្រោងទុកជាមុនដែលបានរៀបចំឡើង» ។

**(នៅមានត)** **អេលីហ្សាប៊ែត វ៉ាន់ស្លាក់**

# គំរូមួយនៃភ័ស្តុតាងឯកសារដែលភ្ជាប់មេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនិស្តកម្ពុជា ដែលនៅរស់ ទៅនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

**(តពីលេខមុន)** ឯកសារបកប្រែដែលប្រគល់ជាភ័ស្តុតាងទៅឲ្យតុលាការជំនុំជម្រះក្តីអំពើប្រល័យពូជសាសន៍ ប៉ុល ពត អៀង សារី ដែលរៀបចំឡើងដោយរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាកាលពីឆ្នាំ១៩៧៩ ទំនងជារាយឈ្មោះក្នុងបញ្ជីគណៈកម្មាធិការអចិន្ត្រៃយ៍កាលពីខែមេសា ឆ្នាំ១៩៧៧ ដោយរួមបញ្ចូល ប៉ុល (ពត), នួន (ជា), (សោ) ភឹម, តាម៉ុក, វន (វេត), វ៉ាន់ (អៀង សារី), (រស់) ញឹម និង ខៀវ (សុន សេន) ។ ការបកប្រែជាភាសាវៀតណាម នូវអ្វីដែលហៅថាសៀវភៅកំណត់ហេតុរបស់កម្មាភិបាលខ្មែរក្រហមម្នាក់ដែលបានចូលរួមប្រជុំក្នុងសមាជបក្សកាលពីខែវិច្ឆិកា ឆ្នាំ១៩៧៨ បន្ទាប់ពីការធ្វើអត្តឃាតរបស់ សោ ភឹម និងការចាប់ខ្លួន រស់ ញឹម មុននេះក្នុងឆ្នាំដដែលរួមបញ្ចូលនូវកំណត់ត្រាដូចខាងក្រោមនេះ÷

## ថ្ងៃទី ២ ខែវិច្ឆិកា ឆ្នាំ១៩៧៨៖

១-បញ្ហានៃការចាត់តាំងនានានៅក្នុងការរៀបចំគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍

ប៉ុល៖ លេខាមើលបញ្ហាទូទៅ ទទួលខុសត្រូវកិច្ចការបក្សនិងយោធា ។

នួន៖ អនុលេខាទទួលបន្ទុកអប់រំ ឃោសនាការ សុខាភិបាល សុខមាលភាពសង្គម វប្បធម៌ និងបំពាក់បំប៉នស្មារតី ។

ម៉ុក៖ អនុលេខា ទទួលបន្ទុកទីជនបទនិងកសិកម្ម ។

វ៉ាន់៖ គណៈកម្មាធិការអចិន្ត្រៃយ៍ ទទួលបន្ទុកកិច្ចការខាងក្រៅរបស់បក្សនិងរដ្ឋ ។

វន៖ គណៈកម្មាធិការអចិន្ត្រៃយ៍ ទទួលបន្ទុកសេដ្ឋកិច្ចនិងផែនការ ។

ខៀវ៖ បក្ស និងសេនាធិការក្រសួងការពារជាតិ ។

កែ៖ អនុលេខាភ័ស្តុភារ ។

ប៉ុន្តែ ទោះបីជាសមាសភាពរបស់គណៈកម្មាធិការអចិន្ត្រៃយ៍នេះកំពុងត្រូវបានពន្យាតបញ្ចូលមន្ត្រីថ្នាក់ក្រោមបន្ទាប់យ៉ាងណាក៏ដោយ វន វេត និង កែ (ហៅ គង់ សុផល ហៅ ពៅ ស៊ូ ហៅ កន) ដែលពេលនោះជាអនុលេខានៃភូមិភាគពាយ័ព្យត្រូវបានតាមចាប់ខ្លួន ។

### គណៈកម្មាធិការយោធានៃគណៈកម្មាធិការមជ្ឈិម

អង្គការមួយទៀតដែលលក្ខន្តិកៈទាំងនោះពុំទាន់និយាយ ប៉ុន្តែវត្តមាននៃអង្គការនេះត្រូវបានបញ្ជាក់ថាមាននៅក្នុងឯកសារដទៃទៀត ហើយត្រូវបានគាំទ្រដោយកសិណសាក្សីជាច្រើនផ្សេងទៀតនោះគឺ«គណៈកម្មាធិការយោធានៃគណៈកម្មាធិការមជ្ឈិម» ។ ដោយយោងទៅតាមការធ្វើសេចក្តីអត្ថាធិប្បាយរបស់មន្ត្រីម្នាក់លើលក្ខន្តិកៈទាំងនោះ អង្គការមួយបែបនេះអាចត្រូវបានបង្កើតឡើងក្រោមឈ្មោះគណៈកម្មាធិការមជ្ឈិមជា«ផ្នែកដាច់ដោយឡែកមួយ»ក្រោម«ការគ្រប់គ្រងផ្ទាល់និងជាប្រយោល»របស់គណៈកម្មាធិការមជ្ឈិម ។

ក្រោយមកគណៈកម្មាធិការយោធានេះត្រូវបានបង្ហាញជាសាធារណៈយ៉ាងច្បាស់ថា គណៈកម្មាធិការយោធាមួយមានវត្តមានចាប់តាំងពីឆ្នាំ១៩៧០យ៉ាងតិច ចាប់ពីពេលនោះមក គណៈកម្មាធិការនេះមាន ប៉ុល ពត ជាប្រធាន។ យោងទៅតាម អៀង សារី ចាប់តាំងពីឆ្នាំ១៩៧០ ដល់ ១៩៧៥ សមាជិកនៃគណៈកម្មាធិការនេះ ដទៃទៀតរួមមាន នួន ជា, សោ ភឹម, តាម៉ុក និង សុន សេន។

បន្ទាប់ពីឆ្នាំ១៩៧៥ សារី និយាយថា សមាសភាពជាផ្លូវការរបស់គណៈកម្មាធិការនេះនៅតែពុំមានអ្វីផ្លាស់ប្តូរ ក៏ប៉ុន្តែក្នុងការអនុវត្តន៍ជាក់ស្តែង ការងាររបស់គណៈកម្មាធិការនេះគឺភាគច្រើនអនុវត្តដោយ ប៉ុល ពត, នួន ជា និង សុន សេន ដោយមានការជួយជ្រោមជ្រែងពីប្រពន្ធរបស់ សុន សេន ឈ្មោះ យ៉ុន យ៉ាត ហៅ អាត ។ សារី និយាយអំពី សោ ភឹម និង តាម៉ុក ថា ទោះបីជាតាមឈ្មោះ «អ្នកទាំង២នេះនៅក្នុង

សមាសភាព» ក្នុងគណៈកម្មាធិការយោធា «តែតាមពិត សោ ភឹម និង តាម៉ុក ពុំនៅក្នុងគណៈកម្មាធិការនេះទេ» ។

សៀវភៅកំណត់ហេតុដែលបានបកប្រែនានាដែលចេញពីសមាជបក្សខែវិច្ឆិកា ឆ្នាំ១៩៧៨ បានដាក់«គណៈកម្មាធិការយោធាមជ្ឈិមបក្ស...ឲ្យនៅក្រោមការដឹកនាំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់មជ្ឈិម» និងបានពិពណ៌នាថា គណៈកម្មាធិការយោធានេះ «ទទួលបន្ទុករាល់កិច្ចការយោធា» ទាំងអស់ ។ សៀវភៅកំណត់ហេតុដែលចេញពីសមាជបក្សនោះបានផ្តល់ឈ្មោះសមាជិកនៃគណៈកម្មាធិការនេះនិងភារកិច្ចរបស់សមាជិកទាំងនោះដូចតទៅ÷

ប៉ុលៈ ប្រធាន

នួនៈ អនុប្រធាន ទទួលបន្ទុកលើកិច្ចការនយោបាយនានា

វ៉ាន់ៈ សមាជិកគណៈកម្មាធិការ

ខៀវៈសមាជិកគណៈកម្មាធិការ...ប្រធានក្រុមប្រឹក្សាសេនាធិការ

**រដ្ឋធម្មនុញ្ញ លក្ខន្តិកៈ សេចក្តីសម្រេច**

ឯកសារនិងកសិណសាក្សីផ្សេងៗ ភ្ជាប់គណៈកម្មាធិការយោធារបស់គណៈកម្មាធិការមជ្ឈិម ទៅនឹងគោលនយោបាយសន្តិសុខផ្សេងៗ និងការអនុវត្តន៍នានាដែលបញ្ចៀសចេញពីរបនាសម្ព័ន្ធ និងដំណើរការផ្លូវការដែលត្រូវបានគេរំពឹងថានឹងយកមកដោះស្រាយសកម្មភាពដែលត្រូវបានចោទប្រកាន់ដែលប្រព្រឹត្តដោយប្រជាជនធម្មតា និងសមាជិកបក្សនានាដែលត្រូវការយល់ថាជា «ឧក្រិដ្ឋជន» ឬ «ក្បត់ជាតិ» ។ ផ្ទុយទៅវិញ ឯកសារទាំងនេះបន្សល់ទុកនូវចំណោទបញ្ហាសំខាន់ៗ ដែលពុំអាចដោះស្រាយបាន អំពីទំនាក់ទំនងនានាក្នុងការអនុវត្តន៍ជាក់ស្តែងក្នុងចំណោមគណៈកម្មាធិការមជ្ឈិម គណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មាធិការយោធា និងអង្គការដទៃទៀតដែលពុំចេញមុខជាចំហ ។





របនាសម្ព័ន្ធនិងដំណើរការនានាដែលគណៈកម្មាធិការទាំងនេះធ្វើការ គឺត្រូវបានចែងច្បាស់នៅក្នុងរដ្ឋធម្មនុញ្ញនៃរបបកម្ពុជាប្រជាធិបតេយ្យដែលចូលជាធរមាននៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ និងនៅក្នុងលក្ខន្តិកៈបក្សដែលត្រូវបានប្រកាសឲ្យប្រើនៅក្នុងខែមករាដដែលនោះ ។

រដ្ឋធម្មនុញ្ញនៃរបបកម្ពុជាប្រជាធិបតេយ្យបានចែងអំពីការដាក់ទណ្ឌកម្មកម្រិតខ្ពស់បំផុតតែពុំបានបញ្ជាក់ពីកម្រិតច្បាស់ចំពោះ «ប្រភេទសកម្មភាពប្រឆាំងនិងបំផ្លិចបំផ្លាញដែលមានលក្ខណៈជាខ្សែស្ទាក់ ហើយគ្រោះថ្នាក់ដល់រដ្ឋ» ទន្ទឹមនឹង

នោះក៏បានប្រកាសថា «ប្រភេទបទល្មើស» ក្រៅពីប្រភេទខាងលើ «ត្រូវអប់រំកសាងក្នុងក្របខ័ណ្ឌអង្គការរដ្ឋ ឬក្នុងក្របខ័ណ្ឌអង្គការប្រជាជន» ។ មិនតែប៉ុណ្ណោះ រដ្ឋធម្មនុញ្ញបានសន្យាថា «តុលាការជាតុលាការប្រជាជន ជាកម្មសិទ្ធរបស់ប្រជាជន» «តំណាងយុត្តិធម៌របស់ប្រជាជន ការពារយុត្តិធម៌របស់ប្រជាជន និងការពារសិទ្ធិ សេរីភាពប្រជាធិបតេយ្យរបស់ប្រជាជន» ប៉ុន្តែ«ផ្តន្ទាទោសដល់គ្រប់សកម្មភាពប្រឆាំងនឹងបដិវត្តន៍ដែលប្រឆាំងនឹងរដ្ឋរបស់ប្រជាជនឬដែលល្មើសនឹងច្បាប់រដ្ឋរបស់ប្រជាជន» ។ ដោយយោងទៅតាមសេចក្តីប្រកាសជាផ្លូវការកាលពីខែមេសា ឆ្នាំ១៩៧៦ កង ចាប ហៅ សែ ដែលជាអនុលេខាភូមិភាគនិរតីនៅពេលនោះ និងក្រោយមកតែងតាំងជាលេខាភូមិភាគឧត្តរថ្មី ត្រូវបានតែងតាំងជាប្រធានគណៈកម្មាធិការតុលាការ ដើម្បីត្រួតពិនិត្យមើលប្រព័ន្ធតុលាការប្រជាជន ។ ទោះបីជាយ៉ាងណាក៏ដោយ ពុំមានភ័ស្តុតាងថាតុលាការប្រជាជនធ្លាប់ត្រូវបានបង្កើតឡើង ឬក៏ថាគណៈកម្មាធិការនេះធ្លាប់បានដំណើរការនោះក៏ទេដែរ ។

### លក្ខន្តិកៈបក្សបានចែងថា

សមាជិកណា អង្គភាពគ្រប់លំដាប់ថ្នាក់ធ្វើឲ្យប៉ះពាល់ ឬរំលោភធ្វើឲ្យខូចអន្តរាយដល់មាគ៌ានយោបាយរបស់បក្ស ជំហរសតិអារម្មណ៍របស់បក្ស ជំហរចាត់តាំងរបស់បក្ស ឬលក្ខន្តិកៈបក្ស ដែលបង្កឲ្យមានការប្រេះឆាសាមគ្គីភាព ឯកភាពផ្ទៃក្នុងបក្ស ដែលបង្កបង្កើតផ្នែកនិយម ដែលធ្វើសកម្មភាពបំផ្លិចបំផ្លាញបក្ស បដិវត្តន៍ ឬប្រជាជន ដែលបោះបង់ភារកិច្ចបក្សរបស់ខ្លួន ដែលបំពាន លក្ខការណ៍សម្ងាត់ដែលមានគ្រោះថ្នាក់ដល់បក្សបដិវត្តន៍ ឬប្រជាជន ដែលបង្កឲ្យមានការបាត់បង់ថវិកាបក្ស ឬទ្រព្យសម្បត្តិបក្ស ដែលប្រព្រឹត្តខុសសីលធម៌ ឬប្រព្រឹត្តបែបអាវ៉ាសែ ឬពុំចូលរួមប្រជុំជីវភាពរយៈពេល៣ខែជាប់ៗគ្នា គឺរំលោភបំពានលើវិន័យបក្ស ហើយត្រូវដាក់វិន័យធ្ងន់និងស្រាលដូចខាងក្រោមនេះ៖

ក-ទិតៀន ស្វ័យទិតៀន

ខ-ដូរសប្តូរមុខងារ និងដកចេញពីតួនាទី

គ-ដកចេញពីបក្ស ឬការដាក់ទណ្ឌកម្មផ្សេងៗ សមស្របទៅតាមអំពើល្មើស ជាឧទាហរណ៍ថាតើសកម្មភាពប្រឆាំងនឹងបក្សមានលក្ខណៈជាប្រព័ន្ធ ឬក៏ជាសកម្មភាពក្បត់នឹងបក្ស ។

វិន័យបក្សនេះត្រូវតែអនុវត្តតាមរយៈការវាយតម្លៃ ការវិភាគ និងការវិនិច្ឆ័យសតិអារម្មណ៍ដោយផ្អែកទាំងស្រុងលើគោលការណ៍សមូហភាព ហើយក្នុងក្របខ័ណ្ឌសមូហភាព ចាំបាច់ប្រើងប្រែងបន្ថែមទៀតដើម្បីពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ទាំងអស់ស្របទៅតាមសារៈសំខាន់នៃបញ្ហាដាក់លាក់នេះ ។

«សេចក្តីសម្រេចចិត្តរបស់គណៈកម្មាធិការមជ្ឈិមចំពោះបញ្ហាមួយចំនួន» កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ មានការបញ្ជាក់មួយចំនួនអំពីអ្វីដែលរដ្ឋធម្មនុញ្ញមានន័យដោយឃ្លាថា «ផ្តន្ទាទោសកម្រិតខ្ពស់បំផុត» ហើយនិងថាតើទ្រង់ទ្រាយនៃវិន័យបក្សធ្ងន់ធ្ងរបំផុតមានន័យយ៉ាងដូចម្តេច ។ ក៏ប៉ុន្តែ សេចក្តីសម្រេចចិត្តទាំងនោះធ្វើមិនដឹងមិនឮអំពីការសន្យាតាមរដ្ឋធម្មនុញ្ញអំពី «តុលាការប្រជាជន» ទោះបីជាមានការទទូចពីលក្ខន្តិកៈបក្សលើសតិអារម្មណ៍និងសមូហភាព និងលើការពិគ្រោះយោបល់គ្រប់លំដាប់ថ្នាក់នោះទេ ។ ការសម្រេចចិត្តមួយក្នុងចំណោមការសម្រេចចិត្តទាំងនោះបានពន្យល់ថា ដើម្បី«ឲ្យមានកម្រិតវាស់វែងដើម្បីវាស់វែងការងារអនុវត្តន៍...ផ្តាច់ការបដិវត្តន៍ ត្រូវតែអនុវត្ត» ហើយថា ដើម្បី«ឲ្យលទ្ធិប្រជាធិបតេយ្យសង្គមនិយមគួរតែត្រូវពង្រឹងពង្រីក» «សិទ្ធិសម្រេចបោសសម្អាតខាងក្នុងនិងខាងក្រៅជួរបក្ស» ត្រូវអនុវត្តដូចតទៅនេះ៖

-នៅថ្នាក់មូលដ្ឋាន គណៈកម្មាធិការអចិន្ត្រៃយ៍របស់ភូមិភាគសម្រេច ។

-ចំពោះការិយាល័យនានាភ្ជាប់ជាមួយមជ្ឈិម គណៈកម្មាធិការនានានៃមន្ទីររបស់មជ្ឈិមសម្រេច ។

-នៅតាមតំបន់ឯករាជ្យ គណៈកម្មាធិការអចិន្ត្រៃយ៍សម្រេច ។

-នៅក្នុងយោធារបស់មជ្ឈិម អគ្គសេនាធិការសម្រេច ។

ពុំមាននិយាយអ្វីទាល់តែសោះអំពីថាតើការសម្រេចចិត្តនានាដែលប៉ះពាល់ដល់សមាជិករបស់គណៈកម្មាធិការមជ្ឈិមជាងនេះទៀតគឺគណៈកម្មាធិការអចិន្ត្រៃយ៍ នឹងត្រូវធ្វើឡើងយ៉ាងដូចម្តេចនោះឡើយ ។

**មន្ទីរស-២១(ទួលស្លែង)**

ស្រដៀងគ្នានេះ ទាំងរដ្ឋធម្មនុញ្ញ លក្ខន្តិកៈបក្ស ព្រមទាំងសេចក្តីសម្រេចចិត្តនានារបស់គណៈកម្មាធិការមជ្ឈិម បានដាក់អាណត្តិឲ្យក្រុមប៉ូលិសឬកងសន្តិសុខឲ្យដោះស្រាយសកម្មភាពប្រឆាំងនានា ឬប្រភេទកំហុសផ្សេងៗទៀតដែលអាចកើតឡើងដោយប្រជាជនសាមញ្ញឬសមាជិកបក្ស ។ ភាពស្ងាត់ជ្រងំផ្ទៃក្នុងនេះបានបញ្ឆាក់ពីគោលជំហរជាសាធារណៈជាផ្លូវការនៃការបដិសេធ ឬនូវវត្តមាននៃកងកម្លាំងបែបនេះ ។ ហេតុដូច្នេះ ប៉ុល ពត និងមន្ត្រីបក្សកុម្មុយនិស្តកម្ពុជាជាន់ខ្ពស់ដទៃទៀត នៅពេលដែលភ្ញៀវពីប្រទេសមិនមែនកុម្មុយនិស្តសួរ បានអះអាងយ៉ាងទទូចថាពុំមានវត្តមាន «អង្គការសន្តិសុខ» ឬគុកនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះទេ ហើយបានអះអាងទៀតថាការកាប់សម្លាប់ផ្អែកនយោបាយគឺមានកម្រិតតិចតួចណាស់ ឬក៏ពុំ ដែលកើតឡើងទាល់តែសោះ ។ ទោះបីជា ប៉ុល ពត និងមន្ត្រីជាន់ខ្ពស់របស់បក្សកុម្មុយនិស្តកម្ពុជាបានព្រមទទួលស្គាល់ថា មេដឹកនាំជាន់ខ្ពស់នៃរបបចាស់មួយចំនួនត្រូវបានប្រហារជីវិតក៏ដោយ ក៏គោលជំហរជាផ្លូវការរបស់ពួកគេគឺថា «ទាហាន មន្ត្រី បុគ្គលិករាជការ ក៏ដូចជាប្រជាជនទីក្រុងដទៃទៀតដែរ គឺគ្រាន់តែត្រូវបានជម្លៀសបញ្ជូនទៅក្នុងសហករណ៍របស់កសិករ» ដែលនៅទីនោះមានតែ «ការដ្ឋានសម្រាប់ធ្វើការលត់ដំជនដែលប្រព្រឹត្តល្មើសដដែលជាដដែល ហើយរឹងត្អឹង»ប៉ុណ្ណោះ ។ កម្មាភិបាលថ្នាក់ដឹកនាំនៃក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យបានគាំទ្រគោលជំហរនេះ នៅពេលដែលកម្មាភិបាលទាំងនោះប្រាប់គណៈប្រតិភូកុម្មុយនិស្តបរទេសថា ជនបង្កប់ស៊ីរូងផ្ទៃក្នុង«រាប់ពាន់នាក់» ដែលបានសន្មតបង្កើតឡើងនូវបណ្តាញប្រឆាំងនឹងបដិវត្តន៍នៅក្នុងក្រុងភ្នំពេញ ដោយសង្ឃឹមថានឹងធ្វើវិទ្ធង្សនាបំផ្លាញបដិវត្តន៍ពីខាងក្នុង បន្ទាប់ពីជ័យជំនះរបស់បក្សកុម្មុយនិស្តកម្ពុជា ត្រូវបានបំបែកដោយការជម្លៀសប្រជាជនចេញពីទីក្រុងជាទូទៅ ។ គួរបញ្ជាក់ថា សកម្មភាពប្រឆាំងនឹងបដិវត្តន៍ពីមុនមកទាំងនេះ នឹងត្រូវបានផ្តល់ឱកាសឲ្យប្រជាជនទាំងនោះកែប្រែផ្លូវរបស់ពួកគេ នៅឯជនបទ ដោយមានការទំនុកបម្រុងក្រោមការជួយមើលខុសត្រូវយ៉ាងជិតស្និទ្ធពីសំណាក់កសិករ ។

តាមពិត សេវាកម្មសន្តិសុខសម្ងាត់ដែលចាត់ចែងដំណើរការគុកព្រមទាំងបម្រើជាយន្តការណ៍ប្រហារជីវិតមនុស្សផងនោះ មានអត្ថិភាពនៅកម្រិតមជ្ឈិមជា«សាខាពិសេស» ជា«សន្តិបាល» ហៅមន្ទីរស-២១ ហើយនិងត្រូវបានបង្កើតឡើងថែមទៀត ក្រោមការគ្រប់គ្រងរបស់បក្សកុម្មុយនិស្តកម្ពុជានៅតាមភូមិភាគនិងតំបន់ដែលបក្សបានបែងចែកប្រទេសទាំងមូល និងតាមបណ្តាស្រុកមុនសម័យកុម្មុយនិស្តដែលបានបន្តជាអង្គភាពរដ្ឋបាល ។ នៅតាមថ្នាក់«មូលដ្ឋាន»ទាបបំផុត មន្ទីរសន្តិបាលទាំងនេះត្រូវបានបង្កើតឡើងដោយប្រធានសហករណ៍និងគណៈកម្មាធិការរដ្ឋបាលភូមិ តាមរយៈការដាក់ពង្រាយឈ្លបដែលរំពឹងថានឹងទទួលការជួយជ្រោមជ្រែងក្នុងការងាររបស់ពួកគេដោយប្រជាជន ។

ស-២១ជាភស្តុតាងដំបូងត្រូវបានផ្តួចផ្តើមគំនិតបែបនេះនៅក្នុងអំឡុងខែតុលា ឆ្នាំ១៩៧៥ ហើយកើតចេញជារូបរាងពេញលេញនៅលើទីតាំងអតីតបរិវេណសាលាទួលស្វែងក្នុងតំបន់ភាគខាងត្បូងភ្នំពេញនៅចន្លោះខែឧសភា និង មិថុនា ឆ្នាំ១៩៧៦ ។ បណ្ណាសារដ្ឋានមន្ទីរស-២១និងឯកសារដទៃទៀតដែលតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារ បណ្ណាសារដ្ឋានរបស់ ស-២១ និងឯកសារដទៃទៀតដែលតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា បង្ហាញថា ដើម្បីបំពេញគោលដៅនៃការបំពាក់ស្មារតីនិងការគ្រប់គ្រង មន្ទីរស-២១ត្រូវបានចាត់ទុកថាស្មើទៅនឹងយោធាមួយកងពលធំ ឬមួយវរសេនាធំឯករាជ្យដែលរួមមាន «យោធាជាកម្លាំងចម្បងរបស់មជ្ឈិម» ដែលត្រូវបាននិយាយនៅក្នុងលក្ខន្តិកៈបក្ស ដោយបែបនោះហើយដែលមន្ទីរ ស-២១នៅក្រោមចំណុះអគ្គសេនាធិការនៃកងទ័ពបដិវត្តន៍កម្ពុជា ។ មន្ទីរស-២១នៅក្រោមការមើលខុសត្រូវរបស់ សុន សេន ដែលនៅក្នុងឋានៈជាប្រធានអគ្គសេនាធិការ ហើយស្របទៅនឹងការទទួលខុសត្រូវដែលត្រូវបានប្រគល់ជូនគាត់នៅក្នុងកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍កាលពីខែតុលា ឆ្នាំ១៩៧៥ ដែលដាក់ សុន សេន ឲ្យទទួលខុសត្រូវលើបញ្ហាសន្តិសុខ ។

***(នៅមានត)***

**ស្ទីវ ហេឌើរ**

# ទស្សនៈថ្មីទិញតុលាការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម

រហូតមកដល់ពេលនេះ ឈុតសំខាន់ៗជាច្រើននៃសាច់រឿងស្តីអំពីតុលាការឧក្រិដ្ឋកម្មសង្រ្គាមរបស់កម្ពុជាត្រូវបានសម្តែងឲ្យឃើញយ៉ាងច្បាស់នៅចំពោះអង្គការសហប្រជាជាតិនិងនៅក្នុងទីក្រុងវ៉ាស៊ីនតោន ។ ការជជែកវែកញែកយ៉ាងក្តៅគគុកដែលប្រព្រឹត្តទៅអស់រយៈពេលជាច្រើនខែពុំបានផ្តោតការយកចិត្តទុកដាក់ជាសំខាន់ថាតើនរណាជាអ្នកទទួលខុសត្រូវចំពោះហេតុការណ៍ដ៏សោកសង្រេងទាំងឡាយដែលបានកើតឡើងនៅក្នុងសម័យប៉ុល ពត ទេ ប៉ុន្តែការជជែកពិភាក្សានេះបែរជាផ្តោតជាចម្បងលើបញ្ហាធម្មតាដែលហាក់ដូចជាមិនសូវសំខាន់អ្វីសោះនោះដូចជាថាតើត្រូវបើកសវនាការកាត់ទោសនៅទីណា ហើយត្រូវយកចៅក្រមនិងព្រះរាជអាជ្ញាមកពីប្រទេសណាខ្លះទៅវិញ ។ ទាំងនេះហើយគឺជាចំណោទបញ្ហានយោបាយដែលបានស៊ីពេលវេលានិងថាមពលរបស់អ្នកនយោបាយអស់យ៉ាងច្រើន ។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយចុះ សង្ឃឹមថាមិនយូរឡើយសវនាការដ៏ពិតប្រាកដមួយនឹងចាប់ដំណើរការ ហើយពិភពលោកទាំងមូល ជាពិសេសប្រជាជាតិកម្ពុជាទាំងអស់នឹងបានព្រុបានឃើញនូវភ័ស្តុតាងនិងការពិតអំពីព្រឹត្តការណ៍ទាំងឡាយដែលបានកើតឡើងនិងរឿងរ៉ាវនានាដែលបានកើតឡើងចំពោះក្រុមគ្រួសាររបស់ខ្លួន ចំពោះខ្លួនឯង និងចំពោះប្រទេសជាតិដ៏ស្រស់ត្រកាលប៉ុន្តែទទួលរងសនាដ៏កម្សត់នេះ ។

ជាការពិតណាស់ ដានផ្លូវដែលបន្សល់ទុកឲ្យដោយក្រុមអ្នកនយោបាយនិងអ្នកការទូតនានាទាំងនោះ នៅក្រោយសវនាការដែលផ្តួចផ្តើមឡើង គឺជាសក្ខីភាពមួយដែលមិនអាចប្រកែកបានឡើយ ។ សវនាការនៅទីក្រុងឡាអេប្រទេសហូល្លង់ដែលប្រព្រឹត្តទៅនៅក្រោមការឧបត្ថម្ភគ្រប់គ្រងរបស់អង្គការសហប្រជាជាតិដោយគ្មានការចូលរួមពីសំណាក់ប្រជាជនសាមញ្ញរបស់កម្ពុជា គឺជាបទពិសោធន៍ខុសស្រឡះយ៉ាងធំធេងមួយសម្រាប់កម្ពុជាជាងសវនាការនៅទីក្រុងភ្នំពេញ ។ សវនាការដែលធ្វើឡើងដោយចៅក្រមនិងព្រះរាជអាជ្ញាបរទេសក៏ជាបទពិសោធន៍ដាច់ដោយឡែកយ៉ាងធំមួយដែរ ហើយបទពិសោធន៍នេះគឺជាបទពិសោធន៍មួយដែលផ្ទុះបញ្ឆាំងគួរឲ្យអស់សំណើចនូវឥរិយាបថធ្វើជាគ្រូរំលងលើការទទួលខុសត្រូវ និងសិទ្ធិជ្រើសរើសមួយ មកលើកម្ពុជា ។ ឥរិយាបថបែបនេះហើយដែលបណ្តាលឲ្យមានការលេចឡើងនូវរបបខ្មែរក្រហមតាំងពីដើមដំបូងមកនោះ ។

ទោះបីជាមានផែនការយ៉ាងសម្ងាត់និងឈ្លាសវៃផ្នែកនយោបាយនិងការទូតដែលជាយថាហេតុនឹងឈានដល់ការបើកសវនាការមួយក៏ដោយ ប៉ុន្តែមិនមែនលោកអគ្គលេខាធិការកូហ្វីអាណាន់ ហើយក៏មិនមែនសម្តេច ហ៊ុន សែន ដែរ ដែលនឹងត្រូវចូលក្នុងបន្ទប់តុលាការដោយអង្គុយធ្វើជាចៅក្រមឬឈរធ្វើជាមេធាវីចោទប្រកាន់ការពារក្តីនោះ ។ នៅពេលសវនាការចាប់ផ្តើមប្រព្រឹត្តឡើង អ្នកនយោបាយនិងអ្នកការទូតប្រាកដជានឹងដកខ្លួនថយ ហើយសំណួរសំខាន់ៗអំពីថាតើអ្នកណាបានប្រព្រឹត្តអ្វីខ្លះ នៅពេលណា ហើយត្រូវមានទោសកម្រិតណានោះបើមានកំហុស គឺនឹងត្រូវបកស្រាយយ៉ាងខ្វះខ្វាះពេញអង្គតុលាការនិងពិភពលោកទាំងមូលជាពុំខាន ។

តើអ្វីខ្លះទៅជាសំណួរសំខាន់តាមផ្លូវច្បាប់និងតាមអង្គហេតុដែលអង្គតុលាការចោទសួរឡើងនោះ? បញ្ហាមួយនៅក្នុងចំណោមបញ្ហាសំខាន់បំផុតនានាដែលលើកឡើងស្តីអំពីការប្រព្រឹត្តទៅនៃការកាត់ទោសនាអំឡុងពេលប៉ុន្មានខែខាងមុខនេះ ពាក់ព័ន្ធនឹងការជជែកពិភាក្សាមុនពេលបើកសវនាការលើសមាសភាពតុលាការគឺចោទឡើងថា តើការគាំទ្ររបស់ប្រទេសលោកខាងលិចចំពោះពួកខ្មែរក្រហម គឺនឹងត្រូវបានមេធាវីខាងការពារក្តីមេដឹកនាំខ្មែរក្រហមយកមកធ្វើជាចំណែកនៃការការពារដែលនឹងត្រូវបកស្រាយនៅចំពោះមុខសវនាការឬក៏យ៉ាងណា ។ មានសេចក្តីរាយការណ៍មកថា លោក បែនសុន សម័យ ដែលជាមេធាវីរបស់តាម៉ុកបានប្រកាសថា គាត់នឹងកោះហៅអតីតមេដឹកនាំទាំងអម្បាលម៉ាននៅក្នុងសកលលោកដូចជាអតីតប្រធានាធិបតីអង់គ្លេស ម៉ាហ្គារ៉េត ថាច់ឆឺរ Margaret Thatcher និងអតីតរដ្ឋមន្ត្រីក្រសួងការបរទេសអាមេរិក ហង់រី ឃីសស៊ីងជឺរ Henry Kissinger ឲ្យចូលមក

ឆ្លើយបំភ្លឺអំពីតួនាទីរបស់លោកខាងលិចក្នុងការឡើងកាន់អំណាច និងការគាំទ្រដល់ពួកខ្មែរក្រហម ។ លើសពីនេះទៅទៀត មានសេចក្តីរាយការណ៍ជាច្រើននៅក្នុងសារព័ត៌មានបានឲ្យដឹងថា នាយករដ្ឋមន្ត្រីកម្ពុជាបានទទួលនូវការជូនយោបល់ពីសំណាក់អតីតអគ្គមេធាវីអាមេរិកាំងម្នាក់ឈ្មោះ រ៉ាមស៊ី ក្លាក (Ramsey Clark) ដែលបានលើកឡើងថា សហរដ្ឋអាមេរិកខ្លួនឯងផ្ទាល់ បានប្រព្រឹត្តនូវឧក្រិដ្ឋកម្មសង្គ្រាមនានាដោយការលួចទម្លាក់គ្រាប់បែកមកលើប្រទេសកម្ពុជា ។

ប្រវត្តិវិទូជាច្រើនរូបជឿជាក់ថា ប្រទេសមហាអំណាចនៅប៉ែកខាងលិចគឺពិតជាបានរួមចំណែក ទោះជាមានខ្លះពុំបានធ្វើដោយឆន្ទៈខ្លួនឯងក៏ដោយ ក្នុងការគាំទ្រការឡើងកាន់កាប់អំណាចរបស់ពួកខ្មែរក្រហម ។ តើពួកខ្មែរក្រហមអាចដណ្តើមអំណាចគ្រប់គ្រងនៅកម្ពុជាបានដែរឬទេប្រសិនបើគ្មានការធ្វើអាណានិគមរាប់សិបឆ្នាំមកលើកម្ពុជា ដោយពួកបារាំងដែលគ្មានការអើពើនិងថែមទាំងបោះបង់ចោលនូវការអប់រំប្រជាជនកម្ពុជាទៀតនោះ? តើពួកខ្មែរក្រហមអាចឡើងកាន់អំណាចបានដែរឬទេប្រសិនបើគ្មានការទម្លាក់គ្រាប់បែកដូចព្យុះភ្លៀងរបស់អាមេរិកមកលើប្រជាជនកម្ពុជាហើយអាមេរិកមិនបោះបង់រដ្ឋាភិបាល លន់ នល់ ចោលទេនោះ? វេទិកាសាធារណៈជាលក្ខណៈអន្តរជាតិមួយស្តីអំពីបញ្ហាទាំងនេះ ពិតជាអាចផ្តល់នូវការអប់រំដល់ពួកលោកខាងលិចឲ្យយល់ច្បាស់អំពីការជះគំនិតរបស់ពួកគេក្នុងការធ្វើឲ្យពួកខ្មែរក្រហមឡើងកាន់កាប់អំណាចនិងការបំផ្លិចបំផ្លាញសង្គមជាតិកម្ពុជាដោយពួកខ្មែរក្រហម ។ តុលាការកាត់ទោសអតីតមេដឹកនាំខ្មែរក្រហមគឺអាចជា«ពេលវេលាខ្លីមួយតែមានសារៈសំខាន់បំផុត»នៅក្នុងរឿងនយោបាយនៅកម្ពុជា ដែលអាចធ្វើឲ្យពួកលោកខាងលិចយល់ដឹងបានច្បាស់អំពីបញ្ហានេះ ជាពិសេសគឺសហរដ្ឋអាមេរិកដែលបានដកខ្លួនថយចេញពីសម័យកាលដ៏អាម៉ាស់នៅក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន។ ម្យ៉ាងវិញទៀត តើកម្ពុជាចង់ឃើញតុលាការកាត់ទោសនោះត្រូវបានឆក់ប្លន់យកទៅក្នុងផ្លូវរបស់ពួកគេដោយពួកអ្នករិះគន់នយោបាយបរទេសរបស់អាមេរិក ដែលអាចបង្វែរការយកចិត្តទុកដាក់របស់តុលាការឲ្យឃ្លាតចេញពីអ្វីដែលជាសោកនាដកម្មពិតយ៉ាងសំខាន់របស់ប្រជាជាតិកម្ពុជាដែរឬទេ?

ប៉ុន្តែបើដាក់រឿងនយោបាយឲ្យនៅដោយឡែកហើយបែរមកពិនិត្យមើលបញ្ហានីតិវិធីរបស់តុលាការវិញ សួរថាតើយើងអាចឃើញអតីតមេដឹកនាំរបស់ប្រទេសលោកខាងលិចនានាចូលខ្លួនមកធ្វើការស្រាយបំភ្លឺអំពីគោលនយោបាយពីមុនៗមករបស់រដ្ឋាភិបាលខ្លួនចំពោះប្រទេសនៅអាស៊ី-អគ្នេយ៍ នៅតុលាការមួយនៅភ្នំពេញដែរឬទេ? ចម្លើយគឺប្រហែលជាមិនអាចទេ ។ ទីមួយគឺថា តុលាការមិនអាចបង្ខំជនបរទេសដែលកំពុងរស់នៅក្រៅប្រទេសកម្ពុជាឲ្យចូលមកស្រាយបំភ្លឺចំពោះមុខតុលាការបានឡើយ ។ ដាក់ស្តែងដូចជាតុលាការអង់គ្លេសមិនអាចបង្ខំសម្តេច ហ៊ុន សែន ឲ្យឆ្លើយបំភ្លឺបានឡើយ ហើយតុលាការកម្ពុជាក៏មិនអាចបង្ខំលោកស្រី ម៉ាហ្គារ៉េត ថាច់ឆឺរ ឬលោក ហង់រី ឃីសស៊ីងជឺរ ឲ្យចូលមកបង្ហាញខ្លួននៅចំពោះមុខតុលាការកម្ពុជាបានដែរ ។ បើសិនជាគ្មានចម្លើយបំភ្លឺពីសំណាក់អតីតមេដឹកនាំពិភពលោកទាំងនោះ ដែលជាអ្នកបង្កើតគោលនយោបាយរបស់ប្រទេសមហាអំណាចលោកខាងលិចមកលើកម្ពុជាទេនោះ ភ័ស្តុតាងអំពីគោលនយោបាយរបស់ប្រទេសលោកខាងលិចទាំងអស់នោះគឺប្រហែលជាតុលាការនឹងមិនអាចទទួលយកបានតាមផ្លូវច្បាប់ឡើយ ។ ទីពីរទៀត ចៅក្រមនឹងមានសិទ្ធិអំណាចក្នុងការសម្រេចថាតើពាក្យបណ្តឹងនិងការការពារណាខ្លះដែលច្បាប់គាំទ្រ ហើយចៅក្រមមានសិទ្ធិអំណាចក្នុងការទាត់ចោលនូវភ័ស្តុតាងនៃពាក្យបណ្តឹងនិងការការពារនានាដែលពុំមានសុពលភាពតាមផ្លូវច្បាប់ ។ តុលាការគួរប្រកាន់នូវទស្សនៈថា ដើមហេតុចុងក្រោយបង្អស់នៃនយោបាយភូមិសាស្ត្រចំពោះការឡើងកាន់អំណាចរបស់ពួកខ្មែរក្រហម គឺពុំទាក់ទងទៅនឹងអ្វីដែលពួកខ្មែរក្រហមបានប្រព្រឹត្តនៅពេលដែលពួកគេកាន់កាប់អំណាចនោះឡើយ ។

ជាការពិតណាស់ ពិភពលោកចាំបាច់ត្រូវទទួលនូវការអប់រំឲ្យមើលឃើញអំពីតួនាទីរបស់ប្រទេសលោកខាងលិចនៅក្នុងការឡើងកាន់កាប់អំណាចរបស់ពួកខ្មែរក្រហម និងការគាំទ្ររបស់ប្រទេសលោកខាងលិចដល់ពួកខ្មែរក្រហម ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ តុលាការអាចចេញច្បាប់ថា គោលនយោបាយរបស់ប្រទេសលោកខាងលិចទោះជាគោលនយោបាយ នោះដឹកនាំខុសយ៉ាងណាក៏ដោយ គឺពុំមែនជាការការពារស្របតាមផ្លូវច្បាប់ចំពោះ

អ្វីដែលពួកខ្មែរក្រហមបានប្រព្រឹត្តនោះឡើយ ។ យ៉ាងច្រើនបំផុតនោះ គឺគោលនយោបាយទាំងនោះអាចផ្តល់ជាមូលដ្ឋានសម្រាប់ឲ្យមានការចេញជាដីកាបន្ថែមទៀតទៅលើជនចុងចោទផ្សេងៗទៀត ប៉ុន្តែមិនអាចធ្វើឲ្យពួកខ្មែរក្រហមរួចផុតពីទោសពៃរ៍បានទេ ។

នេះគឺជាបញ្ហាសំខាន់ ពីព្រោះវាស្រាយបំភ្លឺនូវភាពតានតឹងដែលកើតមានឡើងនៅក្នុងគ្រប់ស្ថាប័នច្បាប់ជឿនលឿននានារវាងអំណាចដ៏ប្រសើរឥតខ្ចោះដែលផ្តល់ទៅឲ្យរដ្ឋមួយក្នុងការចេញដីកាចោទប្រកាន់ ចាប់ខ្លួន កាត់ទោស និងដាក់ពន្ធនាគារឧក្រិដ្ឋជនជាប់ចោទនានា ហើយនិងសិទ្ធិរបស់ជនជាប់ចោទគ្រប់រូបក្នុងការទទួលបាននូវការការពារដោយពេញលេញនិងខ្លាំងក្លា ។ សិទ្ធិរបស់ជនជាប់ចោទ គឺការពារពលរដ្ឋទាំងអស់ ទាំងអ្នកមានទោសនិងអ្នកគ្មានទោស ពីសំណាក់ព្រះរាជអាជ្ញាដែលប្រព្រឹត្តតាមទំនើងចិត្ត និងចង់តែបានសម្រេចឆាប់ៗ ។ របៀបថាតើតុលាការដោះស្រាយភាពតានតឹងនេះ ហើយសម្រេចថាតើនឹងត្រូវអនុញ្ញាតឲ្យមានការការពារអ្វីខ្លះ គឺនឹងក្លាយទៅជាប្រធានបទនៃបញ្ហាការដឹកនាំមួយ ក្នុងចំណោមការដឹកនាំលើកដំបូងនានាដែលចេញមកពីតុលាការកម្ពុជា ដើម្បីទទួលបាននូវការយកចិត្តទុកដាក់ឲ្យបានពេញលេញពីពិភពលោកទាំងមូល ។ សេចក្តីសម្រេចរបស់តុលាការ គឺគួរទុកឲ្យចៅក្រមខ្លួនឯងផ្ទាល់ជាអ្នកធ្វើការវិនិច្ឆ័យឲ្យបានប្រសើរបំផុតដោយសមហេតុផលទទួលយកបានដោយមនុស្សទូទៅ និងជាគំរូដ៏ល្អមួយសម្រាប់ថ្ងៃក្រោយទៀត ហើយដោយពុំមានការជ្រៀតជ្រែក ផ្នែកនយោបាយពីក្នុងនិងក្រៅប្រទេស ។

**ជាក ម៉ាសត្រូអាយនី**

# ទ្រឹស្តីបទ ខ្មែរ សំផន

១- អង្ការមទុកជាមានពណ៌សម្បុរស្រស់ល្អយ៉ាងណាក៏ដោយ ក៏គេមិនអាចយកមកធ្វើម្សៅបានដែរ ។

២- ចាបដល់ពេលអរុណរះ ចាបតែងតែហើរទៅរកស្រែចំការ គឺមិនដែលស្រែចំការហើរមករកចាបទេ ។

៣- ចិត្តមិត្តមិនមែនដូចជាជន្ទល់ដែលគេបត់បែនបានដូចបំណងនោះទេ ។

៤- សេចក្តីស្នេហាប្រៀបបានដូចសត្វដែលគេផ្តាច់កន្ទុះចេញ ។

៥- កល្យាណមិត្តមានប្រាជ្ញា ប្រសើរជាងកល្យាណមិត្តល្ងង់ខ្លៅ ។

៦- ការស្រឡាញ់នារីដែលគេមិនដឹងខ្លួន ប្រៀបដូចជាយកដំបងទៅគោះឈើតូចឲ្យជ្រុះទឹកសន្សើម ។

៧- ការប្រាស្រ័យទាក់ទងជាមួយមនុស្សល្ងង់ខ្លៅ ដូចជាមនុស្សម្រាមដៃដំបៅ នឹងធ្វើឲ្យពងខ្នុះឈាមរលាករលួយមិនខាន ។

៨- បើយើងចង់ដើរឲ្យរហ័សតាមផ្លូវ ត្រូវកុំទៅជាមួយនឹងសត្វបង្គួយ ។

៩- ត្រូវទៅម្នាក់ឯងប្រសើរជាងទៅជាមួយមនុស្សកាចទុច្ចរិត ។

១០-អ្នកណាដែលមិនរើសទឹកន្លែងមុននឹងអង្គុយ ដល់អង្គុយទៅក្រោកឡើងមុខជាជាប់ចំបើង ឬសំរាមមិនខាន ។

១១-នារីបើគ្មានអ្នកណាមួយទូន្មាន គឺមុខជាបានប្តីអ្នករបាំ ។

១២-នារីជាទឹកត្រជាក់ដែលធ្វើឲ្យបុរសស្លាប់ ឬទឹកជ្រៅល្អមនឹងធ្វើឲ្យបុរសលង់បាន ។

១៣-កិច្ចការអ្វីដែលគេបានពិសោធន៍ គឺយើងមិនត្រូវលះបង់ ។

១៤-បុរសជាអ្នកធ្វើគេហដ្ឋានឲ្យសម្បូរដោយភោគទ្រព្យ ប្រពន្ធជាគេហដ្ឋាន ។

១៥-អ្នកដែលជាមេគ្រួសារត្រូវធ្វើត្រចៀកថ្លង់ ភ្នែកខ្វាក់ បើមិនដូចនេះគ្រួសារត្រូវអន្តរាយទៅអនាគត ។

១៦-ការស្ថិតនៅម្នាក់ឯងប្រសើរជាងនៅជាមួយមនុស្សពាលទុច្ចរិត ។

១៧-គេហដ្ឋានសង់នៅជិតគ្នាពុំប្រសើរឡើយ ចិត្តស្ថិតនៅជិតគ្នាប្រសើរជាង ។

១៨-បើពាក្យសួរថាៈបាក់ ពាក្យធ្វើទៅជាមួយមាស ។

១៩-គេនឹងពិភាក្សាផ្លែច្រើន តាំងពីវាចេញផ្កា ។

២០-ផ្លែដែលគេលីលើស្មា គឺចាប់សត្វប្រើសមិនបានទេ ។

២១-ព្រះរាជណាចក្រជាភរិយា កាំភ្លើងគេមិនដែលឲ្យអ្នកណាខ្ចីឡើយ ។

២២-គេលុញដីឥដ្ឋនៅពេលវានៅទន់ ។

២៣-បើទុកជាចចកសូត្រធម៌ទាំងយប់ទាំងថ្ងៃយ៉ាងណាក៏ដោយ ក៏កូនពពែនៅតែមិនទុកចិត្តដែរ ។

២៤-អ្នកដែលមិនទាន់ឆ្លងទន្លេ មិនត្រូវមើលងាយអ្នកដែលលង់ទឹកក្នុងទន្លេនោះទេ ។

២៥-ស៊ីឲ្យស្អប់ កុំឲ្យស្រមោចមើលងាយ ។

២៥-សម្លៀកបំពាក់បិទបាំងរាងកាយបាន តែមិនបាំងពូជអំបូរបានទេ ។**ដកស្រង់ចេញពីសៀវភៅកំណត់ហេតុរបស់សមមិត្ត ញុក សាខុន**



# សុបិន និងការស្វែងរកគ្រួសារ

មិនចំពោះថាគ្រួសារអាមេរិកាំង ឬកម្ពុជា ឬគ្រួសារនៃជាតិសាសន៍ដទៃទៀតក្នុងសកលលោក វាជារឿងសំខាន់ណាស់ដែលបានដឹងឬរកឃើញថាមានពត៌មានទាក់ទងដល់សមាជិកគ្រួសារ ឬសាច់ញាតិជាទីស្រឡាញ់របស់ខ្លួន។ ជាឧទាហរណ៍រដ្ឋាភិបាលអាមេរិកាំងបានចំណាយប្រាក់រាប់លានដុល្លារដើម្បីធ្វើប្រតិបត្តិការលើបញ្ហានេះ ហើយថ្មីៗនេះទៀតសោតមានក្រុមបេសកកម្មមួយដែលដឹកនាំដោយលោករ៉ូបឺតចូន (Robert L. Jones) លេខាធិការខុទ្ទកាល័យក្រសួងការពារប្រទេសអាមេរិកបានមកដល់កម្ពុជាក៏ក្នុងប្រតិបត្តិការបែបនេះដែរ គឺស្វែងរកអដ្ឋិធាតុទាហានរបស់ខ្លួនដែលបាត់ក្នុងពេលសង្គ្រាមនៅឥណ្ឌូចិន។ ចំពោះប្រទេសកម្ពុជាវិញ មានមនុស្សស្លាប់រាប់លាននាក់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងអំឡុងឆ្នាំ១៩៧៥-៧៩ ដែលស្ទើរតែទូទាំងពិភពលោកទទួលស្គាល់ថាជារបបវាលពិឃាត នឹងត្រូវបានរំពឹងថាមានការរកយុត្តិធម៌ឲ្យបានត្រឹមត្រូវនិងមានការទទួលស្គាល់ជាទូទៅទាំងថ្នាក់ជាតិនិងអន្តរជាតិ ឲ្យដល់អ្នកដែលបានស្លាប់ទៅដោយអំពើអយុត្តិធម៌។ ចាន់ ញ៉ូង ហៅ នួន ជាមនុស្សម្នាក់ក្នុងចំណោមជនរងគ្រោះរាប់លាននាក់ដែលត្រូវបានសម្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ សំឡេងខ្សាវៗ និងប្រកបដោយភាពភ័យព្រួយយ៉ាងខ្លាំង រួមនឹងការអស់សង្ឃឹមថានឹងគ្មានផ្លូវរស់តទៅទៀតរបស់ ចាន់ ញ៉ូង នៅក្នុងកាសែតម៉ាញេ៉ ដែលបន្សល់ទុកដោយពួកខ្មែរក្រហម ហាក់ដូចជាដង្ហោយហៅយើងទាំងអស់គ្នាឲ្យជួយរកយុត្តិធម៌ឲ្យ។ តាមរយៈកាសែតម៉ាញេ៉ថតសំឡេងការសួរចម្លើយនេះ បានធ្វើឲ្យក្រុមស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅស្វែងរកក្រុមគ្រួសារនេះផ្ទាល់ដល់ស្រុកកំណើតតែម្តង។

ចាន់ ញ៉ូង ហៅ នួន ជាយោធាម្នាក់មានឋានៈជាអនុលេខាវរសេនាតូច៣៣១ វរសេនាធំ ៣៣ កងពល៧០៣ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ដោយមានការចោទប្រកាន់ថា «ក្បត់អង្គការ» ចាន់ ញ៉ូង ហៅ នួន ក៏ត្រូវបានបង្វែរទៅជាមានឋានៈមួយផ្សេងទៀត គឺជាជនរងគ្រោះដ៏គួរឲ្យអាណិតអាសូរជាទីបំផុត ក្នុងចំណោមជនរងគ្រោះរាប់ម៉ឺននាក់នៅគុកទួលស្លែង ឬមន្ទីរស-២១ ដែលគុកនេះបានទទួលឈ្មោះល្បីល្បាញបំផុតខាងការធ្វើទារុណកម្មអ្នកទោសដើម្បីជម្រិតយកចម្លើយ និងការសម្លាប់រង្គាលដោយគ្មានសវនាការកាត់ទោស ទោះជាក្នុងរបបនោះមានរដ្ឋធម្មនុញ្ញដែលចែងអំពីតុលាការក៏ដោយ។ យោងតាមឯកសារ ជនរងគ្រោះ ចាន់ ញ៉ូង ហៅ នួន រូបនេះត្រូវបានពួកខ្មែរក្រហមបង្ខំឲ្យសារភាពចំនួន៣ដង ដែលគម្លាតនៃការសួរចម្លើយមួយលើកៗ មានរយៈពេលរាប់ខែ។ រីឯចម្លើយសារភាពមានៈ ឯកសារចម្លើយសារភាពថតជាខ្មែរអាត់

សម្លេង ធ្វើនៅថ្ងៃទី១៩ ខែ១១ ឆ្នាំ១៩៧៧ ឯកសារចម្លើយសារភាពជាលាយលក្ខណ៍អក្សរ៦៩សន្លឹក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ ១៩៧៨ (ចាន់ ញូង ឆ្លើយសារភាព១៩ថ្ងៃ) និងឯកសារចម្លើយសារភាពជាលាយលក្ខណ៍អក្សរ៦៨សន្លឹក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៧៨ ដដែល (ចាន់ ញូង ឆ្លើយសារភាពចំនួន១២ថ្ងៃ) ។

ចាន់ ញូង មានស្រុកកំណើតនៅឃុំកោះធំ ស្រុកកោះធំ ខេត្តកណ្តាល ។ ជាការគាប់ជួនគ្នាណាស់ ពេលដែលខ្ញុំចុះទៅស្រាវជ្រាវរកក្រុមគ្រួសារសាច់ញាតិរបស់ ចាន់ ញូង នៅភូមិក្បាលកោះធំ ឃុំស្រុកដូចខាងលើ ក៏ស្រាប់តែបានជួបក្រុមគ្រួសារនេះមែន ។ អ្វីដែលធ្វើឲ្យយើងមានការភ្ញាក់ផ្អើលនោះគឺថា មុនមួយថ្ងៃដែលយើងបានចុះទៅដល់ផ្ទះរបស់ក្រុមគ្រួសារសាច់ញាតិរបស់ ចាន់ ញូង ក្មួយស្រី ចាន់ ញូង ឈ្មោះបងស្រី ថា បានយល់សប្តិឃើញ ចាន់ ញូង ដែលជាពូថាមកលេងជាមួយក្រុមគ្រួសារបងស្រី ។ «ម៉ែអើយ! ពូញូងមោ៉ា យកលុយមកឲ្យម៉ែឯង ។ ថាអាល័យបង យកលុយមកឲ្យបងចាយ ហើយអ្អែងថាអញឆាប់ អញអត់មានឆាប់ទេ អញនៅស្រុកគេសប្បាយចង់អី» បងស្រី ថា និយាយពីការយល់សប្តិរបស់គាត់ប្រាប់ខ្ញុំ ។ វាជារឿងគួរឲ្យជឿដែរឬទេ? មនុស្សម្នាក់ដែលបានបាត់ដំណឹង ឬក៏ថាបានស្លាប់ជាងម្ភៃឆ្នាំទៅហើយ បែរជាមកពន្យល់សប្តិដល់មនុស្សម្នាក់ទៀតថាខ្លួននៅរស់ ។ ចំពោះរូបខ្ញុំផ្ទាល់ខ្ញុំជឿថា «ធ្វើល្អប្រាកដជាបានល្អ» ។ មែន! ព្រឹកបន្ទាប់ពីថ្ងៃយល់សប្តិនោះ ខ្ញុំបានទៅដល់ផ្ទះបងស្រី ថា ហើយសួររកឈ្មោះ ចាន់ ញូង ដែលធ្វើឲ្យក្រុមគ្រួសារនេះមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង មានអ្នកខ្លះស្រែក មានអ្នកខ្លះផ្អើលមកសួរខ្ញុំយ៉ាងជិតជុំ ហើយទឹកមុខម្នាក់ៗហាក់ ដូចជារំភើបរកអ្វីប្រៀបគ្មានឡើយ ។ អ៊ឹ ស្រឿន ដែលជាម្តាយ បងស្រី ថា និយាយបន្ទាប់ពីបងស្រី «មីនេះទើបនិយាយព្រឹកមិញ ស្រាប់ព្រឹកឡើងក្មួយមោ៉ា ។ យី! អាញូងនៅអីចឹងមែនក៏មិនដឹងទេ!» ។

ចាន់ ញូង ជាក្មេងកម្សត់ម្នាក់ដែលមានឳពុកម្តាយបានស្លាប់ចោលតាំងពីខ្លួននៅតូចៗម្ល៉េះ ដែលកាលណោះអាយុមិនទាន់ដល់ដប់ឆ្នាំផង ។ យាយ បូ ដែលមានកូនប្រុសឈ្មោះ ទេស លាង និងកូនស្រីឈ្មោះ ហឹម ស្រឿន បានទទួលយក ចាន់ ញូង មកនៅជាមួយគ្រាន់បានជួយកិច្ចការខ្លះក្នុងផ្ទះ ។ យាយ បូ បែកឋានអស់រយៈពេល៧ឆ្នាំ ហើយរហូតមកដល់សព្វថ្ងៃនេះ ។

កាលពីក្មេងៗ ចាន់ ញូង ច្រើនតែដើរអង្រួនផ្លែអំពិលយកទៅលក់ជាមួយម្តាយធំឈ្មោះយាយ បូ ។ ក្នុងអាយុប្រហែល ១៧ឆ្នាំ ចាន់ ញូង បានបែកពីគ្រួសាររបស់យាយ បូ ទៅធ្វើជាយោធាខ្មែរក្រហម ដែលតាមចម្លើយសារភាពចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៧៨ ចាន់ ញូង ចូលធ្វើយោធាក្នុងអង្គភាពភូមិភាគពិសេសនៅខែ១១ ឆ្នាំ១៩៧៣ បន្ទាប់ពីខ្លួនបានរៀនសូត្រនយោបាយយោធាជាងមួយខែនៅវត្តត្របែក ។ តាំងពី ពេលនោះមក ចាន់ ញូង មិនសូវដែលបានមកអើតផ្ទះឡើយ បាត់ដំណឹងរហូត ។ បងស្រី ចាន់ ធី ដែលត្រូវជាក្មួយស្រីជាទីស្រឡាញ់របស់ ចាន់ ញូង ហើយជាអ្នកដែលបានជួប ចាន់ ញូង ចុងក្រោយគេបង្អស់បាននិយាយថា «គាត់យំ គាត់ស្រក់ទឹកភ្នែក គ្រាន់ថាគាត់អស់ផ្លូវហើយ ចប់ហើយមើលមុខទៅ» ។ បងស្រី ចាន់ ធី ជួប ចាន់ ញូង នៅពេលដែល ចាន់ ញូង បានចូលមកសម្រាកពេទ្យនៅពោធិ៍បានក្នុងឃុំកោះធំ ស្រុកកោះធំ ខេត្តកណ្តាល ។ វាត្រូវគ្នានឹងចម្លើយសារភាពរបស់ ចាន់ ញូង ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ១៩៧៨ ថា ចាន់ ញូង បានមកសម្រាកព្យាបាលជម្ងឺនៅពេទ្យពោធិ៍បានក្នុងឆ្នាំ១៩៧៥ ដែលកាលណោះពេទ្យនេះជាពេទ្យរបស់កងពលលេខ១២ ដែលមានឈ្មោះ គង់ ជាប្រធានមន្ទីរពេទ្យនេះ ។ «ចាំចុងក្រោយណឹងគឺកន្លែងវត្តពោធិ៍បាននេះ គាត់មោ៉ាណឹងពិការហើយណឹង គ្រាន់ផ្តាំខ្ញុំថា លែងបានជួបមុខទៀតហើយ មើលមុខពូឲ្យច្បាស់ទៅ» បងស្រី ចាន់ ធី បញ្ជាក់ប្រាប់ខ្ញុំទាំងទឹកភ្នែកដក់ពេញក្នុងកែវភ្នែក ពីអ្វីដែលគាត់ចងចាំចុងក្រោយបង្អស់នៅពេលដែលបានជួប ចាន់ ញូង ។

បងស្រី ចាន់ ធី បានជួប ចាន់ ញូង ម្តងទៀតក្នុងពេលដែលយើងបានយកកាសែ្សតថតសំឡេងចម្លើយសារភាពរូបថត និងឯកសារចម្លើយសារភាពរាប់រយសន្លឹករបស់ ចាន់ ញូង យកទៅជូនបងស្រីនិងក្រុមគ្រួសារសាច់ញាតិបងស្រី ។ ជួបលើកនេះគឺជួបរូបថត ឮសំឡេង និងអានចម្លើយសារភាព ។ ជាងម្ភៃឆ្នាំ

ហើយដែលបងស្រីបានបែកពី ចាន់ ញូង ។ ពេលដឹងដំណឹងតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជាបានចុះទៅដល់ភូមិក្បាលកោះធំ បងស្រី ចាន់ ធី មានទឹកភ្នែករលីងរលោងគួរឲ្យសង្វេគណាស់ ។ បងស្រីនិយាយថា «ចិត្តខ្ញុំពុះកញ្ជ្រោលអស់ហើយ បុិនដឹងធ្វើយ៉ាងម៉េចទេ បើផលបុណ្យគាត់ទៅអ៊ីចឹងទៅហើយធ្វើម៉េចទេ» ។ បងស្រី ចាន់ ធី និយាយបន្តថា «បានដឹងអ៊ីចឹងទៅ ថាអាល័យគាត់ម៉េចក៏ដោយ ក៏បានធូរតិចដែរ» ។ ចំណែកឯ មីង ស្រឿន ត្រូវជាម្តាយបងស្រី ចាន់ ធី និងត្រូវជាបងជីដូនមួយ ចាន់ ញូង និយាយថា «ខ្ញុំអរគុណបានក្មួយមកស្រាវជ្រាវរកឈ្មោះណឹង បុិនបាត់ហើយក៏ដោយ បានឈ្មោះមកឲ្យសំឡេងណឹងអរហើយ» ។ មីងបានបន្តថា «អរណាស់លោកអើយ! ប្អូនបាត់ហើយ បានយកសំឡេងមកឲ្យបងៗស្តាប់ ហើយបើក្មួយមិនមក មីងបង នៅនេះធ្វើម៉េចដឹង» ។ ទាក់ទិននឹងអារម្មណ៍របស់ពូ ទេស លាង ត្រូវជាបងរបស់ ចាន់ញូង ដែរនិយាយថា «ជីវិតដូចខ្ញុំដែរ ចង់រកតែយុត្តិធម៌ ស្វែងរកការពិត ត្រង់ណាល្អ គឺខ្ញុំទៅជ្រកកន្លែងណឹង» ។

នេះជារឿងរ៉ាវពិតប្រាកដរបស់ក្រុមគ្រួសារសាច់ញាតិ ចាន់ ញូង ដែលខ្ញុំបានចុះទៅដល់ភូមិក្បាលកោះធំ ឃុំកោះធំ ស្រុកកោះធំ នាពេលថ្មីៗនេះ បានជួបនិងសម្ភាសន៍កាលពីថ្ងៃទី ២២ និង ២៦ ខែមករា ឆ្នាំ២០០០ ។ ចុងក្រោយបំផុត យើងបានជូនដោយទឹកចិត្តអាណិតអាសូរនិងទឹកចិត្តរាប់អានពូ មីង បងប្អូនខ្មែរដូចគ្នានូវទឹកប្រាក់បន្តិចបន្តួច ដើម្បីធ្វើបុណ្យបញ្ជូនកុសលផលបុណ្យដល់ជនរងគ្រោះ ចាន់ ញូង ដែលបុណ្យនេះបានប្រារព្ធឡើងកាលពីថ្ងៃអាទិត្យ ទី៣០ ខែមករា ឆ្នាំ២០០០ កន្លងទៅថ្មីៗនេះ ។ សូមឲ្យព្រលឹង ចាន់ ញូង បានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ ។ សូមអរគុណចំពោះតា ជរ, យាយ អ៊ុំច មុត, ពូ ទេស លាង, មីង ហឹម ស្រឿន, បងស្រី ថា, បងស្រី ចាន់ ធី និងអ៊ំ ពូ មីង បងប្អូនទាំងអស់ នៅភូមិក្បាលកោះធំ ឃុំកោះធំ ស្រុកកោះធំ ខេត្តកណ្តាល ។

**ថាន់ថាន់ ពៅ ដារ៉ា**

## លិខិតស្វែងរកឪពុកមា

នាងខ្ញុំឈ្មោះ គិមពៅ សុគន្ធ ខ្ញុំបានបាត់ឪពុកមាឈ្មោះ រ៉ក ហុង អាយុ៥២ឆ្នាំបើគិតមកទល់បច្ចុប្បន្ននេះ ។ គាត់កើតនៅភូមិតានុប ឃុំបាទី ខេត្តតាកែវ ។ មុនសម័យខ្មែរក្រហម ជានិស្សិតនៅសាលាច្បាប់រហូតដល់ឆ្នាំ១៩៧៥ ។

ឆ្នាំ១៩៧៥ ពួកខ្មែរក្រហមជម្លៀសឪពុកមារបស់ខ្ញុំ និងម្តាយរបស់ខ្ញុំទៅខេត្តពោធិសាត់ នៅស្រុកបាកាន ។ ឪពុកមារបស់ខ្ញុំនៅក្នុងសហករណ៍ឈើពុក ។ គាត់ធ្លាប់ជាប់គុកនៅសហករណ៍ឈើពុកអស់រយៈពេល២-៣ខែ ម្តាយរបស់ខ្ញុំបានប្រាប់ខ្ញុំថា ឪពុកមារបស់ខ្ញុំត្រូវខ្មែរក្រហមចាប់ដោយសារគាត់ជាអ្នកលក់អង្ករកាលពីរបបមុន ។ ឆ្នាំ១៩៧៨ អង្គការខ្មែរក្រហមបានគាត់ឲ្យចាកចេញឆ្ងាយពីម្តាយរបស់ខ្ញុំទៅកាប់កូនឈើ ។ គាត់ក៏បាត់ខ្លួនរហូតចាប់ពីពេលនោះមក ។

សូមជួយរកឪពុកមារបស់ខ្ញុំផង ម្តាយរបស់ខ្ញុំតែងតែរង់ចាំប្អូនប្រុសរបស់គាត់វិលត្រឡប់មករកគាត់វិញអស់រយៈពេលជាយូរណាស់មកហើយ ។

សូមទំនាក់ទំនងទូរស័ព្ទលេខៈ ០១២-៨៣៧-៥៤៨

អំពីខ្ញុំៈ សុគន្ធ

## អំណោយពីសប្បុរសជនគាំទ្រការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត

លោក ម៉ៃឃើល ឆូមមុី (Michael Chommie) អង្គការដៃគូអភិវឌ្ឍន៍ (Partner for Development, Phnom Penh) ជាទឹកប្រាក់ចំនួន ២០០ ដុល្លារ ។

សូមផ្ញើលិខិត ឬអត្ថបទ មកទស្សនាវដ្តី
«ស្វែងរកការពិត» មជ្ឈមណ្ឌលឯកសារកម្ពុជា
ប្រអប់សំបុត្រលេខ ១១១០
ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ឬផ្ញើតាមទូរសារលេខ
(៨៥៥) (២៣) ២១០ ៣៥៨

# ខ្ញុំបានជួបឪពុកមាដែលបាត់ខ្លួនក្នុងជំនាន់ ប៉ុល ពត តាមរយៈឯកសារចម្លើយសារភាពរបស់គាត់នៅគុកទួលស្លែង

កាលពីខ្ញុំរៀននៅឆ្នាំទី២នៃសកលវិទ្យាល័យភ្នំពេញ ខ្ញុំបានសុំចូលធ្វើការនៅមជ្ឈមណ្ឌលឯកសារកម្ពុជាដោយធ្វើជាអ្នកស្ម័គ្រចិត្តពុំយកប្រាក់កម្រៃ ហើយមួយរយៈក្រោយមកទៀតក៏បានចូលធ្វើជាសមាជិកបំពេញការងារពាក់កណ្តាលម៉ោងនៅក្នុងមជ្ឈមណ្ឌលនេះ ។ នៅទីនោះឯងដែលខ្ញុំបានយល់ដឹងកាន់តែច្រើនឡើងជាងពេលណាៗទាំងអស់ អំពីសោកនាដកម្មនៅក្នុងសម័យប៉ុលពត ។ ពេលនេះគឺកាន់តែច្បាស់និងជាក់ស្តែងចំពោះរូបខ្ញុំថែមមួយកម្រិតទៀត ។ មានពេលមួយ ខ្ញុំបានសួរអ្នកស្រាវជ្រាវម្នាក់នៅក្នុងមជ្ឈមណ្ឌលឯកសារ ដែលកំពុងធ្វើកាតាឡុកឯកសារចម្លើយសារភាពថា តើខ្ញុំអាចរកឃើញតម្រុយណាមួយតាមរយៈឯកសារទាំងអស់នោះ អំពីឪពុកមារបស់ខ្ញុំដែលបានបាត់ខ្លួនក្នុងជំនាន់ ប៉ុល ពត នោះបានដែរឬទេ ។ ក្នុងចិត្តខ្ញុំដូចជាមានការភ័យព្រួយនិងសោកស្តាយនៅពេលបានសួរសំណួរបែបនេះ ព្រោះថាប្រសិនបើមានឯកសារណាមួយអាចបញ្ជាក់ប្រាប់អំពីដោគវាសនារបស់មាខ្ញុំមែន សំណួរដែលធ្វើឲ្យខ្ញុំមានការបារម្ភជាបន្ទាប់មកទៀតនោះគឺថា តើគាត់មានជីវិតរស់នៅ ឬក៏យ៉ាងណាទៅហើយ...។ ហើយប្រសិនបើទៅជាមានរឿងថាគាត់ត្រូវបានពួកខ្មែរក្រហមសម្លាប់ហើយនោះ តើដំណឹងនោះនឹងទៅជាយ៉ាងណាចំពោះម្តាយមីងរបស់ខ្ញុំដែលត្រូវជាភរិយារបស់គាត់ ។ ម្តាយមីងរបស់ខ្ញុំខ្លួនគាត់ផ្ទាល់ដឹងថាប្តីរបស់ខ្លួនទំនងជាមិននៅមានជីវិតទេក្រោយរបបខ្មែរក្រហម ប៉ុន្តែខ្ញុំអាចយល់បានថា រៀងរាល់ពេលដែលគាត់បានទទួលដំណឹងថាប្តីរបស់គាត់ប្រហែលជានៅមានជីវិត ពេលនោះមានធាតុពីរប្រឆាំងគ្នានៅក្នុងខួរក្បាលរបស់គាត់ ។ ទី១ គឺជាឱកាសឬសំណាងដ៏តិចតួចបំផុតដែលថាពួកពេជ្ឈឃាតខ្មែរក្រហមទាំងនោះអាចទុកជីវិតឲ្យប្តីសម្លាញ់របស់គាត់នៅរស់ ។ មួយទៀតគឺសេចក្តីស្រឡាញ់របស់គាត់ចំពោះប្តីរបស់គាត់ដែលនៅតែដក់ជាប់ក្នុងចិត្តគាត់ជានិច្ច ធ្វើឲ្យគាត់នៅតែមានសង្ឃឹមថាប្តីរបស់គាត់ពិតជានៅមានជីវិតនៅឡើយ ។ គ្មាននរណាម្នាក់យល់ឃើញថាវាជាការងាយនោះឡើយក្នុងការយល់ឲ្យបានថាតើស្ត្រីមេម៉ាយកម្ពុជាដូចជារូបម្តាយមីងរបស់ខ្ញុំមានអារម្មណ៍យ៉ាងណានោះ នៅពេលដែលប្រឈមមុខនឹងបញ្ហាបែបនេះ ។ មិនមែនត្រឹមតែជីវិតប្តីរបស់គាត់ទេដែលត្រូវពួកខ្មែរក្រហមសម្លាប់ចោល ប៉ុន្តែអ្វីៗគ្រប់យ៉ាងក៏ត្រូវពួកខ្មែរក្រហមកម្ទេចចោលស្ទើរតែទាំងអស់ ។ ឆ្នាំ១៩៧៩ គឺជាចំណុចចាប់ផ្តើមនៃការរស់រានមានជីវិតឡើងវិញជាថ្មី ។ ប៉ុន្តែមិនដូចគ្នានឹងកូនក្មេងជំនាន់ក្រោយដែលចាប់កំណើតនិងរស់នៅជាមួយនឹងជីវិតថ្មីមួយដោយបានជួបជុំគ្រួសារហើយទទួលបាននូវការថែទាំនិងសេចក្តីស្រឡាញ់នោះឡើយ ប្រជាជនកម្ពុជាគ្រប់រូបក្រោយឆ្នាំ១៩៧៩គឺហាក់បីដូចជាកើតសាជាថ្មីម្តងទៀតជាមួយនឹងជីវិតចាស់ដដែល ដែលពោរពេញទៅដោយក្តីទុក្ខសោក ការនិរាសព្រាត់ប្រាស និងស្លាកស្នាមរបួសយ៉ាងធ្ងន់ធ្ងរនៅក្នុងបេះដូងនិងខួរក្បាល ។ ស្ត្រីមិនតិចនាក់ឡើយបានក្លាយខ្លួនទៅជាស្ត្រីមេម៉ាយក្រោយឆ្នាំ១៩៧៩ ហើយត្រូវទទួលបន្ទុកតែម្នាក់ឯងក្នុងការចិញ្ចឹមបីបាច់កូនចៅ ។

ខ្ញុំបានរកឃើញឯកសារមួយសំណុំដែលសរសេរដោយឪពុកមារបស់ខ្ញុំ ។ វាជាឯកសារចម្លើយសារភាពមានចំនួន ៨៩ទំព័រ ដែលសរសេរចាប់ពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៧៨ ដល់ថ្ងៃទី២០ ខែធ្នូ ឆ្នាំដដែល ។ នៅលើទំព័រដើមនៃឯកសារចម្លើយសារភាពដែលគាត់បានសរសេរឆ្លើយសារភាពជូនដល់អង្គការស្អីគេនោះ មានចំណារអក្សរដែលប្រហែលជាសរសេរដោយកម្មាភិបាលខ្មែរក្រហមទទួលបន្ទុកផ្ទៀងផ្ទាត់ចម្លើយ

សារភាពរបស់អ្នកទោស ។ នៅចុងបញ្ចប់នៃចំណារអក្សរនោះ មានចុះហត្ថលេខាដោយដាក់ឈ្មោះថា «វ៉ុន» ។ វ៉ុន គឺជាអ្នកសួរចម្លើយនៅគុកទួលស្លែង ហើយយោងតាមឯកសារដែលមាននៅមជ្ឈមណ្ឌលឯកសារកម្ពុជា វ៉ុន គឺជាអ្នកទទួលខុសត្រូវក្នុងការសួរចម្លើយអ្នកទោសនៅក្នុង ក្រុមទី៣នៃក្រុមក្តៅ (ក្រុមអ្នកសួរចម្លើយដែលប្រើវិធានការក្តៅ ឬទារុណកម្មកម្រិតធ្ងន់ចំពោះអ្នកទោស) ។

ចម្លើយសារភាពនេះធ្វើឲ្យខ្ញុំនឹកឃើញដល់កូនសៀវភៅផ្លូវអំពីទួលស្លែងដែលបានលាតត្រដាងនូវរបៀបដែលពួកខ្មែរក្រហមធ្វើទារុណកម្មលើអ្នកទោស ដើម្បីឲ្យសារភាពទៅតាមតែអង្គការ ចង់បាន ការនឹកឃើញរឿងនេះ បានអន្ទ្រួនចិត្តខ្ញុំឲ្យគិតដល់ថាតើ ឯកសារដែលខ្ញុំ កំពុងកាន់ក្នុងដៃ នេះ ចេញមកតាម របៀបដូចដែលវា បានកើតឡើងជា ធម្មតាចំពោះអ្នក ទោសគ្រប់រូបនៅ




គុកទួលស្លែង ឬមួយក៏យ៉ាងណា ។ ខ្ញុំត្រូវចំណាយពេលយ៉ាងយូរដើម្បីអានឯកសារនេះឲ្យចប់ ។ វាជាឯកសារដែលសរសេរដោយឪពុកមាម្នាក់ដែលខ្ញុំពុំធ្លាប់បានឃើញមុខ ។ គាត់គឺជាបងប្អូនសាច់ថ្លៃម្នាក់ ហើយត្រូវជាប្តីរបស់មីងខ្ញុំបង្កើត ដែលគ្រួសាររបស់ខ្ញុំមានមោទនភាពយ៉ាងខ្លាំងនៅពេលមានគាត់ជាចំណែកមួយនៅក្នុងគ្រួសាររបស់យើង ។ ខ្ញុំតែងតែមានបំណងចង់ជួបមុខគាត់ តែខ្ញុំពុំដែលបានគិតថាខ្ញុំអាចមានឱកាសជួបគាត់បានសោះ ។ តែចុងក្រោយនេះខ្ញុំបានប្រទះឃើញឯកសារចម្លើយសារភាពរបស់គាត់ដែលនិយាយមករកខ្ញុំដោយប្រយោល និងដោយមិនដឹងខ្លួន ។ រូបភាពដ៏គួរឲ្យតក់ស្លុតដែលខ្ញុំបានឃើញនៅក្នុងសៀវភៅផ្លូវអំពីទួលស្លែង បេះតែដក់ជាប់នៅក្នុងខួរក្បាលរបស់ខ្ញុំនៅពេលដែលខ្ញុំអានឯកសារនោះ ។ ពេលនោះធ្វើឲ្យខ្ញុំគិតភ្លាមដល់អារម្មណ៍របស់ម្តាយមីងខ្ញុំ ។ ខ្ញុំគិតថា រូបភាពដែលខ្ញុំបានឃើញទាំងអស់នោះគឺប្រាកដជាមានលក្ខណៈជាក់ច្បាស់និងរន្ធត់ខ្លាំងជាងនៅក្នុងចិត្តគំនិតក្នុងការចងចាំរបស់ម្តាយមីងខ្ញុំ ពីព្រោះខ្លួនគាត់ផ្ទាល់ក៏ធ្លាប់បានទទួលរងនូវការឈឺចាប់នៅក្នុងរបបនោះដែរ ។ កូនស្រីវ័យក្មេងនិងគ្មានទោសកំហុសរបស់គាត់ក៏ត្រូវស្លាប់ដោយសាររបបខ្មែរក្រហមនេះដែរ ដោយមូលហេតុកូនរបស់គាត់ពាក់វ៉ែនតាមីញ៉ូប ហើយក៏ត្រូវពួក ខ្មែរក្រហមចោទថា ជាបញ្ញវ័ន្ត ដែលពួកវាចាត់ទុក ថាជាសត្រូវរបស់ អង្គការ ។ នេះគឺ ជាអនុស្សាវរីយ៍ដ៏ ឈឺចាប់បំផុតមួយ ដែលគាត់ពុំដែល បានជួបប្រទះពី មុនមក ។

ឥឡូវនេះគឺដល់ពេលវេលាដែលយើងត្រូវគិតគូរអំពីយុត្តិធម៌ ហើយក៏ជាពេលវេលា ដែលយើងទាំងអស់គ្នាត្រូវសបញ្ជាក់ឲ្យឃើញថាប្រជាជាតិកម្ពុជា និងប្រជាជាតិទាំងអស់នៅលើសកលលោកត្រូវឲ្យតម្លៃជីវិតប្រជាជនកម្ពុជាឲ្យបានស្មើនឹងជីវិតជនបរទេសនានានៅលើពិភពលោកនេះដែរ ។ ថ្វីបើរឿងនេះបានកន្លងផុតអស់រយៈពេល២០ឆ្នាំទៅហើយក្តី ប៉ុន្តែការចងចាំនៅតែស្ថិតក្នុងចិត្តយើងគ្រប់ៗរូប ។ ព្រលឹងដ៏ស្លូតត្រង់និងគ្មានទោសកំហុសរបស់ឪពុកមាខ្ញុំកំពុងតែវិលវល់ស្វែងរកយុត្តិធម៌គ្មានពេលល្ហែ ល្ហើយ ។

**សុខា អ៊ីរ៉ាន**

ចម្រៀងខ្មែរក្រហម

# កសិករសហករណ៍ រីករាយប្រមូលផល

សន្ទូងសាយដើមដើមហើយទុំ　　កួរវែងគ្រាប់ធ្ងន់ឱនឈ្ងោកស្រែ
កណ្តៀវប្រោកៗជិតមួយខែ　　នារីច្រូតហែរាយកណ្តាប់ ។
ជំនោរកត្តិកស្តឹកចុងដៃ　　ក្បែរលានមានល្អីស្រូបពេញព្រៀប
កើបហើយជញ្ជូនដាក់កណ្តាប់　　ផ្អែករោយៗជាប់ញើសតាំងទឹក ។
គរស្រូវមើលទៅដូចកូនភ្នំ　　ពូៗមកជុំដៃប្រញាឹក
ប្រញាប់កើបច្រកបាវទាន់ព្រឹក　　រួចដឹកទៅទុកជង្រុកធំ ។
ភ្លឺភ្លោះខ្ពស់ចាំសិប្បកម្មផាល　　ឈប់សិនកុំអាលស្រូតបង្ខំ
មកផ្តិតម្ញាំងមូលខបត្តម្ភ　　សំរុកឲ្យចំច្រូតរួសរាន់ ។
ស្រែយើងលឿងប្រាលកំរាលព្រំ　　តាយាយមើងអំពោលពាក្យលាន់
ថាឆ្នាំមុនៗស្រូវល្អគ្រាន់　　ម្តេចឡើយនៅអន់ជាងឆ្នាំនេះ ។
អ៊ំប្រុសចាកចុះពីរោងជាង　　ល្ហះៗព្រឹកព្រាងចេញរទេះ
កក្អាកកក្អាយសប្បាយម្ល៉េះ　　សំដៅពីសេះច្រូតស្រូវស្រែ ។
អ៊ំស្រីលឿនណាស់រហ័សខ្មី　　ស្រូវខ្ពស់ទាបក្តីមិនពូកែ
ត្រកងច្រូតកាត់កណ្តាប់ហែ　　គ្មានរុះជ្រុះទេគ្មេរសំបៃ ។
យុវនកងទ័ពក្រុមចល័ត　　ប្រយុទ្ធច្រូតកាត់ស្រូវប្រពៃ
នារីកងស្រួចចាត់តាំងថ្មី　　ច្រូតស្រូវនាងគីនាងមិញទន់ ។
ពូៗទទួលខាងបែកបោក　　កុមារសម្រុកដឹកបញ្ជូន
មីងៗរ៉ាប់រងរោយឲ្យទាន់　　រួចពូរួសរាន់ដឹកទុកដាក់ ។
តាៗក្បង់ស្រូវនៅនឹងដៃ　　ទឹកមុខស្រស់ស្រាយសប្បាយជាក់
ពិនិត្យរួចហើយរួចទម្លាក់　　ជំនឿជឿជាក់លើសហករណ៍ ។
យុវនកងទ័ពចល័ត　　នារីបដិវត្តន៍ច្រៀងអបអរ
ផលនេះបានមកដោយបង្ហូរ　　ឈាមស្រស់កសិករអ្នកក្រក្រី ។
យើងទទួលផលស្រូវវស្សា　　បានច្រើនធានាទុនឆ្នាំថ្មី
សំរុកលើកភ្លឺយកជោគជ័យ　　ផលស្រូវឆ្នាំថ្មី៣តោនថែមទៀត ។

**កត់ត្រាចេញពីឯកសារ**

**កញ្ញា សើ សាយ្យាណា**

---

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន ។
ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។
The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or (855) 18 812 558. Thank you.

A magazine of the Documentation Center of Cambodia: Searching for the Truth! Number 2, February 2000
Funded by the Royal Ministry of Foreign Affairs, Oslo, Norway, Section for the Human Rights and Humanitarian Assistance, and the Canada Funds, Canadian Embassy, Phnom Penh, Cambodia